## ជំពូកទី១

# ការធ្លាក់ចុះរបស់សាតាំង

ទេវតាបានបង្ហាញខ្ញុំថាពីមុនសាតាំង គឺជាទេវតាដែលមានកិត្តិយសបន្ទាប់ពីព្រះយេស៊ូវគ្រីស្ទនៅឯស្ថានសួគ៌។ ទឹកមុខរបស់វាស្លូតបូត ពោរពេញដោយសេចក្តីសប្បាយជាខ្លាំង ដូចជាទេវតាដទៃទៀតដែរ។ ថ្ងាសរបស់វាខ្ពស់ ហើយទូលាយ និងបង្ហាញពីការ ឆ្លាតវាងវៃដ៏ឧត្តម។ រូបរាងរបស់វាល្អគ្រប់លក្ខណ៍។ វាមានភាពថ្លៃថ្នូរ ភាពធំសំបើម និងកិរិយាល្អ។ ហើយខ្ញុំបានឃើញថា នៅពេលដែលព្រះអម្ចាស់បានមានបន្ទូលទៅកាន់ ព្រះបុត្រារបស់ព្រះអង្គថា ចូរយើងបង្កើតមនុស្សអោយដូចជារូបយើង សាតាំងមានការ ច្រណែននឹងព្រះយេស៊ូវ។ វាប្រាថ្នាចង់អោយព្រះពិភាក្សាជាមួយវាអំពីរូបរាងរបស់ មនុស្ស វាបានកើតសេចក្តីច្រណែន ការប្រច័ណ្ឌ និងសម្អប់ឡើង វាចង់អោយបានខ្ពស់ជាង គេបំផុតនៅស្ថានសួគ៌បន្ទាប់ពីព្រះ ហើយអ្វីៗទាំងអស់នៅស្ថានសួគ៌ មានរបៀបរៀបរយ ស៊ីសង្វាក់គ្នា និងមានជំនឿទាំងស្រុងទៅលើការគ្រប់គ្រង (រដ្ឋាភិបាល) របស់ព្រះ។

គឺជាអំពើបាបដ៏ខ្ពស់បំផុត ដែលបះបោរប្រឆាំងនឹងបញ្ជា និងព្រះហឫទ័យរបស់ព្រះ។ ស្ថានសួគ៌ទាំងមូលហាក់មានការរំជើបរំជួល។ ទេវតាជាច្រើនត្រូវបានប្រមែប្រមូលជាក្រុម ជាមួយនឹងទេវតាមួយដែលជាមេលើពួកគេ។ ទេវតាទាំងអស់បានជ្រួលជ្រើម។ សាតាំងបានពោលបញ្ឆិតបញ្ឆៀង ចំពោះរដ្ឋាភិបាលរបស់ព្រះ វាមានសេចក្តីប្រាថ្នាដ៏លើសលប់ ដើម្បីលើកដំកើងខ្លួនឯង ហើយមិនចង់ចុះចូលជាមួយនឹងអំណាចរបស់ព្រះយេស៊ូវ។ ទេវតាខ្លះបានរួមចំណែកជាមួយសាតាំង នៅក្នុងការបះបោររបស់វា។ ហើយទេវតាមួយចំនួនទៀត ប្រជែងចង់បានយ៉ាងខ្លាំងនូវគតិបណ្ឌិត និង



កិត្តិយស ដែលព្រះបានថ្វាយអំណាចទៅលើព្រះរាជបុត្រា។ ហើយក៏មានការមិនចុះសំរុងគ្នារវាងទេវតា។ សាតាំងនិងទេវតាដែលទទួលឥទ្ធិពល ពីវាដែលកំពុងខំប្រឹងប្រែងកែទម្រង់រដ្ឋាភិបាលរបស់ព្រះ ចង់សំឡឹងមើលទៅប្រាជ្ញា ដែលមិនអាចស្វែងរកបានរបស់វា ដើម្បីនឹងធ្វើអោយគោលបំណងរបស់វាបានសំរេច ក្នុងការប្រឆាំងនឹងការលើកដំកើងព្រះយេស៊ូវ និងការថ្វាយដល់ទ្រង់នូវអំណាច និងបញ្ញត្តិដ៏ធំបំផុត។ ពួកទេវតាបានបះបោរប្រឆាំង នឹងអំណាចរបស់ព្រះរាជបុត្រានៃព្រះ ហើយទេវតាទាំងអស់ត្រូវបានកោះអោយមកប្រជុំនៅចំពោះព្រះវរបិតា ដើម្បីវិនិច្ឆ័យរឿងរបស់គេ។ ហើយព្រះបានវិនិច្ឆ័យថា សាតាំងត្រូវតែបណ្តេញចេញពីស្ថានសួគ៌ និងទេវតាទាំងឡាយដែលបានចូលរួមក្នុងការបះបោរជាមួយសាតាំង ក៏ត្រូវតែទៅជាមួយវាដែរ។ ពេលនោះក៏មានជាចម្បាំងនៅស្ថានសួគ៌។ ទេវតាត្រូវបានបញ្ចូលទៅក្នុងសមរភូមិ។ សាតាំងប្រាថ្នាគ្រប់គ្រងលើព្រះរាជបុត្រារបស់ព្រះ និងអ្នកដែលចុះចូលនឹងព្រះហឫទ័យរបស់ទ្រង់។ ប៉ុន្តែទេវតាល្អ និងស្មោះត្រង់បានទទួលជ័យជំនះ ហើយសាតាំង និងទេវតារបស់វាត្រូវបានកំចាត់ចេញពីស្ថានសួគ៌។

នៅពេលដែលសាតាំងត្រូវបានបណ្តេញចេញពីស្ថានសួគ៌ ជាមួយនឹងទេវតាដែលធ្លាក់ចុះនោះមក វាបានដឹងថា វាបានបាត់បង់ភាពបរិសុទ្ធ និងសិរីល្អនៅស្ថានសួគ៌ទាំងអស់ជារៀងរហូត។ រួចវាក៏បានស្តាយក្រោយ និងមានបំណងចង់ឡើងទៅកាន់ស្ថានសួគ៌វិញ។ វាមានបំណងចង់យកកន្លែងដ៏ត្រឹមត្រូវរបស់វា ឬកន្លែងផ្សេងទៀតដែលនឹងត្រូវបានចាត់អោយវា។ ប៉ុន្តែ មិនបានទេ ស្ថានសួគ៌មិនមែនជាកន្លែងដែលមានគ្រោះថ្នាក់ឡើយ។ អ្វីៗទាំងអស់នៅស្ថានសួគ៌អាចនឹងទៅជាសៅហ្មងប្រសិនបើព្រះព្រមទទួលយកវាមកវិញ ព្រោះអំពើបាប បានចាប់ផ្តើមនៅក្នុងខ្លួនវា ហើយគ្រាប់ពូជនៃការបះបោរក៏មាននៅក្នុងវាហើយដែរ។ សាតាំងបានគ្រប់គ្រងអ្នក

ដែលដើរតាមវា អ្នកដែលបានចូលរួមជាមួយនឹងការប្រឆាំងបះបោររបស់វា។ វានិងបក្សពួកវាបានស្តាយក្រោយ បានយំសោក និងអង្វរករ សុំអោយព្រះទទួលយកពួកវាត្រឡប់មកវិញ។ ប៉ុន្តែ មិនបានឡើយ អំពើបាបរបស់ពួកវា សម្អប់របស់ពួកវា សេចក្តីប្រច័ណ្ឌនិងច្រណែនរបស់ពួកវា ធំធេងណាស់ ព្រះមិនអាចលប់បំបាត់ចេញបានឡើយ។ វាត្រូវតែទទួលនូវទណ្ឌកម្មចុងក្រោយបង្អស់របស់វា។

នៅពេលដែលសាតាំងបានដឹងយ៉ាងច្បាស់ថា មិនមានលទ្ធភាពឱ្យព្រះសព្វព្រះហឫទ័យឡើងវិញបានទេនោះ ការព្យាបាទនិងសម្អប់របស់វាបានចាប់ផ្តើមកើតឡើង។ វាបានពិភាក្សាជាមួយទេវតារបស់វា ហើយបានដាក់គំរោងការមួយដើម្បីប្រឆាំងនឹងរដ្ឋាភិបាលរបស់ព្រះ។ នៅពេលដែលអ័ដាមនិងនាងអេវ៉ាត្រូវបានដាក់នៅក្នុងសួនច្បារដ៏ស្រស់ស្អាត សាតាំងបានដាក់ផែនការដើម្បីកំចាត់ពួកគេ។ ការពិគ្រោះបានធ្វើជាមួយនឹងទេវតាអាក្រក់។ ប្រសិនបើគូស្រករដ៏រីករាយនេះបានស្តាប់បង្គាប់ព្រះនោះនឹងគ្មានវិធីណាដែលអាចដកហូតសេចក្តីសប្បាយរីករាយចេញពីគេបានឡើយ។ សាតាំងនឹងមិនអាចប្រើអំណាចរបស់វាទៅលើពួកគេបានទេ ប្រសិនបើពួកគេស្តាប់បង្គាប់ព្រះជាមុន និងចុះចូលចំពោះអ្វីដែលទ្រង់បានបង្គាប់នោះ។ ពួកវាបានប្រឌិតផែនការដើម្បីដឹកនាំពួកគេកុំអោយស្តាប់បង្គាប់ ដើម្បីអោយគេមានការមិនចុះសំរុងជាមួយនឹងព្រះអម្ចាស់ និងត្រូវបាននាំអោយនៅក្រោមឥទ្ធិពលរបស់សាតាំង និងទេវតារបស់វាកាន់តែខ្លាំង។ សាតាំងបានសំរេចចិត្តថា វានឹងក្លែងធ្វើរូបរាងមួយទៀតដែលធ្វើអោយមនុស្សចាប់អារម្មណ៏។ វាត្រូវតែពោលបញ្ជិតបញ្ឆៀងប្រឆាំងនឹងសេចក្តីពិតរបស់ព្រះ បង្កើតការសង្ស័យនូវអ្វីដែលព្រះអង្គបានមានព្រះបន្ទូល ធ្វើអោយរំភើបដល់មហិច្ឆិតារបស់គេ បន្ទាប់មកក៏ដឹកនាំគេអោយធ្លាក់ទៅក្នុងផែនការដែលព្រះមិនបានដាក់ចុះ ដែលសាតាំងជាអ្នកមានទោស ហើយបុព្វហេតុនោះគឺលក្ខខ័ណ្ឌមួយ



ទាក់ទងនឹងដើមដឹងខុសត្រូវ។

សូមអានអេសាយ ១៤:១២-២០ អេសេគាល ២៨:១-១៩ វិវរណៈ ១២:៧-៩។

## ជំពូកទី២
## **ការធ្លាក់ចុះរបស់មនុស្ស**

ខ្ញុំបានឃើញទេវតាបរិសុទ្ធតែងតែយាងទៅកាន់សួនច្បារ និងណែនាំដល់អ័ដាមនិងនាងអេវ៉ាទាក់ទងនឹងការងាររបស់គេ និងបង្រៀនគេអំពីការបះបោរ និងការធ្លាក់ចុះរបស់សាតាំង។ ទេវតាបានព្រមានគេអំពីសាតាំង និងបានប្រាប់អោយគេប្រុងប្រយ័ត្នកុំអោយបែកចេញពីគ្នាឡើយ នៅក្នុងការងារទាំងឡាយរបស់គេ ដ្បិតគេអាចនឹងត្រូវនាំអោយទាក់ទងជាមួយនឹងសត្រូវដែលធ្លាក់ចុះនេះ។ ទេវតាបានបង្គាប់ពួកគេអោយធ្វើតាមការណែនាំរបស់ព្រះយ៉ាងជិតស្និទ្ធ ដ្បិតមានតែការគោរពតាមព្រះដ៏គ្រប់លក្ខណ៏ប៉ុណ្ណោះទេ ដែលពួកគេមានសុវត្ថិភាព។ ហើយប្រសិនបើពួកគេស្តាប់បង្គាប់ព្រះ សត្រូវដែលធ្លាក់ចុះនោះ នឹងមិនមានអំណាចលើពួកគេឡើយ។

សាតាំងបានចាប់ផ្តើមការងាររបស់វា ជាមួយនឹងនាងអេវ៉ា ដើម្បីធ្វើអោយនាងមិនស្តាប់បង្គាប់។ ដំបូងនាងបានធ្វើខុសដោយដើរឃ្លាតពីប្តីរបស់នាង បន្ទាប់មកបង្អែបង្អង់នៅជុំវិញដើមឈើដែលព្រះបានហាមប្រាម ហើយបន្ទាប់មកដោយស្តាប់សំឡេងនៃអ្នកល្បួង រហូតដល់ទៅហ៊ានសង្ស័យចំពោះអ្វីដែលព្រះបានមានព្រះបន្ទូលថា ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះឯងនឹងត្រូវស្លាប់ជាមិនខានទៀតផង។ នាងបានគិតថាប្រហែលជាវាមិនពិតដូចអ្វីដែលព្រះបានមានបន្ទូលនោះឡើយ។ នាងបានប្រថុយមិន

ស្តាប់បង្គាប់។ នាងបានលូកដៃទៅបេះផ្លែឈើ ហើយបានបរិភោគ។ វាជាផ្លែដែលគាប់ភ្នែក ជាផ្លែដែលអាចបរិភោគបាន។ នាងបានប្រច័ណ្ឌនឹងព្រះដែលបានលាក់អ្វីដែលពិតជាល្អពីនាង។ នាងបានអោយផ្លែឈើទៅប្តីនាង ដោយហេតុនោះគាត់ក៏ត្រូវល្បួង។ នាងក៏បានភ្ជាប់ទៅអ័ដាមនូវអ្វីដែលពស់បាននិយាយ និងបញ្ចេញការភ្ញាក់ផ្អើលថានាងមានអំណាចក្នុងការនិយាយ។

ខ្ញុំបានឃើញទឹកមុខអ័ដាមពោរពេញដោយភាពក្រៀមក្រំ។ គាត់បង្ហាញការភ័យខ្លាចនិងការភ្ញាក់ផ្អើល។ ការពិបាកបានកើតឡើងនៅក្នុងគំនិតគាត់។ គាត់ដឹងយ៉ាងច្បាស់ថា នេះគឺជាសត្រូវដែលព្រះបានព្រមានអោយគេប្រឆាំង និងបានដឹងថាប្រពន្ធរបស់គាត់ត្រូវតែស្លាប់។ គេទាំងពីរពិតជាត្រូវបែកគ្នា។ សេចក្តីស្រឡាញ់របស់គាត់ ចំពោះនាងអេវ៉ាខ្លាំងក្លាណាស់។ ហើយនៅក្នុងការបាក់ទឹកចិត្តទាំងស្រុង គាត់បានសំរេចចិត្តចែករំលែកនូវវាសនារបស់នាង។ គាត់បានទទួលយកផ្លែឈើនោះមកបរិភោគយ៉ាងរហ័ស។ ពេលនោះ សាតាំងបានសំដែងនូវសេចក្តីរីករាយយ៉ាងក្រៃលែង។ វាបានបះបោរនៅឯស្ថានសួគ៌ ហើយមានអ្នកចូលរួមជាមួយវា គឺអ្នកដែលបានស្រឡាញ់វា ហើយបានដើរតាមវានៅក្នុងការបះបោរនោះ។ វាបានធ្លាក់ចុះ ហើយបានបណ្តាលអោយអ្នកដទៃធ្លាក់ជាមួយវា។ ហើយឥឡូវនេះវាបានល្បួងស្ត្រីមិនអោយទុកចិត្តលើព្រះ អោយចង់ដឹងអំពីប្រាជ្ញារបស់វា និងអោយស្វែងរកការយល់ដឹង អំពីផែនការនៃប្រាជ្ញាទាំងអស់របស់វា។ សាតាំងបានដឹងថាស្ត្រីនោះមិនធ្លាក់ចុះតែម្នាក់ឯងឡើយ។ ដោយសេចក្តីស្រឡាញ់ចំពោះនាងអេវ៉ា អ័ដាមក៏លែងស្តាប់បង្គាប់ព្រះ ហើយធ្លាក់ក្នុងសេចក្តីល្បួងជាមួយនាង។

ដំណឹងនៃការធ្លាក់ចុះរបស់មនុស្ស បានផ្សព្វផ្សាយពាសពេញស្ថានសួគ៌។ ពិណទាំងឡាយបាននៅស្ងៀម។ ទេវតាទាំងឡាយបានដោះមកុដចេញពីព្រះសិរ ដោយ



សោកស្តាយ។ អ្វីៗទាំងអស់ដែលនៅស្ថានសួគ៌មានការរំជួលជាខ្លាំង។ ការប្រជុំមួយបានបើកឡើងដើម្បីសំរេចថា តើត្រូវធ្វើអ្វីចំពោះមនុស្សមានទោសមួយគូនេះ។ ទេវតាព្រួយបារម្ភខ្លាចក្រែងគេលូកដៃទៅបេះផ្លែជីវិត ហើយបរិភោគ រួចរស់នៅជាអ្នកមានបាបរហូត។ ប៉ុន្តែ ព្រះបានមានព្រះបន្ទូលថា ត្រូវតែបណ្តេញពួកគេចេញពីសួនច្បារ។ ទេវតាត្រូវបានបង្គាប់អោយថែរក្សាដើមជីវិតជាបន្ទាន់។ វាគឺជាផែនការដែលបានរៀបចំរបស់សាតាំង ដែលអ័ដាមនិងអេវ៉ាបានលែងស្តាប់បង្គាប់ព្រះ ទទួលយកការបោកបញ្ឆោតរបស់វា ហើយបន្ទាប់មក ត្រូវបានដឹកនាំអោយទទួលដើមជីវិត ធ្វើឱ្យគេអាចរស់នៅក្នុងអំពើបាបជារៀងរហូត និងការមិនស្តាប់បង្គាប់ ហើយអំពើបាបក៏មានជារៀងរហូត។ ប៉ុន្តែ ព្រះបានបញ្ជូនទេវតាបរិសុទ្ធអោយទៅបណ្តេញគេចេញពីសួនច្បារ នៅពេលដែលទេវតាមួយក្រុមទៀត ត្រូវបានចាត់អោយថែរក្សាផ្លូវទៅឯដើមជីវិត។ ទេវតាដ៏មានព្រះចេស្តាទាំងនេះគ្រប់ៗអង្គមានរបស់ម្យ៉ាងនៅដៃស្តាំដែលមើលទៅដូចជាដាវនៃអណ្តាតភ្លើង។

បន្ទាប់មកសាតាំងបានជ័យជំនះ។ អ្នកទាំងឡាយដែលវាបានធ្វើឱ្យមានការឈឺចាប់ ដោយការធ្លាក់ចុះរបស់វា។ វាត្រូវបានបណ្តេញចេញពីស្ថានសួគ៌ ពួកវាត្រូវបានចេញពីស្ថានបរមសុខ។

សូមអាន លោកកុប្បត្តិ ជំពូកទី៣។

ជំពូកទី៣

## ផែនការនៃសេចក្តីសង្គ្រោះ

សេចក្តីទុក្ខព្រួយបានបំពេញស្ថានសួគ៌ នៅពេលដែលគេបានដឹងថា មនុស្ស

ត្រូវបានបាត់បង់ ហើយលោកីយ៍ដែលព្រះបានបង្កើតក៏ត្រូវបានបំពេញដោយសេចក្ដីស្លាប់ ផ្ដន្ទាដោយសេចក្ដីវេទនា ជំងឺនិងសេចក្ដីស្លាប់ ហើយអ្នកដែលមិនពេញចិត្តនឹងសេចក្ដីទាំងនេះ មិនអាចគេចវេះបានឡើយ។ គ្រួសារលោកអ័ដាមទាំងមូលត្រូវតែស្លាប់។ ខ្ញុំបានឃើញព្រះយេស៊ូវជាទីស្រឡាញ់ និងឃើញមានការបង្ហាញពីការអាណិតអាសូរ និងការសោកស្ដាយ នៅក្នុងទឹកព្រះភ័ក្ត្ររបស់ទ្រង់។ រំពេចនោះ ខ្ញុំបានឃើញទ្រង់យាងចូលទៅជិតពន្លឺដ៏ភ្លឺក្រៃលែងនៃព្រះវរបិតា។ ព្រះអង្គដែលនៅក្នុងការពិភាក្សាជិតស្និទ្ធជាមួយព្រះវរបិតាបានមានបន្ទូលថា ទេវតាដែលហែហមខ្ញុំទាំងឡាយអើយ។ ការចាប់អារម្មណ៍របស់ពួកទេវតាហាក់បីដូចជាមានខ្លាំងក្លា នៅពេលដែលព្រះយេស៊ូវកំពុងតែទាក់ទងជាមួយព្រះវរបិតា។ ព្រះអង្គត្រូវបានបិទដោយសិរីល្អរបស់ព្រះវរបិតាបីដង ហើយលើកទីបី ព្រះអង្គបានចេញពីព្រះវរបិតា ព្រះកាយរបស់ព្រះអង្គអាចមើលឃើញ ទឹកព្រះភ័ក្ត្ររបស់ព្រះអង្គស្ងប់ស្ងៀម រួចផុតពីភាពអល់ឯកនិងបញ្ហាទាំងឡាយ និងបានចែងចាំងដោយព្រះទ័យមេត្តានិងសេចក្ដីស្រឡាញ់ដែលគ្មានពាក្យអ្វីអាចពិពណ៌នាបាន។ បន្ទាប់មក ទ្រង់បានប្រាប់ដល់ពពួកទេវតាអោយដឹងថា ផ្លូវនៃការរំដោះខ្លួន ត្រូវបានបង្កើតឡើងសំរាប់មនុស្សហើយ។ ព្រះអង្គបានប្រាប់ដល់ពួកទេវតាថា ទ្រង់បានអង្វរករព្រះវរបិតា ហើយបានលះបង់ព្រះជន្មរបស់ទ្រង់ជាតម្លៃលោះ ហើយទទួលការវិនិច្ឆ័យនៃសេចក្ដីស្លាប់មកលើអង្គទ្រង់ ដែលតាមរយៈព្រះអង្គមនុស្សអាចរកឃើញការអត់អោនទោស។ គឺតាមរយៈគុណសម្បត្តិនៃព្រះលោហិតនិងការស្ដាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះ គេអាចមានការគាប់ព្រះហឫទ័យរបស់ព្រះ ហើយត្រូវបាននាំត្រឡប់មកកាន់សួនច្បារដ៏ល្អ និងទទួលផ្លែជីវិតវិញ។

ដំបូងឡើយ ទេវតាមិនមានភាពរីករាយឡើយ ព្រោះមេ(ព្រះយេស៊ូវ) របស់លោកមិនបានពិភាក្សាអ្វីជាមួយគេសោះ តែបានបើកបង្ហាញដល់លោកនូវផែនការ



នៃសេចក្ដីសង្គ្រោះទៅវិញ។ ព្រះយេស៊ូវបានប្រាប់ដល់ពួកទេវតាថា ព្រះអង្គនឹងគង់នៅចន្លោះសេចក្ដីក្រោធរបស់ព្រះវរបិតា និងមនុស្សដែលមានទោស ដែលទ្រង់អាចទទួលការទុច្ចរិត និងការប្រមាថ ប៉ុន្ដែមានមនុស្សមួយចំនួននឹងទទួលទ្រង់ជាព្រះរាជ-បុត្រារបស់ព្រះ។ មនុស្សសឹងតែទាំងអស់នឹងស្អប់ទ្រង់ និងបដិសេធទ្រង់។ ព្រះអង្គនឹងលះចោលសិរីល្អទាំងអស់របស់ទ្រង់នៅស្ថានសួគ៌ មកនៅផែនដីជាមនុស្ស បន្ទាបព្រះកាយទ្រង់ដូចជាមនុស្ស ជួបប្រទះនូវបទពិសោធន៍របស់ព្រះអង្គផ្ទាល់ ជាមួយនឹងសេចក្ដីល្បួងផ្សេងៗដែលបានវាយប្រហារមនុស្សឥតឈប់ឈរ ដើម្បីអោយទ្រង់អាចជ្រាបនូវវិធីជួយដល់អ្នកដែលត្រូវទទួលការល្បួង ហើយទីបំផុត បន្ទាប់ពីបេសកកម្មរបស់ទ្រង់ជាគ្រូដែលទ្រង់បានបំពេញមក ទ្រង់ត្រូវធ្លាក់ទៅក្នុងដៃមនុស្ស ហើយទទួលរងនូវអំពើឃោរឃៅនិងការឈឺចាប់យ៉ាងខ្លាំង ដែលសាតាំង និងទេវតារបស់វាអាចបណ្ដាលដល់មនុស្សកំណាចអោយធ្វើ ដែលទ្រង់ត្រូវសុគតយ៉ាងឃោរឃៅបំផុត គឺព្យួរនៅចន្លោះស្ថានសួគ៌និងផែនដី ដូចជាមនុស្សមានបាប ដែលមានទោសដែរ ដែលទ្រង់ត្រូវរងនូវការឈឺចាប់ដ៏គួរអោយភ័យខ្លាច ដែលសូម្បីតែទេវតាក៏មិនអាចមើលមកចំដែរ ហើយត្រូវបានបែរព្រះភ័ក្ត្រចេញពីទស្សនីយភាពនោះទៅវិញ។ មិនមែនគ្រាន់តែការឈឺចាប់ខាងរាងកាយប៉ុណ្ណោះទេដែលទ្រង់ត្រូវរងទ្រាំ ប៉ុន្ដែគឺការឈឺចាប់ខាងផ្លូវចិត្តទៀតផង ដែលការឈឺចាប់ខាងរាងកាយ មិនអាចប្រៀបផ្ទឹមបានឡើយ។

ទម្ងន់នៃអំពើបាបលើលោកីយ៍ទាំងមូលនៅលើទ្រង់។ ទ្រង់បានប្រាប់គេថា ទ្រង់នឹងសុគតហើយមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទី៣ ហើយនឹងឡើងទៅឯព្រះវរ-បិតា ដើម្បីទូលអង្វរអំពីអំពើបាបរបស់មនុស្សមានទោសជំនួសគេ។

ទេវតាបានក្រាបនៅចំពោះទ្រង់។ ទេវតាទាំងអស់បានលះបង់ជីវិតរបស់លោក។ ព្រះយេស៊ូវបានមានបន្ទូលទៅកាន់ពួកទេវតាថា ទ្រង់ត្រូវតែលះបង់ព្រះជន្ម

របស់ព្រះអង្គផ្ទាល់ ដើម្បីសង្គ្រោះមនុស្សជាច្រើន ដ្បិតព្រះជន្មរបស់ទេវតាមិនអាចសងបំណុលរួចឡើយ ។ មានតែព្រះជន្មរបស់ព្រះអង្គមួយគត់ដែលព្រះវរបិតាទទួលជាថ្លៃលោះមនុស្ស ។

ព្រះយេស៊ូវក៏បានប្រាប់ទៅទេវតាទាំងអស់ថា ពួកលោកនឹងមានចំណែកដែលត្រូវបំពេញដែរ គឺនៅជាមួយព្រះអង្គ និងពង្រឹងព្រះអង្គនៅពេលពិបាកៗ ។ ដ្បិតទ្រង់នឹងយកធម្មជាតិជាមនុស្សដែលធ្លាក់ចុះ (មានបាប) ហើយកម្លាំងរបស់ទ្រង់មិនស្មើនឹងទេវតាឡើយ ។ រួចមានទេវតានឹងធ្វើជាសាក្សីនៃការបន្ទាបព្រះកាយ និងការឈឺចាប់ដ៏ធំរបស់ទ្រង់ ។ ហើយនៅពេលដែលទេវតាធ្វើទីបន្ទាល់អំពីការឈឺចាប់របស់ព្រះអង្គ និងការស្អប់ខ្ពើមរបស់មនុស្សចំពោះទ្រង់ លោក(ទេវតា)នឹងមានអារម្មណ៍រំជើបរំជួលយ៉ាងជ្រាលជ្រៅ ហើយតាមរយៈសេចក្ដីស្រឡាញ់របស់ទេវតាចំពោះទ្រង់ ដែលប្រាថ្នាចង់ជួយសង្គ្រោះនិងរំដោះព្រះអង្គចេញពីឃាតក ប៉ុន្តែគេមិនត្រូវរំខានដល់អ្វីដែលគេបានសង្កេតមើលឃើញនោះឡើយ ហើយគេគួរតែរួមចំណែកនៃការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ដែលផែនការនៃសេចក្ដីសង្គ្រោះត្រូវបានបង្កើតឡើង ហើយព្រះវរបិតារបស់ទ្រង់បានទទួលផែនការនោះ ។

ជាមួយនឹងការក្រៀមក្រំដ៏បរិសុទ្ធ ព្រះយេស៊ូវបានកំសាន្តចិត្ត និងលើកទឹកចិត្តដល់ពួកទេវតា និងប្រាប់ដល់ទេវតាទាំងអស់ថា ពីនេះទៅមុខអ្នកដែលទ្រង់បានលោះនឹងនៅជាមួយទ្រង់ និងរស់នៅជាមួយទ្រង់ជារៀងរហូត និងថាដោយការសុគតរបស់ទ្រង់ ទ្រង់នឹងចេញថ្លៃលោះអោយមនុស្សជាច្រើន និងបំផ្លាញដល់អ្នកដែលមានអំណាចនៃសេចក្ដីស្លាប់ ។ ហើយព្រះវរបិតារបស់ព្រះអង្គនឹងប្រទាននគរថ្វាយទ្រង់ និងភាពដ៏ឧត្តមនៃនគរនៅខាងក្រោមស្ថានសួគ៌ទាំងមូល ហើយព្រះអង្គនឹងគ្រប់គ្រងជារៀងរហូត ។ សាតាំងនិងអ្នកមានបាបនឹងត្រូវបានបំផ្លាញ និងមិនអាចរំខានដល់



ស្ថានសួគ៌ ឬផែនដីថ្មីដ៏ស្អាតតទៅទៀតឡើយ ។ ព្រះយេស៊ូវបានផ្សះផ្សាទេវតានៃស្ថាន-សួគ៌ជាមួយនឹងផែនការដែលព្រះវរបិតាបានទទួល និងអំណរព្រោះមនុស្សដែលបានធ្លាក់ចុះ អាចនឹងត្រូវបានលើកដំកើងឡើងវិញ តាមរយៈការសុគតរបស់ទ្រង់ ដើម្បីនឹងបានការគាប់ព្រះហឫទ័យជាមួយព្រះវរបិតា និងស្ថានសួគ៌ជាទីរីករាយ ។

ពេលនោះសេចក្ដីអំណរដែលមិនអាចពណ៌នាបាន បានបំពេញដល់ស្ថានសួគ៌ទាំងមូល ។ ហើយទេវតានៃស្ថានសួគ៌បានច្រៀងនូវចំរៀងសរសើរដំកើង និងសេចក្ដីស្រឡាញ់ ។ ពួកលោកបានកេះពិណ ហើយបានច្រៀងសំឡេងយ៉ាងខ្ពស់ដែលគេមិនធ្លាប់បានច្រៀងពីមុនមក ដ្បិតសេចក្ដីមេត្តាករុណាដ៏ឧត្តម និងភាពដ៏ឧត្តមរបស់ព្រះក្នុងការប្រទានព្រះរាជបុត្រាជាទីស្រឡាញ់ អោយសុគតសំរាប់ពួកអ្នកបះបោរ ។ សេចក្ដីសរសើរនិងសេចក្ដីស្រឡាញ់ ត្រូវបានចាកចេញទៅលើការលះបង់ និងពលិកម្មរបស់ព្រះយេស៊ូវ ដែលទ្រង់យល់ព្រមចាកចេញពីព្រះឱរារបស់ព្រះវរបិតា ហើយជ្រើសរើសយកជីវិតនៃការឈឺចាប់និងការទង្គឹះព្រះទ័យ និងសុគតដោយអាម៉ាស់ ដើម្បីប្រទានជីវិតដល់មនុស្សដទៃ ។

ទេវតាបានមានបន្ទូលថា អ្នកគិតថាព្រះវរបិតាបានប្រទានព្រះរាជបុត្រាជាទីស្រឡាញ់ដោយគ្មានការឈឺចាប់ឬអី? ទេ ពិតជាមានការឈឺចាប់ណាស់ សូម្បីតែព្រះនៅស្ថានសួគ៌ក៏ដោយ ថាតើត្រូវទុកអោយមនុស្សដែលមានទោសត្រូវស្លាប់ ឬមួយក៏ត្រូវលះបង់ព្រះរាជបុត្រាជាទីស្រឡាញ់អោយសុគតជំនួសពួកគេ ។ ពួកទេវតាមានការចាប់អារម្មណ៍ចំពោះការសង្គ្រោះរបស់មនុស្សណាស់ ដែលអាចរកឃើញនៅក្នុងចំណោមពួកគេ នូវអ្នកដែលផ្ដល់សិរីល្អ និងលះបង់ជីវិតសំរាប់មនុស្សដែលត្រូវវិនាស ។ ប៉ុន្តែសំដីនៃទេវតាដែលហែហមខ្ញុំនោះ គ្មានប្រយោជន៍សោះឡើយ ។ ការល្មើសច្បាប់នោះធំណាស់ ដែលព្រះជន្មរបស់ទេវតាមិនអាចសងបំណុលនោះបានឡើយ ។ គ្មានអ្វី

ក្រៅពីការសុគត និងការជួយសុំទោសរបស់ព្រះរាជបុត្រានោះសោះឡើយដែលអាចនឹងសងថ្លៃលោះ និងសង្គ្រោះមនុស្សបាត់បង់ពីទុក្ខដ៏គួរអោយអស់សង្ឃឹម និងសេចក្តីវេទនានេះ។

ប៉ុន្តែ ការងាររបស់ទេវតាគឺត្រូវបានចាត់តាំងអោយចុះនិងឡើងជាមួយនឹងការកំសាន្តចិត្តដ៏មានកម្លាំងពីសិរីល្អ ទៅលួងលោមព្រះរាជបុត្រានៃព្រះនៅក្នុងការឈឺចាប់របស់ទ្រង់ និងថែរក្សាដល់ទ្រង់។ ទេវតាក៏មានការងារដើម្បីយាងតាមនិងថែរក្សាប្រជារាស្ត្ររបស់ព្រះដ៏មានព្រះគុណពីទេវតាអាក្រក់ និងពីភាពងងឹតដែលហ៊ុំព័ទ្ធជុំវិញគេជានិច្ច ដោយសាតាំងផងដែរ។ ខ្ញុំបានឃើញថា ព្រះអង្គមិនមានលទ្ធភាពនឹងកែប្រែឬផ្លាស់ប្តូរច្បាប់របស់ព្រះអង្គដើម្បីសង្គ្រោះមនុស្សបាត់បង់ មនុស្សដែលត្រូវវិនាសឡើយ ហេតុនេះហើយទើបព្រះអង្គបានអនុញ្ញាតអោយព្រះរាជបុត្រាជាទីស្រឡាញ់មកសុគតដោយសារការប្រព្រឹត្តិរំលងរបស់មនុស្ស។

សាតាំងមានអំណរម្តងទៀតជាមួយទេវតារបស់វា ដោយបានទាញព្រះរាជ-បុត្រារបស់ព្រះពីដំណែងដ៏ខ្ពស់ ដោយការធ្វើអោយមនុស្សធ្លាក់ចុះ។ វាបានប្រាប់ដល់ទេវតារបស់វាថា នៅពេលដែលព្រះយេស៊ូវទទួលយកធម្មជាតិនៃមនុស្សដែលធ្លាក់ចុះ(មានបាប) វានឹងអាចយកឈ្នះលើទ្រង់ និងរារាំងការសំរេចផែនការនៃសេចក្តីសង្គ្រោះរបស់ទ្រង់។

រួចខ្ញុំបានឃើញថា សាតាំងវាបានបង្ហាញជាទេវតាដ៏សប្បាយរីករាយយ៉ាងខ្ពស់មួយអង្គ។ រួចខ្ញុំត្រូវបានបង្ហាញឱ្យឃើញដូចជាវាមាននៅសព្វថ្ងៃនេះ។ វានៅតែបញ្ចេញទ្រង់ទ្រាយជាសប្បុរស លក្ខណៈពិសេសរបស់វា នៅតែថ្លៃថ្នូរ ដ្បិតវាជាទេវតាដែលបានធ្លាក់ចុះ។ ប៉ុន្តែ ការបង្ហាញនៃទឹកមុខរបស់វានៅតែពោរពេញដោយការថប់បារម្ភ ការយកចិត្តទុកដាក់ ការសប្បាយរីករាយ ការព្យាបាទ សម្អប់ សេចក្តីប៉ង



ប្រាថ្នា ការបោកបញ្ឆោត និងអំពើអាក្រក់ទាំងឡាយដដែល។ ខ្ញុំបានកត់សំគាល់យ៉ាងច្បាស់ថា មានម្តង ចិញ្ចើមរបស់វាល្អជាខ្លាំង។ ថ្ងាសរបស់វាបានចាប់ផ្តើមពីភ្នែករបស់វារហូតដល់ឆកខាងក្រោយ។ ខ្ញុំបានឃើញថា វាបានបន្ទាបខ្លួនវាយ៉ាងយូរដែលគុណសម្បត្តិល្អៗទាំងអស់ត្រូវបានបន្ទាប។ ភ្នែករបស់វាមុត វាងវៃ និងបង្ហាញនូវសេចក្តីអង់អាច។ មាឌរបស់វាធំ ហើយសាច់ឈាមរបស់វាស្រស់ថ្លា ដូចជាដៃនិងមុខរបស់វា។ នៅពេលដែលខ្ញុំបានសំឡឹងមើលវា វាយកដៃស្តាំវាទ្រចង្កា។ បង្ហាញថាវាកំពុងគិតពិចារណាយ៉ាងវែងឆ្ងាយ។ ការញញឹមនៅលើទឹកមុខរបស់វា ធ្វើអោយខ្ញុំញ័រវាមានពេញដោយការអាក្រក់ និងភាពវាងវៃនៃសាតាំង។ ភាពញញឹមនេះ គឺជាការញញឹមដែលវាមាននៅពេលដែលវាដឹងច្បាស់ពីអ្នករងគ្រោះរបស់វា ហើយនៅពេលដែលវាសំឡឹងមិនដាក់ភ្នែក ទៅលើអ្នករងគ្រោះទាំងឡាយនៅក្នុងអន្ទាក់របស់វា។ ភាពញញឹមនេះ រីកធំយ៉ាងគួរអោយរន្ធត់។

សូមអាន អេសាយ ជំពូកទី៥៣។

## ជំពូកទី៤
## **ព្រឹត្តិការណ៍ទីមួយរបស់ព្រះគ្រីស្ទ**

នោះខ្ញុំត្រូវបានគេនាំចុះទៅដល់ពេលដែលព្រះយេស៊ូវត្រូវបានទទួលយកធម្ម-ជាតិជាមនុស្សផ្ទាល់ ទ្រង់បន្ទាបអង្គទ្រង់ជាមនុស្ស ហើយទទួលរងនូវការល្បួងរបស់សាតាំង។ ការប្រសូតរបស់ទ្រង់គ្មានភាពប្រសើរនៃលោកីយ៍នេះឡើយ។ ទ្រង់បានប្រសូតនៅក្នុងក្រោលសត្វ ផ្តេកនៅក្នុងស្នូក តែការប្រសូតរបស់ទ្រង់ត្រូវបានដំកើងឡើង លើសពីកូនរបស់មនុស្សណាៗទាំងអស់ ទេវតានៃស្ថានសួគ៌បានប្រាប់ដល់ពួក

អ្នកគង្វាលចៀមអំពីការយាងមករបស់ព្រះយេស៊ូវនៅពេលដែលពន្លឺនិងសិរីល្អមកពីព្រះអមទីបន្ទាល់របស់លោក (ទេវតា)។ ពពួកទេវតានៃស្ថានសួគ៌ដេញពិណ ហើយថ្វាយសិរីល្អដល់ព្រះ។ ទេវតាប្រកាសដោយជោគជ័យនូវការយាងមកនៃព្រះរាជបុត្រារបស់ព្រះមកកាន់ផែនដីដែលមានបាប ដើម្បីបំពេញអោយបានសំរេចនូវការងារនៃការប្រោសលោះ ហើយការសុគតរបស់ទ្រង់ នាំមកនូវសេចក្តីសុខសាន្ត សេចក្តីរីករាយ និងជីវិតអស់កល្បដល់មនុស្ស។ ព្រះអម្ចាស់បានផ្តល់សិរីរុងរឿងដល់ការយាងមករបស់ព្រះរាជបុត្រា។ ទេវតាបានថ្វាយបង្គំទ្រង់។

ទេវតារបស់ព្រះនៅពីលើទស្សនីយភាពនៃការជ្រមុជទឹករបស់ទ្រង់ ហើយព្រះវិញ្ញាណបរិសុទ្ធយាងចុះមក មានសណ្ឋានដូចជាសត្វព្រាប ហើយជះឥទ្ធិពលមកលើទ្រង់ បន្ទាប់មក នៅពេលដែលមនុស្សទាំងឡាយកំពុងសំឡឹងមើលមិនដាក់ភ្នែក ដោយអស្ចារ្យជាខ្លាំង ព្រះសូរសៀងនៃព្រះវរបិតាបានបន្លឺឡើងពីស្ថានសួគ៌មកថា នេះជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់។

លោកយ៉ូហានមិនបានដឹងច្បាស់ឡើយថា គឺព្រះអង្គសង្គ្រោះដែលបានយាងមកអោយគាត់ជ្រមុជទឹកអោយនៅទន្លេយ័រដាន់។ ប៉ុន្តែ ព្រះបានសន្យាដល់គាត់ដោយសញ្ញាដែលគាត់ស្គាល់ថាជាកូនចៀមរបស់ព្រះ។ សញ្ញានេះបានប្រទានមកជាសត្វព្រាបនៃស្ថានសួគ៌មកទំលើព្រះយេស៊ូវ ហើយសិរីល្អរបស់ព្រះចាំងមកលើទ្រង់។ លោកយ៉ូហានបានលើកដៃចង្អុលទៅព្រះយេស៊ូវ ដោយស្រែកជាសំឡេងយ៉ាងខ្លាំងថា នុ៎ះន៏កូនចៀមរបស់ព្រះ ដែលលោះបាបមនុស្សលោក។

លោកយ៉ូហានបានប្រាប់ដល់សិស្សរបស់គាត់ថា ព្រះយេស៊ូវគឺជាព្រះមែស៊ីដែលព្រះបានសន្យា គឺជាព្រះអង្គសង្គ្រោះនៃលោកីយ៏។ នៅពេលដែលលោកយ៉ូហានបានបញ្ចប់ការងាររបស់គាត់ គាត់បានបង្រៀនដល់សិស្សរបស់គាត់អោយសំឡឹងមើល



ទៅព្រះយេស៊ូវ ហើយដើរតាមទ្រង់ជាគ្រូដ៏ឧត្តម។ ជីវិតរបស់យ៉ូហានពុំមានសេចក្តីរីករាយឡើយ។ វាពោរពេញទៅដោយទុក្ខព្រួយនិងការលះបង់។ គាត់បានប្រកាសជាមុនអំពីការយាងមកជាលើកទីមួយរបស់ព្រះគ្រីស្ទ ហើយគាត់មិនត្រូវបានអនុញ្ញាតអោយបានធ្វើទីបន្ទាល់ពីការអស្ចារ្យរបស់ព្រះអង្គ និងមានអំណរជាមួយនឹងអំណាចដ៏អស្ចារ្យរបស់ទ្រង់ឡើយ។ គាត់បានដឹងថា នៅពេលដែលព្រះយេស៊ូវបានសំរេចអង្គទ្រង់ជាគ្រូនោះ គាត់ត្រូវតែស្លាប់។ ពាក្យពេចន៏របស់គាត់មិនសូវបានគេឮនោះទេលើកលែងតែនៅឯវាលរហោស្ថានតែប៉ុណ្ណោះ។ ជីវិតរបស់គាត់មានភាពឯកោ។ គាត់មិនបាននៅជាប់ជាមួយនឹងគ្រួសាររបស់ឪពុកគាត់ ដើម្បីមានសេចក្តីអំណរនៅក្នុងសង្គមរបស់គាត់ឡើយ ប៉ុន្តែគាត់បានចាកចេញពីការជួបជុំគ្នានោះដើម្បីបំពេញបេសកកម្មរបស់គាត់វិញ។ មនុស្សជាច្រើនបានចាកចោលស្រុកភូមិ និងទីក្រុងដ៏មមាញឹក និងហ្វូងសត្វរបស់ខ្លួន ទៅកាន់វាលរហោស្ថាន ដើម្បីស្តាប់ពាក្យពេចន៏ដ៏អស្ចារ្យរបស់ហោរាតែមួយគត់។ លោកយ៉ូហានដាក់ពូថៅនៅឫសដើមឈើ។ គាត់បានស្តីបន្ទោសដល់លទ្ធផលនៃការមិនភ័យខ្លាចចំពោះអំពើបាប និងបានរៀបចំផ្លូវសំរាប់កូនចៀមរបស់ព្រះ។

ស្តេចហេរូឌត្រូវបានទទួលឥទ្ធិពល នៅពេលដែលទ្រង់បានស្តាប់ទីបន្ទាល់ដ៏អស្ចារ្យ និងចំៗរបស់លោកយ៉ូហាន។ ដោយការចាប់អារម្មណ៏ជាខ្លាំង ព្រះអង្គបានសួរអំពីអ្វីដែលទ្រង់ធ្វើ ដើម្បីអោយក្លាយជាសិស្សរបស់គាត់។ លោកយ៉ូហានបានដឹងយ៉ាងច្បាស់អំពីរឿងពិត ដែលទ្រង់ប្រុងនឹងរៀបអាពាហ៏ពិពាហ៏ជាមួយប្រពន្ធរបស់ព្រះអនុជទ្រង់ ដែលស្វាមីរបស់នាងនៅរស់នៅឡើយ ហើយបានទូលដល់ស្តេចហេរូឌដោយស្មោះត្រង់ថា វាមិនត្រឹមត្រូវតាមច្បាប់ទេ។ ស្តេចហេរូឌពុំមានបំណងលះបង់ឡើយ។ ទ្រង់បានរៀបអាពាហ៏ពិពាហ៏ជាមួយនឹងប្រពន្ធរបស់ព្រះអនុជរបស់ព្រះអង្គ

ផ្ទាល់ ហើយតាមរយៈឥទ្ធិពលរបស់នាងនោះ លោកយ៉ូហានក៏ត្រូវគេចាប់ដាក់គុក។ ប៉ុន្តែ ស្តេចហេរូឌមានបំណងនឹងដោះលែងគាត់ចេញវិញ។ នៅពេលជាប់ឃុំឃាំង លោកយ៉ូហានបានឮតាមរយៈសិស្សរបស់គាត់នូវការងារដ៏មានឫទ្ធិបារមីរបស់ព្រះយេស៊ូវ។ គាត់មិនអាចស្តាប់ព្រះបន្ទូលទ្រង់បានទេ ប៉ុន្តែពួកសិស្សរបស់គាត់បានប្រាប់គាត់ និងកំសាន្តចិត្តគាត់ពីអ្វីដែលពួកគាត់បានឮ។ មិនយូរប៉ុន្មាន លោកយ៉ូហានត្រូវបានគេកាត់ក ដោយសារតែឥទ្ធិពលនៃមហេសីរបស់ស្តេចហេរូឌ។ ខ្ញុំបានឃើញថា សិស្សដ៏តូចបំផុតដែលបានដើរតាមព្រះយេស៊ូវ ធ្វើទីបន្ទាល់ពីការអស្ចារ្យរបស់ទ្រង់ និងឮពាក្យពេចន៍លួងលោមកំសាន្តចិត្ត ដែលបានមានបន្ទូលចេញពីព្រះឱស្ឋទ្រង់ នឹងបានធំជាងលោកយ៉ូហាន។ ហេតុនេះហើយពួកគេបានត្រូវលើកដំកើងឡើង ហើយកាន់តែមានអំណរនៅក្នុងជីវិតរបស់ពួកគេ។

លោកយ៉ូហានបានលេចមកក្នុងព្រះវិញ្ញាណ និងអំណាចរបស់អេលីយ៉ាដើម្បីប្រកាសអំពីការយាងមកជាលើកទីមួយរបស់ព្រះយេស៊ូវ។ ខ្ញុំត្រូវបានគេចង្អុលបង្ហាញនូវថ្ងៃចុងក្រោយបង្អស់ ហើយបានឃើញថា យ៉ូហានបានតំណាងអោយអ្នកដែលត្រូវចេញទៅក្នុងវិញ្ញាណ និងអំណាចរបស់អេលីយ៉ាដើម្បីប្រកាសប្រាប់អោយដឹងអំពីថ្ងៃនៃការឃោរឃៅ និងការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវ។ បន្ទាប់ពីការជ្រមុជទឹករបស់ព្រះយេស៊ូវនៅទន្លេយ័រដាន់មក ព្រះវិញ្ញាណបរិសុទ្ធបាននាំទ្រង់ទៅឯទីរហោស្ថានដើម្បីអោយអារក្សល្បួង។ ព្រះវិញ្ញាណបរិសុទ្ធបានប្រទានកម្លាំងដល់ទ្រង់ អោយទប់ទល់ចំពោះឆាកជីវិតដ៏ពិសេសនៃការល្បួងដ៏ខ្លាំងក្លានេះ។ ទ្រង់ត្រូវអារក្សល្បួងសែសិបថ្ងៃ ហើយនៅពេលនោះទ្រង់មិនបានសោយអ្វីសោះឡើយ។ អ្វីៗទាំងឡាយដែលនៅជុំវិញព្រះយេស៊ូវសុទ្ធតែក្រៀមក្រំដែលមនុស្សម្នាគេគេចវេះ។ ទ្រង់នៅជាមួយសត្វព្រៃនិងអារក្សនៅក្នុងទីស្ងាត់ដាច់ស្រយាល។ ខ្ញុំបានឃើញព្រះរាជបុត្រានៃព្រះ



ស្លេកស្លាំងនិងស្គមស្គាំងដោយការតមអត់អាហារ និងការឈឺចាប់។ ប៉ុន្តែទ្រង់នៅតែតម្រង់ទិសដៅដដែល ហើយទ្រង់ត្រូវតែសំរេចកិច្ចការដែលទ្រង់បានយាងមកបំពេញ។

សាតាំងបានយកចំណេញពីការឈឺចាប់របស់ព្រះរាជបុត្រានៃព្រះ ហើយរៀបចំដណ្តើមយកជ័យជំនះពីទ្រង់ ដោយការល្បួងផ្សេងៗជាច្រើន។ ដោយសង្ឃឹមថាវាអាចយកជ័យជំនះពីទ្រង់បាន ដោយសារទ្រង់បានបន្ទាបអង្គទ្រង់មកជាមនុស្ស។ សាតាំងបានមកជាមួយនឹងសេចក្តីល្បួងថា បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរបង្គាប់ដុំថ្មនេះអោយក្លាយជានំប៉័ងចុះ។ វាបានល្បួងព្រះយេស៊ូវអោយដំកើងខ្លួនឯង ហើយបង្ហាញដល់វាថាទ្រង់គឺជាព្រះមែស៊ីដោយប្រើអំណាចនៃព្រះ។ ព្រះយេស៊ូវបានឆ្លើយតបយ៉ាងចំៗទៅវាថា "ដ្បិតមានសេចក្តីចែងទុកមកថា មនុស្សមិនមែនរស់ដោយសារតែនំប៉័ងប៉ុណ្ណោះទេ គឺដោយសារគ្រប់ទាំងព្រះបន្ទូលដែលចេញពីព្រះឱស្ឋព្រះផងដែរ"។

សាតាំងបានស្វែងរកទំនាស់ជាមួយនឹងព្រះយេស៊ូវ ទាក់ទងទៅនឹងភាពជាព្រះរាជបុត្រានៃព្រះរបស់ទ្រង់។ វាសំដៅទៅលើភាពទន់ខ្សោយ ការឈឺចាប់របស់ទ្រង់ និងបញ្ជាក់ដោយអំនួតថា វាខ្លាំងជាងព្រះយេស៊ូវ។ ប៉ុន្តែ ព្រះបន្ទូលថ្លែងចេញពីស្ថានសួគ៌មកថា នេះជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់។ វាល្មមគ្រប់គ្រាន់សំរាប់ពង្រឹងព្រះយេស៊ូវនូវគ្រប់ការឈឺចាប់ទាំងអស់។ ខ្ញុំបានឃើញថា នៅគ្រប់ទាំងបេសកកម្មរបស់ទ្រង់ ព្រះអង្គមិនបានបង្ហាញឱ្យសាតាំងឃើញថា ទ្រង់ជាព្រះអង្គសង្គ្រោះនៃលោកីយ៍នេះឡើយ។ សាតាំងមានភស្តុតាងគ្រប់គ្រាន់អំពីឋានៈ និងអំណាចដ៏ខ្ពស់របស់ទ្រង់។ ការមិនសុខចិត្តរបស់វាក្នុងការទទួលស្គាល់អំណាចព្រះយេស៊ូវនេះហើយ ដែលបានធ្វើអោយវាធ្លាក់ចុះពីស្ថានសួគ៌។

សាតាំងបាននាំព្រះយេស៊ូវទៅកាន់ទីក្រុងយេរូសាឡិម ដើម្បីបញ្ជាក់ពីកម្លាំងរបស់វា ហើយដាក់ទ្រង់នៅលើកំពូលព្រះវិហារ រួចល្បួងទ្រង់ម្តងទៀតថា ប្រសិនបើ

ទ្រង់ជាព្រះរាជបុត្រានៃព្រះ អ្នកត្រូវបង្ហាញភស្តុតាង ដោយលោតពីកំពូលដ៏ខ្ពស់នេះចុះទៅ។ សាតាំងបានមកជាមួយនឹងពាក្យពេចន៏នៃសេចក្តីល្បួង។ ដ្បិតមានសេចក្តីចែងទុកមកថា ព្រះនឹងចាត់ទេវតាមកទ្រអ្នក ក្រែងជើងអ្នកទង្គិចនឹងថ្ម។ ព្រះយេស៊ូវឆ្លើយតបដោយមានបន្ទូលទៅកាន់វាថា "ដ្បិតមានសេចក្តីចែងទុកមកដូច្នេះថា ឯងមិនត្រូវល្បួងលព្រះអម្ចាស់នៃឯងឡើយ"។ សាតាំងមានបំណងធ្វើអោយព្រះយេស៊ូវប្រើប្រាស់សេចក្តីមេត្តាករុណារបស់ព្រះវរបិតា ហើយប្រថុយព្រះជន្មរបស់ទ្រង់ចំពោះការបំពេញបេសកកម្មរបស់ទ្រង់។ វាសង្ឃឹមថាផែនការនៃសេចក្តីសង្គ្រោះនឹងត្រូវបរាជ័យ ប៉ុន្តែខ្ញុំបានឃើញថា ផែនការត្រូវបានរៀបចំឡើងយ៉ាងមាំដើម្បីនឹងរំលំផែនការ ឬការធ្វើអោយសៅហ្មងរបស់សាតាំង។

ខ្ញុំបានឃើញថា ព្រះគ្រីស្ទគឺជាគំរូដល់គ្រីស្ទានទាំងអស់នៅពេលត្រូវល្បួង ឬនៅគ្រាមានទំនាស់។ គេត្រូវតែទប់ទល់ដោយអំណត់។ គេមិនត្រូវមានអារម្មណ៏ថាគេមានសិទ្ធិនឹងសុំអោយព្រះប្រើអំណាចរបស់ព្រះអង្គដើម្បីអោយខ្លួនមានជ័យជំនះទៅលើសត្រូវរបស់ខ្លួនឡើយ។ លុះត្រាណាតែមានកម្មវត្ថុនៅក្នុងគំនិតជាពិសេសណាមួយដែលសិរីល្អរបស់ព្រះត្រូវបានសរសើរដំកើងឡើងដោយសារការនោះ។ ខ្ញុំបានឃើញថាប្រសិនបើព្រះយេស៊ូវបានទម្លាក់អង្គទ្រង់ពីលើកំពូលព្រះវិហារមក វាមិនបានសរសើរដំកើងដល់ព្រះវរបិតាទ្រង់និងទេវតារបស់ព្រះឡើយ ដ្បិតនឹងគ្មានអ្នកណានឹងធ្វើទីបន្ទាល់ពីការនោះឡើយ មានតែសាតាំងប៉ុណ្ណោះ ហើយវាជាការល្បួងដល់ព្រះដើម្បីអោយទ្រង់ប្រើអំណាចរបស់ទ្រង់ទៅលើសត្រូវដ៏ជូរចត់របស់ទ្រង់។ វានឹងដំឡើងឫទ្ធិដាក់អ្នកដែលព្រះយេស៊ូវបានយាងមកដើម្បីយកជ័យជំនះ ហើយសាតាំងបាននាំទ្រង់ទៅកាន់កំពូលភ្នំដ៏ខ្ពស់ បង្ហាញទ្រង់ទតនូវនគរទាំងឡាយក្នុងលោកីយ៏ ហើយសាតាំងបាននិយាយទៅទ្រង់ថា បើឯងថ្វាយបង្គំខ្ញុំ ខ្ញុំនឹងអោយនគរទាំងនេះ និងសិរីល្អរបស់វា



ដល់អ្នក ដ្បិតនគរទាំងនេះជារបស់ខ្ញុំ ខ្ញុំនឹងអោយទៅអ្នកណាតាមតែចិត្តខ្ញុំ។ ព្រះយេស៊ូវមានបន្ទូលឆ្លើយទៅសាតាំងវិញថា "នែសាតាំងចូរថយចេញទៅ ដ្បិតមានសេចក្តីចែងទុកមកថា ឯងត្រូវថ្វាយបង្គំដល់ព្រះអម្ចាស់ជាព្រះនៃឯង តែមួយអង្គប៉ុណ្ណោះ"។

ត្រង់នេះ សាតាំងបានបង្ហាញនគរក្នុងលោកីយ៏ទាំងមូលទៅព្រះយេស៊ូវ វាបង្ហាញនូវពន្លឺដ៏គួរអោយចាប់អារម្មណ៏បំផុត។ វានឹងអោយទាំងអស់ទៅព្រះយេស៊ូវប្រសិនបើទ្រង់ថ្វាយបង្គំដល់វា។ វាបានទូលព្រះយេស៊ូវថា វានឹងលះបង់ចោលនូវការទាមទារទ្រព្យសម្បត្តិលោកីយ៏របស់វា។ សាតាំងដឹងថាអំណាចរបស់វាមានព្រំដែនហើយទីបំផុតនឹងត្រូវដកយកចេញប្រសិនបើផែនការនៃសេចក្តីសង្គ្រោះត្រូវបានសំរេច។ វាបានដឹងច្បាស់ថាប្រសិនបើព្រះយេស៊ូវត្រូវបានសុគត ដើម្បីលោះបាបមនុស្សលោកអំណាចរបស់វានឹងត្រូវបញ្ចប់ បន្ទាប់ពីពេលនោះតទៅ ហើយវាក៏នឹងត្រូវបានបំផ្លាញ។ ហេតុដូច្នេះហើយបានជាវាមានផែនការដែលបានរៀបចំយ៉ាងត្រឹមត្រូវ ដើម្បីទប់ស្កាត់ការសំរេចការងារដែលបានបង្គាប់ដល់ព្រះរាជបុត្រានៃព្រះ ប្រសិនបើអាចធ្វើទៅបាន។ ប្រសិនបើផែនការនៃការលោះបាបមនុស្សលោកត្រូវបរាជ័យ វានៅតែរក្សានគរដែលវាបានដណ្តើមយកនោះដដែល។ ហើយប្រសិនបើវាមានជោគជ័យ វានឹងដំកើងខ្លួនវាថាវាអាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់ព្រះនៅនគរស្ថានសួគ៌។

សាតាំងបានសំដែងសេចក្តីរីករាយយ៉ាងក្រៃលែង នៅពេលដែលព្រះយេស៊ូវបានចាកចេញពីស្ថានសួគ៌ និងចាកចេញពីអំណាចនិងសិរីល្អរបស់ទ្រង់នៅទីនោះ។ វាបានគិតថា ព្រះរាជបុត្រានៃព្រះត្រូវបានប្រគល់មកក្នុងអំណាចវាហើយ។ សេចក្តីល្បួងបានកើតឡើងយ៉ាងងាយស្រួលចំពោះគូស្រករបរិសុទ្ធមួយនៅសួនច្បារអេដែន ដែលវាសង្ឃឹមថា ដោយសារល្បិចកលរបស់វា វាអាចផ្តួលរំលំទាំងព្រះរាជបុត្រានៃព្រះបាន

ហើយអាចរក្សាជីវិតនិងនគររបស់វាបាន។ ប្រសិនបើវាអាចល្បួងព្រះយេស៊ូវអោយងាកបែរចេញពីព្រះហឫទ័យនៃព្រះវរបិតាបាន នោះគោលបំណងរបស់វានឹងបានសំរេច។ ព្រះយេស៊ូវបានកំចាត់សាតាំងអោយចេញពីទ្រង់។ ទ្រង់ត្រូវតែថ្វាយបង្គំចំពោះព្រះវរបិតាតែប៉ុណ្ណោះ។ ពេលវេលាដែលព្រះយេស៊ូវត្រូវលោះមនុស្សពីសាតាំងដោយព្រះជន្មរបស់ទ្រង់ផ្ទាល់បានមកដល់ហើយ ហើយបន្ទាប់ពីពេលនោះមក អ្វីៗទាំងអស់នៅស្ថានសួគ៌ និងផែនដីត្រូវតែចុះចូលជាមួយនឹងទ្រង់។ សាតាំងបានទាមទារថា ផែនដីជារបស់វា ហើយវានិយាយបញ្ឆិតបញ្ឆៀងទៅព្រះយេស៊ូវថា ការឈឺចាប់របស់ទ្រង់អាចត្រូវបានសង្គ្រោះ។ ទ្រង់មិនចាំបាច់ត្រូវសុគត ដើម្បីរក្សានគរលោកីយ៍នេះឡើយ។ ប៉ុន្តែ ទ្រង់អាចគ្រប់គ្រងលើនគរទាំងនោះ និងសិរីរុងរឿងរបស់វាផង ប្រសិនបើទ្រង់គ្រាន់តែថ្វាយបង្គំដល់វាតែប៉ុណ្ណោះ។ ព្រះយេស៊ូវមិនបានប្រែប្រួលឡើយ។ ទ្រង់បានជ្រើសរើសយកការឈឺចាប់ដល់ព្រះជន្មរបស់ព្រះអង្គ យកការសុគតយ៉ាងឈឺចាប់ ហើយនៅក្នុងរបៀបដែលព្រះវរបិតាបានតំរូវអោយទ្រង់។ ដើម្បីគ្រប់គ្រងនគរផែនដីដោយស្របច្បាប់ ហើយមរតកទាំងអស់ត្រូវប្រគល់ទៅលើព្រះហស្តរបស់ទ្រង់ដ៏អស់កល្ប។ សាតាំងក៏នឹងត្រូវប្រគល់ថ្វាយទ្រង់ដើម្បីនឹងបំផ្លាញ ដោយសេចក្តីស្លាប់ដែលមិនអាចនឹងមករំខានដល់ព្រះយេស៊ូវ ឬអ្នកបរិសុទ្ធក្នុងសិរីល្អតទៅទៀតឡើយ។

សូមអាន ចោទិយកថា ៦:១៦, ៨:៣ ពង្សាវតាក្សត្រទី២ ១៧:៣៥-៣៦ ទំនុកដំកើង ៩១:១១-១២, លូកាជំពូក ២-៤។



ជំពូកទី៥

## ការងាររបស់ព្រះគ្រីស្ទ

បន្ទាប់ពីសាតាំងបានបញ្ចប់ការល្បួងរបស់វា វាបានចាកចេញពីព្រះយេស៊ូវ ហើយទេវតាក៏បាននាំយកអាហារមកថ្វាយទ្រង់សោយនៅទីរហោស្ថាន និងចំរើនកម្លាំងដល់ទ្រង់ ហើយព្រះពររបស់ព្រះវរបិតាក៏មកសណ្ឋិតលើទ្រង់។ សាតាំងបានទទួលបរាជ័យក្នុងការល្បួងដ៏ខ្លាំងក្លារបស់វា ប៉ុន្តែ វាស្វែងរកឱកាសនៅក្នុងការងាររបស់ព្រះយេស៊ូវ ដើម្បីរកពេលណាមួយនឹងប្រើល្បិចកលរបស់វា ទាស់នឹងព្រះយេស៊ូវម្តងទៀត។ វានៅតែសង្ឃឹមថា វាអាចយកជ័យជំនះពីទ្រង់បាន ដោយបំផុសអ្នកដែលមិនទទួលព្រះយេស៊ូវអោយស្អប់ខ្ពើម និងរកឱកាសបំផ្លាញទ្រង់។ សាតាំងបានពិភាក្សាពិសេសមួយជាមួយទេវតារបស់វា។ ពួកវាមានការខកចិត្តនិងខឹងជាខ្លាំងដោយវាគ្មានជោគជ័យអ្វីទៅលើព្រះរាជបុត្រានៃព្រះបន្ទិចសោះ។ ពួកវាបានសំរេចចិត្តថា ពួកវាត្រូវតែប្រើល្បិចកលនិងអំណាចរបស់វាអោយខ្លាំងបំផុត ដើម្បីបណ្តាលដល់អ្នកមិនជឿព្រះយេស៊ូវ នៅក្នុងគំនិតនៃជាតិសាសន៍របស់វា ថាវាជាអ្នកសង្គ្រោះលោកីយ៍ ហើយរបៀបនេះ នឹងធ្វើអោយព្រះយេស៊ូវអស់សេចក្តីក្លាហាននឹងការងាររបស់ទ្រង់។ ទោះបីជាពួកយូដា នៅក្នុងពិធីបុណ្យ និងការថ្វាយយញ្ញបូជាយ៉ាងត្រឹមត្រូវយ៉ាងណាក៏ដោយ ប្រសិនបើពួកវាអាចបិទភ្នែកគេពីបទទំនាយទាំងស្រុង ហើយធ្វើអោយពួកគេជឿថាមានអំណាចអស្ចារ្យមួយ ស្តេចផែនដីដែលកើតឡើង ដើម្បីសំរេចនូវបទទំនាយ ពួកគេនឹងបង្វែរគំនិតរបស់គេ ហើយសំឡឹងមើលទៅលើការយាងមករបស់ព្រះមែស៊ី។

ខ្ញុំត្រូវបានគេបង្ហាញថាសាតាំង និងទេវតារបស់វារវល់ណាស់ក្នុងការបញ្ចុះ-

បញ្ចូលមនុស្សដោយការមិនជឿ សម្អប់និងការប្រមាថ នៅពេលដែលព្រះគ្រីស្ទកំពុងបំពេញការងាររបស់ទ្រង់។ ជាញឹកញាប់ នៅពេលដែលព្រះយេស៊ូវបន្លឺព្រះសូរសៀងអំពីសេចក្ដីពិតដើម្បីបញ្ជាក់ពីអំពើបាបរបស់វា វាខឹងជាខ្លាំង។ សាតាំងនិងទេវតារបស់វា ជំរុញអ្នកមានបាបទាំងនោះ អោយធ្វើគុតព្រះរាជបុត្រានៃព្រះ។ មានម្ដងពួកគេបានយកដុំថ្មគប់ទ្រង់ ប៉ុន្តែទេវតាបានថែរក្សាទ្រង់ ហើយនាំទ្រង់ចេញពីហ្វូងមនុស្សដ៏ឃោរឃៅទៅកាន់កន្លែងសុខសាន្តមួយ។ នៅពេលដែលផែនការនៃសេចក្ដីពិតបានចេញពីព្រះឱស្ឋទ្រង់ម្ដងទៀត ហ្វូងមនុស្សបានចាប់ទ្រង់ ហើយនាំទ្រង់យកទៅលើកំពូលភ្នំ បំរុងនឹងច្រានទម្លាក់។ ការមិនចុះសំរុងគ្នា បានកើតឡើងនៅក្នុងចំណោមពួកគេអំពីការដែលគេបំរុងនឹងធ្វើទៅលើទ្រង់ នៅពេលនោះទេវតាបានលាក់ទ្រង់ពីភ្នែកហ្វូងមនុស្សម្ដងទៀត ហើយទ្រង់បានយាងចេញពីចំណោមពួកគេទៅ។

សាតាំងនៅតែសង្ឃឹមថា ផែនការសង្គ្រោះដ៏ឧត្ដមនឹងបរាជ័យជាមិនខាន។ វាបង្កើនអំណាចទាំងប៉ុន្មានរបស់វា ដើម្បីធ្វើអោយចិត្តមនុស្សឈឺចាប់ និងអារម្មណ៍របស់គេជូរចត់ ប្រឆាំងនឹងព្រះយេស៊ូវ។ វាសង្ឃឹមថា ចំនួនអ្នកដែលទទួលទ្រង់ថាជាព្រះរាជបុត្រានៃព្រះនឹងមានយ៉ាងតិច ដែលព្រះយេស៊ូវនឹងពិចារណាថា ការឈឺចាប់និងការលះបង់របស់ទ្រង់ សំរាប់តែមនុស្សមួយក្រុមយ៉ាងតូច។ ប៉ុន្តែ ខ្ញុំបានឃើញថាប្រសិនបើមានមនុស្សតែពីរនាក់នឹងទទួលព្រះយេស៊ូវថាជាព្រះរាជបុត្រានៃព្រះ ហើយជឿលើទ្រង់ថាជាអ្នកសង្គ្រោះដល់ព្រលឹងរបស់គេ ព្រះយេស៊ូវនៅតែបន្តផែនការនោះដដែល។

ព្រះយេស៊ូវបានចាប់ផ្ដើមកិច្ចការរបស់ទ្រង់ ដោយបំបាក់អំណាចដែលសាតាំងដាក់លើមនុស្សឱ្យមានការឈឺចាប់។ ទ្រង់បានព្យាបាលអ្នកដែលបានឈឺចាប់ ដោយសារអំណាចអាក្រក់របស់វា។ ទ្រង់ព្យាបាលអ្នកឈឺអោយជាឡើងវិញ ទ្រង់បានព្យាបាល



អ្នកពិការ និងធ្វើអោយពួកគេលោតឡើង ដោយអំណរនៅក្នុងចិត្តគេ ហើយថ្វាយសិរីល្អដល់ព្រះ។ ទ្រង់បានប្រទានពន្លឺដល់អ្នកខ្វាក់ ទ្រង់បានប្រើអំណាចរបស់ទ្រង់ ដើម្បីព្យាបាលអ្នកដែលត្រូវបានអារក្សចង និងជិះជាន់ដោយអំណាចដ៏ឃោរឃៅរបស់វាអស់ពេលជាច្រើនឆ្នាំ។ ទ្រង់បានកំសាន្តចិត្តដល់អ្នកខ្សោយ អ្នកញ័ររន្ធត់ និងអ្នកខូចចិត្តដោយព្រះបន្ទូលនៃព្រះគុណ។ ទ្រង់បានប្រោសអ្នកដែលស្លាប់អោយរស់ឡើងវិញ ហើយពួកគេបានសរសើរសិរីល្អរបស់ព្រះ ចំពោះការបញ្ចេញអំណាចដ៏អស្ចារ្យរបស់ទ្រង់។ ទ្រង់មានព្រះហឫទ័យខ្វល់ខ្វាយយ៉ាងខ្លាំងចំពោះអ្នកដែលជឿលើទ្រង់។ ហើយអ្នកខ្សោយដែលឈឺចាប់ដោយសាតាំងមានជោគជ័យលើពួកគេ ព្រះយេស៊ូវទាញចេញពីកណ្ដាប់ដៃរបស់វាយកគេត្រឡប់មកវិញ ដោយអំណាចរបស់ទ្រង់ ដោយរាងកាយមាំមួន និងអំណាច ព្រមទាំងដោយភាពរីករាយយ៉ាងខ្លាំង។

ព្រះជន្មរបស់ព្រះយេស៊ូវ ពោរពេញទៅដោយសេចក្ដីមេត្តាករុណា អាណិតអាសូរ និងសេចក្ដីស្រឡាញ់។ ទ្រង់តែងតែយកព្រះទ័យទុកដាក់ស្ដាប់ និងធ្វើអោយធូរស្បើយនូវទុក្ខកង្វល់របស់អ្នកដែលមករកទ្រង់។

ហ្វូងមនុស្សនាំយកភស្តុតាងនៅក្នុងខ្លួនគេផ្ទាល់នៃអំណាចរបស់ព្រះ។ បន្ទាប់ពីការងារត្រូវបានសំរេច មិនយូរប៉ុន្មាន ពួកគេជាច្រើនត្រូវបានអៀនខ្មាសដោយការបន្ទាបខ្លួនរបស់លោកគ្រូដ៏មានចេស្ដា។ ដោយសារអ្នកដឹកនាំមិនបានជឿដល់ទ្រង់ គេមិនចង់ឈឺចាប់ជាមួយព្រះយេស៊ូវឡើយ។ ប៉ុន្តែ មានតិចតួចណាស់ដែលអាចយល់ព្រមលះបង់ខ្លួនឯងឱ្យព្រះអង្គដឹកនាំដោយស្រគត់ស្រគំ។ គេមានបំណងចង់រីករាយជាមួយនឹងកិត្តិយសដែលលោកីយ៍ផ្ដល់ឱ្យ។ មនុស្សជាច្រើនបានដើរតាមព្រះរាជបុត្រានៃព្រះ ហើយស្ដាប់ការបង្រៀនរបស់ព្រះអង្គ ទទួលព្រះបន្ទូលដែលចេញពីព្រះឱស្ឋដែលប្រកបដោយព្រះគុណរបស់ទ្រង់។ ព្រះបន្ទូលរបស់ទ្រង់មាន

អត្ថន័យយ៉ាងក្រៃលែង ត្រង់ៗ ដែលអ្នកខ្សោយអាចយល់បាន ។

សាតាំងនិងទេវតារបស់វារវល់ជាខ្លាំង វាបិទភ្នែកនឹងធ្វើអោយការយល់របស់ពួកយូដាទៅជាងងឹតងងល់ ។ សាតាំងបានបណ្តាលអោយមេនៃមនុស្សនិងអ្នកដឹកនាំធ្វើគុតព្រះយេស៊ូវ ។ គេបានចាត់អ្នកដឹកនាំអោយនាំព្រះយេស៊ូវទៅឯគេ ហើយនៅពេលដែលទៅជិតដល់កន្លែងដែលទ្រង់គង់នៅគេមានការអស្ចារ្យជាខ្លាំង ។ ពួកគេបានឃើញព្រះយេស៊ូវបង្ហាញសេចក្តីមេត្តាករុណា និងអាណិតអាសូរ នៅពេលដែលទ្រង់ធ្វើទីបន្ទាល់នៅចំពោះមនុស្សពីទុក្ខព្រួយ ។ ពួកគេបានឃើញទ្រង់កំពុងមានព្រះបន្ទូលលើកទឹកចិត្តដល់អ្នកទន់ខ្សោយនិងអ្នកមានទុក្ខវេទនាដោយសេចក្តីស្រឡាញ់ និងភាពថ្នាក់ថ្នម ។ ពួកគេក៏បានឮទ្រង់បណ្តេញអំណាចរបស់សាតាំងដោយសំឡេងនៃអំណាច ហើយដណ្តើមយកអ្នកដែលសាតាំងគ្រប់គ្រងអោយមានសេរីភាពមកវិញដែរ ។ ពួកគេបានស្តាប់ព្រះបន្ទូលនៃគតិបណ្ឌិតដែលចេញពីព្រះឱស្ឋទ្រង់ ហើយពួកគេបានចាប់អារម្មណ៍យ៉ាងខ្លាំង ។ ពួកគេមិនអាចយកដៃគេទៅចាប់ព្រះយេស៊ូវឡើយ ។ អ្នកដឹកនាំបានសួរគេថា តើហេតុអ្វីបានជាអ្នករាល់គ្នាមិនបាននាំវាមក? ពួកគេបង្ហាញនូវអ្វីដែលគេបានឃើញអំពីការអស្ចារ្យរបស់ទ្រង់ និងព្រះបន្ទូលដ៏បរិសុទ្ធដែលពោរពេញដោយគតិបណ្ឌិត សេចក្តីស្រឡាញ់ និងចំណេះដឹង ដែលពួកគេបានឮហើយបានបញ្ចប់ ដោយនិយាយថា មិនដែលមានអ្នកណានិយាយដូចមនុស្សនេះទេ ។ សម្តេចសង្ឃបានចោទប្រកាន់ពួកគេថា ត្រូវបានគេបោកបញ្ឆោតដែរហើយ ។ ខ្លះមានការខ្មាសអៀនជាខ្លាំងដោយទាហានមិនបានចាប់ព្រះយេស៊ូវមក ។ សម្តេចសង្ឃបានសួរដោយអាកប្បកិរិយាម៉ឺងម៉ាត់ថា តើមានអ្នកដឹកនាំណាបានជឿដល់វាឬទេ? ខ្ញុំបានឃើញថា មានចៅក្រមនិងអ្នកដឹកនាំជាច្រើនបានជឿលើព្រះយេស៊ូវ ប៉ុន្តែសាតាំងបានរារាំងពួកគេមិនអោយប្រកាសពីការនោះ ។ ពួកគេខ្លាចការស្តីបន្ទោសរបស់មនុស្សខ្លាំង ជាងខ្លាចព្រះ ។



ទោះបីជាយ៉ាងនេះក៏ដោយ ក៏កលល្បិចនិងសម្ងប់របស់សាតាំងមិនបានបំបែកផែនការនៃសេចក្តីសង្គ្រោះឡើយ ។ ពេលវេលានៃការសំរេចកិច្ចការដែលព្រះយេស៊ូវបានយាងមកបំពេញនោះបានមកដល់ហើយ ។ សាតាំងនិងទេវតារបស់វាបានពិគ្រោះគ្នាហើយបានសំរេចចិត្តថា នឹងបណ្តាលអោយរាស្ត្ររបស់ព្រះអង្គផ្ទាល់ ស្រែកទាមទារលោហិតរបស់ព្រះអង្គដោយអន្ទះសារ និងបង្កើតរឿងឃោរឃៅ និងប្រមាថមកលើទ្រង់ ។ វាសង្ឃឹមថា ព្រះយេស៊ូវនឹងតូចព្រះទ័យចំពោះការប្រព្រឹត្តិបែបនេះ ហើយលែងរក្សាការបន្ទាបព្រះកាយនិងភាពស្លូតបូតបន្តទៅទៀត ។

នៅពេលដែលសាតាំងកំពុងរៀបចំផែនការរបស់វា ព្រះយេស៊ូវបានបើកសំដែងពីការរងទុក្ខដែលទ្រង់ត្រូវទទួលប្រាប់ដល់ពួកសាវកយ៉ាងប្រុងប្រយ័ត្ន ថាទ្រង់នឹងត្រូវគេឆ្កាង ហើយថាទ្រង់នឹងមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី ។ ប៉ុន្តែ ការយល់របស់គេ ហាក់បីដូចជាងងឹតឈឹង ។ ពួកគេមិនអាចយល់ពីអ្វីដែលទ្រង់មានបន្ទូលប្រាប់ពួកគេឡើយ ។

សូមអានលូកា ៤:២៩ យ៉ូហាន ៧:៤៥-៤៨, ៨:៥៩ ។

ជំពូកទី៦

## **សិរីរុងរឿង**

ខ្ញុំបានឃើញថា សេចក្តីជំនឿរបស់ពួកសាវកត្រូវបានចំរើនឡើងយ៉ាងខ្លាំងនៅពេលដែលមានសិរីរុងរឿង ។ ព្រះអម្ចាស់បានជ្រើសរើសប្រទានដល់សិស្សរបស់ព្រះយេស៊ូវនូវភស្តុតាងយ៉ាងធំដែលបញ្ជាក់ថា ទ្រង់គឺជាព្រះមែស៊ីដែលព្រះបានសន្យាថាពួកគេនឹងមានសង្ឃឹមទាំងស្រុងទៅលើព្រះអង្គនោះ ទោះបីជាគេមានទុក្ខព្រួយដ៏

ជូរចត់ក៏ដោយ។ នៅគ្រាមានសិរីរុងរឿង ព្រះអម្ចាស់បានចាត់លោកម៉ូសេ និងលោកអេលីយ៉ាមកនិយាយជាមួយនឹងព្រះយេស៊ូវអំពីការរងទុក្ខនិងការសុគតរបស់ទ្រង់។ ជាជាងចាត់ទេវតាឱ្យមកសន្ទនាជាមួយនឹងព្រះរាជបុត្រារបស់ទ្រង់ ព្រះអម្ចាស់បានចាត់មនុស្សដែលធ្លាប់មានបទពិសោធន៏ក្នុងការឈឺចាប់នៃលោកីយ៏នេះមកវិញ។ សាវករបស់ព្រះអង្គពីរបីនាក់ត្រូវបានអនុញ្ញាតអោយទៅជាមួយទ្រង់ ហើយបានឃើញព្រះភ័ក្ត្ររបស់ទ្រង់ភ្លឺដោយសិរីល្អនៃព្រះ និងទីបន្ទាល់នៃកម្មវត្ថុពណ៌ស និងបញ្ចេញពន្លឺស្រអ័ព្ទ ហើយនិងឮព្រះសូរសៀងរបស់ព្រះដោយព្រះបារមីគួរអោយភ័យខ្លាច មានបន្ទូលមកថា នេះជាកូនស្ងួនភ្ងាអញ ចូរស្តាប់ទ្រង់ចុះ។

លោកអេលីយ៉ាបានដើរជាមួយព្រះ។ ការងាររបស់គាត់មិនបានសប្បាយឡើយ។ តាមរយៈគាត់ ព្រះអម្ចាស់បានស្តីបន្ទោសដល់អំពើបាប។ គាត់គឺជាហោរារបស់ព្រះអម្ចាស់ ហើយបានផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀត ដើម្បីរក្សាអាយុជីវិតរបស់គាត់។ គាត់ត្រូវគេតាមប្រមាញ់ដូចជាសត្វព្រៃដែលគេរកបំផ្លាញ។ ព្រះអម្ចាស់ទ្រង់បានការពារអេលីយ៉ា។ ទេវតាបាននាំយកលោកទៅកាន់ស្ថានសួគ៌នៅក្នុងសិរីល្អ និងជោគជ័យ។

ម៉ូសេធ្លាប់ជាមនុស្សម្នាក់ដែលព្រះបានទទួលកិត្តិយសយ៉ាងធំ។ គាត់បានជាធំឧត្តមជាងមនុស្សណាទាំងអស់ដែលរស់នៅមុនគាត់។ គាត់មានកិត្តិយសបាននិយាយជាមួយនឹងព្រះមុខទល់និងមុខ ដូចជាមនុស្សនិយាយជាមួយមិត្តភ័ក្តិ។ គាត់ត្រូវបានអនុញ្ញាតអោយឃើញពន្លឺយ៉ាងត្រចះត្រចង់ និងសិរីល្អដ៏រុងរឿងដែលចេញពីព្រះវរ-បិតា។ តាមរយៈលោកម៉ូសេ ព្រះបានរំដោះពួកអ៊ីស្រាអែលចេញពីចំណងនៅស្រុកអេស៊ីព្ទ។ លោកម៉ូសេគឺជាអ្នកនាំពាក្យនៃកូនចៅអ៊ីស្រាអែល។ គាត់តែងតែឈរនៅកណ្តាលសេចក្តីក្រោធរបស់ព្រះនិងពួកគេ។ នៅពេលដែលសេចក្តីក្រោធរបស់ព្រះ



ធំធេងបានបង្កឡើងទាស់នឹងអ៊ីស្រាអែលចំពោះការមិនជឿរបស់គេ ការរអ៊ូរទាំរបស់គេ និងអំពើបាបធ្ងន់ធ្ងររបស់គេ សេចក្តីស្រឡាញ់របស់ម៉ូសេចំពោះគេត្រូវបានសាកល្បង។ ព្រះបានសន្យាចំពោះគាត់ថា ប្រសិនបើទ្រង់អនុញ្ញាតអោយពួកអ៊ីស្រាអែលចេញទៅចូរអោយគេត្រូវបំផ្លាញចុះ ទ្រង់នឹងធ្វើអោយពួកគេក្លាយជាជាតិសាសន៏ដ៏ធំមួយ។ លោកម៉ូសេបានបង្ហាញសេចក្តីស្រឡាញ់របស់គាត់ដល់ពួកអ៊ីស្រាអែល ដោយការទទូចអង្វរដោយស្មោះអស់ពីចិត្ត។ នៅក្នុងកង្វល់របស់គាត់ គាត់បានអធិស្ឋានទៅព្រះសុំអោយព្រះអង្គបង្វែរការក្រោធដ៏ខ្លាំងរបស់ទ្រង់ ហើយអត់ទោសដល់ពួកអ៊ីស្រាអែលឬលុបឈ្មោះរបស់គាត់ចេញពីបញ្ជីរបស់ទ្រង់។

នៅពេលដែលពួកអ៊ីស្រាអែលរអ៊ូរទាំទាស់នឹងព្រះ និងលោកម៉ូសេ ព្រោះគេមិនមានទឹក ពួកគេបានចោទប្រកាន់គាត់ថា បាននាំគេមកសម្លាប់ ព្រមទាំងកូនចៅគេផង។ ព្រះបានឮការរអ៊ូរទាំរបស់ពួកគេ ហើយបានបង្គាប់អោយលោកម៉ូសេនិយាយទៅថ្ម។ កូនចៅអ៊ីស្រាអែលបានបណ្តាលអោយគាត់រងទុក្ខព្រួយដ៏ខ្លាំងបំផុត ហើយនៅក្នុងរយៈពេលតែបន្តិចសោះ គាត់បានភ្លេចថា តើព្រះបាននៅជាមួយពួកគេ ហើយការរអ៊ូរទាំរបស់ពួកគេ មិនមែនទាស់នឹងម៉ូសេទេ គឺទាស់នឹងព្រះ។ គេគិតតែពីខ្លួនឯងគេខុសយ៉ាងខ្លាំង ហើយគេមានការដឹងគុណចំពោះសេចក្តីស្រឡាញ់មកលើពួកគេ មានយ៉ាងតិចតួច។

នៅពេលដែលម៉ូសេបានវាយថ្ម គាត់មិនបានថ្វាយសិរីល្អទៅព្រះ និងលើកដំកើងទ្រង់នៅចំពោះមុខពួកកូនចៅអ៊ីស្រាអែល ដែលគេត្រូវតែថ្វាយសិរីល្អទៅព្រះនោះឡើយ។ ដូច្នេះព្រះមិនសព្វព្រះទ័យចំពោះលោកម៉ូសេឡើយ ទ្រង់បានមានបន្ទូលថា គាត់មិនអាចចូលទៅកាន់ដែនដីនៃសេចក្តីសន្យាបានឡើយ។ វាគឺជាផែនការរបស់ព្រះដែលតែងតែបង្ហាញដល់ពួកអ៊ីស្រាអែលដោយការនាំគេមកកាន់ច្រកសមុទ្រ ហើយ

បន្ទាប់មកនៅក្នុងការបង្ហាញនូវអំណាចដ៏សំខាន់របស់ទ្រង់ដ៏ឧត្តមដែលទ្រង់អាចគង់នៅក្នុងការចងចាំរបស់ពួកគេ ហើយគេត្រូវតែសរសើរដំកើងទ្រង់។

នៅពេលដែលលោកម៉ូសេចុះពីលើភ្នំជាមួយនឹងបន្ទះថ្មពីរផ្ទាំង ហើយនិងបានឃើញពួកអ៊ីស្រាអែលដែលកំពុងថ្វាយបង្គំរូបគោមាស កំហឹងរបស់គាត់ក៏បានពុះពោរឡើងយ៉ាងខ្លាំង គាត់ក៏បោះបន្ទះថ្មហើយបំបែកខ្ទេចខ្ទី។ ខ្ញុំបានឃើញថាលោកម៉ូសេពុំបានអនុញ្ញាតឱ្យគេថ្វាយបង្គំគោនោះទេ។ គាត់មានតម្លៃនៅចំពោះព្រះព្រោះគាត់ការពារសិរីល្អរបស់ព្រះ។ ប៉ុន្តែ នៅពេលដែលគាត់បានបណ្តោយទៅតាមអារម្មណ៍នៃចិត្តពីកំណើតរបស់គាត់ ហើយយកសិរីល្អដែលគួរតែថ្វាយទៅព្រះនោះសម្រាប់ខ្លួនឯង គាត់បានធ្វើបាប ហើយអំពើបាបនោះព្រះនឹងមិនអនុញ្ញាតអោយគាត់ចូលទៅក្នុងទឹកដីដែលបានសន្យានោះឡើយ។

សាតាំងបានព្យាយាមរករឿងចោទប្រកាន់លោកម៉ូសេមុខទេវតា។ សាតាំងមានជោគជ័យ នៅពេលនោះ វាបានបណ្តាលអោយម៉ូសេធ្វើអោយព្រះមិនសព្វព្រះហឫទ័យ ហើយវាបានសំដែងសេចក្តីរីករាយយ៉ាងក្រៃលែង រួចបានប្រាប់ទៅទេវតាថានៅពេលដែលព្រះអង្គសង្គ្រោះនៃពិភពលោកនេះ នឹងយាងមកវិញដើម្បីលោះបាបមនុស្សលោក វាអាចមានជ័យជំនះលើគាត់។ ចំពោះការប្រព្រឹត្តិល្មើសនេះ ម៉ូសេបានធ្លាក់ទៅក្រោមអំណាចរបស់សាតាំង ជារាស្ត្រនៃសេចក្តីស្លាប់ ប៉ុន្តែ ទេវតាមីកែលបានចុះមកហើយបានប្រទានជីវិតដល់គាត់ មុននឹងគាត់បានឃើញការពុករលួយ សាតាំងបានទាមទារយកសពរបស់លោកម៉ូសេ ប៉ុន្តែទេវតាមីកែលបានប្រោសម៉ូសេអោយរស់ឡើងវិញ ហើយបានយកគាត់ទៅកាន់ស្ថានសួគ៌។ អារក្សបានព្យាយាមយកសពរបស់គាត់ហើយប្រមាថទាស់នឹងព្រះយ៉ាងជូរចត់ ថ្កោលទោសថា ទ្រង់មិនយុត្តិធម៌ឡើយក្នុងការយកជនរងគ្រោះពីវាដូច្នេះ។ ប៉ុន្តែទេវតាមីកែលមិនបានគំរាមអារក្សទេ ទោះបី



ជាបានឆ្លងកាត់ការល្បួងរបស់វានិងអំណាចដែលអ្នកបំរើរបស់ព្រះបានធ្លាក់ចុះក៏ដោយ។ ព្រះគ្រីស្ទបានលើកគាត់ទៅឯព្រះវរបិតាយ៉ាងស្លូតបូតដោយមានបន្ទូលថា ព្រះអម្ចាស់ស្តីបន្ទោសអ្នក។ ព្រះយេស៊ូវបានមានបន្ទូលប្រាប់ពួកសាវករបស់ទ្រង់ថា នឹងមានអ្នកខ្លះឈរនៅជាមួយនឹងទ្រង់ដោយមិនបានភ្លក្សសេចក្តីស្លាប់ឡើយ រហូតដល់គេបានឃើញនគរព្រះមកដល់ដោយអំណាច។ នៅគ្រាមានសិរីរុងរឿង សេចក្តីសន្យានេះបានសំរេចហើយ។ ទឹកព្រះភ័ក្ត្ររបស់ព្រះយេស៊ូវត្រូវបានផ្លាស់ប្រែ និងបានចែងចាំងដូចជាព្រះអាទិត្យ។ កាំរស្មីរបស់ទ្រង់មានពណ៌ស និងភ្លឺចែងចាំង។ លោកម៉ូសេមានវត្តមាននិងតំណាងអោយអ្នកដែលបានលើកពីស្លាប់ឡើងវិញ នៅពេលដែលព្រះលេចឡើងជាលើកទីពីរ។ ហើយលោកអេលីយ៉ាដែលត្រូវបានបកស្រាយថា អ្នកដែលមិនបានឃើញសេចក្តីស្លាប់ តំណាងអោយអ្នកដែលនឹងត្រូវបានផ្លាស់ប្រែ ទៅជាមិនពុករលួយ នៅគ្រានៃការយាងមកវិញជាលើកទីពីររបស់ព្រះគ្រីស្ទ ហើយការដែលមិនបានឃើញសេចក្តីស្លាប់នឹងបានយកទៅកាន់ស្ថានសួគ៌។ ពួកសាវកបានសំឡឹងមើលដោយការភ័យខ្លាចនិងការភ្ញាក់ផ្អើល នូវឧត្តមភាពដ៏ប្រសើររបស់ព្រះយេស៊ូវ និងពពកដែលបាំងពួកគេ ហើយបានឮព្រះសូរសៀងរបស់ព្រះ នៅក្នុងព្រះចេស្តាដ៏គួរអោយរន្ធត់មកថា នេះជាកូនស្ងួនភ្ងាអញ ចូរស្តាប់ទ្រង់ចុះ។

សូមអាន និក្ខមនំ ជំពូក៣២ ជនគណនា ២០:៧-១២ ចោទិយកថា ៣៤:៥ ពង្សាវតាក្សត្រទី២ ២:១១ ម៉ាកុសជំពូក៩ និង យូដាស៩។

ជំពូកទី៧

## ការឃុបឃិតចាប់ព្រះយេស៊ូវ

ពេលនោះខ្ញុំត្រូវបានគេនាំទៅដល់ពេលវេលា ដែលព្រះយេស៊ូវបានសោយអាហារពេលល្ងាច ក្នុងពិធីបុណ្យរំលងជាមួយនឹងពួកសាវករបស់ទ្រង់។ សាតាំងបានបញ្ឆោតយូដាស ហើយអោយគាត់គិតថា គាត់គឺជាសាវកម្នាក់ក្នុងចំណោមសាវកដ៏ពិតរបស់ព្រះគ្រីស្ទ ប៉ុន្តែចិត្តរបស់គាត់គឺជាអ្នកលោភលន់ គាត់ធ្លាប់បានឃើញការដ៏អស្ចារ្យរបស់ព្រះយេស៊ូវ គាត់ធ្លាប់នៅជាមួយទ្រង់ នៅគ្រាដែលទ្រង់បានបំពេញការងារ ហើយបានចុះចូលជាមួយនឹងអំណាចដ៏ហួសវិស័យរបស់ទ្រង់ ដែលជាភស្តុតាងថា ទ្រង់គឺជាព្រះមែស៊ី ប៉ុន្តែគាត់ជាមនុស្សកំណាញ់ និងលោភលន់។ គាត់ស្រឡាញ់ប្រាក់។ គាត់បានរអ៊ូរទាំចំពោះទឹកអប់ដ៏មានតម្លៃដែលនាងម៉ារីបានចាក់លើព្រះយេស៊ូវ។ នាងម៉ារីបានស្រឡាញ់ព្រះអម្ចាស់របស់នាង។ ទ្រង់បានអត់ទោសបាបដល់នាងជាច្រើន ហើយបានប្រោសប្អូនប្រុសជាទីស្រឡាញ់របស់នាងអោយរស់ពីស្លាប់ឡើងវិញ ហើយនាងបានគិតថា គ្មានអ្វីដែលមានតម្លៃច្រើនពេកសំរាប់នឹងថ្វាយដល់ព្រះយេស៊ូវនោះឡើយ។ ទឹកអប់ដ៏ថ្លៃវិសេស នាងម៉ារីកាន់តែអាចបង្ហាញពីការដឹងគុណរបស់នាងចំពោះព្រះអង្គសង្គ្រោះកាន់តែខ្លាំងឡើង ដោយបូជាថ្វាយទៅទ្រង់។ ដើម្បីជាលេសនៃ ការលោភលន់របស់ខ្លួនយូដាសបាននិយាយថា ទឹកអប់នេះថ្លៃណាស់ គួរតែលក់យក លុយទៅចែកអ្នកក្រីក្រវិញ។ ដោយគាត់ជាមនុស្សអាត្មានិយម គាត់តែងតែលួចប្រើប្រាស់ឈ្មោះអ្នកក្រីក្រដែលជាការទទួលខុសត្រូវរបស់គាត់ សំរាប់ផលប្រយោជន៏ ខ្លួនគាត់ផ្ទាល់ដោយស្ងាត់កំបាំង។ យូដាសមិនបានយកចិត្តទុកដាក់ដល់ការកំសាន្តចិត្ត នឹងបំណងព្រះហឫទ័យរបស់ព្រះយេស៊ូវឡើយ ហើយគាត់បានបិទបាំងការលោភលន់ របស់ខ្លួនគាត់តែងតែ



យកអ្នកក្រីក្រមកបិទបាំងធ្វើជាលេស។ ហើយសកម្មភាពនៃការ សប្បុរសរបស់នាងម៉ារី គឺជាការប៉ះពាល់យ៉ាងខ្លាំងបំផុតចំពោះគំនិតលោភលន់របស់គាត់។

ផ្លូវសំរាប់ការល្បួងរបស់សាតាំងត្រូវបានរៀបចំដើម្បីស្វែងរកការរៀបចំទទួលនៅក្នុងចិត្តយូដាស។ ពួកយូដាបានស្អប់ព្រះយេស៊ូវ ប៉ុន្តែហ្វូងមនុស្សបានចោមរោមទ្រង់ដើម្បីស្តាប់ព្រះបន្ទូលនៃគតិបណ្ឌិតរបស់ទ្រង់ និងមើលការងារដ៏មានព្រះចេស្តារបស់ទ្រង់។ ការនេះបានទាក់ទាញពួកមនុស្សចេញពីសម្តេចសង្ឃ និងពួកអ្នកដឹកនាំ ត្បិតពួកមនុស្សត្រូវបានពុះកញ្ជ្រោលដោយការចាប់អារម្មណ៏យ៉ាងខ្លាំងបំផុត និងបានដើរតាមព្រះយេស៊ូវ ដោយនៅមិនសុខ និងស្តាប់ការបង្រៀនរបស់គ្រូដ៏អស្ចារ្យនោះ។ មានមេលើអ្នកដឹកនាំជាច្រើនបានជឿលើព្រះយេស៊ូវ ប៉ុន្តែគេមិនហ៊ានសារភាពដោយភ័យខ្លាចក្រែងត្រូវគេបណ្តេញចេញពីព្រះវិហារ។ ពួកសង្គ្រាជនិងចាស់ទុំបានសំរេចចិត្តថាត្រូវតែធ្វើនុយដើម្បីទាក់ទាញមនុស្សចេញពីព្រះយេស៊ូវ។ គេព្រួយបារម្ភខ្លាចក្រែងមនុស្សទាំងអស់ជឿលើទ្រង់។ គេអាចឃើញថាមិនមានសុវត្ថិភាពដល់ពួកគេឡើយ។ ពួកគេត្រូវតែបាត់បង់តួនាទី ឬត្រូវតែធ្វើគុតព្រះយេស៊ូវ។ ប៉ុន្តែក្រោយពីគេធ្វើគុតព្រះយេស៊ូវមក ក៏នៅតែមានអ្នកដែលនឹកចាំពីអំណាចរបស់ទ្រង់ដែរ។ ព្រះយេស៊ូវបានលើកឡាសារពីស្លាប់។ ហើយគេបារម្ភថា ប្រសិនបើគេធ្វើគុតព្រះយេស៊ូវ ឡាសារអាចធ្វើបន្ទាល់ពីអំណាចរបស់ទ្រង់។ មនុស្សម្នាបានចោមរោមមើលឡាសារដែលបានប្រោសអោយរស់ឡើងវិញ ហើយអ្នកដឹកនាំបានសំរេចចិត្តថា នឹងសម្លាប់ឡាសារចោលដែរ ព្រមទាំងកំចាត់ការភ្ញាក់ផ្អើលនោះចេញ។ ពេលនោះគេអាចបង្វែរមនុស្សមករកប្រពៃណី និងគោលលទ្ធិរបស់មនុស្សវិញអោយថ្វាយដង្វាយដប់ហូតមួយ ពីជីអង្កាម និងជីរនាងល័ក្ខណ៏ ហើយនឹងមានឥទ្ធិពលទៅលើពួកគេជាថ្មីឡើងវិញ។ គេបានយល់ព្រមគ្នាថានឹងចាប់ព្រះយេស៊ូវនៅពេលដែលទ្រង់គង់នៅតែមួយអង្គឯង ព្រោះ

ប្រសិនបើគេចាប់ទ្រង់នៅចំពោះមុខហ្វូងមនុស្ស នៅពេលដែលគំនិតរបស់មនុស្សទាំងឡាយកំពុងតែចាប់អារម្មណ៍ទៅលើទ្រង់ នោះពួកគេនឹងត្រូវហ្វូងមនុស្សគប់នឹងថ្មជាមិនខាន។ យូដាសបានដឹងអំពីវិធីដែលអាចចាប់ព្រះយេស៊ូវបាន ហើយយល់ព្រមក្បត់ទ្រង់ជាមួយនឹងសម្តេចសង្ឃនិងពួកនាហ្មឺន ដោយសារប្រាក់បន្តិចបន្តួច។ ការស្រឡាញ់ប្រាក់របស់គាត់ បានដឹកនាំគាត់អោយយល់ព្រមឃុបឃិតប្រគល់ព្រះអម្ចាស់របស់គាត់ទៅក្នុងកណ្តាប់ដៃនៃសត្រូវដ៏ជូរចត់របស់ទ្រង់។ សាតាំងបានធ្វើការយ៉ាងធំចំពោះមុខ ជាមួយយូដាស ហើយនៅពាក់កណ្តាលឆាកដ៏គួរឱ្យរំភើបនៃបុណ្យរំលងចុងក្រោយបង្អស់ វាបានប្រឌិតផែនការដើម្បីចាប់ព្រះយេស៊ូវ។ ព្រះយេស៊ូវបានមានបន្ទូលប្រាប់ដល់ពួកសាវកទាំងក្រៀមក្រំថា នៅយប់នោះ ពួកគេទាំងអស់នឹងបោះបង់ទ្រង់។ ប៉ុន្តែពេត្រុសប្រកែកយ៉ាងដាច់អហង្កាថា ទោះបីជាគេទាំងអស់គ្នាបោះបង់ចោលទ្រង់ក៏ដោយ ក៏គាត់មិនបោះបង់ទ្រង់ដែរ។ ព្រះយេស៊ូវបានមានបន្ទូលទៅកាន់ពេត្រុសថា សាតាំងចង់បានអ្នកហើយដើម្បីអោយវាអាចព្រោះអ្នកដូចជាគ្រាប់ពូជ ប៉ុន្តែខ្ញុំបានអធិស្ឋានអោយអ្នកដើម្បីកុំអោយជំនឿអ្នកត្រូវដួលឡើយ ហើយនៅពេលដែលអ្នកបានដឹងខ្លួនឡើង អ្នកអាចជួយចំរើនកម្លាំងដល់បងប្អូនអ្នកផង។

ពេលនោះ ខ្ញុំបានឃើញព្រះយេស៊ូវនៅក្នុងសួនច្បារជាមួយនឹងពួកសាវក។ នៅក្នុងការក្រៀមក្រំជាទីបំផុត ព្រះអង្គបានប្រាប់អោយពួកគេចាំយាម និងអធិស្ឋានដើម្បីកុំអោយត្រូវល្បួង។ ព្រះយេស៊ូវបានជ្រាបថាសេចក្តីជំនឿរបស់ពួកគេប្រុងប្រៀបជាស្រេច តែសាច់ឈាមនៅខ្សោយទេ ហេតុដូច្នេះពួកគេត្រូវការកម្លាំងទាំងអស់នេះដោយការប្រុងប្រៀប និងការអធិស្ឋានយ៉ាងខ្ជាប់ខ្ជួន។ ព្រះយេស៊ូវបានអធិស្ឋានដោយយំស្រែកថា ព្រះវរបិតាអើយ បើសិនជាបាន សូមអោយពែងនេះរំលងពីទូលបង្គំទៅ តែសូមកុំតាមចិត្តទូលបង្គំឡើយ គឺតាមព្រះហឫទ័យទ្រង់វិញ។ ព្រះរាជបុត្រា



របស់ព្រះបានអធិស្ឋានដោយការឈឺចាប់ជាខ្លាំង។ តំណក់ញើសធំៗដូចជាគ្រាប់ឈាមបានហូរចេញពីព្រះភ័ក្រ្តទ្រង់ធ្លាក់ទៅលើដី។ ទេវតាបានបន្ទាបខ្លួនមកជិតកន្លែងនោះដើម្បីមើលទស្សនីយភាពដែលមានតែម្នាក់គត់ ដែលត្រូវបានត្រាស់បង្គាប់អោយចំរើនកម្លាំងដល់ព្រះរាជបុត្រានៃព្រះនៅក្នុងការឈឺចាប់របស់ទ្រង់។ ទេវតាទាំងឡាយនៅស្ថានសួគ៌ បានដោះមកុដនិងទំលាក់ពិណចោល ហើយបានសំឡឹងមើលទៅឯព្រះយេស៊ូវដោយការចាប់អារម្មណ៍យ៉ាងជ្រៅនិងស្ងៀមស្ងាត់។ គ្មានអំណរនៅស្ថានសួគ៌ឡើយ។ ពពួកទេវតាប្រាថ្នាចង់ចោមរោមព្រះរាជបុត្រានៃព្រះ ប៉ុន្តែមេលើពួកទេវតាទាំងនោះត្រាស់បង្គាប់មិនអោយទៅឡើយ ទុកអោយពួកលោកនៅសំឡឹងមើលការឈឺចាប់របស់ទ្រង់ ពពួកលោកអាចរំដោះទ្រង់បាន តែផែនការបានរៀបចំជាស្រេច ហើយផែនការនោះត្រូវតែបានសំរេច។

បន្ទាប់ពីព្រះយេស៊ូវបានអធិស្ឋានមក ទ្រង់បានយាងទៅមើលពួកសាវក។ ពួកគេកំពុងដេកលក់។ ទ្រង់គ្មានការកំសាន្តចិត្តដោយការអធិស្ឋានពីអ្នកណាឡើយនៅក្នុងឱកាសដ៏គួរអោយខ្លាចនោះ សូម្បីតែពួកសាវកក៏គ្មានដែរ។ ពេត្រុសដែលបានការពារទ្រង់កាលពីមុនបន្តិចនេះ បានដេកលក់សូន្យឈឹង។ ព្រះយេស៊ូវបានរំឭកដល់ពួកគេដោយប្រកាសជាវិជ្ជមាន ដោយបានមានព្រះបន្ទូលទៅកាន់ពួកគេថា ដូច្នេះ តើអ្នករាល់គ្នាចាំយាមជាមួយនឹងខ្ញុំតែមួយម៉ោងមិនបានទេឬអី? ព្រះរាជបុត្រានៃព្រះអធិស្ឋានដោយការឈឺចាប់បីដង នៅពេលដែលយូដាសនិងពួកទាហានបានមកដល់។ គាត់បានជួបព្រះយេស៊ូវ ហើយគោរពទ្រង់ដូចធម្មតា។ ពួកទាហានក៏បានព័ទ្ធព្រះយេស៊ូវ ប៉ុន្តែនៅទីនោះ ទ្រង់បានបញ្ចេញអំណាចជាព្រះរបស់ទ្រង់ ដោយមានបន្ទូលថា តើអ្នករកអ្នកណា រកខ្ញុំឬអី?។ ពួកទាហានដួលផ្ងាទៅលើដី។ ព្រះយេស៊ូវបានធ្វើការនេះដើម្បីអោយពួកគេបានឃើញអំណាចរបស់ទ្រង់ និងជាភស្តុតាងថា ទ្រង់អាចរំដោះអង្គ

ទ្រង់ចេញពីពួកគេបាន ប្រសិនបើទ្រង់ចង់គេចព្រះកាយ។

ពួកសាវកគេមានសង្ឃឹមឡើងវិញ ដោយគេបានឃើញហ្វូងទាហានដែលមានទាំងដំបង និងដាវ ដួលយ៉ាងរហ័សបែបនេះ។ នៅពេលដែលពួកគេក្រោកឡើង ហើយហ៊ុំព័ទ្ធព្រះរាជបុត្រានៃព្រះម្តងទៀត ពេត្រុសបានដកដាវ កាត់ដាច់ស្លឹកត្រចៀកទាហានម្នាក់។ ព្រះយេស៊ូវបានបង្គាប់អោយគាត់ទុកដាវទៅវិញ ហើយមានបន្ទូលទៅគាត់ថា តើអ្នកស្មានថាខ្ញុំមិនអាចនឹងសូមដល់ព្រះវរបិតាឥឡូវ ដែលទ្រង់នឹងចាត់ទេវតា១២កងមកខ្ញុំជាមួយរំពេចទេឬអី? ខ្ញុំបានឃើញថា នៅពេលដែលព្រះអង្គមានបន្ទូលនូវពាក្យទាំងនេះ ទឹកមុខរបស់ពួកទេវតាមានភាពរីតតែមាំឡើង។ ពេលនោះ លោកចង់ទៅចោមរោមមេបញ្ជាការរបស់លោក និងកំចាត់កងទ័ពឃោរឃៅនោះ។ ប៉ុន្តែភាពក្រៀមក្រំបានធ្លាក់មកលើទេវតាទាំងនោះម្តងទៀត នៅពេលដែលព្រះយេស៊ូវបានមានព្រះបន្ទូលបន្ថែមថា បើយ៉ាងនោះ ធ្វើដូចម្តេចនឹងបានសំរេចតាមគម្ពីរដែលថាត្រូវតែកើតមានដូច្នេះ? ចិត្តរបស់ពួកសាវកបានស្រុតចុះទៅវិញដោយការអស់សង្ឃឹម និងការខកចិត្តយ៉ាងជូរចត់ នៅពេលដែលព្រះយេស៊ូវប្រាប់ឱ្យទាហាននាំទ្រង់ចេញទៅ។

ពួកសាវកគេមានការភ័យខ្លាចចំពោះអាយុជីវិតរបស់គេ គេនាំគ្នារត់ចែកផ្លូវគ្នា ហើយទុកអោយព្រះយេស៊ូវនៅតែមួយអង្គឯង។ ឱ! នោះគឺជា ជោគជ័យដ៏ធំរបស់សាតាំង។ ហើយគឺជាការក្រៀមក្រំនិងសោកស្តាយជាទីបំផុតដល់ទេវតារបស់ព្រះ។ ទេវតាបរិសុទ្ធជាច្រើនកង ដែលមានទេវតាខ្ពស់១ ជាមេគ្រប់គ្រង ត្រូវបានចាត់អោយទៅមើលទស្សនីយភាពនោះ។ លោកត្រូវកត់ត្រានូវរាល់សកម្មភាព រាល់ការប្រមាថ និងការឃោរឃៅ ដែលគេបានធ្វើមកលើព្រះរាជបុត្រានៃព្រះ និងចុះក្នុងបញ្ជីនូវរាល់ការឈឺចាប់ខាងផ្លូវចិត្តដែលព្រះយេស៊ូវបានទទួល ដ្បិតមនុស្សទាំងឡាយនឹងឃើញបញ្ជីទាំងនោះម្តងទៀត នៅក្នុងគ្រារស់ឡើងវិញ។



សូមអាន ម៉ាថាយ ២៦:១-៥៦ ម៉ាកុស ១៤:១-៥២ លូកា ២២: ១-៤៦ យ៉ូហានជំពូក ១១, ១២:១-១១, ១៨:១-១២។

ជំពូកទី៨

## ការឈឺចាប់របស់ព្រះគ្រីស្ទ

នៅពេលដែលទេវតាបានចាកចេញពីស្ថានសួគ៌ទាំងក្រៀមក្រំ បានដោះមកុដដ៏ភ្លឺចាំងចេញ។ លោកមិនអាចពាក់ឡើងវិញឡើយ នៅពេលដែលមេបញ្ជាការលោករងការឈឺចាប់ នឹងត្រូវពាក់ភួងបន្លានោះ។ សាតាំងនិងទេវតារបស់វារវល់យ៉ាងខ្លាំងនៅក្នុងបន្ទប់ជំនុំជំរះ ដើម្បីបំផ្លាញមនុស្សជាតិ និងភាពអាណិតអាសូរ។ បរិយាកាសនៅគ្រានោះធ្ងន់ធ្ងរ និងពិសពុលជាខ្លាំង ដោយសារឥទ្ធិពលរបស់វា។ វាបានដឹកនាំសម្តេចសង្ឃនិងពួកអ្នកដឹកនាំអោយធ្វើទុក្ខ និងប្រមាថដល់ព្រះយេស៊ូវនៅក្នុងអាកប្ប-កិរិយាមួយដែលមនុស្សជាតិពិបាកនឹងទ្រាំទ្រ។ សាតាំងបានសង្ឃឹមថា ការប្រមាថ និងការឈឺចាប់បែបនេះ នឹងធ្វើអោយព្រះរាជបុត្រានៃព្រះហើបព្រះឱស្ឋត្អូញត្អែរនិងរអ៊ូរទាំ ឬក៏ទ្រង់អាចបញ្ចេញអំណាចជាព្រះរបស់ទ្រង់ រួចរំដោះអង្គទ្រង់ចេញពីការឈឺចាប់នៃហ្វូងមនុស្សហើយ ធ្វើដូច្នេះផែនការនៃសេចក្តីសង្គ្រោះនឹងត្រូវបរាជ័យជាចុងក្រោយបង្អស់។

លោកពេត្រុសបានដើរតាមព្រះអម្ចាស់របស់គាត់ បន្ទាប់ពីការកាត់ទោសមកគាត់បានឃើញការដែលគេបានធ្វើទៅលើព្រះយេស៊ូវ។ ហើយនៅពេលដែលគេបានចោទថា គាត់ជាមនុស្សម្នាក់ក្នុងចំណោមសិស្សរបស់ព្រះយេស៊ូវ គាត់បានប្រកែក។ គាត់មានការភ័យខ្លាចចំពោះជីវិតរបស់គាត់ ហើយនៅពេលដែលគេបានចោទគាត់ថាជា

អ្នកដែលបាននៅជាមួយនឹងទ្រង់ដែរនោះ គាត់បានអះអាងថា គាត់មិនបានស្គាល់អ្នកនោះទេ។ ពួកសាវ័កបានកត់សំគាល់នូវភាពបរិសុទ្ធនៃព្រះបន្ទូលរបស់ទ្រង់ ត្រូវបានបញ្ឆោតនិងបំភ័ន្តថាគេមិនមែនជាសាវ័ករបស់ទ្រង់ទេ ហើយពេត្រុសបានប្រកែកថាមិនមែនជាសាវ័ករបស់ព្រះយេស៊ូវបីដង ដោយពាក្យប្រមាថនិងស្បថស្បែ។ ព្រះយេស៊ូវដែលនៅមិនឆ្ងាយប៉ុន្មានពីពេត្រុសនោះ ទ្រង់បានបែរព្រះភ័ក្ត្រទតមើលមកពេត្រុសទាំងក្រៀមក្រំ។ ពេលនោះគាត់បាននឹកឃើញព្រះបន្ទូលរបស់ព្រះយេស៊ូវដែលមានបន្ទូលទៅកាន់គាត់នៅបន្ទប់ខាងលើ និងការដែលគាត់បានអះអាងថានៅតែស្មោះត្រង់ជាមួយព្រះយេស៊ូវរបស់គាត់ជានិច្ច ទោះបីជាមនុស្សទាំងអស់នឹងរវាតចិត្តដោយព្រោះទ្រង់ក៏ដោយ គង់តែទូលបង្គំមិនដូច្នេះទេ។ គាត់បានបោះបង់ចោលព្រះអម្ចាស់របស់គាត់ទាំងប្រមាថនិងស្បថ ប៉ុន្តែការក្រឡេកមើលរបស់ព្រះយេស៊ូវ បានបំបែកចិត្តពេត្រុស និងសង្គ្រោះគាត់ភ្លាម។ គាត់បានយំទួញយ៉ាងខ្លាំង ហើយបានលន់តួទោសពីអំពើបាបដ៏ធំរបស់គាត់ ហើយបានកែប្រែចិត្ត រួចត្រូវបានរៀបចំដើម្បីចំរើនកម្លាំងដល់បងប្អូនរបស់គាត់។

ហ្វូងមនុស្សបានស្រែកទាមទារលោហិតរបស់ព្រះយេស៊ូវ។ ពួកគេបានធ្វើទុក្ខដល់ទ្រង់យ៉ាងឃោរឃៅ ហើយបំពាក់អាវស្តេចពណ៌ស្វាយឱ្យទ្រង់ ព្រមទាំងបំពាក់ភួងបន្លាលើព្រះសិរទ្រង់ផង។ ពួកគេបានយកដើមត្រែងដាក់លើព្រះហស្តទ្រង់ រួចថ្វាយបង្គំទ្រង់ដោយចំអក ហើយគោរពទ្រង់ ដោយពាក្យថា សូមថ្វាយបង្គំស្តេចនៃសាសន៍យូដា រួចពួកគេយកដើមត្រែងចេញពីព្រះហស្តទ្រង់ ហើយយកមកវាយព្រះសិរទ្រង់ធ្វើអោយបន្លាចាក់ទម្លុះព្រះសិរទ្រង់ បង្ហូរឈាមរហាមកាត់ព្រះភ័ក្ត្រនិងពុកចង្កាទ្រង់។

វាជាការពិបាកណាស់ដល់ទេវតាទាំងឡាយក្នុងការទ្រាំទ្រចំពោះទិដ្ឋភាពបែបនេះ។ ពួកលោកគួរតែរំដោះព្រះយេស៊ូវចេញពីពួកគេ ប៉ុន្តែមេលើពួកទេវតា បានហាម



ប្រាមដល់លោក ហើយបានមានបន្ទូលថា នោះគឺជាការលោះយ៉ាងធំដែលត្រូវបានចេញសងជំនួសមនុស្ស ប៉ុន្តែនឹងត្រូវចប់សព្វគ្រប់ ហើយបណ្តាលអោយអ្នកមានអំណាចលើសេចក្តីស្លាប់ត្រូវសុគត។ ព្រះយេស៊ូវបានជ្រាបថា ទេវតាបានទតមើលទិដ្ឋភាពនៃការបន្ទាបព្រះកាយរបស់ទ្រង់។

ខ្ញុំបានឃើញថា ទេវតាដ៏ខ្សោយបំផុត អាចបណ្តាលអោយហ្វូងមនុស្សបាត់បង់អំណាច ហើយរំដោះព្រះយេស៊ូវបាន។ ទ្រង់បានជ្រាបថា ប្រសិនបើទ្រង់សុំការនេះពីព្រះវរបិតា ទេវតានឹងពិតជារំដោះទ្រង់មិនខាន។ ប៉ុន្តែវាជាការសំខាន់ដែលព្រះយេស៊ូវត្រូវតែរងទុក្ខជាច្រើនយ៉ាង ពីមនុស្សអាក្រក់ ដើម្បីសំរេចផែនការនៃសេចក្តីសង្គ្រោះ។

នៅទីនោះព្រះយេស៊ូវបានឈរយ៉ាងស្លូតបូត និងសុភាពរាបសារនៅចំពោះហ្វូងមនុស្សដែលមានកំហឹង នៅពេលដែលពួកគេបានផ្តល់ដល់ទ្រង់នូវការរំលោភបំពានយ៉ាងសាហាវបំផុត។ ពួកគេបានស្តោះដាក់ព្រះភ័ក្ត្រទ្រង់ ជាព្រះភ័ក្ត្រដែលថ្ងៃណាមួយគេនឹងរត់ពួនហើយគេចចេញ ជាព្រះភ័ក្ត្រដែលនឹងផ្តល់ពន្លឺដល់ទីក្រុងរបស់ព្រះ ហើយនិងចាំងពន្លឺភ្លឺជាងព្រះអាទិត្យ ប៉ុន្តែ មិនឃើញមានកំហឹងណាមួយចេញទៅរកអ្នកប្រឆាំងទាំងនោះឡើយ។ គេបានលើកដៃដ៏ឃោរឃៅរបស់គេឡើង ហើយវាយទ្រង់។ គេបានគ្របព្រះសិរទ្រង់ដោយអាវផាយកញ្ចាស់ មិនអោយទ្រង់មើលឃើញ ហើយទះកំភ្លៀងទ្រង់ រួចសួរថា ចូរឯងទាយទៅមើល អ្នកណាវាយឯង។ មានការរំជើបរំជួលយ៉ាងខ្លាំងក្នុងចំណោមពួកទេវតា។ លោកគួរតែរំដោះទ្រង់ភ្លាម ប៉ុន្តែមេលើពួកទេវតាហាមឃាត់ពួកលោក។

ពួកសាវ័កគេមានសេចក្តីក្លាហានឡើងវិញ ហើយបានទៅមើលការកាត់ទោសរបស់ទ្រង់។ ពួកគេរំពឹងថា ទ្រង់នឹងបញ្ចេញអំណាចជាព្រះរបស់ទ្រង់ ហើយរំដោះអង្គទ្រង់ចេញពីកណ្តាប់ដៃនៃពួកសត្រូវ និងដាក់ទណ្ឌកម្មដល់ពួកនោះ ចំពោះអំពើឃោរ-

យោដែលគេបានប្រព្រឹត្តមកលើទ្រង់។ សេចក្តីសង្ឃឹមរបស់គេបានឡើងចុះៗ នៅពេលដែលទស្សនីយភាពផ្សេងៗគ្នាបានកើតឡើង។ ជួនកាលគេភ័យខ្លាចនិងសង្ស័យ ក្រែងគេត្រូវបានបោកបញ្ឆោត ប៉ុន្តែសំឡេងនៅលើភ្នំនៃសិរីរុងរឿង និងសិរីល្អដែលគេបានឃើញ ចំរើនកំឡាំងដល់គេ ថាទ្រង់ពិតជាព្រះរាជបុត្រានៃព្រះមែន។ ពួកគេបាននឹកឃើញនូវទិដ្ឋភាពដ៏គួរអោយរំភើប ដែលគេបានឃើញការអស្ចារ្យ ដែលព្រះយេស៊ូវធ្វើក្នុងការព្យាបាលអ្នកឈឺ បើកភ្នែកអ្នកខ្វាក់អោយមើលឃើញ បើកត្រចៀកអ្នកថ្លង់អោយស្តាប់បាន គំរាមនិងបណ្តេញអារក្ស ប្រោសអ្នកស្លាប់អោយរស់ឡើងវិញ ហើយរហូតដល់គំរាមដល់ខ្យល់ ហើយខ្យល់ក៏ស្តាប់ទ្រង់ថែមទៀត។ ពួកគេមិនអាចជឿថាទ្រង់នឹងសុគតឡើយ។ ពួកគេបានសង្ឃឹមថា ទ្រង់នឹងប្រើអំណាចរបស់ទ្រង់ ហើយដោយសារព្រះសូរសៀងដែលទ្រង់បានបង្គាប់ នឹងធ្វើអោយហ្វូងមនុស្សដែលស្រេកឈាមនោះ គេរត់គេចចេញពីទ្រង់ ដូចជាមានទាហានមួយកងដេញតាមគេ ដូច្នោះដែរ។ ពួកសាវកបានសង្ឃឹមថា ព្រះយេស៊ូវនឹងបញ្ចេញអំណាចរបស់ទ្រង់ នឹងបង្ហាញដល់មនុស្សទាំងឡាយថា ទ្រង់ពិតជាស្តេចនៃសាសន៍អ៊ីស្រាអែល។

យូដាសពោរពេញទៅដោយវិប្បដិសារីនិងការអៀនខ្មាស យ៉ាងជូរចត់ ចំពោះសកម្មភាពក្បត់ក្នុងការចាប់ព្រះយេស៊ូវរបស់ខ្លួន។ ហើយនៅពេលដែលគាត់បានឃើញនូវការធ្វើទុក្ខដែលទ្រង់បានទទួល គាត់បានទទួលបរាជ័យ។ គាត់បានស្រឡាញ់ព្រះ-យេស៊ូវ ប៉ុន្តែគាត់ស្រឡាញ់ប្រាក់ជាង។ គាត់មិនបានគិតថាព្រះយេស៊ូវនឹងរងទុក្ខ ហើយត្រូវទាហានចាប់យកទៅដូច្នេះឡើយ។ គាត់បានគិតថា ព្រះយេស៊ូវនឹងសំដែងការអស្ចារ្យហើយរំដោះអង្គទ្រង់ពីពួកគេ។ ប៉ុន្តែ នៅពេលដែលគាត់បានឃើញហ្វូងមនុស្សដែលពោរពេញដោយកំហឹងនៅឯបន្ទប់កាត់ក្តី កំពុងស្រេកឃ្លានលោហិតរបស់ទ្រង់ គាត់ដឹងខ្លួនថាគាត់មានទោស ហើយនៅពេលដែលមនុស្សជាច្រើនកំពុងចោទប្រកាន់



ព្រះយេស៊ូវយ៉ាងខ្លាំងក្លា យូដាសប្រញាប់ប្រញាល់កាត់ហ្វូងមនុស្សសារភាពថាគាត់មានបាបក្នុងការកំចាយឈាមដែលគ្មានកំហុស។ គាត់បានប្រគល់ប្រាក់អោយគេវិញ ហើយសុំអោយគេដោះលែងព្រះយេស៊ូវ ដោយអះអាងថាទ្រង់ពិតជាគ្មានទោសទេ។ ការមួ-ម៉ៅនិងការច្របូកច្របល់ បានធ្វើអោយពួកសង្គ្រាជស្ងៀមស្ងាត់តែមួយរយៈពេលខ្លីតែប៉ុណ្ណោះ។ គេមិនចង់អោយមនុស្សទាំងឡាយដឹងថា គេបានជួលសាវករបស់ព្រះយេស៊ូវម្នាក់អោយប្រគល់ទ្រង់មកក្នុងកណ្តាប់ដៃពួកគេឡើយ។ ការតាមប្រមាញ់ព្រះយេស៊ូវរបស់ពួកគេ ដូចជាចោរ ហើយគេបានយកទ្រង់ទៅដោយសម្ងាត់ ពួកគេចង់លាក់រឿងនេះ។ ប៉ុន្តែការសារភាពរបស់យូដាស ភាពស្គមស្គាំង និងកំហុសរបស់គាត់ដែលកើតឡើង បានបើកមុខពួកសង្គ្រាជនៅចំពោះមុខហ្វូងមនុស្ស ដោយបង្ហាញថាការចាប់ព្រះយេស៊ូវគឺជាសម្អប់របស់គេ។ នៅពេលដែលយូដាសបានអះអាងយ៉ាងខ្លាំងៗថាព្រះយេស៊ូវគ្មានទោសនោះ ពួកសង្គ្រាជបានឆ្លើយតបថា រឿងនេះគ្មានទាក់ទងនឹងយើងទេ ជារឿងរបស់អ្នកទេតើ។ ពួកគេមានព្រះយេស៊ូវនៅក្នុងអំណាចរបស់ពួកគេ ហើយពួកគេបានសំរេចចិត្តថា គេនឹងធ្វើគុតទ្រង់។ យូដាសពោរពេញដោយការទង្គឹះចិត្ត និងកំហុសឆ្គង ចំពោះឧក្រិដ្ឋកម្មរបស់ខ្លួន ហើយក៏បានចេញទៅចងកសម្លាប់ខ្លួនឯង។

ព្រះយេស៊ូវមានការអាណិតអាសូរដល់ពួកគេជាខ្លាំង ហើយចម្លើយរបស់ទ្រង់គ្មានអ្វីធ្វើអោយហ្វូងមនុស្សភ្ញាក់ផ្អើលឡើយ។ ចំពោះការប្រមាថ និងការចំអកទាំងឡាយ មិនមែនជាការចងចិញ្ចើម មិនមែនជាការធ្វើអោយមានបញ្ហាធ្លាក់លើព្រះភ័ក្ត្ររបស់ទ្រង់ឡើយ។ ទ្រង់មានសេចក្តីថ្លៃថ្នូរ និងស្ងប់ស្ងាត់។ ទ្រង់មានភាពគ្រប់លក្ខណ៍និងថ្លៃថ្នូរ។ ទស្សនិកជនទាំងឡាយ គេសំឡឹងមើលទ្រង់ដោយការងឿងឆ្ងល់។ ពួកគេបានប្រៀបធៀបទ្រង់ទ្រាយគ្រប់លក្ខណ៍របស់ទ្រង់ ភាពហ្មឹងម៉ាត់របស់ទ្រង់ និងការបង្ហាញភាពថ្លៃថ្នូរជាមួយនឹងអ្នកដែលបានអង្គុយជំនុំជំរះប្រឆាំងនឹងទ្រង់ ហើយនិយាយ

ទៅកាន់គ្នាទៅវិញទៅមកថា ទ្រង់មានសណ្ឋានដូចជាស្ដេចដែលគ្រងនគរប្រសើរជាងអ្នកដឹកនាំណាៗទាំងអស់។ ទ្រង់គ្មានសញ្ញាឧក្រិដ្ឋកម្មណាមួយទាល់តែសោះ។ ព្រះនេត្ររបស់ទ្រង់ស្លូតនិងមិនចុះចាញ់ ថ្ងាសរបស់ទ្រង់ធំទូលាយ។ ទឹកមុខទាំងឡាយបានបង្ហាញយ៉ាងច្បាស់ដោយគោលការណ៍ថ្លៃថ្នូរ និងឧត្ដុង្គឧត្ដម។ ភាពអត់ធ្មត់និងការអត់ទ្រាំរបស់ទ្រង់ខុសពីមនុស្សទាំងឡាយដែលមានការរន្ធត់ជាច្រើន។ សូម្បីតែស្ដេចហេរូឌនិងលោកពីឡាត់ ក៏មានការរន្ធត់ចំពោះភាពថ្លៃថ្នូររបស់ទ្រង់ដែរ។ ភាពជាព្រះរបស់ទ្រង់បានលេចឡើង។

ដំបូងឡើយលោកពីឡាត់ជឿថា ទ្រង់ពិតជាមិនមែនមនុស្សធម្មតាទេ ប៉ុន្តែគឺជាតួអង្គយ៉ាងប្រសើរឧត្ដម។ គាត់បានជឿថាទ្រង់ពិតជាគ្មានទោសសោះ។ ទេវតាដែលបានឃើញព្រឹត្តិការណ៍ទាំងអស់នោះ បានកត់សំគាល់នូវការកាត់ទោសរបស់លោកពីឡាត់ និងបានកត់សំគាល់សេចក្ដីអាណិតអាសូររបស់គាត់ចំពោះព្រះយេស៊ូវ ហើយបានជួយគាត់អោយផុតពីការជាប់ទាក់ទងទៅនឹងសកម្មភាពយកព្រះយេស៊ូវទៅឆ្កាងដ៏គួរអោយភ័យខ្លាច ហើយទេវតាមួយអង្គត្រូវបានបញ្ជូនមកឯប្រពន្ធលោកពីឡាត់ពន្យល់សប្តិនាងថា ទ្រង់គឺជាព្រះរាជបុត្រានៃព្រះដែលលោកពីឡាត់កំពុងកាត់ទោស ហើយថាទ្រង់ជាអ្នករងការឈឺចាប់ដោយគ្មានកំហុសទេ។ នាងបានអោយដំណឹងទៅលោកពីឡាត់ថា នាងបានទទួលការឈឺចាប់យ៉ាងខ្លាំងនៅក្នុងយល់សប្តិដោយសារព្រះយេស៊ូវ ហើយបានព្រមានដល់លោកពីឡាត់មិនអោយធ្វើអ្វីដល់ព្រះយេស៊ូវដែលជាមនុស្សបរិសុទ្ធនោះឡើយ។ អ្នកនាំសារនេះបានប្រជ្រៀតហ្វូងមនុស្សយ៉ាងណែនណាន់តាន់តាប់ ហើយបានជូនដំណឹងនោះទៅលោកពីឡាត់។ នៅពេលដែលគាត់បានអានដំណឹងនោះ គាត់ញ័ររន្ធត់ ហើយមានសម្បុរស្លេកស្លាំង។ រំពេចនោះ គាត់បានគិតថាគាត់មិនគួរធ្វើអ្វីទាក់ទងនឹងរឿងនោះទេ គាត់នឹងមិនអោយការទាមទារឈាមព្រះយេ-



ស៊ូវរបស់ពួកគេ មានឥទ្ធិពលមកលើគាត់ឡើយ ប៉ុន្តែគាត់ នឹងដោះលែងទ្រង់វិញ។

នៅពេលដែលលោកពីឡាត់បានឮថា ស្ដេចហេរូឌគង់នៅទីក្រុងយេរូសាឡិម គាត់សប្បាយចិត្តណាស់ ហើយបានសង្ឃឹមថានឹងដោះខ្លួនគាត់រួច ពីរឿងដ៏ចំរូងចំរាស់នេះ ហើយមិនមានទាក់ទងទៅនឹងការចោទប្រកាន់ព្រះយេស៊ូវ។ គាត់បានបញ្ជូនទ្រង់ជាមួយនឹងអ្នកដែលចោទប្រកាន់ទ្រង់ទៅឯស្ដេចហេរូឌ។ ហេរូឌគឺជាស្ដេចរីងរូស។ ការសម្លាប់លោកយ៉ូហាន ធ្វើអោយទ្រង់មានព្រះទ័យសៅហ្មងជាខ្លាំង ដោយទ្រង់មិនអាចដោះព្រះអង្គអោយរួចចេញបាន ហើយនៅពេលដែលព្រះអង្គបានឮអំពីព្រះយេស៊ូវ និងការងារដ៏អស្ចារ្យដែលទ្រង់បានធ្វើ ព្រះអង្គបានគិតថា លោកយ៉ូហានបានរស់ពីស្លាប់ឡើងវិញ។ ព្រះអង្គបានភ័យខ្លាចនិងញ័ររន្ធត់ ដ្បិតព្រះអង្គមានទោសនៅក្នុងមនសិការរបស់ទ្រង់។ លោកពីឡាត់បានបញ្ជូនព្រះយេស៊ូវមកក្នុងកណ្ដាប់ដៃស្ដេចហេរូឌ។ ព្រះអង្គបានពិចារណាសកម្មភាពនៃការទទួលស្គាល់អំណាចរបស់ទ្រង់ និងការជំនុំជំរះពីលោកពីឡាត់។ ពីមុនពួកគេជាសត្រូវ ប៉ុន្តែក្រោយមកគេបានចងជាមិត្ត។ ស្ដេចហេរូឌមានព្រះទ័យរីករាយណាស់ដែលបានជួបព្រះយេស៊ូវ ព្រោះព្រះអង្គរំពឹងថា ព្រះយេស៊ូវនឹងសំដែងការអស្ចារ្យដើម្បីបំពេញព្រះហឫទ័យទ្រង់។ ប៉ុន្តែ វាមិនមែនជាការងាររបស់ព្រះយេស៊ូវសំរាប់បំពេញចិត្តអ្នកដែលចង់ឃើញនោះឡើយ។ អំណាចនិងការអស្ចារ្យជាព្រះរបស់ព្រះអង្គ សំរាប់តែសំដែងដើម្បីសង្គ្រោះអ្នកដទៃតែប៉ុណ្ណោះ ប៉ុន្តែមិនមែនតាំងនាមរបស់ព្រះអង្គផ្ទាល់ឡើយ។

ព្រះយេស៊ូវមិនបានឆ្លើយអ្វីទាំងអស់ទៅនឹងសំនួរជាច្រើនដែលស្ដេចហេរូឌបានសួរទ្រង់ ហើយទ្រង់ក៏មិនបានធ្វើអ្វីតបទៅសត្រូវរបស់ទ្រង់ដែលបានចោទប្រកាន់ទ្រង់យ៉ាងក្លៀវក្លានោះដែរ។ ស្ដេចហេរូឌក្រោធជាខ្លាំង ព្រោះព្រះយេស៊ូវមិនបានខ្លាចអំណាចរបស់ព្រះអង្គ ហើយថែមទាំងបានចំអកមើលងាយនិងធ្វើទារុណកម្មដល់ព្រះរាជ

បុត្រានៃព្រះទៀតផង។ ស្ដេចហេរូឌមានការភ្ញាក់ផ្អើលចំពោះភាពថ្លៃថ្នូរ និងការសំដែងលក្ខណៈជាព្រះរបស់ព្រះយេស៊ូវ នៅពេលដែលគេធ្វើទារុណកម្មយ៉ាងអាម៉ាស់ និងចោទប្រកាន់ដល់ទ្រង់ ហើយគេក៏បញ្ជូនទ្រង់ទៅឯលោកពីឡាត់វិញ។

សាតាំងនិងទេវតារបស់វាបានល្បួងលោកពីឡាត់ ហើយបានព្យាយាមដឹកនាំគាត់អោយចូលទៅក្នុងការហិនហោចរបស់វា។ វាបានអោយយោបល់ទៅគាត់ថា ប្រសិនបើគាត់មិនចូលរួមក្នុងការចោទប្រកាន់ដល់ព្រះយេស៊ូវទេ អ្នកដទៃ អ្នកស្រេកឈាមព្រះយេស៊ូវ គេនឹងចោទប្រកាន់គាត់ ហើយប្រសិនបើគាត់មិនបញ្ជូនទ្រង់អោយទៅឆ្កាងទេ គាត់នឹងបាត់បង់អំណាច និងកិត្តិយសនៅលោកីយ៍របស់គាត់ ហើយនឹងត្រូវបានគេប្រកាសថា ជាអ្នកដោះលែងមនុស្សក្លែងខ្លួន ដូចដែលគេបានដាក់ឈ្មោះអោយ។ ដោយការភ័យខ្លាចបាត់បង់អំណាច និងតួនាទីរបស់ខ្លួន លោកពីឡាត់បានយល់ព្រមអោយគេធ្វើគុតព្រះយេស៊ូវ។ ហើយទោះបីជាគាត់បានដាក់ព្រះលោហិតរបស់ព្រះ-យេស៊ូវអោយអ្នកចោទប្រកាន់ទ្រង់ និងហ្វូងមនុស្សអោយទទួល ដោយស្រែកថា សូមអោយឈាមរបស់គេធ្លាក់លើយើង និងកូនចៅរបស់យើងចុះក៏ដោយ ក៏លោកពីឡាត់មិនរួចខ្លួនដែរ គាត់មានទោសចំពោះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ។ ព្រោះតែការចាប់អារម្មណ៍យ៉ាងអាត្មានិយមផ្ទាល់របស់គាត់ ហើយស្រឡាញ់កិត្តិយសពីមនុស្សអ្នកធំនៅផែនដី គាត់បានបញ្ជូនអ្នកគ្មានទោស អោយគេយកទៅសម្លាប់។ ប្រសិនបើលោកពីឡាត់បានធ្វើតាមជំនឿរបស់គាត់ គាត់នឹងគ្មានអ្វីទាក់ទងនឹងការចោទប្រកាន់ព្រះយេស៊ូវឡើយ។ ការកាត់ទោសនិងការចោទប្រកាន់ទៅលើព្រះយេស៊ូវបានធ្វើការនៅក្នុងគំនិតមនុស្សជាច្រើន ហើយការបណ្ដាលចិត្តនឹងមានឡើង បន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញ ហើយមានមនុស្សជាច្រើនត្រូវបានបំពេញទៅក្នុងពួកជំនុំដែលមានបទពិសោធន៍ និងសេចក្ដីជំនឿដែលមានចាប់ពីពេលនៃការកាត់ទោសព្រះយេស៊ូវ



មក។

កំហឹងរបស់សាតាំងកាន់តែខ្លាំងឡើង នៅពេលដែលវាឃើញថាការឃោរ-ឃៅដែលវាប្រើឱ្យពួកសម្ដេចសង្ឃធ្វើទៅលើព្រះយេស៊ូវ មិនបានធ្វើអោយទ្រង់រអ្ញបន្តិចសោះឡើយ។ ខ្ញុំបានឃើញថា ទោះបើជាព្រះយេស៊ូវ បានយកកំណើតជាមនុស្សក៏ដោយ ក៏អំណាចនិងការអត់ធ្មត់នៃព្រះ នៅជាប់ជាមួយទ្រង់ ហើយទ្រង់មិនដែលបែកចេញពីព្រះហឫទ័យនៃព្រះវរបិតារបស់ទ្រង់បន្តិចណាសោះឡើយ។

សូមអានម៉ាថាយ ២៦:៥៧-៧៥, ២៧:១-៣១ ម៉ាកុស ១៤:៥៣-៧២, ១៥:១-២០ លូកា ២២:៤៧-៧១, ២៣:១-២៥
យ៉ូហានជំពូក ១៨, ១៩: ១-១៦។

ជំពូកទី៩

## **ព្រះរាជបុត្រាត្រូវបានគេឆ្កាង**

ព្រះរាជបុត្រារបស់ព្រះត្រូវបានប្រគល់ទៅអោយហ្វូងមនុស្សយកទៅឆ្កាង។ ពួកគេបាននាំព្រះអង្គសង្គ្រោះជាទីស្រឡាញ់ចេញទៅ។ ទ្រង់ហេវហត់និងទន់ខ្សោយដោយការឈឺចាប់ដែលបណ្ដាលឡើងដោយការធ្វើទុក្ខទោសនិងការដែលទ្រង់បានទទួល ហើយគេបានអោយទ្រង់លីឈើឆ្កាងយ៉ាងធ្ងន់ដែលគេនឹងបោះដែកគោលទ្រង់ នៅពេលឆាប់ៗនោះ។ ប៉ុន្តែព្រះយេស៊ូវបានសន្លប់នៅក្រោមបន្ទុកធ្ងន់។ គេបានដាក់ឈើឆ្កាងលើទ្រង់បីដង ហើយទ្រង់បានសន្លប់បីដង។ ពេលនោះគេបានឃើញអ្នកដើរតាមទ្រង់ម្នាក់ជាមនុស្សដែលមិនបានបង្ហាញសេចក្ដីជំនឿដោយចំហចំពោះព្រះគ្រីស្ទទេ តែគាត់បានជឿទ្រង់។ គេបានអោយគាត់លីឈើឆ្កាង ហើយគាត់បានលីសំដៅទៅកន្លែងប្រហារ

ជីវិត។ ហ្វូងទេវតាបានសំដៅនៅលើកន្លែងនោះ។ សិស្សរបស់ព្រះអង្គមួយចំនួនបានធ្វើដំណើរទៅកាន់កាល់វ៉ារីទាំងក្រៀមក្រំ និងយំសោកយ៉ាងជូរចត់។ ពួកគេបាននឹកឃើញព្រះយេស៊ូវជិះសេះយ៉ាងមានជោគជ័យចូលទៅក្រុងយេរ៉ូសាឡិម ហើយពួកគេបានដង្ហែទ្រង់ដោយស្រែកឡើងថា ហូសាណាព្រះដ៏ខ្ពស់បំផុត ហើយបានក្រាលអាវគេនិងធាងចាកនៅតាមផ្លូវ។ ពួកគេបានគិតថាពេលនោះព្រះអង្គនឹងសោយរាជ្យជាស្តេចលើនគរអ៊ីស្រាអែល។ ទស្សនីយភាពផ្លាស់ប្តូរជាខ្លាំង។ ក្តីសង្ឃឹមរបស់គេបានរលាយសូន្យ។ គេបានដើរតាមព្រះយេស៊ូវ មិនមែនដោយអំណរទេ មិនមែនដោយចិត្តរីករាយលោតកញ្ឆេងនិងក្តីសង្ឃឹមទេ ប៉ុន្តែដោយចិត្តខ្ទេចខ្ទាំជាមួយនឹងការភ័យខ្លាច និងអស់សង្ឃឹម។ ពួកគេបានដើរយ៉ាងយឺត១និងក្រៀមក្រំតាមទ្រង់ដែលពោរពេញដោយភាពអាម៉ាស់ និងការបន្ទាបខ្លួន ហើយដែលនឹងត្រូវសុគតនៅពេលបន្តិចទៀតនេះ។ ម្តាយរបស់ព្រះយេស៊ូវបាននៅទីនោះដែរ។ ចិត្តរបស់នាងត្រូវបានចាក់ទំលុះដោយការឈឺចាប់ដែលគ្មានម្តាយណាមួយធ្លាប់បានជួបប្រទះឡើយ។ ចិត្តដ៏ខ្ទេចខ្ទាំរបស់នាងនៅតែមានសង្ឃឹមជាមួយនឹងពួកសាវ័កថា កូនរបស់នាងនឹងបញ្ចេញឫទ្ធិបារមីដើម្បីរំដោះខ្លួនចេញពីឃាតកររបស់ទ្រង់ជាមិនខាន។ នាងមិនអាចទ្រាំទ្រនឹងគំនិតថាព្រះយេស៊ូវនឹងសុខចិត្តរងទ្រាំនូវការជាប់ឆ្កាងបែបនេះឡើយ។ ប៉ុន្តែការរៀបចំបានរួចរាល់ជាស្រេច គេបានដាក់ព្រះយេស៊ូវផ្តេកលើឈើឆ្កាង គេបានយកញញួរនិងដែកគោលមក។ ចិត្តរបស់ពួកសាវ័កស្លុតរន្ធត់។ ម្តាយរបស់ព្រះយេស៊ូវតានតឹងយ៉ាងខ្លាំង សឹងតែមិនអាចទ្រាំបាន ហើយនៅពេលដែលគេសន្ធឹងព្រះយេស៊ូវនៅលើឈើឆ្កាង ហៀបនឹងដំដែកគោលព្រះហស្តទ្រង់ភ្ជាប់ទៅនឹងឈើឆ្កាង ពួកសាវ័កបាននាំម្តាយព្រះយេស៊ូវចេញដើម្បីកុំអោយគាត់សំឡឹងឃើញគេដំដែកគោលទំលុះឆ្អឹងនិងសាច់ដៃ និងជើងដ៏ទន់របស់ទ្រង់។ ព្រះយេស៊ូវមិនបានត្អូញត្អែរឡើយ តែទ្រង់គ្រហឹមដោយការឈឺចាប់។ ព្រះភ័ក្ត្ររបស់



ទ្រង់ឡើងស្លាំង ហើយតំណក់ឈាមធំ១ហូរកាត់ចញ្ចើមទ្រង់។ សាតាំងបានប្រមាថទៅលើការឈឺចាប់ដែលព្រះរាជបុត្រានៃព្រះបានឆ្លងកាត់ ទាំងព្រួយបារម្ភខ្លាចទ្រង់សុគត ហើយនគររបស់វាត្រូវបាត់បង់។

គេបានលើកឈើឆ្កាងបន្ទាប់ពីគេបានបោះដែកគោលព្រះយេស៊ូវភ្ជាប់រួចមក ហើយបញ្ចូលទៅក្នុងរណ្តៅដែលបានជីកទុក ដោយកម្លាំងយ៉ាងខ្លាំង ដោយទាញសាច់ព្រះយេស៊ូវបណ្តាលអោយមានការឈឺចាប់យ៉ាងខ្លាំង។ គេបានធ្វើអោយការសុគតរបស់ទ្រង់មានភាពអាម៉ាស់ជាទីបំផុត។ គេបានឆ្កាងចោរពីរនាក់នៅសងខាងព្រះយេស៊ូវម្នាក់ម្ខាង។ គេបានចាប់ចោរដោយបង្ខំ ហើយបន្ទាប់ពីវាបានរើបំរះយ៉ាងខ្លាំងមក គេបានទាញដៃរបស់វាមកបោះដែកគោលភ្ជាប់នឹងឈើឆ្កាង។ ប៉ុន្តែព្រះយេស៊ូវទ្រង់បានប្រគល់ដៃទៅអោយគេបោះដែកគោលយ៉ាងសុភាព។ ទ្រង់មិនចាំបាច់អោយអ្នកណាចាប់ទាញព្រះហស្តទ្រង់ដាក់លើឈើឆ្កាងឡើយ។ ព្រះយេស៊ូវបានអធិស្ឋានអោយសត្រូវរបស់ទ្រង់ "ព្រះវរបិតាអើយ សូមទ្រង់អត់ទោសអោយគេផង ដ្បិតគេមិនដឹងថាគេកំពុងធ្វើអ្វីទេ" នៅពេលដែលចោរទាំងពីរកំពុងជេរប្រទេចអ្នកធ្វើបាបវា។

ព្រះយេស៊ូវមិនគ្រាន់តែទ្រាំទ្រនូវការឈឺចាប់ខាងរាងកាយប៉ុណ្ណោះទេ តែអំពើបាបរបស់លោកីយ៍ទាំងមូលបានត្រូវផ្ទុកមកលើទ្រង់។

នៅពេលដែលព្រះយេស៊ូវត្រូវបានគេព្យួរនៅលើឈើឆ្កាង គេបានដើរមកជិតទ្រង់ដោយជេរប្រមាថទ្រង់ ដោយឱនក្បាលគេដូចជាគោរពស្តេចដោយនិយាយថាឯងដែលអាចបំផ្លាញព្រះវិហារ ហើយសង់ឡើងវិញក្នុងរវាងបីថ្ងៃអើយ ចូរសង្គ្រោះខ្លួនឯងចុះ។ បើឯងជាព្រះរាជបុត្រានៃព្រះមែន ចូរចុះពីលើឈើឆ្កាងមក។ សាតាំងបានប្រើពាក្យដូចគ្នានេះទៅលើព្រះគ្រីស្ទនៅទីរហោស្ថានថា បើឯងជាព្រះរាជបុត្រានៃព្រះមែន។ ពួកសម្តេចសង្ឃ អ្នកដឹកនាំនិងពួកអាចារ្យនិយាយដោយចំអកថាវាអាចសង្គ្រោះ

អ្នកដទៃ តែវាមិនអាចជួយខ្លួនឯងបានទេ។ ប្រសិនបើវាជាស្តេចនៃសាសន៍អ៊ីស្រាអែលពិតមែន ចូរអោយវាចុះពីលើឈើឆ្កាងឥឡូវនេះចុះ នោះយើងនឹងជឿវា។ ពពួកទេវតាដែលសំកាំងនៅពីលើទស្សនីយភាពនៃការឆ្កាងព្រះយេស៊ូវ បានតូចព្រះទ័យយ៉ាងខ្លាំងនៅពេលដែលអ្នកដឹកនាំបានចំអកមើលងាយទ្រង់ដោយនិយាយថា បើវាជាព្រះរាជបុត្រានៃព្រះមែន ចូរអោយវាជួយខ្លួនឯងទៅ។ ពួកលោកចង់ចុះទៅជួយរំដោះព្រះ-យេស៊ូវ តែពួកលោកមិនត្រូវបានអនុញ្ញាតអោយធ្វើដូច្នេះឡើយ។ នៅពេលដែលព្រះយេស៊ូវបានជាប់នៅលើឈើឆ្កាងដោយការឈឺចាប់ ទ្រង់មិនបានបំភ្លេចម្តាយរបស់ទ្រង់ឡើយ។ មេរៀនចុងក្រោយបង្អស់របស់ព្រះយេស៊ូវគឺការអាណិតអាសូរ និងការបន្ទាបខ្លួន។ ទ្រង់ទតមើលទៅម្តាយទ្រង់ដែលមានចិត្តពោរពេញដោយការទុក្ខព្រួយហើយដែលនៅលើដៃសាវកយ៉ូហានជាទីស្រឡាញ់របស់ទ្រង់។ ទ្រង់មានបន្ទូលទៅកាន់មាតាទ្រង់ថា មាតាអើយ នុ៎ះនឹកូនរបស់មាតា។ រួចទ្រង់មានបន្ទូលទៅយ៉ូហានថា នុ៎ះនឹម្តាយរបស់អ្នក តាំងពីពេលនោះមក លោកយ៉ូហានបាននាំគាត់ទៅផ្ទះរបស់ខ្លួន។

នៅក្នុងការឈឺចាប់ ព្រះយេស៊ូវស្រេកទឹកជាខ្លាំង ប៉ុន្តែគេបានគរលើទ្រង់នូវការប្រមាថ បន្ថែមដោយយកទឹកខ្មេះ និងសារាយរំហួតមកថ្វាយទ្រង់សោយ។ ពួកទេវតាបានទតមើលនូវការឈឺចាប់នៅលើឈើឆ្កាងរបស់មេបញ្ជាការដ៏ជាទីស្រឡាញ់របស់លោករហូតដល់លោកមិនអាចមើលតទៅទៀតបាន រួចក៏បែរព្រះភ័ក្ត្រលោកចេញពីទស្សនីយភាពនោះ។ ព្រះអាទិត្យមិនព្រមសំឡឹងមើលទស្សនីយភាពដ៏រន្ធត់នេះឡើយ។ ព្រះយេស៊ូវបានស្រែកឡើងដោយសំឡេងយ៉ាងខ្លាំងៗដែលបានវាយសំពងដល់ចិត្តរបស់ឃាតកទ្រង់ឱ្យភ័យញ័រដោយពាក្យថា "**ការស្រេចហើយ**"។ គ្រានោះវាំងននទៅក្នុងព្រះវិហារ ក៏រហែកជាពីរភាគចាប់តាំងពីលើចុះដល់ក្រោម ក៏មានកក្រើកដីហើយថ្មប្រេះដាច់ពីគ្នា។ មានងងឹតដាបគ្របមកលើផែនដី។ សេចក្តីសង្ឃឹមចុង



ក្រោយរបស់ពួកសាវកហាក់បីដូចជារសាត់បាត់អស់ នៅគ្រាដែលព្រះយេស៊ូវសុគត។ ពួកសិស្សរបស់ព្រះអង្គជាច្រើនបានឃើញឆាកឈឺចាប់និងការសុគតរបស់ទ្រង់ ហើយពែងនៃសេចក្តីទុក្ខព្រួយរបស់ទ្រង់បានពេញហៀរ។

គ្រានោះសាតាំងមិនបានប្រមាថដូចដែលវាធ្លាប់ធ្វើនោះទេ។ វាបានសង្ឃឹមថា វាអាចបំផ្លាញផែនការនៃការសង្គ្រោះ ប៉ុន្តែផែនការនោះបានចាក់គ្រឹះយ៉ាងជ្រៅ។ ហើយឥឡូវនេះ ដោយការសុគតរបស់ព្រះយេស៊ូវ វាដឹងថា វាពិតជាត្រូវស្លាប់ជាចុងក្រោយបំផុត ហើយនគររបស់វានឹងត្រូវបានដកហូត ហើយប្រគល់ទៅឱ្យព្រះយេស៊ូវវិញ។ វាបានប្រជុំពិភាក្សាជាមួយនឹងទេវតារបស់វា។ វាមិនមានជ័យជំនះអ្វីទៅលើព្រះរាជបុត្រានៃព្រះបន្តិចសោះឡើយ ហើយឥឡូវនេះវាត្រូវតែបន្ថែមកម្លាំង ជាមួយនឹងកលល្បិច និងអំណាចរបស់វាបង្វែរមកលើអ្នកដែលដើរតាមព្រះយេស៊ូវវិញ។ ពួកវាត្រូវតែការពារមនុស្សទាំងអស់ពីការទទួលសេចក្តីសង្គ្រោះដែលព្រះយេស៊ូវបានចេញថ្លៃលោះជំនួសពួកគេ។ ដោយធ្វើដូច្នេះ សាតាំងនៅតែអាចធ្វើការប្រឆាំងនឹងនគររបស់ព្រះបាន។ ហើយការនេះ វាក៏អាចរក្សាអ្នកដែលចាប់អារម្មណ៍លើវាបានយ៉ាងគង់វង្សល្អ។ ដ្បិតអំពើបាបរបស់អ្នកដែលព្រះបានចេញថ្លៃលោះដោយលោហិតរបស់ព្រះគ្រីស្ទ ហើយមានជ័យជំនះ នៅទីបញ្ចប់នឹងត្រឡប់ទៅលើមេនៃអំពើបាបគឺអារក្សវិញ ហើយវានឹងត្រូវទទួលនូវអំពើបាបនោះនៅពេលដែលអ្នកមិនបានទទួលសេចក្តីសង្គ្រោះ ដោយព្រះយេស៊ូវនឹងទទួលអំពើបាបរបស់គេ។

ព្រះជន្មរបស់ព្រះយេស៊ូវ មិនបានបង្ហាញភាពរុងរឿង និងពិសេសពិសាលនៃលោកីយ៍ឡើយ។ ព្រះជន្មដ៏លះបង់និងបន្ទាបព្រះកាយរបស់ព្រះអង្គ ផ្ទុយគ្នាស្រឡះអំពីជីវិតរបស់ពួកសង្គ្រាជនិងអ្នកដឹកនាំ ដែលស្រឡាញ់តែការងាយស្រួលនិងកិត្តិយសនៃលោកីយ៍ ហើយព្រះជន្មដ៏ត្រឹមត្រូវ និងបរិសុទ្ធរបស់ព្រះយេស៊ូវ គឺជាការស្តីបន្ទោស

ដល់ពួកគេជាបន្ត ចំពោះអំពើបាបរបស់ពួកគេ។ ពួកគេស្អប់ទ្រង់ដោយសារការបន្ទាបខ្លួន និងភាពបរិសុទ្ធរបស់ទ្រង់។ ប៉ុន្តែអ្នកដែលស្អប់ទ្រង់នៅទីនេះ ថ្ងៃណាមួយនឹងឃើញទ្រង់នៅក្នុងភាពដ៏រុងរឿងនៃស្ថានសួគ៌ និងសិរីល្អដ៏លើសលប់របស់ព្រះវរបិតា។ ទ្រង់ត្រូវបានព័ទ្ធជុំវិញដោយសត្រូវរបស់ទ្រង់នៅក្នុងបន្ទប់ជំនុំជំរះ ដែលជាអ្នកស្រេកឃ្លានលោហិតរបស់ទ្រង់ ប៉ុន្តែអ្នកមានចិត្តរឹងដែលបានស្រែកឡើងថា ចូរឱ្យឈាមរបស់វាធ្លាក់លើយើងនិងកូនចៅយើងចុះ នឹងឃើញទ្រង់ជាស្តេចដ៏មានកិត្តិយស។ ពួកទេវតានឹងហែហមទ្រង់ដោយចំរៀងនៃជ័យជំនះ ឧត្តមភាព និងព្រះចេស្តា។ អ្នកដែលត្រូវបានសម្លាប់ ត្រូវតែរស់ឡើងវិញ គឺជាអ្នកឈ្នះដ៏ឧត្តម។ អ្នកក្រ អ្នកខ្សោយ និងអ្នកពិការដែលបានស្តោះដាក់ព្រះភ័ក្ត្រទ្រង់ក្នុងសំរែកនៃសេចក្តីឃោរឃៅយ៉ាងមានជោគជ័យកាត់ហ្វូងទាហាន នាពេលជេរប្រមាថយ៉ាងថោកទាប។ គេបង្ខូចព្រះភ័ក្ត្រនោះដោយវាយដំ និងអំពើឃោរឃៅដែលធ្វើអោយស្ថានសួគ៌ពេញទៅដោយសេចក្តីកោតសរសើរ។ គេនឹងឃើញព្រះភ័ក្ត្រនោះម្តងទៀត ភ្លឺដូចព្រះអាទិត្យនៅពេលថ្ងៃត្រង់រួចគេប្រុងនឹងរត់គេចចេញពីព្រះភ័ក្ត្រនោះ។ ជំនួសអោយសំរែកនៃជ័យជំនះដ៏ឃោរ-ឃៅក្នុងការភ័យស្លន់ស្លោដែលគេទ្រហោយំដោយសារទ្រង់។ ព្រះយេស៊ូវនឹងបង្ហាញព្រះហស្តដែលមានស្នាមដែកគោល។ សញ្ញានៃអំពើឃោរឃៅដែលទ្រង់បានរងទ្រាំ។ ស្នាមដែកគោលប្រាប់អំពីរឿងរ៉ាវនៃការប្រោសលោះមនុស្សលោកដ៏អស្ចារ្យ និងតម្លៃពិសេសដែលបានចេញថ្លៃលោះនោះ។ ទាហានដែលបានចាក់លំពែងទំលុះចំហៀងព្រះអម្ចាស់នៃជីវិត នឹងឃើញស្នាមលំពែង ហើយនិងសោកស្តាយដោយទង្គិះចិត្តនឹងអំពើដែលខ្លួនបានប្រព្រឹត្តធ្វើអោយរាងកាយទ្រង់ឈឺចាប់។ ទាហានបានធ្វើអោយទ្រង់រឹតតែអាម៉ាស់ដោយយកពាក្យស្លោកថា ស្តេចនៃសាសន៍យូដា ទៅព្យួរនៅលើឈើឆ្កាងពីលើព្រះសិរទ្រង់។ ប៉ុន្តែនៅពេលនោះ ពួកគេនឹងតម្រូវអោយមើលទ្រង់ក្នុងសិរី



ល្អទាំងអស់របស់ទ្រង់ និងអំណាចដ៏ជាស្តេច។ ពួកគេនឹងឃើញមានព្រះនាមកត់ទុកនៅលើព្រះពស្ត្រនិងព្រះឱរារបស់ទ្រង់ថា ស្តេចលើអស់ទាំងស្តេច ព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់។ អ្នកដែលស្រែកចំអកដាក់ទ្រង់នៅពេលដែលទ្រង់ជាប់នៅលើឈើឆ្កាងថា ចូរអោយស្តេចលើសាសន៍អ៊ីស្រាអែលចុះពីលើឈើឆ្កាងមកចុះ ដើម្បីអោយយើងបានឃើញ និងជឿដល់ទ្រង់។ ពេលនោះ គេនឹងឃើញទ្រង់ដោយអំណាច និងកម្លាំង ជាស្តេចរបស់ទ្រង់។ ពេលនោះ គេនឹងមិនទាមទារអ្វីដើម្បីជាភស្តុតាងបញ្ជាក់ថាទ្រង់ជាស្តេចនៃសាសន៍អ៊ីស្រាអែលទៀតឡើយ ប៉ុន្តែនឹងរំភើបជាខ្លាំងដោយទស្សនីយភាពនៃព្រះចេស្តា និងសិរីល្អដ៏លើសលប់របស់ទ្រង់។ ពេលនោះ ពួកគេនឹងត្រូវបានបង្ខិតបង្ខំអោយទទួលស្គាល់ថា មានពរហើយអ្នកដែលបានយាងមកក្នុងព្រះនាមរបស់ព្រះអម្ចាស់។ ការរញ្ជួយផែនដី ថ្មរបេះពីគ្នា ភាពងងឹតគ្របដណ្តប់លើផែនដី និងសំរែកយ៉ាងខ្លាំងរបស់ព្រះយេស៊ូវថា "ការស្រេចហើយ" នឹងឮនៅពេលដែលទ្រង់ប្រគល់ព្រះជន្មទ្រង់ទៅឯព្រះវរបិតា បានធ្វើអោយសត្រូវរបស់ទ្រង់ភិតភ័យ និងធ្វើអោយពួកទាហានដែលធ្វើគតទ្រង់ញ័ររន្ធត់។ ពួកសាវករំពឹងថានឹងមានការអស្ចារ្យណាមួយកើតឡើង ប៉ុន្តែ សេចក្តីសង្ឃឹមរបស់គេត្រូវបានរលាយសាបសូន្យទាំងអស់។ ពួកគេភ័យខ្លាចក្រែងពួកយូដាតាមរកបំផ្លាញដល់គេផងដែរ។ គេបានគិតថាសម្អប់ទាស់នឹងព្រះរាជបុត្រានៃព្រះបែបនេះ នឹងមិនបញ្ចប់នៅត្រឹមនោះឡើយ។ នៅគ្រាឯកោ ពួកសាវកបានចំណាយពេលយំសោកយ៉ាងក្រៀមក្រំចំពោះការអស់សង្ឃឹមរបស់ពួកគេ។ ពួកគេរំពឹងថាទ្រង់នឹងសោយរាជ្យលើនគរនៃលោកីយ៍នេះ ប៉ុន្តែសេចក្តីសង្ឃឹមរបស់គេបានស្លាប់ទៅជាមួយនឹងព្រះយេស៊ូវទៅវិញ។ ពួកគេសង្ស័យនៅក្នុងចិត្តដ៏ក្រៀមក្រំ និងអស់សង្ឃឹមរបស់គេថា ក្រែងព្រះគ្រីស្ទបំភ័ន្តគេទេដឹង។ មាតារបស់ទ្រង់បានបន្ទាបខ្លួន ហើយសូម្បីតែសេចក្តីជំនឿថាព្រះយេស៊ូវជាព្រះមែស៊ីរបស់នាង ក៏

នាងនៅអល់ឯកដែរ ។

ប៉ុន្តែទោះបីជាពួកសាវកមានការខកចិត្តចំពោះសេចក្តីសង្ឃឹមរបស់ពួកគេទាក់ទងនឹងព្រះយេស៊ូវក៏ដោយ ក៏ពួកគេនៅតែស្រឡាញ់ទ្រង់ គោរព និងសរសើរដំកើងព្រះសពរបស់ទ្រង់ដែរ ។ តែគេមិនដឹងជាធ្វើយ៉ាងណា ។ លោកយ៉ូសែបជាអ្នកស្រុកអារីម៉ាថេ និងជាអ្នកដែលមានកេរ្តិ៍ឈ្មោះក្នុងពួកជំនុំដ៏មានឥទ្ធិពល និងសិស្សរបស់ព្រះយេស៊ូវជាសម្ងាត់ម្នាក់ ។ គាត់បានទៅជួបលោកពីឡាត់ដោយសម្ងាត់ និងអង់អាចក្លាហានដើម្បីសុំព្រះសពព្រះយេស៊ូវ ។ គាត់មិនបានទៅដោយចំហទេ ព្រោះកំហឹងរបស់ពួកយូដាពុះពោរខ្លាំងពេក ទើបពួកសាវកបារម្ភក្រែងគេប្រើកម្លាំងដើម្បីការពារព្រះសពព្រះយេស៊ូវ ទុកជាកន្លែងដ៏មានកិត្តិយសមួយ ។ ប៉ុន្តែ លោកពីឡាត់បានប្រគល់សាកសពតាមសំណូមពរ ហើយនៅពេលដែលគេដាក់ព្រះសពព្រះយេស៊ូវចុះពីឈើឆ្កាងការសោកសង្រេងរបស់គេក៏បានរំឭកឡើងវិញ ហើយគេបានយំសោកទៅលើសេចក្តីសង្ឃឹមដ៏និរាសព្រាត់ប្រាសរបស់គេ នៅក្នុងការទង្គិះចិត្តយ៉ាងជ្រាលជ្រៅ ។ គេបានរុំព្រះសពព្រះយេស៊ូវដោយសំពត់ទេសឯក ហើយលោកយ៉ូសែបបានបញ្ចុះព្រះសពទ្រង់នៅក្នុងផ្នូរថ្មីរបស់គាត់ ។ ពួកស្រីៗដែលជាសិស្សដ៏ទន់ទាបរបស់ទ្រង់កាលដែលទ្រង់មានព្រះជន្មរស់នៅឡើយ ក៏បាននៅជិតទ្រង់ដែរពេលដែលទ្រង់សុគត ហើយគេមិនចាកចេញពីទ្រង់ឡើយ រហូតទាល់តែពួកគេបានឃើញព្រះសពដ៏ពិសិដ្ឋរបស់ទ្រង់ត្រូវបានគេដាក់ក្នុងផ្នូរ ហើយបានប្រមៀលដុំថ្មដ៏ធ្ងន់មួយមកខ្ទប់នៅមាត់ផ្នូរ ក្រែងលោពួកសត្រូវរបស់ទ្រង់ស្វែងរកយកព្រះសពទ្រង់បាត់ ។ មានទេវតាបានយាមផ្នូរដោយយកចិត្តទុកដាក់ រង់ចាំបញ្ជា និងអនុវត្តន៍នូវតួនាទីរបស់លោក ដើម្បីដោះលែងស្តេចនៃសិរីរុងរឿងពីការសុគតរបស់ទ្រង់ ។

ពួកអ្នកដែលធ្វើគុតព្រះគ្រីស្ទបានភ័យខ្លាចក្រែងទ្រង់រស់ឡើងវិញ ហើយគេច



ចេញពីពួកគេ ។ គេបានសុំលោកពីឡាត់អោយចាត់ទាហានមកយាមផ្នូររហូតដល់ថ្ងៃទីបី ។ លោកពីឡាត់ក៏បានប្រគល់ទាហានដល់គេដើម្បីយាមផ្នូរ ថែមទាំងបោះត្រានៅលើថ្មផ្នូរផង ក្រែងសិស្សរបស់ទ្រង់នឹងលួចព្រះសពយកទៅ ហើយនិយាយថាទ្រង់មានព្រះជន្មរស់ឡើងវិញ ។

សូមអាន ម៉ាថាយ ២១:១-១១, ២៧:៣២-៦៦ ម៉ាកុស ១៥:២១-៤៧
លូកា ២៣:២៦-៥៦ យ៉ូហាន ១៩:១៧-៤២ វិវរណៈ ១៩: ១១-១៦ ។

ជំពូកទី១០

## ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ

ពួកសាវកបានសំរាកនៅថ្ងៃបរិសុទ្ធ ដោយមានការក្រៀមក្រំនឹងការសុគតនៃព្រះអម្ចាស់របស់ពួកគេ នៅពេលដែលព្រះយេស៊ូវជាស្តេចនៃសិរីល្អបានសំរាកនៅក្នុងផ្នូរ ។ រាត្រីកាលបានរំកិលផុតទៅយ៉ាងយឺត ហើយនៅពេលដែលងងឹតនៅឡើយទេវតាបានហោះរំលងផ្នូរ ទាំងដឹងថាពេលវេលាដែលត្រូវរំដោះព្រះរាជបុត្រាជាទីស្រឡាញ់នៃព្រះដែលជាមេបញ្ជាការជាទីស្រឡាញ់របស់លោកបានខិតមកជិតដល់ហើយ ។ ហើយនៅពេលដែលលោកបានរង់ចាំដោយព្រះហឫទ័យរំជើបរំជួលយ៉ាងខ្លាំងនូវពេលវេលាដ៏មានជោគជ័យ ទេវតាដ៏ខ្លាំង និងមានព្រះចេស្តាមួយអង្គ បានយាងចុះមកពីស្ថានសួគ៌ ។ ព្រះភ័ក្ត្ររបស់លោកដូចជាផ្លេកបន្ទោរ ហើយព្រះពស្ត្រាទ្រង់សដូចហិមៈ ។ ពន្លឺរបស់លោកបំបែកភាពងងឹតចេញពីដានព្រះបាទលោក បណ្តាលអោយទេវតារបស់អារក្សដែលបានទាមទារព្រះសពព្រះយេស៊ូវរត់បែកខ្ញែកគេចចេញពីសិរីរុងរឿងរបស់លោក ។

ទេវតាមួយអង្គដែលបានទតមើលទិដ្ឋភាពនៃការបន្ទាបព្រះកាយរបស់ព្រះ

គ្រីស្ទ និងបានយាមរក្សាផ្នូរដែលព្រះយេស៊ូវបានសំរាក បានរួមជាមួយនឹងទេវតាដែលយាងមកពីស្ថានសួគ៌ ហើយយាងចុះទៅកាន់ផ្នូរទាំងពីរអង្គ។ ផែនដីញ័រកក្រើកនៅពេលដែលលោកទាំងពីរចុះដល់ដី ហើយមានការរញ្ជួយផែនដីយ៉ាងខ្លាំង។ ទេវតាដ៏ខ្លាំងនិងមានព្រះចេស្ដាចាប់ថ្មដែលនៅមាត់ផ្នូរ ហើយប្រមៀលយ៉ាងរហ័ស ចេញពីមាត់ផ្នូរ ហើយគង់នៅពីលើ។

ការភ័យខ្លាចដ៏រន្ធត់បានធ្វើអោយអ្នកយាមភ័យតក្កមា។ ឥឡូវនេះតើអំណាចរបស់គេក្នុងការរក្សាព្រះសពព្រះយេស៊ូវនោះនៅឯណា? គេពុំបានគិតពីតួនាទីរបស់គេ ឬពីការដែលពួកសាវកមកលួចព្រះសពនោះឡើយ។ ពួកគេងឿងឆ្ងល់និងភ័យខ្លាចនៅពេលដែលពន្លឺដ៏ភ្លឺក្រៃលែងរបស់ទេវតាចាំងភ្លឺជាងពន្លឺព្រះអាទិត្យ នៅជុំវិញគេ។ ទាហាន រ៉ូមដែលយាមរក្សាផ្នូរបានឃើញទេវតាហើយបានដួលទៅលើដីដូចមនុស្សស្លាប់។ ទេវតាមួយអង្គបានប្រមៀលថ្មចេញដោយជោគជ័យ ទាំងបន្លឺសំឡេងប្រកបដោយព្រះចេស្ដាយ៉ាងច្បាស់ថា ឱព្រះរាជបុត្រានៃព្រះអើយ ព្រះវរបិតានៃទ្រង់ត្រាស់-ហៅព្រះអង្គហើយសូមយាងក្រោកឡើង។ ព្រះយេស៊ូវបានមានព្រះជន្មរស់ពីសុគតឡើងវិញ។ ទេវតាផ្សេងៗទៀតបានចូលទៅក្នុងផ្នូរ ហើយនៅពេលដែលព្រះយេស៊ូវបានយាង ក្រោកឡើងដោយជោគជ័យ ទ្រង់បានបត់សំពត់ស្នបដែលរុំព្រះសពទ្រង់ ព្រះយេស៊ូវ បានយាងចេញមកជាអ្នកឈ្នះដ៏មានជោគជ័យ។ ពួកទេវតាបានសំឡឹងមើលមិនដាក់ភ្នែក ទៅលើទិដ្ឋភាពដ៏គួរអោយស្ញើចសរសើរនោះ។ ហើយនៅពេលដែលព្រះយេស៊ូវ បានយាងចេញពីផ្នូរដោយព្រះចេស្ដា ទេវតាដ៏ចែងចាំងទាំងនោះក្រាបថ្វាយបង្គំទ្រង់ដល់ដី រួចអបអរសាទរគំនាប់ទ្រង់ដោយចំរៀងនៃជ័យជំនះ ដែលសេចក្ដីស្លាប់មិនអាចមាន ជ័យជំនះលើទ្រង់តទៅទៀតបាន។ ឥឡូវនេះសាតាំងពុំមានជោគជ័យឡើយ។ ទេវតារបស់វាបានគេចខ្លួនចេញពីពន្លឺដ៏ចាំងចែងរបស់ទេវតានៃ



ស្ថានសួគ៌។ គេបានត្អូញត្អែរ យ៉ាងជូរចត់ ទៅកាន់ស្ដេចរបស់គេថា អំណោររបស់គេត្រូវបានគេដណ្ដើមយកបាត់ទៅហើយ និងថាអ្នកដែលគេបានស្អប់បំផុតនោះបានរស់ពីស្លាប់ឡើងវិញហើយ។

សាតាំងនិងទេវតារបស់វាមានអំណរជាមួយជោគជ័យរបស់វា បានតែមួយភ្លែតប៉ុណ្ណោះ ដែលអំណាចរបស់វាទៅលើមនុស្សមានបាប បានធ្វើឱ្យព្រះអម្ចាស់នៃជីវិតនៅក្នុងផ្នូរ ប៉ុន្តែក្នុងរយៈពេលយ៉ាងខ្លីបំផុត ជោគជ័យនៃស្ថាននរកក៏បានមកដល់។

ដ្បិតនៅពេលដែលព្រះយេស៊ូវបានយាងចេញពីផ្នូរដោយជោគជ័យជាអ្នកឈ្នះដ៏មានព្រះចេស្ដា សាតាំងបានដឹងថា បន្ទាប់ពីពេលនោះមកវាត្រូវតែស្លាប់ ហើយនគររបស់វាក៏ត្រូវតែប្រគល់ទៅអោយអ្នកដែលត្រូវគ្រប់គ្រងវិញដែរ។ វាយំសោក និងខឹងយ៉ាងខ្លាំង ព្រោះទោះបីជាវាប្រើគ្រប់អំណាច និងកម្លាំងរបស់វាយ៉ាងណាក៏ដោយ ក៏វាមិនអាចយកឈ្នះលើព្រះយេស៊ូវបានឡើយ ប៉ុន្តែទ្រង់បានបើកផ្លូវនៃសេចក្ដីសង្គ្រោះសំរាប់មនុស្ស ហើយអស់អ្នកណាដែលដើរនៅលើផ្លូវនោះនឹងត្រូវបានសង្គ្រោះ។

សាតាំងហាក់ដូចជាមានកង្វល់ និងទុក្ខព្រួយមួយផ្នែក។ វាបានប្រជុំពិភាក្សាជាមួយទេវតារបស់វា ថាតើវាត្រូវធ្វើយ៉ាងណាតទៅទៀត ដើម្បីប្រឆាំងនឹងនគររបស់ព្រះ។ សាតាំងបាននិយាយថា អ្នកត្រូវតែបង្ខំពួកសម្ដេចសង្ឃនិងអ្នកដឹកនាំ។ យើងបានជោគជ័យក្នុងការបញ្ឆោត និងបិទភ្នែកពួកគេ និងធ្វើអោយគេមានចិត្តរឹងទាស់នឹងព្រះយេស៊ូវ។ យើងធ្វើឱ្យគេជឿថា ទ្រង់គឺជាព្រះក្លែងក្លាយ។ ដែលទាហានរ៉ូមនឹងនាំដំណឹងដ៏គួរអោយស្អប់ខ្ពើម ថាព្រះគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញ។ យើងបន្តដឹកនាំពួកសម្ដេចសង្ឃនិងអ្នកដឹកនាំអោយនៅតែស្អប់ព្រះយេស៊ូវតទៅទៀត និងអោយធ្វើគុតទ្រង់។ ឥឡូវនេះចូរបង្ហាញនូវពន្លឺដ៏ភ្លឺនៅចំពោះមុខគេថា ដោយពួកគេបានធ្វើគុតព្រះយេស៊ូវហើយ ប្រសិនបើមនុស្សគេបានដឹងថា ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ

មនុស្សទាំងឡាយនឹងគប់សម្លាប់ពួកគេនឹងដុំថ្ម ព្រោះគេបានសម្លាប់អ្នកគ្មានទោស។

ខ្ញុំបានឃើញទាហានរ៉ូមដែលយាមផ្នូរបានក្រោកឡើង ហើយបើកភ្នែកមើលថា តើគេអាចមើលជុំវិញខ្លួនបានឬទេ បន្ទាប់ពីទេវតាបានយាងត្រឡប់ទៅស្ថានសួគ៌វិញ ហើយមានតែពន្លឺនៃសិរីល្អនោះ។ គេមានការងឿងឆ្ងល់ជាខ្លាំងដោយដុំថ្មដែលបាំងមាត់ផ្នូរ ត្រូវបានប្រមៀលចេញហើយព្រះយេស៊ូវត្រូវបានលើកឡើង។ គេក៏បានជំរាបរឿងដ៏អស្ចារ្យដែលគេបានឃើញនោះដល់សម្តេចសង្ឃ និងពួកមេដឹកនាំ ហើយនៅពេលដែលពួកឃាតកទាំងនោះបានឮនូវរបាយការណ៍ដ៏គួរអោយរន្ធត់នោះ មុខគេឡើងស្លាំងគ្រប់ៗគ្នា។ គេបានឃើញនូវកំហុសទាំងឡាយដែលគេបានប្រព្រឹត្ត។ ពេលនោះ គេបានដឹងថាប្រសិនបើទាហានបានរាយការណ៍នោះជាការពិត នោះពួកគេនឹងត្រូវបាត់បង់។ ពួកគេស្រឡាំងកាំងមួយស្របក់ ហើយសំឡឹងមើលគ្នាទៅវិញទៅមកដោយស្ងៀមស្ងាត់ ដោយមិនដឹងថាត្រូវធ្វើយ៉ាងណានិងនិយាយពីអ្វីឡើយ។ ពួកគេបានមកដល់កន្លែងមួយដែលគេមិនអាចជឿបាន លុះត្រាតែរឿងនោះគឺជាការចោទប្រកាន់របស់ពួកគេ។ ពួកគេបានបែកគ្នារៀងៗខ្លួនដើម្បីពិភាក្សាថា តើត្រូវធ្វើយ៉ាងណា។ ពួកគេបានសំរេចចិត្តថា ប្រសិនបើដំណឹងដែលថាព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញ និងរបាយការណ៍ដ៏គួរឱ្យភ្ញាក់ផ្អើល ដែលធ្វើអោយទាហានដែលយាមល្បាតបានដួលសន្លប់ត្រូវបានឮខ្ចរខ្ចាវដល់មនុស្សម្នា ពួកគេពិតជានឹងត្រូវមនុស្សខឹងសំបារយ៉ាងខ្លាំង ហើយនិងសម្លាប់ពួកគេជាមិនខាន គេចង់ជួលទាហានអោយលាក់រឿងនោះជាសម្ងាត់ គេបានផ្តល់ប្រាក់អោយទាហានជាច្រើន ហើយបង្ខំអោយនិយាយថា ពួកសិស្សរបស់ទ្រង់បានមកលួចព្រះសពយកទៅនៅពេលយប់ដែលយើងដេកលក់។ ហើយនៅពេលដែលទាហានត្រូវគេសួរថា ហេតុអ្វីបានជាគេដេកលក់នៅពេលយាមនោះ ពួកសម្តេចសង្ឃនិងអ្នកដឹកនាំបាននិយាយថា គេនឹងអង្វរចៅហ្វាយខេត្តអោយជួយដល់ពួកគេ។ ដោយសារប្រាក់



ទាហានរ៉ូមដែលជាអ្នកយាម បានលក់កិត្តិយសរបស់ខ្លួន ហើយយល់ព្រមធ្វើតាមការណែនាំរបស់សម្តេចសង្ឃនិងពួកចាស់ទុំ។

នៅពេលព្រះយេស៊ូវត្រូវបានព្យួរនៅលើឈើឆ្កាង ទ្រង់បានស្រែកថា ការស្រេចហើយ ផ្នូររបើកចេញពីគ្នា ផែនដីរញ្ជួយ ហើយមានផ្នូរជាច្រើនបានបើកឡើង ដ្បិតនៅពេលដែលព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញពីការសុគត ហើយមានជ័យជំ-នះលើសេចក្តីស្លាប់ នៅពេលដែលព្រះអង្គបានយាងចេញពីផ្នូរ ជាអ្នកមានជោគជ័យនៅពេលដែលផែនដីឃ្លេងឃ្លោងនិងរញ្ជួយ ហើយសិរីល្អដ៏អស្ចារ្យនៃស្ថានសួគ៌ចោមរោមត្រង់កន្លែងដ៏ពិសិដ្ឋ ស្តាប់បង្គាប់តាមការត្រាស់បង្គាប់របស់ទ្រង់ អ្នកស្លាប់ដោយសុចរិតជាច្រើនបានរស់ឡើងជាទីបន្ទាល់ថាទ្រង់មានព្រះជន្មរស់ឡើងវិញមែន។ ពួកអ្នកបរិសុទ្ធជាទីស្រឡាញ់ដែលបានរស់ឡើងវិញនោះ បានចោមរោមសរសើរដំកើងទ្រង់។ ពួកគេជាអ្នកជ្រើសរើសមួយចំនួនតិច ដែលមានជីវិតតាំងពីសម័យបង្កបង្កើតផែនដី រហូតដល់សម័យព្រះគ្រីស្ទ។ ហើយនៅពេលដែលពួកសម្តេចសង្ឃ និងពួកផារិស៊ីបានខំប្រឹងប្រែងលាក់បាំងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ ព្រះអម្ចាស់បានជ្រើសរើសនាំមនុស្សមួយក្រុមចេញពីផ្នូរ ដើម្បីបញ្ជាក់ថា ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញពិតប្រាកដមែន និងដើម្បីប្រកាសពីសិរីល្អរបស់ទ្រង់។ អ្នកដែលបានរស់ឡើងវិញ មានរូបរាងនិងទ្រង់ទ្រាយខុសៗគ្នា។ ខ្ញុំត្រូវបានគេប្រាប់ថា អ្នកដែលរស់នៅលើផែនដីត្រូវបានផ្លាស់ប្តូរបាត់បង់កម្លាំងនិងភាពស្រស់របស់ខ្លួន។ សាតាំងមានអំណាចធ្វើអោយមានជំងឺនិងស្លាប់ ហើយនៅគ្រប់សម័យ បណ្តាសារបស់វាឃើញ កាន់តែច្បាស់ ហើយអំណាចរបស់សាតាំង ក៏បានឃើញកាន់តែច្បាស់ដែរ។ អ្នកដែលបានរស់ឡើងវិញខ្លះមានរូបរាងនិងទ្រង់ទ្រាយល្អជាងអ្នកខ្លះទៀត។ ខ្ញុំត្រូវបានគេប្រាប់ថា អ្នកដែលបានរស់នៅជំនាន់លោកណូអេនិងអ័ប្រាហាំ មានទ្រង់ទ្រាយដូចទេវតា សម្រស់ និងកម្លាំងដូច

ទេវតា។ ប៉ុន្តែគ្រប់ជំនាន់ កាន់តែខ្សោយទៅៗ មានជំងឺនិងមានអាយុកាន់តែខ្លី។ សាតាំងបានដឹងអំពីរបៀបបំផ្លាញមនុស្ស និងធ្វើអោយពូជមនុស្សទន់ខ្សោយ។

អ្នកបរិសុទ្ធដែលបានរស់បន្ទាប់ពីការមានព្រះជន្មរបស់ព្រះយេស៊ូវ បានលេចឡើងនៅចំពោះមនុស្សជាច្រើន ដោយប្រាប់ពួកគេថាការលះបង់របស់មនុស្សបានសំរេចហើយ ដ្បិតព្រះយេស៊ូវដែលពួកយូដាបានឆ្កាងបានមានព្រះជន្មរស់ពីសុគតឡើងវិញ ហើយលើសពីនេះទៅទៀត យើងត្រូវបានប្រោសអោយរស់ឡើងវិញជាមួយទ្រង់។ គេបានផ្តល់ទីសំគាល់ថា ដោយសារតែអំណាចដ៏មានព្រះចេស្តារបស់ទ្រង់ ពួកគេត្រូវបានហៅអោយក្រោកចេញពីផ្នូរ។ ទោះបីជារបាយការណ៏កុហកនោះ ត្រូវបានឮសុសសាយក៏ដោយ ក៏រឿងនោះមិនអាចត្រូវបានបិទបាំងដោយសាតាំង ទេវតារបស់វា ឬពួកសម្តេចសង្ឃបានឡើយ ដ្បិតពួកមនុស្សបរិសុទ្ធត្រូវបាននាំចេញពីផ្នូរ បានឮជាដំណឹងអស្ចារ្យដ៏មានអំណរ ឮសុសសាយ ហើយព្រះយេស៊ូវក៏បានបង្ហាញអង្គទ្រង់ដល់ពួកសាវកដែលកំពុងក្រៀមក្រំ និងមានចិត្តខ្ទេចខ្ទាំ ដោយបំបាត់ការភ័យខ្លាចរបស់គេ ហើយធ្វើអោយគេមានអំណររីករាយឡើង។

នៅពេលដែលដំណឹងនេះបានឮពីទីក្រុងមួយទៅទីក្រុងមួយ ពីស្រុកមួយទៅស្រុកមួយ ពួកយូដាមានការភិតភ័យចំពោះអាយុជីវិតរបស់គេ ហើយបានលាក់កំបាំងកំហឹងរបស់គេនឹងពួកសាវក។ សេចក្តីសង្ឃឹមតែមួយគត់របស់គេ គឺផ្សព្វផ្សាយដំណឹងមិនពិត។ តែអ្នកដែលយល់ថាការកុហកនោះជារឿងពិត ក៏ជឿវា។ លោកពីឡាត់បានតក់ស្លុត។ គាត់បានជឿលើទីបន្ទាល់ដ៏អស្ចារ្យថា ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ហើយសេចក្តីសុខសាន្តបាននៅជាមួយនឹងទ្រង់ជារៀងរហូត។ ដោយសារតែកិត្តិយសនៃលោកីយ៏ ដោយសារតែការភ័យខ្លាចបាត់បង់អំណាច និងជីវិតរបស់ខ្លួន គាត់បានបញ្ជូនព្រះយេស៊ូវទៅអោយគេធ្វើគុត។ ឥឡូវនេះគាត់បានដឹងយ៉ាងច្បាស់ថាគាត់មិនគ្រាន់តែ



មានទោសដោយឈាមរបស់មនុស្សគ្មានទោសនោះទេ ប៉ុន្តែមានទោសដោយព្រះលោហិតនៃព្រះរាជបុត្រានៃព្រះថែមទៀត។ វេទនាដល់ជីវិតលោកពីឡាត់ វេទនាដល់ទីបញ្ចប់របស់វា។ ការអស់សង្ឃឹមនិងការឈឺចាប់បានបំបែកសេចក្តីសង្ឃឹមនិងសេចក្តីរីករាយទាំងឡាយខ្ទេចខ្ទី។ គាត់មិនបានទទួលការកំសាន្តចិត្តឡើយ ហើយគាត់បានស្លាប់យ៉ាងវេទនាជាទីបំផុត។

ព្រះទ័យរបស់ស្តេចហេរូឌនៅតែរឹងរូសដដែល ហើយនៅពេលដែលទ្រង់បានឮថាព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញនោះ ព្រះអង្គមិនសូវជាខ្វល់ខ្វាយប៉ុន្មានទេ។ ទ្រង់បានសម្លាប់លោកយ៉ាកុប ហើយនៅពេលដែលទ្រង់ទតឃើញថា ការសម្លាប់នោះបានធ្វើអោយពួកយូដាពេញចិត្ត ព្រះអង្គក៏បានចាប់លោកពេត្រុស ដើម្បីសម្លាប់ទៀត។ ប៉ុន្តែព្រះមានផែនការអោយលោកពេត្រុសធ្វើ ហើយក៏បានចាត់ទេវតារបស់ទ្រង់អោយទៅរំដោះគាត់។ ស្តេចហេរូដឌបានទទួលការជំនុំជំរះ។ ព្រះបានវាយព្រះអង្គនៅកណ្តាលហ្វូងមនុស្ស នៅពេលដែលទ្រង់កំពុងលើកដំកើងខ្លួនឯងនៅកណ្តាលពួកគេ ហើយទ្រង់បានសុគតយ៉ាងវេទនាជាទីបំផុត។

នៅពេលភ្លឺស្រាងៗ កាលនៅងងឹតនៅឡើយ ពួកសិស្សស្រីៗបានទៅឯផ្នូរនាំយកគ្រឿងក្រអូបទៅថ្វាយព្រះសពព្រះយេស៊ូវ នៅពេលនោះគេបានឃើញដុំថ្មដ៏ធ្ងន់ត្រូវបានគេប្រមៀលចេញពីមាត់ផ្នូរ ហើយព្រះសពព្រះយេស៊ូវមិននៅទីនោះទេ។ ចិត្តរបស់គេបានលិចលង់ គេភ័យខ្លាចពួកសត្រូវ បានលួចព្រះសពយកទៅបាត់។ តែមើលន៎ទេវតាពីរអង្គ ដែលមានសំលៀកបំពាក់ស ឈរនៅជិតគេ ព្រះភ័ក្ត្ររបស់លោកភ្លឺចាំង។ ទេវតាបានយល់អំពីការងាររបស់ស្ត្រីទាំងនោះ ហើយក៏មានបន្ទូលប្រាប់ទៅស្ត្រីទាំងនោះភ្លាមថា ពួកនាងបានមករកព្រះយេស៊ូវ ប៉ុន្តែទ្រង់មិនគង់នៅទីនេះទេ ទ្រង់បានមានព្រះជន្មរស់ឡើងវិញហើយ សូមមកមើលកន្លែងដែលទ្រង់ផ្ទុំចុះ។ ទេវតាប្រាប់ពួកនាង

អោយទៅប្រាប់ដល់ពួកសាវកថា ព្រះអង្គនឹងយាងទៅស្រុកកាលីឡេមុនពួកគេ។ ប៉ុន្តែពួកសិស្សស្រីៗមានការភ័យខ្លាចនិងភ្ញាក់ផ្អើលជាខ្លាំង។ ពួកនាងក៏ប្រញាប់រត់ទៅឯពួកសាវកដែលកំពុងកើតទុក្ខមិនស្រាកស្រាន្ត ដោយព្រះអម្ចាស់របស់ពួកគេត្រូវបានគេឆ្កាង។ ពួកនាងក៏បានប្រាប់ដល់ពួកសាវកនូវអ្វីដែលនាងបានឃើញ និងបានឮជាប្រញាប់។ ពួកសាវកមិនបានជឿថាទ្រង់មានព្រះជន្មរស់ឡើងវិញឡើយ ហើយក៏ប្រញាប់រត់ទៅឯផ្នូរជាមួយពួកស្រីៗដែលបានប្រាប់គេ ហើយបានឃើញថា ព្រះយេស៊ូវពិតជាមិនបាននៅទីនោះមែន។ មានតែសំពត់ស្បបក្រណាត់ទេសឯករបស់ទ្រង់។ ប៉ុន្តែពួកគេមិនអាចជឿដំណឹងល្អថា ព្រះគ្រីស្ទមានព្រះជន្មរស់ពីសុគតឡើងវិញឡើយ។ ពួកគេបានត្រឡប់មកផ្ទះវិញ ដោយនឹកអស្ចារ្យនូវអ្វីៗដែលគេបានឃើញ និងការដែលពួកស្រីៗបានប្រាប់គេ។ តែនាងម៉ារីបានរារង់នៅជុំវិញផ្នូរ គិតអំពីការដែលនាងបានឃើញទាំងមានកង្វល់ដោយគិតថា នាងត្រូវបានគេបញ្ឆោតទេ។ នាងបាននឹកឃើញការដែលគេកាត់ទោសព្រះយេស៊ូវ។ ទុក្ខសោករបស់នាងក៏បានកើតឡើងសារជាថ្មី ហើយនាងបានយំសោកយ៉ាងឈឺចាប់ក្រៃលែង។ នាងបានចូលទៅមើលផ្នូរម្តងទៀត ហើយបានឃើញទេវតាពីរអង្គដែលមានសំលៀកបំពាក់ស។ ព្រះភ័ក្ត្ររបស់លោកភ្លឺចាំង។ មួយអង្គគង់នៅខាងព្រះសិរ មួយអង្គទៀតគង់នៅខាងព្រះបាទនៃកន្លែងដែលគេដាក់ព្រះសពរបស់ព្រះយេស៊ូវ។ ទេវតាបានមានបន្ទូលមកកាន់នាងនិងសួរនាងដោយស្រទន់ថា តើហេតុអ្វីបានជានាងយំ។ នាងឆ្លើយតបថា លោកនាយអើយ គេបានយកព្រះអម្ចាស់របស់ខ្ញុំ ទៅណាបាត់ហើយ ហើយខ្ញុំមិនដឹងថាគេទុកទ្រង់នៅទីណាទេ។

ហើយនៅពេលដែលនាងបែរមុខចេញពីផ្នូរ នាងបានឃើញព្រះយេស៊ូវ តែនាង មិនបានស្គាល់ទ្រង់ទេ។ ព្រះយេស៊ូវបានមានបន្ទូលទៅកាន់នាងម៉ារីដោយស្រទន់និងប្រាប់នាងពីបុព្វហេតុនៃការសោកសង្រេងរបស់នាង ហើយសួរនាងថា តើនាងកំពុង



រកអ្នកណា។ នាងគិតស្មានថាជាអ្នកថែសួន ក៏បានសុំអង្វរគេថា បើគេបានយកព្រះសពរបស់ព្រះអម្ចាស់របស់នាង តើគេបានទុកទ្រង់នៅឯណា ចូរប្រាប់នាងមកដើម្បីនាងបាននាំយកទៅ។ ព្រះយេស៊ូវបានមានបន្ទូលទៅកាន់នាងដោយព្រះសូរសៀងនៃស្ថានសួគ៌ថា ម៉ារីអើយ។ នាងបានស្គាល់ច្បាស់នូវសំឡេងដ៏ជាទីស្រឡាញ់របស់នាងហើយក៏ឆ្លើយតបភ្លាមទៅវិញថា លោកគ្រូអើយ ហើយដោយសេចក្តីអំណរនិងភាពរីករាយ នាងក៏បានទៅឱបទ្រង់ តែព្រះយេស៊ូវបានថយក្រោយ ហើយមានបន្ទូលថា កុំពាល់ខ្ញុំ ព្រោះខ្ញុំមិនទាន់ឡើងទៅឯព្រះវរបិតាខ្ញុំនៅឡើយ ចូរនាងទៅឯពួកបងប្អូនខ្ញុំ ប្រាប់ថាខ្ញុំឡើងទៅឯព្រះវរបិតាខ្ញុំ ជាព្រះវរបិតានៃអ្នករាល់គ្នា គឺជាព្រះនៃខ្ញុំ ហើយជាព្រះនៃអ្នករាល់គ្នាដែរ។ នាងបានរត់ទៅឯពួកសាវក ដោយអំណរជាមួយនឹងដំណឹងល្អ។ ព្រះយេស៊ូវបានយាងទៅកាន់ស្ថានសួគ៌យ៉ាងលឿនទៅឯព្រះវរបិតានៃទ្រង់ ដើម្បីទូលទ្រង់ថា ព្រះអង្គបានទទួលការលះបង់និងបានធ្វើការងារទាំងអស់បានល្អប្រពៃ ហើយនឹងដើម្បីទទួលអំណាចនៅស្ថានសួគ៌និងនៅផែនដីពីព្រះវរបិតាទ្រង់។

ពពួកទេវតាដូចពពកបានហែហមព្រះរាជបុត្រានៃព្រះ និងគោះទ្វាដ៏អស់កល្បអោយបើកឡើង អោយទទួលស្តេចនៃសិរីល្អយាងចូល។ ខ្ញុំបានឃើញថា នៅពេលដែលព្រះយេស៊ូវគង់ជាមួយពន្លឺទេវតានៃស្ថានសួគ៌ និងព្រះវត្តមាននៃព្រះវរបិតា ព្រមទាំងមានសិរីល្អនៃព្រះហែហមទ្រង់ ទ្រង់មិនបានភ្លេចពួកសាវកដ៏កំសត់នៅផែនដីនោះឡើយ ហើយទ្រង់បានទទួលអំណាចពីព្រះវរបិតា រួចទ្រង់ត្រូវយាងត្រឡប់មករកពួកគេវិញ ហើយនៅពេលដែលទ្រង់គង់នៅជាមួយពួកគេ ទ្រង់បានប្រទានអំណាចដល់គេ។ នៅថ្ងៃជាមួយគ្នានោះឯង ទ្រង់បានយាងត្រឡប់មកវិញ ហើយបង្ហាញអង្គទ្រង់អោយពួកសាវកឃើញ។ ពេលនោះ ទ្រង់បានអោយពួកគេពាល់ទ្រង់ ដ្បិតទ្រង់បានយាងទៅកាន់ព្រះវរបិតាហើយ ហើយបានទាំងទទួលអំណាចពីទ្រង់ផង។

ប៉ុន្តែពេលនោះ ថូម៉ាសមិនបាននៅទីនោះទេ។ គាត់មិនបានទទួលយកការរៀបរាប់ប្រាប់របស់ពួកសាវកឡើយ ហើយបានអះអាងដោយទុកចិត្តខ្លួនឯងថា គាត់មិនជឿឡើយ (យូហ៉ាន ២០:២៥)។ លុះត្រាតែគាត់ បានដាក់ដៃគាត់ចូលទៅក្នុងស្នាមដែកគោល និងទៅលើចំហៀងទ្រង់ដែលត្រូវគេចាក់នឹងលំពែងនោះ។ ធ្វើដូច្នេះគាត់បានបង្ហាញថា គាត់ខ្វះការទុកចិត្តទៅលើបងប្អូនគាត់ហើយ។ ហើយប្រសិនបើមនុស្សទាំងអស់ទាមទារនូវភស្តុតាងបែបនេះ នឹងមានមនុស្សយ៉ាងតិចនឹងទទួលព្រះយេស៊ូវ។ ប៉ុន្តែវាគឺជាព្រះហប្ញទ័យរបស់ព្រះដែលរបាយការណ៍របស់ពួកសាវកបានឮពីម្នាក់ទៅម្នាក់ ហើយមនុស្សជាច្រើនទទួលដំណឹងនោះពីមាត់របស់អ្នកដែលបានឮនិងបានឃើញផ្ទាល់។ ព្រះអម្ចាស់មិនសព្វព្រះហប្ញទ័យចំពោះអ្នកមិនជឿបែបនោះឡើយ។ ហើយនៅពេលដែលព្រះយេស៊ូវបានជួបជាមួយនឹងពួកសាវកម្តងទៀត ថូម៉ាសក៏បាននៅជាមួយនឹងពួកគេដែរ។ នៅពេលដែលគាត់បានឃើញព្រះយេស៊ូវភ្លាម គាត់ក៏ជឿ។ ប៉ុន្តែគាត់បានប្រ-កាសថា គាត់នឹងមិនជឿឡើយ បើគ្មានភស្តុតាងដែលគាត់បានប៉ះពាល់បន្ថែមលើការឃើញទេនោះ។ ហើយព្រះយេស៊ូវបានប្រទានភស្តុតាងដែលគាត់ចង់បាននោះទៅគាត់។ ថូម៉ាស់ឆ្លើយឡើងថា ឱ ព្រះអម្ចាស់នៃទូលបង្គំ ឱព្រះនៃទូលបង្គំអើយ។ ប៉ុន្តែព្រះយេ-ស៊ូវ បានបន្ទោសដល់ថូម៉ាស់ ចំពោះការដែលគាត់មិនបានជឿ។ ទ្រង់បានមានបន្ទូលទៅគាត់ថា ថូម៉ាស់អើយ អ្នកជឿដោយព្រោះបានឃើញខ្ញុំ តែមានពរហើយអស់អ្នកដែលជឿតែមិនឃើញសោះ។

ដូច្នេះខ្ញុំបានឃើញថា អ្នកដែលមិនបានដឹងពីសាររបស់ទេវតាទីមួយ ទេវតាទីពីរ ត្រូវតែទទួលសារទាំងនោះពីអ្នកដែលធ្លាប់បានដឹង ហើយធ្វើតាមសារនោះ។ ខ្ញុំបានឃើញថា នៅពេលដែលព្រះយេស៊ូវបានជាប់ឆ្កាង សារទាំងនោះក៏បានជាប់ឆ្កាងដែរ។ ហើយពួកសាវកបានប្រកាសថា នឹងគ្មានសេចក្តីសង្គ្រោះដោយឈ្មោះណានៅក្រោម



មេឃនេះដែលត្រូវបានប្រទានដល់មនុស្សឡើយ ហើយគួរអោយអ្នកបំរើរបស់ព្រះប្រ-កាសដោយសេចក្តីជំនឿនិងគ្មានការភ័យខ្លាចថា អ្នកដែលកាន់ហើយចូលរួមក្នុងសេចក្តីពិត បានភ្ជាប់ជាមួយនឹងសាររបស់ទេវតាទីបី ត្រូវតែកាន់តាមសារទីមួយ និងទីពីរ និងទីបី ដូចដែលព្រះបានប្រទានដល់ពួកគេ បើពុំនោះទេ គេនឹងគ្មានចំណែកនៅក្នុងការរស់ឡើងវិញរបស់ព្រះយេស៊ូវឡើយ។ ខ្ញុំត្រូវបានគេបង្ហាញថានៅពេលដែលពួកស្រីបរិ-សុទ្ធកំពុងបាននាំដំណឹងអំពីព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ពួកទាហានរ៉ូមក៏បានផ្សព្វផ្សាយរឿងកុហកដែលពួកសង្គ្រាជ និងអ្នកដឹកនាំបានដាក់នៅក្នុងមាត់របស់គេដែរថាពួកសាវកបានចូលមកនៅពេលយប់ នៅពេលគេកំពុងដេកលក់ ហើយបានលួចសពរបស់ព្រះយេស៊ូវទៅបាត់ សាតាំងបានដាក់ពាក្យកុហកទាំងនេះទៅក្នុងចិត្តនិងក្នុងមាត់ពួកសម្តេចសង្ឃ ហើយមនុស្សក្រោកឈរឡើងប្រុងនឹងទទួលពាក្យពេចន៍របស់វា។ ប៉ុន្តែព្រះបានបង្ហាញអំពីការរស់ឡើងវិញរបស់ទ្រង់យ៉ាងច្បាស់លាស់ និងបានដាក់ព្រឹត្តិការណ៍សំខាន់លើការបង្ហាញសេចក្តីសង្គ្រោះ អោយផុតពីការសង្ស័យ ហើយឱ្យពួកសម្តេចសង្ឃនិងអ្នកដឹកនាំដឹងពីរឿងនោះ។ ទីបន្ទាល់ទាំងឡាយបានងើបឡើងពីការស្លាប់ ដើម្បីបញ្ជាក់អំពីការមានព្រះជន្មរបស់ព្រះគ្រីស្ទ។

ព្រះយេស៊ូវបាននៅជាមួយពួកសាវកសែសិបថ្ងៃ បណ្តាលអោយពួកគេមានអំណរនិងភាពរីករាយក្នុងចិត្ត និងបានបើកបង្ហាញដល់ពួកគេអោយធ្វើទីបន្ទាល់អំពីអ្វីដែលគេបានឃើញនិងបានឮទាក់ទងនឹងការឈឺចាប់ ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ដែលទ្រង់បានលះបង់ដើម្បីអំពើបាប ដើម្បីអោយអ្នកដែលមកឯទ្រង់ និងបានជីវិត។ ទ្រង់បានប្រាប់គេដោយស្មោះត្រង់និងដោយស្រទន់ថា ពួកគេនឹងត្រូវទទួលការបៀតបៀន និងទុក្ខព្រួយ ប៉ុន្តែពួកគេនឹងបានស្រាកស្រាន្តដោយការទាំងនោះនិងនឹកចាំពីព្រះបន្ទូលដែលទ្រង់បានមានបន្ទូលទៅកាន់ពួកគេ។ ទ្រង់បានប្រាប់គេ

ថា ទ្រង់បានឈ្នះលើសេចក្តីល្បួងរបស់អារក្ស ហើយទ្រង់មានជ័យជំនះដោយសារការពិបាកនិងការឈឺចាប់ដែលសាតាំងមិនមានអំណាចលើទ្រង់ទៀតឡើយ ប៉ុន្តែនឹងនាំយកការល្បួង និងអំណាចរបស់វាទៅដាក់លើពួកជឿលើព្រះផ្ទាល់ និងអ្នកដែលជឿលើព្រះអម្ចាស់កាន់តែខ្លាំងឡើង។ ទ្រង់បានប្រាប់គេថា ពួកគេនឹងបានឈ្នះដូចជាទ្រង់ឈ្នះដែរ។ ព្រះយេស៊ូវបានប្រទានអំណាចរបស់ទ្រង់ដល់ពួកសាវ័កអោយធ្វើការអស្ចារ្យ ហើយទ្រង់បានប្រាប់ពួកគេថា ទោះបីមនុស្សកំណាចអាចមានអំណាចលើរាងកាយគេក៏ដោយ ក៏គង់តែទ្រង់នឹងបញ្ជូនទេវតារបស់ទ្រង់អោយមករំដោះគេនៅពេលណាមួយមិនខានដើម្បីមិនអោយមានអ្នកណាអាចយកជីវិតគេបានឡើយ លុះត្រាតែការងាររបស់គេបានសំរេច។ ហើយនៅពេលដែលទីបន្ទាល់របស់គេត្រូវបានបញ្ចប់ ជីវិតរបស់គេអាចតម្រូវអោយបោះត្រាទីបន្ទាល់ដែលគេបានធ្វើ។ ពួកសាវ័ករបស់ទ្រង់បានស្តាប់ការបង្រៀនរបស់ទ្រង់ដោយសប្បាយរីករាយ។ គេទទួលព្រះបន្ទូលរបស់ទ្រង់គ្រប់ម៉ាត់ដោយយកចិត្តទុកដាក់។ ពេលនោះគេបានដឹងយ៉ាងច្បាស់ថា ទ្រង់គឺជាព្រះអង្គសង្គ្រោះនៃលោកីយ៏។ ព្រះបន្ទូលគ្រប់ម៉ាត់បានចូលយ៉ាងជ្រៅទៅក្នុងចិត្តរបស់គេ ហើយពួកគេមានការសោកស្តាយជាខ្លាំងដោយគេត្រូវឃ្លាតឆ្ងាយពីគ្រូដ៏មានព្រះពរនៃស្ថានសួគ៌របស់គេ ដែលបន្តិចទៀត គេលែងបានឮព្រះបន្ទូលប្រកបដោយព្រះគុណចេញពីព្រះឱស្ឋទ្រង់មកកំសាន្តចិត្តគេទៀតហើយ។ ប៉ុន្តែម្តងទៀត ចិត្តរបស់គេបានកក់ក្តៅដោយសេចក្តីស្រឡាញ់ និងអំណរដ៏ក្រៃលែងនៅពេលដែលព្រះយេស៊ូវបានប្រាប់គេថា ទ្រង់បានយាងទៅរៀបចំកន្លែងសំរាប់ពួកគេ ហើយទ្រង់នឹងយាងមកវិញដើម្បីទទួលពួកគេ អោយគេអាចនៅកន្លែងដែលទ្រង់នៅនោះដែរ។ ទ្រង់បានប្រាប់គេថា ទ្រង់នឹងចាត់ព្រះដ៏ជាជំនួយមួយអង្គ ព្រះវិញ្ញាណបរិសុទ្ធ ដើម្បីណែនាំ ប្រទានពរ និងដឹកនាំពួកគេទៅឯសេចក្តីពិតហើយទ្រង់បានលើកពាហុរបស់ ទ្រង់ឡើងប្រទានពរដល់ពួកគេ។



១.សូមអាន វិវរណៈ ១៤:៦-៨ បានពន្យល់នៅក្នុងជំពូកទី ២៣ និង២៤ នៃសៀវភៅនេះ។

២.សូមអានវិវរណៈ ១៤:៩-១២។ បានពន្យល់នៅក្នុងជំពូកទី២៨នៃ សៀវភៅនេះ។

សូមអានម៉ាថាយ ២៧: ៥២-៥៣ ជំពូកទី២៨ ម៉ាកុស ១៦: ១-១៨ លូកា ២៤: ១-៥០ យ៉ូហានជំពូកទី ២០ កិច្ចការជំពូកទី១២។

ជំពូកទី១១

## ការយាងឡើងរបស់ព្រះគ្រីស្ទ

ស្ថានសួគ៌បានរង់ចាំឱកាស ដែលព្រះយេស៊ូវបានយាងឡើងទៅឯព្រះវរបិតាដោយជោគជ័យ។ ទេវតាទាំងឡាយបានយាងមកទទួលស្តេចនៃសិរីល្អ ហើយបានហែហមព្រះអង្គដោយជោគជ័យទៅកាន់ស្ថានសួគ៌។ បន្ទាប់ពីព្រះយេស៊ូវបានប្រទានពរដល់ពួកសាវ័ករួចមក ទ្រង់បានចាកចេញពីគេ ហើយត្រូវបានព្រះវរបិតាយកទៅកាន់ស្ថានសួគ៌។ ហើយនៅពេលដែលទ្រង់បាននាំមុខគេឡើងទៅ ពួកមនុស្សដែលបានរស់ពីស្លាប់ឡើងវិញ បានទៅតាមទ្រង់។ ទេវតានៃស្ថានសួគ៌ដ៏ច្រើនកុះករបាននៅទីនោះ នៅពេលដែលទេវតាជាច្រើនបានរង់ចាំការយាងមករបស់ទ្រង់។ នៅពេលដែលបានទៅដល់ទីក្រុងបរិសុទ្ធ មានទេវតាបានហែហមទ្រង់ ព្រះយេស៊ូវបានស្រែកថា ឱទ្វារទាំងឡាយអើយ ចូរងើបក្បាលឡើង ឱទ្វាដ៏អស់កល្បអើយ ចូរនៅចំហចុះ នោះមហាក្សត្រាដ៏មានសិរីល្អទ្រង់នឹងយាងចូលមក។ តើមហាក្សត្រដ៏មានសិរីល្អនោះជាអ្នកណា? ទេវតាដែលបានហែហមស្រែកថា គឺព្រះយេហូវ៉ាដ៏មានព្រះចេស្តា និងឥទ្ធិឫទ្ធិ ជាព្រះ-

យេហូវ៉ាដ៏មានឫទ្ធិក្នុងចំបាំង។ ឱទ្វារទាំងឡាយអើយ ចូរងើបក្បាលឡើង ឱទ្វារដ៏អស់កល្បជានិច្ចអើយ ចូរនៅចំហចុះ នោះមហាក្សត្រដ៏មានសិរីល្អ ទ្រង់នឹងយាងចូលមក។ ទេវតានៃស្ថានសួគ៌បានបន្លឺឡើងទៀតថា តើព្រះមហាក្សត្រាដ៏មានសិរីល្អនេះជាអ្នកណា? គឺព្រះយេហូវ៉ានៃពួកពលបរិវា ទ្រង់ជាមហាក្សត្រដ៏មានសិរីល្អ ហើយក្បួនដំណើរក៏បានចូលទៅក្នុងស្ថានសួគ៌។ ពេលនោះពពួកទេវតានៃស្ថានសួគ៌បានចោមរោមព្រះរាជបុត្រានៃព្រះ ជាមេបញ្ជាការដ៏មានព្រះចេស្តារបស់គេ ហើយបានឱនក្រាបដោយកោតសរសើរ ធ្វើអោយពន្លឺចេញពីមកុដរបស់លោក ចាំងទៅលើព្រះបាទទ្រង់។ ហើយបន្ទាប់មកបានដេញពិណរបស់លោក ហើយបទភ្លេងដ៏ពិរោះរណ្ដំ បានបំពេញស្ថានសួគ៌ទាំងមូលអមដោយចំរៀងសរសើរដំកើង កូនចៀមដែលត្រូវបានគេសម្លាប់ ហើយមានជីវិតឡើងវិញប្រកបដោយព្រះបារមី និងសិរីរុងរឿង។

បន្ទាប់មក ខ្ញុំត្រូវបានគេបង្ហាញអោយឃើញពួកសាវក នៅពេលដែលគេបានសំឡឹងមើលទៅលើមេឃ ដើម្បីមើលព្រះអម្ចាស់របស់គេឡើងទៅស្ថានសួគ៌ នៅក្នុងក្រសែភ្នែកចុងក្រោយបង្អស់។ ទេវតាពីរអង្គដែលមានសំលៀកបំពាក់ស បានឈរនៅក្បែរគេ ហើយបានមានបន្ទូលទៅកាន់ពួកគេថា ពួកអ្នកស្រុកកាលីឡេអើយ ហេតុអ្វីបានជាឈរមើលទៅលើមេឃដូច្នេះ? ព្រះយេស៊ូវនេះឯង ដែលព្រះបានលើកពីអ្នករាល់គ្នាឡើងទៅស្ថានសួគ៌ ទ្រង់នឹងយាងមកវិញតាមបែបដដែល ដូចជាអ្នករាល់គ្នាបានឃើញទ្រង់ទៅនោះដែរ។ ពួកសាវកនិងមាតារបស់ព្រះយេស៊ូវបានធ្វើទីបន្ទាល់ពីការយាងឡើងទៅកាន់ស្ថានសួគ៌របស់ព្រះរាជបុត្រានៃព្រះ ហើយគេបានចំណាយពេលពេញមួយយប់និយាយគ្នាអំពីសកម្មភាពដ៏អស្ចារ្យរបស់ទ្រង់ និងរឿងដ៏មានសិរីរុងរឿងដែលបានកើតឡើងនៅក្នុងពេលដ៏ខ្លី។

សាតាំងបានពិភាក្សាជាមួយទេវតារបស់វា និងប្រើសម្អប់យ៉ាងជូរចត់ទាស់



នឹងនគររបស់ព្រះ វាបានប្រាប់ទេវតារបស់វាថា នៅពេលដែលទ្រង់បានប្រគល់អំណាចនិងកម្លាំងរបស់ទ្រង់មកផែនដី វាត្រូវតែបន្ថែមការខំប្រឹងប្រែងរបស់វាអោយកាន់តែខ្លាំងទាស់នឹងអ្នកដើរតាមព្រះយេស៊ូវ។ វាមិនអាចយកឈ្នះលើព្រះយេស៊ូវបានឡើយ តែវាត្រូវតែផ្តួលរំលំសាវករបស់ព្រះយេស៊ូវ ប្រសិនបើអាចធ្វើបាន ហើយបន្តការងាររបស់វាដល់មនុស្សគ្រប់ជំនាន់ ដើម្បីទាក់ទាញអ្នកដែលនឹងជឿទៅលើព្រះយេស៊ូវ ការមានព្រះជន្មរស់ឡើងវិញ និងការយាងឡើងទៅកាន់ស្ថានសួគ៌របស់ទ្រង់។ សាតាំងបានប្រាប់ដល់ទេវតារបស់វាថា ព្រះយេស៊ូវបានប្រទានអំណាចដល់ពួកសាវក ឱ្យបណ្តេញពួកវា គំរាមពួកវា និងព្យាបាលដល់អ្នកដែលពួកវាបានបៀតបៀន។ រួចទេវតារបស់សាតាំងបានចេញទៅដូចជាសិង្ហគ្រហឹមដើម្បីស្វែងរកបំផ្លាញសិស្សរបស់ព្រះយេស៊ូវ។

សូមអាន ទំនុកដំកើង ២៤:៧-១០ កិច្ចការ ១:១-១១។

## ជំពូកទី១២
## **សាវករបស់ព្រះគ្រីស្ទ**

ពួកសាវកបានផ្សព្វផ្សាយអំពីព្រះអង្គសង្គ្រោះដែលត្រូវបានគេឆ្កាង និងមានព្រះជន្មរស់ឡើងវិញដោយសារព្រះចេស្តា។ ពួកគេបានព្យាបាលអ្នកឈឺ សូម្បីតែអ្នកខ្វិនពីកំណើតក៏ត្រូវបានព្យាបាលអោយជាស្អាតឡើងវិញដែរ ហើយដើរចូលទៅក្នុងព្រះវិហារជាមួយពួកគេ ទាំងលោតកញ្ឆេងនិងសរសើរដំកើង ដល់ព្រះនៅចំពោះមនុស្សទាំងឡាយ។ ដំណឹងនេះបានឮសុសសាយ ហើយមនុស្សម្នាចាប់ផ្តើមចូលរួមជាមួយពួកសាវក។ មនុស្សជាច្រើនបានរួបរួមគ្នាទាំងមានការអស្ចារ្យនិងរន្ធត់ជាខ្លាំងចំពោះការព្យាបាលដែលបានកើតឡើង។

នៅពេលដែលព្រះយេស៊ូវបានសុគត ពួកសង្គ្រាជបានគិតថា នឹងគ្មានការអស្ចារ្យណាមួយកើតឡើងនៅចំពោះគេឡើយ ដែលធ្វើអោយការរំជើបរំជួលស្ងប់រំងាប់ ហើយមនុស្សទាំងឡាយគេនឹងបែរមករកប្រពៃណីរបស់មនុស្សវិញ។ ប៉ុន្តែ នៅចំកណ្តាលពួកគេ ពួកសាវកបានធ្វើការអស្ចារ្យ ហើយមនុស្សម្នាពោរពេញទៅដោយការភ្ញាក់ផ្អើលនិងការអស្ចារ្យចំពោះគេ។ព្រះយេស៊ូវបានត្រូវគេឆ្កាងទៅហើយ ហើយពួកគេបានឆ្ងល់ថា តើពួកសាវកគេបានអំណាចពីណាមក។ នៅពេលដែលទ្រង់នៅមានព្រះជន្មនៅឡើយ គេបានគិតថាទ្រង់បានចែកអំណាចអោយពួកសាវក ហើយនៅពេលដែលព្រះយេស៊ូវបានសុគត ពួកគេបានរំពឹងថា ការអស្ចារ្យទាំងនោះនឹងត្រូវចប់។ លោកពេ-ត្រុសបានយល់អំពីការស្ទាក់ស្ទើររបស់ពួកគេ ហើយបាននិយាយថាឱសាសន៍អ៊ីស្រាអែលរាល់គ្នាអើយ ហេតុអ្វីបានជាមានសេចក្តីប្លែកក្នុងចិត្តពីការនេះ ហើយសំឡឹងមើលមកយើងខ្ញុំហាក់ដូចជាយើងខ្ញុំបានធ្វើអោយមនុស្សនេះដើររួចដោយអាងអំណាចឬគុណភាពរបស់ខ្លួនខ្ញុំដូច្នេះ? ព្រះនៃលោកអ័ប្រាហាំ លោកអ៊ីសាក និងលោកយ៉ាកុបជាព្រះនៃពួកព្ធយុកោនៃយើងរាល់គ្នា ទ្រង់បានដំកើងអ្នកបំរើទ្រង់ នោះគឺព្រះយេស៊ូវដែលអ្នករាល់គ្នាបានបញ្ជូនទៅ ហើយក្នុងកាលដែលលោកពីឡាត់សំរេចសេចក្តីថានឹងលែងទ្រង់នោះអ្នករាល់គ្នាបានប្រកែកបដិសេធនៅមុខលោកមិនព្រមទទួលទ្រង់ទេ គឺថាមិនព្រមទទួលព្រះដ៏បរិសុទ្ធហើយសុចរិតនោះឯង បែរជាសូមអោយលោកលែងមនុស្សដែលសម្លាប់គេដល់អ្នករាល់គ្នាវិញ។ អ្នករាល់គ្នាបានសម្លាប់ព្រះអម្ចាស់នៃជីវិតនោះទៅ តែព្រះបានប្រោសអោយទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញ យើងខ្ញុំនេះជាទីបន្ទាល់ពីការនេះឯង។ លោកពេត្រុសបានប្រាប់គេថា ដោយសារសេចក្តីជំនឿលើព្រះយេស៊ូវដែលធ្វើអោយមនុស្សពិការនេះបានជាស្រឡះនៅមុខអ្នករាល់គ្នាដូច្នេះ។

ពួកសម្តេចសង្ឃនិងពួកនាហ្មឺនមិនទទួលពាក្យទាំងនោះឡើយ។ គេបានចាប់



ពួកសាវក ហើយយកពួកគេទៅដាក់គុក។ ប៉ុន្តែមនុស្សរាប់ពាន់នាក់បានផ្លាស់ប្តូរជំនឿ និងបានជឿលើការមានព្រះជន្មរស់ឡើងវិញ និងការយាងទៅកាន់ស្ថានសួគ៌របស់ព្រះគ្រីស្ទដោយបានឮសេចក្តីបរិយាយតែមួយរបស់ពួកសាវកតែប៉ុណ្ណោះ។ ពួកសង្គ្រាជនិងពួកនាហ្មឺនមានអំពល់ជាខ្លាំង។ គេបានធ្វើគុតព្រះយេស៊ូវដើម្បីអោយមនុស្សទាំងឡាយបែរគំនិតមករកពួកគេ ប៉ុន្តែឥឡូវនេះបញ្ហាវាធ្ងន់ធ្ងរជាងពីមុនទៅទៀត។ ពួកសាវកបានចោទប្រកាន់គេដោយចំហថា ជាឃាតកដែលធ្វើគុតព្រះរាជបុត្រានៃព្រះ ហើយគេមិនអាចទប់ស្កាត់មិនអោយរឿងនេះឮសុសសាយបានទេ ហើយគេក៏មិនដឹងជាមនុស្សទាំងឡាយនឹងចាត់ទុកគេជាយ៉ាងណានោះឡើយ។ ពួកគេអាចសម្លាប់ពួកសាវកចោល ប៉ុន្តែមិនហ៊ានព្រោះខ្លាចពួកមនុស្សគប់គេនឹងថ្មសម្លាប់។ គេក៏បានហៅពួកសាវកមកឯពួកចៅក្រម។ អ្នកដែលទាមទារលោហិតរបស់ព្រះយេស៊ូវដោយអន្ទះសារនោះ ក៏នៅទីនោះដែរ។ គេបានឮពេត្រុសប្រកែកដោយភ័យខ្លាចមិនស្គាល់ព្រះយេស៊ូវ ទាំងស្បថផងនៅពេលដែលគេចោទគាត់ថាជាសាវកម្នាក់របស់ព្រះយេស៊ូវ។ គេបានគិតថា នឹងបំភ័យពេត្រុស ប៉ុន្តែឥឡូវនេះ គាត់បានកែប្រែចិត្តទៅហើយ។ ឱកាសដែលត្រូវប្រមាថដល់ព្រះ បានកន្លងបាត់ពីពេត្រុសហើយ។ គាត់បានបដិសេធទ្រង់ម្តង ប៉ុន្តែឥឡូវនេះ គាត់អាចដកយកសេចក្តីសៅហ្មងនៃការបដិសេធនីយ៉ាងកំសាក និងយ៉ាងប្រញាប់ប្រញាល់ចេញ ហើយសរសើរដំកើងព្រះនាមដែលគាត់បានបដិសេធនោះវិញ។ ពេលនោះ គ្មានការភ័យខ្លាចយ៉ាងតក់ក្រហល់គ្រប់គ្រងលើដង្ហើមរបស់ពេត្រុសទៀតឡើយ ប៉ុន្តែគាត់បានប្រកែកដោយអង់អាចក្លាហាន គ្មានភ័យខ្លាចនិងដោយអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធប្រាប់ពួកគេថា ដោយសារព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទពីស្រុកណាសារ៉ែតដែលអ្នករាល់គ្នាបានឆ្កាងដែលព្រះវរបិតាបានលើកទ្រង់ពីសុគតឡើងវិញ ហើយដោយសារទ្រង់ មនុស្សនេះឈរនៅចំពោះមុខអ្នករាល់គ្នា។ នេះគឺជាថ្មដែលពួកជាងបានបោះ

ចោល បានក្លាយជាថ្មជ្រុងយ៉ាងឯកវិញ។ ក៏គ្មានសេចក្ដីសង្គ្រោះដោយឈ្មោះណាឡើយ ដ្បិត នឹងគ្មានឈ្មោះណានៅក្រោមមេឃនេះដែលត្រូវបានប្រទានមកមនុស្សអោយបានសង្គ្រោះឡើយ។

ពួកមនុស្សគេមានការស្ញប់ស្ញែងចំពោះសេចក្ដីក្លាហានរបស់ពេត្រុសនិងយ៉ូហាន។ គេបានដឹងថា ពួកគេនៅជាមួយព្រះយេស៊ូវ បានជាភាពថ្លៃថ្នូរនិងអង់អាចរបស់គេរឹងមាំដូចជាព្រះយេស៊ូវនៅពេលដែលទ្រង់ត្រូវឃាតករបស់ទ្រង់គំរាមកំហែង។ ព្រះយេស៊ូវបានទតមើលទៅលោកពេត្រុសទាំងអាណិតអាសូរនិងក្រៀមក្រំដោយបន្ទោសគាត់ពីការដែលគាត់បានបដិសេធទ្រង់ ប៉ុន្តែឥឡូវនេះ គាត់បានទទួលស្គាល់ព្រះអម្ចាស់របស់គាត់យ៉ាងអង់អាច ព្រះបានទទួលយកលោកពេត្រុស ហើយបានប្រទានពរដល់គាត់។ ជាសញ្ញានៃការរង់ចាំព្រះយេស៊ូវ ព្រះវិញ្ញាណបរិសុទ្ធបានបំពេញគាត់។

ពួកសម្ដេចសង្ឃមិនហ៊ានបង្ហាញកំហឹងរបស់គេដែលមានទៅលើពួកសាវកឡើយ។ ពួកគេក៏បានបញ្ជាអោយពួកសាវកចេញពីមុខពួកចៅក្រម គេបានសន្ទនាគ្នាថា តើយើងត្រូវធ្វើអ្វីជាមួយនឹងមនុស្សនេះ? ព្រោះថាការអស្ចារ្យដ៏គួរអោយកត់សំគាល់ដែលពួកគេបានធ្វើត្រូវបានបង្ហាញដល់មនុស្សនៅទីក្រុងយេរូសាឡិមគ្រប់គ្នាទៅហើយ។ ហើយយើងមិនអាចបដិសេធបានឡើយ។ ពួកគេមិនចង់អោយការងារដ៏ល្អនេះបានរីករាលដាលទេ។ ប្រសិនបើរឿងនេះបានឮសុសសាយ អំណាចរបស់គេនឹងត្រូវបាត់បង់ ហើយមនុស្សទាំងឡាយនឹងមើលមកពួកគេថា ជាឃាតកធ្វើគុតព្រះយេស៊ូវ។ គេហ៊ានត្រឹមតែគំរាមកំហែងដល់ពួកសាវក និងបង្គាប់កុំអោយនិយាយពីព្រះនាមរបស់ព្រះយេស៊ូវទៀតតែប៉ុណ្ណោះ បើពុំនោះទេ ពួកគេនឹងត្រូវស្លាប់ជាមិនខាន។ ប៉ុន្តែពេត្រុសបានប្រកាសដោយអង់អាចក្លាហានថា ពួកខ្ញុំនឹងលែងនិយាយពីការដែលគាត់បានឃើញហើយឮពុំបានឡើយ។



ដោយសារអំណាចរបស់ព្រះយេស៊ូវ ពួកសាវកបានបន្តព្យាបាលអ្នកជំងឺនិងអ្នកមានទុក្ខដែលគេបាននាំទៅឯពួកគាត់។ សម្ដេចសង្ឃនិងមេពួកអ្នកដឹកនាំព្រមទាំងដៃជើងរបស់គេបានភ្ញាក់ផ្អើលជាខ្លាំង។ មនុស្សរាប់រយនាក់បានបញ្ចូលទៅក្រោមផ្ទាំងបដានៃសេចក្ដីសង្គ្រោះរបស់ព្រះដែលគេបានឆ្កាងដែលមានព្រះជន្មរស់ឡើងវិញនិងដែលបានយាងឡើងទៅកាន់ស្ថានសួគ៌ជារៀងរាល់ថ្ងៃ។ពួកគេបានចាប់ពួកសាវកដាក់គុកដោយសង្ឃឹមថាការរំជើបរំជួលនឹងត្រូវស្ងប់។ សាតាំងមានជោគជ័យ ហើយទេវតារបស់វាបានប្រមាថពួកសាវក ប៉ុន្តែព្រះបានចាត់ពួកទេវតារបស់ទ្រង់ឱ្យទៅបើកទ្វារគុកហើយបណ្ដាលអោយពួកគេទៅឯព្រះវិហារ និងនិយាយអំពីពាក្យពេចន៍នៃជីវិតរបស់គេផ្ទុយពីការបញ្ជារបស់ពួកសង្គ្រាជនិងពួកនាហ្មឺន។ គេបានប្រជុំក្រុមប្រឹក្សាអោយគេនាំអ្នកជាប់គុកចូលមក។ ឆ្មាំគុកបានបើកទ្វារគុក ប៉ុន្តែអ្នកគុកដែលគេបានរកនោះពុំបាននៅទីនោះទេ។ គេបានវិលត្រឡប់ទៅឯសម្ដេចសង្ឃនិងពួកនាហ្មឺនវិញ ហើយនិយាយទៅកាន់គាត់ថា យើងខ្ញុំបានឃើញគុកនៅបិទទ្វារជាប់ទាំងប្រយ័ត្នគ្រប់ជំពូកព្រមទាំងមានពួកយាមល្បាតឈរនៅមាត់ទ្វារផង តែកាលបានបើកទៅ នោះមិនឃើញមានអ្នកណាមួយនៅក្នុងទីនោះសោះ។ ស្រាប់តែមានមនុស្សម្នាក់ទៀតមកប្រាប់ថា មើលពួកមនុស្សដែលលោកបានដាក់គុកនោះ ឥឡូវនេះគេកំពុងតែឈរបង្រៀនដល់ពួកជននៅក្នុងព្រះវិហារវិញ។ នោះមេទ័ពនិងពួកអាជ្ញាក៏ទៅនាំគេមកដោយឥតមានគំហកកំហែងសោះ ដ្បិតគេខ្លាចក្រែងបណ្ដាជនចោលខ្លួននឹងថ្ម។ កាលបាននាំមកដាក់នៅមុខក្រុមជំនុំហើយ នោះសម្ដេចសង្ឃស្ដីថា តើយើងមិនបានហាមផ្ដាច់មិនអោយឯងរាល់គ្នាបង្រៀនសេចក្ដីនោះនៅពេញក្រុងយេរូសាឡិមទាំងមូលវិញ ព្រមទាំងគិតទម្លាក់ទោសពីឈាមមនុស្សនោះមកលើយើងផង។

ពួកគេជាអ្នកមានពុត ហើយចូលចិត្តនឹងការសរសើររបស់មនុស្សជាជាងស្រ-

ឡាញ់ព្រះ។ សកម្មភាពដ៏មានព្រះចេស្តាដែលពួកសាវកបានធ្វើឡើងនោះ រឹតតែធ្វើអោយពួកគេខឹងខ្លាំងឡើង។ ពួកគេបានដឹងថា ប្រសិនបើពួកសាវកផ្សព្វផ្សាយអំពីព្រះយេស៊ូវ ការឆ្កាងទ្រង់ ការមានព្រះជន្មរស់ឡើងវិញនិងការយាងឡើងទៅកាន់ស្ថានសួគ៌របស់ទ្រង់ វានឹងធ្វើអោយកំហុសធ្លាក់ទៅលើពួកគេ និងប្រកាសថា ពួកគេជាឃាតក គេមិនចង់ទទួលលោហិតរបស់ព្រះយេស៊ូវដូចជាកាលដែលគេបានស្រែកជាឱឡារិកថា ចូរអោយឈាមវាធ្លាក់មកលើយើងនិងកូនចៅយើងចុះនោះឡើយ។ ពួកសាវកបានប្រកាសយ៉ាងអង់អាចក្លាហានថាពួកគេត្រូវតែស្តាប់បង្គាប់ព្រះជាជាងមនុស្ស។ ពេត្រុសបាននិយាយថា រីឯព្រះនៃពួកឰយុកោយើងរាល់គ្នា ទ្រង់បានប្រោសព្រះយេស៊ូវដែលលោករាល់គ្នាបានសម្លាប់ដោយព្យួរនៅលើឈើឆ្កាង ទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយព្រះបានដំកើងទ្រង់ឡើងដោយសារព្រះហស្តស្តាំអោយធ្វើជាព្រះអម្ចាស់និងជាព្រះអង្គសង្គ្រោះដើម្បីនឹងប្រោសប្រទានការកែប្រែចិត្តដល់សាសន៍អ៊ីស្រាអែលប្រយោជន៍អោយបានរួចពីបាប។ យើងខ្ញុំនេះព្រមទាំងព្រះវិញ្ញាណបរិសុទ្ធដែលព្រះបានប្រទានដល់អស់អ្នកដែលស្តាប់បង្គាប់ទ្រង់ដែលជាស្មរបន្ទាល់របស់ទ្រង់ពីការទាំងនោះ។ ពេលនោះ ពួកឃាតកមានចិត្តក្តៅក្រហាយជាខ្លាំង។ គេបានចង់សំអាតដៃរបស់គេកុំអោយប្រឡាក់ឈាមដោយសម្លាប់ពួកសាវក។ គេបានរៀបចំផែនការដើម្បីធ្វើការសម្ងាត់នោះ នៅពេលនោះព្រះបានចាត់ទេវតារបស់ទ្រង់ទៅឯអ្នកផារិស៊ីម្នាក់ ឈ្មោះកាម៉ាណុល ដើម្បីជំរុញចិត្តគាត់ចំពោះក្រុមជំនុំសម្តេចសង្ឃនិងពួកនាហ្មឺនដោយនិយាយថា ចូរដកខ្លួនចេញពីមនុស្សទាំងនេះកុំអោយធ្វើអ្វីដល់គេឡើយ ដ្បិតបើសិនជាគំនិតគេឬការគេធ្វើនេះកើតឡើងពីមនុស្សនោះ នឹងត្រូវវិនាសជាមិនខាន តែបើកើតមកពីព្រះវិញនោះអ្នករាល់គ្នាពុំអាចធ្វើអោយវិនាសបានទេ ក្រែងអ្នករាល់គ្នាជាប់ទោសជាពួកអ្នកតយុទ្ធនឹងព្រះដែរ។ ទេវតារបស់អារក្ស វាបានធ្វើការក្នុងចិត្តរបស់សម្តេចសង្ឃដើម្បី



អោយសម្លាប់ពួកសាវក ប៉ុន្តែព្រះបានចាត់ទេវតារបស់ទ្រង់អោយការពារគេដោយធ្វើអោយមានសំឡេងគាំទ្រដល់ពួកសាវកពីក្នុងចំណោមពួកគេ។

ការងាររបស់ពួកសាវកមិនទាន់ចប់ទេ។ ពួកគេត្រូវតែធ្វើទីបន្ទាល់ពីព្រះយេស៊ូវនៅចំពោះស្តេចដើម្បីបង្ហាញពីការដែលគេបានឃើញនិងបានឮ។ ប៉ុន្តែមុននឹងពួកសម្តេចសង្ឃនិងពួកនាហ្មឺនដោះលែងពួកសាវក គេបានវាយដោយរំពាត់ព្រមទាំងហាមឃាត់មិនអោយនិយាយពីព្រះនាមព្រះយេស៊ូវទៀត។ ពួកសាវកក៏ចេញពីក្រុមជំនុំទៅដោយសប្បាយពីព្រោះព្រះបានរាប់ជាអ្នកគួរនឹងទ្រាំសេចក្តីដំនៀលដោយព្រះនាមទ្រង់។ ហើយអ្នកទាំងនោះ ចេះតែបង្រៀននិងប្រាប់ដំណឹងល្អពីព្រះយេស៊ូវនៅក្នុងព្រះវិហារ ហើយនៅអស់ទាំងផ្ទះរាល់តែថ្ងៃ។ ព្រះបន្ទូលរបស់ព្រះបានរីកលូតលាស់និងបានចំរើនឡើង។ សាតាំងបានធ្វើការក្នុងចិត្តសម្តេចសង្ឃនិងពួកនាហ្មឺនអោយជួលទាហានរ៉ូមដែលយាមផ្នូរអោយនិយាយកុហកថា ពួកសាវកបានចូលទៅលួចព្រះសពព្រះយេស៊ូវនៅពេលដែលគេដេកលក់។ តាមរយៈការកុហកនេះ ពួកគេសង្ឃឹមថានឹងអាចបិទបាំងរឿងពិតបាន ប៉ុន្តែមើលទំ ភស្តុតាងដ៏មានចេស្តានៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវបានផុសឡើងដូចផ្សិតនៅជុំវិញគេ។ ពួកសាវកបានប្រកាសពីការនោះយ៉ាងអង់អាចក្លាហានព្រមទាំងបានបញ្ជាក់ពីអ្វីដែលគេបានឃើញនិងបានឮព្រមទាំងបានធ្វើការអស្ចារ្យជាច្រើនដោយនូវព្រះនាមរបស់ព្រះយេស៊ូវ។ ពួកគេបានដាក់លោហិតរបស់ព្រះយេស៊ូវទៅលើអ្នកដែលចង់ទទួលនៅពេលដែលគេបានទទួលការអនុញ្ញាតអោយមានអំណាចលើព្រះយេស៊ូវដោយអង់អាចក្លាហាន។

ខ្ញុំបានឃើញថាព្រះបានត្រាស់បង្គាប់ដល់ទេវតារបស់ទ្រង់អោយថែរក្សានិងការពារជាពិសេសដល់សេចក្តីពិតដ៏ពិសិដ្ឋដែលជាយុថ្កាទ្រទ្រង់ពួកសាវករបស់ព្រះគ្រីស្ទនៅគ្រប់ជំនាន់។

ព្រះវិញ្ញាណបរិសុទ្ធបានសណ្ឋិតយ៉ាងពិសេសលើពួកសាវ័កដែលជាអ្នកធ្វើទីបន្ទាល់ពីការឆ្កាង ពីការមានព្រះជន្មរស់ឡើងវិញ និងការយាងទៅកាន់ស្ថានសួគ៌របស់ព្រះគ្រីស្ទ ជាសេចក្តីពិតដ៏សំខាន់ដែលទ្រទ្រង់សេចក្តីជំនឿរបស់សាសន៍អ៊ីស្រាអែល។ ទាំងអស់គ្នាត្រូវតែសំឡឹងមើលទៅឯព្រះអង្គសង្គ្រោះនៃលោកីយ៍ថាជាសេចក្តីសង្ឃឹមរបស់គេតែមួយគត់និងដើរតាមផ្លូវដែលព្រះយេស៊ូវបានបើកទុកអោយដោយលះបង់ព្រះជន្មរបស់ទ្រង់ផ្ទាល់ហើយនិងរក្សាបញ្ញត្តិរបស់ព្រះក្នុងជីវិត។ ខ្ញុំបានឃើញគតិបណ្ឌិតនិងសេចក្តីល្អរបស់ព្រះយេស៊ូវក្នុងការប្រទានអំណាចដល់ពួកសាវ័កអោយបន្តការងារដដែល ដែលបណ្តាលអោយពួកយូដាស្អប់ទ្រង់និងធ្វើគុតទ្រង់។ គេបានទទួលអំណាចអោយធ្វើការលើការងាររបស់សាតាំង។ គេបានបង្ហាញសញ្ញានិងការអស្ចារ្យដោយព្រះនាមព្រះយេស៊ូវដែលត្រូវបានមើលងាយនិងធ្វើគុតដោយដៃជនកំណាច។ រង់រស្មីនៃពន្លឺនិងសិរីល្អបានចាំងពីពេលនៃការសុគតនិងការមានព្រះជន្មរស់របស់ព្រះគ្រីស្ទ ធ្វើអោយរឿងពិតថាទ្រង់ជាព្រះអង្គសង្គ្រោះនៃលោកីយ៍ នៅស្ថិតស្ថេរជានិច្ច។

សូមអាន កិច្ចការជំពូក ៣-៥។

ជំពូកទី១៣

## ការស្លាប់របស់ស្ទេផាន

ពួកសាវ័កបានកើនឡើងយ៉ាងខ្លាំងនៅទីក្រុងយេរូសាឡិម។ ព្រះបន្ទូលរបស់ព្រះបានកើនឡើង ហើយមានពួកសង្ឃជាច្រើនគោរពតាមនៅក្នុងសេចក្តីជំនឿរបស់គេ។ លោកស្ទេផាន ពោរពេញដោយសេចក្តីជំនឿ ហើយបានធ្វើការអស្ចារ្យនិងសំដែងឫទ្ធិបារមីជាច្រើននៅក្នុងចំណោមពួកសាវ័ក។ មានមនុស្សជាច្រើនបានខឹងសំបាដោយ



មានពួកសង្ឃបានបែរចេញពីប្រពៃណីនិងបែរចេញពីការថ្វាយយញ្ញបូជាដ៏ឧត្តម។ ដោយអំណាចដ៏ខ្ពស់ លោកស្ទេផានបានស្តីបន្ទោសដល់ពួកសង្ឃនិងនិងពួកនាហ្មឺន និងបានសរសើរព្រះយេស៊ូវនៅចំពោះមុខគេ។ ពួកគេមិនអាចតស៊ូនឹងប្រាជ្ញានិងអំណាចដែលគាត់បាននិយាយនោះឡើយ ហើយនៅពេលដែលគេឃើញថា គេមិនអាចយកឈ្នះលើគាត់បាន គេបានជួលមនុស្សឱ្យពោលបង្ខុសថា គេបានឮគាត់និយាយប្រមាថទាស់នឹងលោកម៉ូសេនិងទាស់នឹងព្រះ។ គេបានបំផុសមនុស្សឡើង ហើយដោយធ្វើទីបន្ទាល់ក្លែង គេបានចាប់លោកស្ទេផាននិងបានចោទប្រកាន់គាត់ពីបទនិយាយទាស់នឹងព្រះវិហារ និងទាស់នឹងច្បាប់។

ពួកគេបានបញ្ជាក់ថា គេបានឮស្ទេផាននិយាយថាព្រះយេស៊ូវពីស្រុកណាសារ៉ែតនេះនឹងបំផ្លាញទំនៀមទម្លាប់ដែលលោកម៉ូសេបានទុកឱ្យ។

អ្នកដែលបានអង្គុយនៅក្នុងបន្ទប់ជំនុំជំរះស្ទេផានទាំងអស់ បានឃើញពន្លឺនៃសិរីល្អរបស់ព្រះនៅលើផ្ទៃមុខរបស់គាត់។ មុខរបស់គាត់បានភ្លឺឡើងដូចជាព្រះភ័ក្ត្ររបស់ទេវតា។ គាត់បានក្រោកឈរឡើងពេញដោយសេចក្តីជំនឿ និងព្រះវិញ្ញាណបរិសុទ្ធក៏ចាប់ផ្តើមនិយាយពីពួកហោរាគាត់បាននាំគេទៅឯព្រឹត្តិការណ៍នៃព្រះយេស៊ូវ ការឆ្កាងរបស់ទ្រង់ការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ និងការយាងឡើងទៅកាន់ស្ថានសួគ៌របស់ទ្រង់ និងបានបង្ហាញគេថា ព្រះអម្ចាស់មិនបានគង់នៅក្នុងព្រះវិហារដែលដៃមនុស្សធ្វើនោះទេ។ ពួកគេបានថ្វាយបង្គំព្រះវិហារ។ អ្វីដែលអ្នកណានិយាយទាស់នឹងព្រះវិហារធ្វើអោយគេឈឺចិត្តខ្លាំងជាងការនិយាយទាស់នឹងព្រះទៅទៀត។ វិញ្ញាណរបស់ស្ទេផានបានជំរុញដោយការឈឺចាប់នៃស្ថានសួគ៌នៅពេលដែលគាត់បានស្រែកប្រឆាំងនឹងពួកគេព្រោះការកាចសាហាវនិងមិនកាត់ស្បែកចិត្ត។ អ្នករាល់គ្នាចេះតែទាស់ទទឹងនឹងព្រះវិញ្ញាណបរិសុទ្ធជាដរាប។ ពួកគេបានសំឡឹងមើលតែអាការៈខាងក្រៅ

នៅពេលដែលចិត្តរបស់គេពុករលួយនិងពោរពេញដោយការអាក្រក់ហួសប្រមាណ។ ស្ទេផានបានប្រដូចពួកគេទៅនឹងព្ធយុកោរបស់គេដែលបានបៀតបៀនពួកហោរាដោយនិយាយថា ឥឡូវនេះអ្នករាល់គ្នាក៏បានក្បត់ហើយសម្លាប់ព្រះអង្គនោះ។

ពួកសម្តេចសង្ឃ និងពួកនាហ្មឺន មានការក្តៅក្រហាយយ៉ាងខ្លាំងនៅពេលដែលស្ទេផានបាននិយាយពីសេចក្តីពិតយ៉ាងចំៗ ហើយគេក៏ស្ទុះទៅរកស្ទេផាន។ ពន្លឺនៃស្ថានសួគ៌បានចាំងមកលើគាត់ ហើយនៅពេលដែលគាត់បានសំឡឹងមើលមេឃ ព្រះបានប្រទានការបើកសំដែងអោយគាត់ឃើញសិរីល្អនៃទ្រង់ ហើយទេវតាបានចោមរោមនៅជុំវិញគាត់។ គាត់បានស្រែកថាមើលខ្ញុំបានឃើញមេឃចំហនិងកូនមនុស្សនៅខាងស្តាំព្រះ។ មនុស្សមិនបានឮគាត់ឡើយ។ ពួកគេបានស្រែកឡើងដោយសំឡេងយ៉ាងខ្លាំងទាំងចុកត្រចៀករបស់គេ ទាំងរត់ទៅរកគាត់ទាំងអស់គ្នា ហើយបណ្តេញគាត់ចេញពីទីក្រុងនិងគប់គាត់នឹងថ្ម។ ហើយស្ទេផានបានលុតជង្គង់ចុះ ព្រមទាំងស្រែកដោយសំឡេងខ្លាំងៗថា ឱព្រះអម្ចាស់អើយ សូមកុំរាប់បាបនេះដល់គេឡើយ។

ខ្ញុំបានឃើញថាស្ទេផានគឺជាមនុស្សដែលមានបារមីរបស់ព្រះ ជាពិសេសត្រូវបានលើកឡើងដើម្បីបំពេញកន្លែងដ៏សំខាន់មួយក្នុងពួកជំនុំ។ សាតាំងបានសំដែងសេចក្តីរីករាយយ៉ាងក្រៃលែងនៅពេលដែលស្ទេផានត្រូវស្លាប់ដោយគេគប់នឹងថ្ម ព្រោះវាដឹងថាពួកសាវកបានទទួលការបរាជ័យយ៉ាងធំ។ ប៉ុន្តែជោគជ័យរបស់សាតាំងបានតែមួយភ្លែតប៉ុណ្ណោះ ព្រោះមានម្នាក់ដែលបានឈរនៅក្នុងហ្វូងមនុស្ស បានឃើញការស្លាប់របស់ស្ទេផាន ជាអ្នកដែលព្រះយេស៊ូវបានបង្ហាញអង្គទ្រង់ដល់គាត់។ ទោះបីជាគាត់មិនបានរួមចំណែកក្នុងការគប់ស្ទេផាននឹងថ្មក៏ដោយ ក៏គាត់បានយល់ព្រមក្នុងការស្លាប់របស់ស្ទេផានដែរ។ សុលបានច្រណែននឹងការបៀតបៀនដល់ព្រះវិហាររបស់ព្រះ គាត់បានស្វែងរកចាប់ខ្លួនពួកគេ បណ្តេញគេចេញពីផ្ទះ ហើយបានប្រគល់ពួកគេយកទៅសម្លាប់។



សាតាំងបានប្រើសុលយ៉ាងមានប្រសិទ្ធិភាព។ ប៉ុន្តែព្រះអាចបំផ្លាញអំណាចរបស់សាតាំងហើយដោះលែងអ្នកដែលវាចាប់ចង។ សុលជាមនុស្សដែលមានការចេះដឹង ហើយសាតាំងបានប្រើប្រាស់អំណោយទានគាត់ដោយជោគជ័យអោយធ្វើការប្រឆាំងនឹងព្រះរាជបុត្រានៃព្រះនិងអ្នកដែលជឿលើទ្រង់។ ប៉ុន្តែព្រះយេស៊ូវបានជ្រើសរើសសុលជាអ្នកដែលបានរើសតាំងអោយផ្សព្វផ្សាយព្រះនាមរបស់ទ្រង់ អោយពង្រឹងពួកសាវកក្នុងការងាររបស់គេលើសពីលោកស្ទេផានទៅទៀត។ សុលគឺជាមនុស្សដែលសាសន៍យូដាអោយតម្លៃយ៉ាងខ្ពស់។ គុណសម្បត្តិនិងការសិក្សារបស់គាត់ ធ្វើឱ្យគេពេញចិត្តណាស់ ហើយគាត់គឺជាមនុស្សដែលពួកសាវកភ័យខ្លាចជាខ្លាំង។

សូមអានកិច្ចការជំពូកទី៦និង៧។

## ជំពូកទី១៤
## ការសន្ទនារបស់សុល

នៅពេលដែលសុលបានធ្វើដំណើរទៅកាន់ទីក្រុងដាម៉ាស ជាមួយនឹងលិខិតអនុញ្ញាតដើម្បីចាប់មនុស្សប្រុសស្រីទាំងឡាយដែលផ្សព្វផ្សាយពីព្រះយេស៊ូវហើយចាប់គេយកមកទីក្រុងយេរ៉ូសាឡិម។ ទេវតារបស់អារក្សបានត្រេកអរយ៉ាងខ្លាំងនៅជុំវិញគាត់ ។ប៉ុន្តែនៅពេលដែលគាត់កំពុងធ្វើដំណើរ ស្រាប់តែមានពន្លឺមកពីលើមេឃភ្លឺមកនៅជុំវិញខ្លួនគាត់ដែលធ្វើអោយទេវតារបស់អារក្សបានរត់គេចខ្លួន ហើយធ្វើអោយសុលដួលទៅនឹងដីមួយរំពេច។ គាត់បានឮសំឡេងថា សុល នៃសុល ហេតុអ្វីបានជាអ្នកបៀតបៀនដល់ខ្ញុំដូច្នេះ? សុលទូលឆ្លើយថា ព្រះអម្ចាស់អើយ ព្រះអង្គណានុះន៎? រួចព្រះអម្ចាស់ទ្រង់តបថា ខ្ញុំនេះជាព្រះយេស៊ូវដែលអ្នកបៀតបៀន អ្នកធាក់ជល់នឹង

ជន្លញដូច្នេះ នោះពិបាកដល់អ្នកណាស់។ នោះសុលក៏ញាប់ញ័រ ទាំងអស្ចារ្យក្នុងចិត្ត ព្រះអម្ចាស់អើយ តើទ្រង់សព្វព្រះហឫទ័យអោយទូលបង្គំធ្វើដូចម្ដេច? ព្រះអម្ចាស់ទ្រង់មានបន្ទូលថា ចូរក្រោកឡើងទៅក្នុងទីក្រុងទៅ នោះគេនឹងប្រាប់អ្នកអោយដឹងពីការដែលអ្នកត្រូវធ្វើ។

ឯពួកអ្នកដែលធ្វើដំណើរជាមួយគាត់ គេក៏ឈរស្រឡាំងកាំងដោយបានឮសូរសំឡេងមែន តែមិនបានឃើញអ្នកណាសោះ។ រួចសុលក៏ក្រោកពីដីឡើង តែកាលគាត់បើកភ្នែកហើយ នោះមើលមិនឃើញអ្វីទេ។ គេក៏ដឹកដៃគាត់នាំទៅឯដាម៉ាស ក្នុងរវាងបីថ្ងៃគាត់មើលមិនឃើញឡើយ ក៏មិនបរិភោគអ្វីផង។ ពេលនោះព្រះបានចាត់ទេវតារបស់ទ្រង់ទៅឯបុរសម្នាក់ដែលសុលបានសង្ឃឹមថានឹងចាប់ខ្លួន ហើយបង្ហាញអោយគាត់ឃើញក្នុងការជាក់ស្ដែងមួយថាគាត់ត្រូវធ្វើដំណើរទៅឯផ្លូវដែលហៅថាផ្លូវត្រង់ ហើយសួររកមនុស្សម្នាក់ឈ្មោះសុលជាអ្នកស្រុកតើសុសនៅផ្ទះយូដាស ដ្បិតមើលគាត់កំពុងអធិស្ឋានហើយក្នុងការជាក់ស្ដែង គាត់បានឃើញថាមានមនុស្សម្នាក់ឈ្មោះអាន៉ានាសចូលមកដាក់ដៃលើគាត់អោយបានភ្លឺភ្នែកឡើង។

អាន៉ានាសបានភ័យខ្លាចមានបញ្ហាចំពោះរឿងនេះ ហើយចាប់ផ្ដើមទូលទៅព្រះពីអ្វីដែលគាត់បានឮពីសុល។ ប៉ុន្តែព្រះអម្ចាស់មានបន្ទូលទៅអាន៉ានាសថា ចូរទៅចុះពីព្រោះអ្នកនោះជាប្រដាប់រើសតាំងដល់ខ្ញុំសំរាប់នឹងប្រកាស់ឈ្មោះខ្ញុំដល់ពួកសាសន៍ដទៃទៃនិងពួកស្ដេច ហើយនិងពួកកូនចៅអ៊ីស្រាអែលផង។ ដ្បិតខ្ញុំនឹងបង្ហាញអោយគាត់ដឹងថា ត្រូវរងទុក្ខលំបាកទាំងអប្បាលម៉ានដោយព្រោះឈ្មោះខ្ញុំ។ ដូច្នេះអាន៉ានាសក៏ទៅហើយចូលក្នុងផ្ទះនោះដាក់ដៃលើគាត់និយាយថា អ្នកសុលអើយ ព្រះអម្ចាស់គឺព្រះយេ-ស៊ូវដែលលេចមកអោយអ្នកឃើញតាមផ្លូវ ទ្រង់បានចាត់ខ្ញុំមកដើម្បីអោយអ្នកបានភ្លឺភ្នែក ហើយអោយអ្នកបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ។



សុលក៏ភ្លឺភ្នែកភ្លាម ហើយក្រោកឡើងទទួលបុណ្យជ្រមុជទឹក។ ពេលនោះគាត់បានប្រកាសនៅក្នុងសាលាប្រជុំអំពីព្រះគ្រីស្ទថាទ្រង់គឺជាព្រះរាជបុត្រានៃព្រះ។ ឯអស់អ្នកដែលឮ ក៏មានសេចក្ដីងឿងឆ្ងល់ ហើយគេនិយាយថា តើមិនមែនអ្នកនេះទេឬអីដែលបំផ្លាញពួកអ្នកដែលអំពាវនាវដល់ព្រះនាមនោះនៅក្រុងយេរូសាឡិម។ ហើយគាត់មកទីនេះដើម្បីនឹងចាប់ចងបញ្ជូនទៅអោយពួកសង្គ្រាជដែរ។ តែសុលគាត់មានកម្លាំងកាន់តែខ្លាំងឡើងក៏ផ្ចុញផ្ចាល់ដល់ពួកសាសន៍យូដាវិញ។ ពួកគេមានបញ្ហាម្ដងទៀតហើយ។ សុលបានប្រាប់គេពីបទពិសោធន៍របស់គាត់ជាមួយព្រះវិញ្ញាណបរិសុទ្ធ។ មនុស្សទាំងអស់គេបានដឹងអំពីរឿងដែលសុលបានប្រឆាំងនឹងព្រះយេស៊ូវព្រមទាំងតាមចាប់និងសម្លាប់ដល់អ្នកដែលជឿលើព្រះនាមទ្រង់។ ការសន្ទនាដ៏អស្ចារ្យរបស់គាត់ ធ្វើឱ្យមនុស្សជាច្រើនបានជឿថាព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះ។ សុលបានបង្ហាញអំពីបទពិសោធន៍របស់គាត់ថានៅពេលដែលគាត់បានតាមបៀតបៀន ធ្វើទុក្ខបុកម្នេញនិងកាប់សម្លាប់ ចាប់ដាក់គុកដល់បុរសស្ត្រីទាំងឡាយ មានគ្រាមួយ ពេលគាត់កំពុងធ្វើដំណើរទៅកាន់ទីក្រុងដាម៉ាស រំពេចនោះមានពន្លឺមកពីលើមេឃចាំងជុំវិញខ្លួនគាត់ ហើយព្រះយេស៊ូវបានបង្ហាញអង្គទ្រង់ដល់គាត់ ហើយបង្រៀនគាត់ថាទ្រង់គឺជាព្រះរាជ-បុត្រានៃព្រះ។ នៅពេលដែលសុលបានប្រកាសពីព្រះយេស៊ូវដោយក្លាហាន គាត់មានឥទ្ធិពលយ៉ាងខ្លាំង។ គាត់មានចំណេះដឹងខាងព្រះគម្ពីរ ហើយបន្ទាប់ពីគាត់បានផ្លាស់ប្ដូរជំនឿ ពន្លឺនៃព្រះបានចាំងទៅលើបទទំនាយទាំងឡាយទាក់ទងនឹងព្រះយេស៊ូវដែលធ្វើអោយគាត់អាចបង្ហាញពីសេចក្ដីពិតយ៉ាងច្បាស់និងយ៉ាងអង់អាច និងកែលំអន្ទូវការកែ-ប្រែបទគម្ពីរទាំងឡាយ។ ដោយព្រះវិញ្ញាណរបស់ព្រះបានគង់នៅជាមួយគាត់ គាត់បាននាំអ្នកស្ដាប់របស់គាត់អោយដឹងពីបទទំនាយតាំងពីការយាងមកជាលើកទីមួយរបស់ព្រះយេស៊ូវ និងបង្ហាញគេថាបទគម្ពីរត្រូវបានសំរេចហើយដែលយោងទៅលើការរងទុក្ខ

របស់ព្រះគ្រីស្ទ ការសុគតនិងការរស់ឡើងវិញរបស់ទ្រង់។

សូមអានគម្ពីរកិច្ចការ ជំពូកទី៩

## ជំពូកទី១៥
## សាសន៍យូដាបានសំរេចចិត្តសម្លាប់ប៉ុល

ពួកសង្គ្រាជនិងពួកមេដឹកនាំគេមានកំហឹងទាស់នឹងប៉ុលជាខ្លាំងនៅពេលដែលគាត់បានធ្វើទីបន្ទាល់អំពីហេតុដែលទាក់ទងនឹងបទពិសោធន៏របស់គាត់។ គេបានឃើញថាគាត់ប្រកាសពីព្រះយេស៊ូវដោយអង់អាចហើយបានធ្វើការឫទ្ធិបារមីក្នុងព្រះនាមទ្រង់ ហើយមានមនុស្សជាច្រើនបានស្តាប់គាត់ ហើយបែរចេញពីប្រពៃណីរបស់គេ ព្រមទាំងបានសំឡឹងមើលទៅពួកគេថា អ្នកធ្វើគុតព្រះរាជបុត្រានៃព្រះ។ កំហឹងរបស់គេបានពុះ-ពោរឡើង ហើយគេក៏បានប្រជុំពិភាក្សាគ្នាថាតើត្រូវធ្វើយ៉ាងណាដើម្បីបំបាត់ការរំជើប-រំជួលនេះអោយមានប្រសិទ្ធិភាពបំផុត។ គេបានព្រមព្រៀងគ្នាថាវិធីដ៏ល្អបំផុតសំរាប់ពួកគេគឺសម្លាប់ប៉ុលចោល។ ប៉ុន្តែព្រះទ្រង់ជ្រាបអំពីគោលបំណងរបស់គេ ហើយបានចាត់ទេវតាអោយតាមថែរក្សាគាត់ដើម្បីអោយគាត់រស់នៅបំពេញការងាររបស់ទ្រង់និងរង-ទុក្ខដោយសារព្រះនាមរបស់ព្រះយេស៊ូវ។

គេបានប្រាប់ដល់ប៉ុលថា សាសន៏យូដាតាមសម្លាប់គាត់។ សាតាំងបានដឹកនាំអោយសាសន៏យូដាដែលមិនជឿឱ្យចាំយាមមាត់ទ្វារទីក្រុងដាម៉ាសទាំងយប់ទាំងថ្ងៃដើម្បីឃ្លាំមើលនៅពេលណាដែលប៉ុលចេញតាមទ្វារ នោះគេនឹងសម្លាប់គាត់ភ្លាម។ ប៉ុន្តែនៅពេលយប់ពួកសាវកបានសំរូតលោកចុះមកតាមកន្ទ្រក។ នៅទីនោះពួកយូដាមានការអាម៉ាស់ដោយការបរាជ័យរបស់ពួកគេ ហើយរាស្ត្ររបស់សាតាំងត្រូវបរាជ័យ។



ប៉ុលក៏បានធ្វើដំណើរទៅទីក្រុងយេរ៉ូសាឡិមដើម្បីចូលរួមជាមួយពួកសាវក ប៉ុន្តែពួកគេបានភ័យខ្លាចចំពោះគាត់។ គេមិនអាចជឿថាគាត់ជាសាវកឡើយ។ ជីវិតរបស់គាត់ត្រូវបានពួកយូដាតាមរក ហើយបងប្អូនរបស់គាត់ក៏មិនបានទទួលគាត់ទៀត ប៉ុន្តែបារ៉ាបាសបាននាំគាត់ទៅជួបពួកសាវក ហើយក៏រ៉ាយរ៉ាប់ប្រាប់ពួកគេអំពីការដែលគាត់បានជួបព្រះនៅតាមផ្លូវ និងអំពីការដែលគាត់បានប្រកាសអំពីព្រះនាមរបស់ព្រះយេស៊ូវយ៉ាងក្លៀវក្លានៅទីក្រុងដាម៉ាស។ ប៉ុន្តែសាតាំងបានកកូកកាយចិត្តរបស់សាសន៏យូដាអោយបំផ្លាញប៉ុល ហើយព្រះយេស៊ូវក៏បានប្រាប់អោយគាត់ចេញពីទីក្រុងយេរ៉ូសាឡិម។ គាត់បានធ្វើដំណើរទៅកាន់ទីក្រុងជាច្រើនដោយអធិប្បាយអំពីព្រះយេស៊ូវនិងធ្វើការអស្ចារ្យផង មានមនុស្សជាច្រើនបានទទួលជឿ ហើយនៅពេលដែលមនុស្សពិការពីកំណើតម្នាក់ត្រូវបានព្យាបាលអោយជាឡើងវិញ អ្នកដែលថ្វាយបង្គំរូបសំណាករៀបតែនឹងថ្វាយយញ្ញបូជាដល់ពួកសាវកទៅហើយ។ ប៉ុលបានហែកអាវខ្លួនហើយបានប្រាប់គេថា ពួកគេគ្រាន់តែជាមនុស្សប៉ុណ្ណោះ ហើយពួកគេត្រូវថ្វាយបង្គំព្រះដែលបង្កើតផ្ទៃមេឃ ផែនដីសមុទ្រនិងរបស់ទាំងអស់ដែលនៅស្ថានទាំងនោះផង។ ប៉ុលបានសរសើរតំកើងព្រះនៅមុខគេរាល់គ្នា ប៉ុន្តែគាត់ឃាត់គេមិនអោយថ្វាយយញ្ញបូជាដល់គាត់សឹងតែមិនបាន។ ចំណេះដឹងនៃសេចក្តីជំនឿលើព្រះដ៏ពិតដំបូង ហើយការថ្វាយបង្គំនិងកិត្តិយសដោយសារគាត់ បានចាប់ផ្តើមកើតឡើងនៅក្នុងគំនិតពួកគេ ហើយនៅពេលដែលពួកគេកំពុងតែស្តាប់ប៉ុល សាតាំងបានជំរុញអោយសាសន៏យូដាដែលគ្មានជំនឿមកពីទីក្រុងមួយទៀតអោយតាមប៉ុលដើម្បីបំផ្លាញការងារល្អដែលគាត់បានធ្វើ។ សាសន៏យូដាបានបំផុសនិងបញ្ឆេះកំហឹងដល់ពួកអ្នកថ្វាយបង្គំរូបព្រះដោយនិយាយបំផ្លើសទាស់នឹងប៉ុល។ ឥឡូវនេះមនុស្សដ៏អស្ចារ្យនិងគួរគោរពបានក្លាយជាគេស្អប់ហើយអ្នកដែលរៀបនឹងថ្វាយយញ្ញបូជានិងថ្វាយបង្គំដល់ពួកសាវកថ្មីៗ នោះបានចោលប៉ុលនឹងដុំថ្ម រួចអូសគាត់

ចេញទៅទុកចោលនៅក្រៅទីក្រុងដោយស្មានថា គាត់ស្លាប់ហើយ។ ប៉ុន្តែនៅពេលពួកសិស្សកំពុងឈរយំសោកនៅជុំវិញគាត់ គាត់បានក្រោកឡើងហើយដើរចូលទៅក្នុងទីក្រុងវិញជាមួយគេ។

នៅពេលដែលប៉ុលបានអធិប្បាយអំពីព្រះយេស៊ូវ មានស្ត្រីម្នាក់ដែលមានអារក្សចូលដើរតាមពួកគាត់ដោយស្រែកថាអ្នកទាំងនេះជាអ្នកបំរើដ៏ខ្ពស់បំផុតដែលប្រាប់យើងពីផ្លូវសង្គ្រោះ។ នាងក៏ធ្វើដូចនេះជាយូរថ្ងៃទាល់តែប៉ុលមានសេចក្តីរំខានចិត្តជាខ្លាំងព្រោះការស្រែកនេះបង្វែងគំនិតរបស់មនុស្សចេញពីសេចក្តីពិត។ ទិសដៅរបស់សាតាំងក្នុងការដឹកនាំនាងអោយធ្វើដូច្នេះគឺដើម្បីធ្វើអោយមនុស្សជិនឆ្អន់និងបំផ្លាញឥទ្ធិពលរបស់ពួកសិស្ស។ ប៉ុន្តែវិញ្ញាណរបស់ប៉ុលបានពុះពោរឡើង ហើយគាត់បានបែរទៅឯស្រីនោះទាំងនិយាយថា អញបង្គាប់ឯងដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទអោយឯងចេញពីនាងនេះទៅ។ វិញ្ញាណរបស់អារក្សក៏បានទទួលការគំរាមហើយក៏ចេញពីនាងនៅពេលនោះទៅ។

ចៅហ្វាយរបស់នាងពេញចិត្តណាស់ដែលនាងតាមស្រែកពីក្រោយពួកសិស្ស ប៉ុន្តែនៅពេលដែលវិញ្ញាណអារក្សបានចេញពីនាងទៅ ហើយពួកគេបានឃើញនាងជាសិស្សយ៉ាងស្លូតបូតរបស់ព្រះគ្រីស្ទម្នាក់នោះ គេក្តៅក្រហាយជាខ្លាំង។ គេបានប្រមូលប្រាក់យ៉ាងច្រើនដោយសារការទស្សទាយរបស់នាង ឥឡូវនេះសេចក្តីសង្ឃឹមដែលនឹងបានកំរៃរបស់គេបានបាត់អស់ទៅហើយ។ គោលបំណងរបស់សាតាំងបានបរាជ័យ ប៉ុន្តែអ្នកបំរើរបស់វាបានចាប់ប៉ុលនិងសីឡាសដោយកន្ត្រាក់កន្ត្រៃងនាំទៅទីផ្សារនៅចំពោះមុខមេនគរបាលនិងពួកចៅក្រមដោយនិយាយថា ពួកយូដាទាំងនេះនាំអោយទី-ក្រុងយើងកើតវឹកវរខ្លាំងណាស់។ ហ្វូងមនុស្សក៏លើកគ្នាទាស់នឹងប៉ុលនិងសីឡាស រួចមេនគរបាលបានកន្ត្រាក់ហែកអាវគេចេញហើយបង្គាប់អោយវាយនឹងរំពាត់។ ក្រោយ



ដែលមានស្នាមជាច្រើនរួចមកហើយនោះ ក៏យកទៅដាក់គុកទាំងបង្គាប់មេភូឃុំអោយរក្សាដោយប្រយ័ត្នប្រយែង មេគុកក៏ទទួលបង្គាប់យ៉ាងដូច្នេះ ហើយក៏នាំគេទៅដាក់គុកក្នុងគុកជ្រៅព្រមទាំងដាក់ខ្នោះជាប់នៅជើងផង។ ប៉ុន្តែទេវតារបស់ព្រះបានយាងតាមគេទៅក្នុងជញ្ជាំងគុក។ ការចេញពីគុករបស់ពួកគេបានប្រាប់អំពីសិរីល្អរបស់ព្រះ និងបានបង្ហាញដល់មនុស្សថា ព្រះបានធ្វើការជាមួយនឹងអ្នកបំរើដែលបានរើសតាំងរបស់ទ្រង់និងថាព្រះអង្គអាចធ្វើអោយជញ្ជាំងគុករញ្ជួយ ហើយនិងបើកចំរឹងដ៏មាំបានយ៉ាងងាយ។

នៅពេលពាក់កណ្តាលអាធ្រាត្រ ប៉ុលនិងសីឡាសបានអធិស្ឋាននិងច្រៀងសរសើរព្រះ រំពេចនោះ ស្រាប់តែមានកក្រើកដីជាខ្លាំងដល់ម្លេះ បានជារញ្ជួយដល់ជើងជញ្ជាំងគុកផង ហើយខ្ញុំបានឃើញថា ទេវតារបស់ព្រះបានដោះខ្នោះចេញពីមនុស្សគ្រប់ៗគ្នា។ ឆ្មាំគុកបានក្រោកឡើងហើយតក់ស្លុតជាខ្លាំងនៅពេលដែលឃើញទ្វារគុកបានរបើក។ គាត់ស្មានថាអ្នកទោសរត់រួចអស់ហើយ ហើយគាត់មុខជានឹងទទួលទោសប្រហារជីវិតមិនខាន។ នៅពេលដែលគាត់ហៀបនឹងសម្លាប់ខ្លួនឯង ប៉ុលស្រែកឡើងដោយសំឡេងខ្លាំងៗថា កុំធ្វើបាបខ្លួនឯងឡើយ ដ្បិតយើងនៅឯណេះទាំងអស់គ្នាទេ។ អំណាចរបស់ព្រះបានបំផ្លាស់បំប្រែឆ្មាំគុក។ គាត់ក៏អោយគេយកភ្លើងមក រួចម្នីម្នាស្ទុះចូលទៅក្នុងគុកផ្តួលខ្លួននៅទៀបជើងប៉ុលនិងសីឡាសទាំងញាប់ញ័រ គាត់នាំគេចេញទៅក្រៅសួរថា លោកម្ចាស់អើយ តើត្រូវអោយខ្ញុំធ្វើដូចម្តេចអោយបានសង្គ្រោះផង? គេក៏ប្រាប់គាត់ថា ចូរជឿដល់ព្រះអម្ចាស់យេស៊ូវទៅ នោះនឹងបានសង្គ្រោះហើយ ព្រមទាំងគ្រួសារលោកផង។ ពេលនោះអ្នកយាមគុកប្រមូលក្រុមគ្រួសាររបស់គាត់មកប្រជុំគ្នា ហើយប៉ុលក៏បាននិយាយរឿងពីព្រះយេស៊ូវប្រាប់ដល់គេ។ ចិត្តរបស់អ្នកយាមគុកបានផ្សារភ្ជាប់ជាមួយពួកសិស្ស ហើយគាត់បានលាងស្នាមរំពាត់របស់គេ រួចខ្លួនគាត់និងគ្រួ-

សារគាត់ទាំងអស់គ្នាក៏ទទួលបុណ្យជ្រមុជទឹកនៅយប់នោះ។ នោះគាត់ក៏នាំគេចូលទៅក្នុងផ្ទះរៀបតុអោយបរិភោគដោយមានចិត្តរីករាយសាទរព្រមទាំងពួកក្រុមគ្រួសារគាត់ផង ដោយព្រោះបានជឿដល់ព្រះហើយ។

ដំណើងល្អដ៏អស្ចារ្យនៃអំណាចដ៏មានសិរីល្អរបស់ព្រះដែលបានបង្ហាញដោយការបើកទ្វារគុក និងការកែប្រែចិត្ត ព្រមទាំងទទួលបុណ្យជ្រមុជទឹករបស់មេគុកនិងគ្រួសាររបស់គាត់ត្រូវបានគេផ្សព្វផ្សាយយ៉ាងទូលំទូលាយ។ ពួកនាហ្មឺនបានឮពីរឿងទាំងនេះ ក៏មានការភ័យខ្លាចជាខ្លាំង ក៏ចាត់ពួកនាយអោយទៅប្រាប់ថា ចូរលែងអ្នកទាំងពីរនោះទៅ។តែប៉ុលមិនបានចេញពីគុកទេដោយរឿងផ្ទាល់ខ្លួន។ គាត់បាននិយាយទៅគេថាពួកគេបានវាយយើងនឹងរំពាត់នៅកណ្តាលជំនុំទាំងមានកាត់ទោស ហើយបានដាក់គុកយើងផងដែលយើងជាជាតិរ៉ូម ដូច្នេះឥឡូវនេះ លោកចង់គេចកែប្រែជាដេញយើងទៅដោយសម្ងាត់វិញឬ? ធ្វើដូច្នេះពុំបានទេ ត្រូវឱ្យខ្លួនលោកមកនាំយើងចេញទៅវិញ។ ប៉ុលនិងសីឡាសមិនចង់អោយការបង្ហាញពីអំណាចរបស់ព្រះត្រូវបានបិទបាំងនោះឡើយ។ ពួកនាយក៏ទៅជំរាបដល់នគរបាលតាមពាក្យនោះ រួចក៏មានសេចក្តីភ័យខ្លាចជាខ្លាំងដោយឮថាជាជាតិរ៉ូម។ ក៏មកសូមអង្វរដល់គាត់ទាំងពីរនាក់ រួចនាំចេញពីក្នុងគុកហើយសូមអោយចេញពីទីក្រុងនេះទៅ។

សូមអានកិច្ចការជំពូកទី១៤ និង១៦។

ជំពូកទី១៦

## ប៉ុលបានទៅឯទីក្រុងយេរូសាឡិម

ក្រោយពីប៉ុលបានកែប្រែចិត្តមួយរយៈពេលខ្លីមក គាត់ក៏បានទៅផ្សព្វផ្សាយ



អំពីព្រះយេស៊ូវនិងព្រះគុណដ៏អស្ចារ្យរបស់ទ្រង់នៅទីក្រុងយេរូសាឡិម គាត់បានដំណាលប្រាប់គេពីការកែប្រែចិត្តដោយការអស្ចារ្យរបស់គាត់ដែលធ្វើអោយពួកសង្ឃនិងពួកនាហ្មឺនក្តៅក្រហាយជាខ្លាំង ហើយគេបានគិតថានឹងសម្លាប់គាត់។ តែជីវិតរបស់គាត់ត្រូវបានជួយសង្គ្រោះ ព្រះយេស៊ូវបានលេចមកឯគាត់ម្តងទៀតក្នុងការជាក់ស្តែងមួយពេលគាត់កំពុងអធិស្ឋានដោយមានបន្ទូលទៅគាត់ថា ចូរឯងចេញពីទីក្រុងយេរ៉ូសាឡិមអោយបានរហ័សទៅដ្បិតគេមិនទទួលទីបន្ទាល់របស់ខ្ញុំពីអ្នកទេ។ ប៉ុលបានអង្វរព្រះ-យេស៊ូវដោយទទូចថា ព្រះអម្ចាស់អើយ គេនឹងថាទូលបង្គំជាប់ដាក់គុកទូលបង្គំបានវាយដល់អ្នកដែលជឿលើព្រះនាមទ្រង់នៅគ្រប់វេលាប្រជុំ។ ហើយនៅពេលដែលឈាមរបស់ស្ទេផានជាទុក្ករបុគ្គលរបស់ទ្រង់បានខ្ចាយទូលបង្គំក៏ឈរនៅទីនោះ ហើយយល់ព្រមទៅនឹងការសម្លាប់គាត់ដែរ ហើយបានការពារអ្នកដែលសម្លាប់គាត់ទៀត។ ប៉ុលបានគិតថាសាសន៏យូដានៅក្រុងយេរូសាឡិមនឹងមិនបដិសេធទីបន្ទាល់របស់គាត់ទេដោយគេនឹងពិចារណាការផ្លាស់ប្តូរដ៏ធំរបស់គាត់អាចធ្វើទៅបានអាស្រ័យដោយសារតែអំណាចដ៏ធំរបស់ព្រះតែប៉ុណ្ណោះ។ ប៉ុន្តែព្រះយេស៊ូវបានមានបន្ទូលទៅគាត់ថា ចូរចេញទៅ ដ្បិតខ្ញុំនឹងបញ្ជូនអ្នកអោយទៅឯសាសន៏ដទៃ។

នៅក្នុងការចាកចេញពីទីក្រុងយេរូសាឡិម គាត់បានសរសេរសំបុត្រជាច្រើនផ្ញើទៅកាន់កន្លែងផ្សេងៗរៀបរាប់ពីបទពិសោធន៏របស់គាត់និងប្រាប់ពីទីបន្ទាល់ដ៏អស្ចារ្យ។ ប៉ុន្តែមានមនុស្សខ្លះខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីបំផ្លាញឥទ្ធិពលនៃសំបុត្រទាំងនោះ។ គេត្រូវតែទទួលស្គាល់ថាសំបុត្ររបស់គាត់មានទម្ងន់និងមានអំណាច។ ប៉ុន្តែគេអះអាងថាការបង្ហាញដោយក្បៀវក្លារបស់គាត់ទន់ខ្សោយនិងការនិយាយរបស់គាត់គួរអោយមើលងាយ។

ខ្ញុំបានឃើញថាប៉ុលគឺជាមនុស្សដែលមានការចេះដឹងខ្ពស់ ហើយគតិបណ្ឌិតនិង

អាកប្បកិរិយារបស់គាត់ធ្វើអោយអ្នកស្តាប់ចូលចិត្ត ។ អ្នកចេះដឹងជាច្រើនពេញចិត្តនឹងចំណេះដឹងរបស់គាត់ ហើយពួកគេជាច្រើនបានជឿលើព្រះយេស៊ូវ ។ នៅចំពោះស្តេចនិងអង្គប្រជុំយ៉ាងធំគាត់បានបញ្ចេញវោហារដែលធ្វើអោយគេទាំងអស់ចុះចូលចំពោះគាត់ ។ ការនេះធ្វើអោយពួកសង្គ្រាជនិងពួកនាហ្មឺនខឹងកាន់តែខ្លាំងឡើង ។ ប៉ុលអាចបង្ហាញហេតុផលដល់គេបានយ៉ាងច្បាស់ព្រមទាំងនាំមនុស្សមកឯគាត់ជាច្រើនយ៉ាងអស្ចារ្យក្នុងគំនិតនៃការសរសើរដំកើងនិងនាំអោយគេឃើញនូវព្រះគុណដ៏ធំធេងរបស់ព្រះនិងពណិនានៅចំពោះមុខគេពីសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះគ្រីស្ទ ។ ហើយជាមួយនឹងភាពងាយស្រួល គាត់អាចយល់ពីមនុស្សសាមញ្ញហើយអាចបរិយាយប្រាប់គេពីបទ-ពិសោធន៏របស់គាត់យ៉ាងមានអំណាចបំផុតដែលធ្វើអោយគេចង់ក្លាយជាសិស្សរបស់ព្រះ គ្រីស្ទយ៉ាងខ្លាំង ។

ព្រះបានបង្ហាញដល់ប៉ុលអោយត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ ហើយនៅទីនោះគាត់នឹងត្រូវគេចាប់និងត្រូវរងទុក្ខដោយសារព្រះនាមរបស់ទ្រង់ ។ ទោះបីជាគាត់ជាប់ក្នុងពេលដ៏យូរក៏ដោយ ក៏ព្រះនៅតែធ្វើការងារជាពិសេសតាមរយៈគាត់ដែរ ។ ការចាប់ប៉ុលគឺជាមធ្យោបាយនៃការប្រកាសផ្សាយអំពីចំណេះដឹងនៃព្រះ-គ្រីស្ទនិងដើម្បីសរសើរដំកើងព្រះ ។ នៅពេលដែលគេបញ្ជូនគាត់ពីទីក្រុងមួយទៅទី-ក្រុងមួយ គាត់បានរៀបរាប់ទីបន្ទាល់ដែលទាក់ទងនឹងព្រះយេស៊ូវនិងឧបត្តិហេតុដ៏គួរអោយចាប់អារម្មណ៏នៃការកែប្រែចិត្តរបស់គាត់នៅចំពោះស្តេចចៅហ្វាយខេត្តដែលគាត់មិនដែលចាកចេញទៅដោយមិនបានធ្វើទីបន្ទាល់ពីព្រះយេស៊ូវឡើយ ។ មនុស្សរាប់ពាន់នាក់បានជឿទ្រង់និងមានអំណរចំពោះព្រះនាមទ្រង់ ។ ខ្ញុំបានឃើញថា ព្រះរាជបំណងដ៏ពិសេសរបស់ព្រះបានសំរេចហើយនៅក្នុងដំណើរតាមទឹករបស់ប៉ុល អ្នកមិនជឿសាសនាអាចឮព្រះនាមរបស់ព្រះយេស៊ូវដែរនិងមានមនុស្សជាច្រើនបានកែប្រែចិត្តដោយសារ



ការបង្រៀនរបស់គាត់ និងដោយបានឃើញការអស្ចារ្យដែលគាត់បានធ្វើ ។ ស្តេចនិងចៅហ្វាយខេត្តពេញចិត្តនឹងហេតុផលរបស់គាត់ជាខ្លាំង ហើយគាត់ក៏បានអធិប្បាយអំពីព្រះយេស៊ូវនិងរ៉ាយរ៉ាប់អំពីព្រឹត្តិការណ៏នៃទីបន្ទាល់ដ៏គួរអោយចាប់អារម្មណ៏របស់គាត់ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធបានទាក់ទាញពួកគេអោយជឿថាព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះ ហើយនៅពេលដែលមានអ្នកខ្លះបានភ្ញាក់ផ្អើលនិងការអស្ចារ្យចំពោះរឿងដែលគេបានស្តាប់ប៉ុលមានម្នាក់បានស្រែកឡើងថា បន្តិចទៀតឯងនឹងនាំអោយយើងត្រឡប់ជាគ្រីស្ទានដែរ ។ មែនហើយ គេគិតថា នៅថ្ងៃណាមួយនាពេលអនាគតគេនឹងពិចារណានូវអ្វីដែលគេបានឮ ។ សាតាំងបានឆ្លៀតឱកាសនៃការពន្យាពេលនេះ ហើយនៅពេលដែលគេមិនរវល់នឹងឱកាសល្អពេលដែលចិត្តគេទន់នោះ គេនឹងបាត់បង់ជារៀងរហូត ។ ចិត្តរបស់គេបានរឹងរូសឡើងវិញ ។

គេបានបង្ហាញខ្ញុំអោយឃើញការងាររបស់សាតាំង ដំបូងវាបានបំបិទភ្នែករបស់សាសន៏យូដាដើម្បីកុំអោយគេទទួលព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់គេហើយបន្ទាប់មកគឺការដឹកនាំពួកគេអោយច្រណែននឹងការងារដ៏មានព្រះចេស្តារបស់ទ្រង់ និងប្រាថ្នាចង់ធ្វើគុតទ្រង់ ។ សាតាំងបានចូលទៅក្នុងសាវករបស់ព្រះយេស៊ូវផ្ទាល់ម្នាក់ហើយធ្វើអោយវាបញ្ជូនទ្រង់ទៅក្នុងកណ្តាប់ដៃរបស់ពួកគេ ហើយគេក៏បានឆ្កាងព្រះអម្ចាស់នៃជីវិតជាព្រះនៃសិរីល្អ ។ បន្ទាប់ពីព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ សាសន៏យូដាបានបន្ថែមបាបទៅលើអំពើបាបដោយស្វះស្វែងរកការលាក់កំបាំងរឿងនៃការមានព្រះជន្មរស់ឡើងវិញដោយយកលុយទៅជូលទាហានរ៉ូមដែលយាមផ្នូរអោយប្រាប់រឿងមិនពិត ។ ប៉ុន្តែការមានព្រះជន្មរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវត្រូវបានធ្វើអោយកាន់តែពិតប្រាកដឡើងទ្វេមួយជាពីរដោយសាក្សីជាច្រើនដែលបានរស់ពីស្លាប់ឡើងវិញជាមួយនឹងទ្រង់ ។ ព្រះយេស៊ូវបានលេចមកឯពួកសាវក និងលេចមកឯមនុស្សជាងប្រាំ

ពាន់នាក់ម្តងទៀត នៅពេលដែលទ្រង់បានលើកមនុស្សទាំងនោះឡើងពីស្លាប់ជាមួយទ្រង់ បានលេចមកឯមនុស្សជាច្រើន ដោយប្រកាសថាព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញហើយ ។

សាតាំងបានបណ្តាលអោយពួកយូដាបះបោរប្រឆាំងនឹងព្រះដោយបដិសេធមិនទទួលបុត្រារបស់ទ្រង់ដោយធ្វើអោយដៃរបស់គេប្រឡាក់ដោយព្រះលោហិតដ៏មានតម្លៃក្នុងការឆ្កាងទ្រង់ ។ ទោះបីជាមានភស្តុតាងដ៏មានថាមពលជាច្រើនបញ្ជាក់ថាព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះជាអ្នកចេញថ្លៃលោះលោកីយ៏ក៏ដោយ ក៏គេបានធ្វើគុតទ្រង់ដែរនិងមិនទទួលភស្តុតាងណាមួយដែលទ្រង់បានបង្ហាញនោះឡើយ ។ សេចក្តីសង្ឃឹមតែមួយគត់របស់គេក៏ដូចជារបស់សាតាំងបន្ទាប់ពីវាធ្លាក់ចុះនោះដែរ គឺព្យាយាមប្រយុទ្ធយកឈ្នះលើព្រះរាជបុត្រានៃព្រះ ។ ពួកគេបន្តការបះបោររបស់គេដោយបៀតបៀនដល់ពួកសាវករបស់ព្រះគ្រីស្ទនិងសម្លាប់ពួកគេ ។ គ្មានអ្វីដែលមិនពិរោះនៅត្រចៀករបស់គេជាងពាក្យថាព្រះយេស៊ូវបានឆ្កាងនោះឡើយ ហើយគេក៏បានប្តេជ្ញាចិត្តថានឹងមិនស្តាប់ភស្តុតាងណាមួយដែលជាទីពេញចិត្តរបស់គេដែរ ។ ដូចជានៅក្នុងករណីរបស់លោកស្ទេផានគ្រាដែលព្រះវិញ្ញាណបរិសុទ្ធបានប្រកាសតាមរយៈគាត់អំពីភស្តុតាងដ៏មានព្រះចេស្តានៃភាពជាព្រះរាជបុត្រានៃព្រះរបស់ទ្រង់ គេបិទត្រចៀកគេក្រែងគេត្រូវបានកែប្រែចិត្ត ។ ហើយនៅពេលដែលសិរីល្អរបស់ព្រះបានព័ទ្ធជុំវិញស្ទេផាន គេបានចោលគាត់នឹងថ្មសម្លាប់ ។ សាតាំងមានឃាតកសម្លាប់ព្រះយេស៊ូវក្តាប់ជាប់នៅដៃ ។ ដោយការងារដ៏កំណាចរបស់វា វាបានប្រគល់ខ្លួនវាទៅអោយអ្នកដែលដើរតាមវា ហើយតាមរយៈពួកគេ វាបានធ្វើការរំខាននិងបន្ទុចបង្អាក់ដល់អ្នកជឿលើព្រះគ្រីស្ទ ។ វាបានធ្វើការតាមរយៈសាសន៍យូដាដើម្បីបំផុសពួកក្រៅសាសន៍អោយប្រឆាំងនឹងព្រះនាមរបស់ព្រះយេស៊ូវនឹងប្រឆាំងជាមួយនឹងអ្នកដែលដើរតាមទ្រង់និងជឿលើព្រះនាម



ទ្រង់ ។ ប៉ុន្តែព្រះបានចាត់ពួកទេវតាអោយមកចំរើនកម្លាំងពួកសាវកសំរាប់ការងាររបស់គេដើម្បីបង្ហាញពីការដែលគេបានឃើញនិងបានឮ ហើយនៅទីចុងបំផុតនៃការឈរមាំមួនរបស់គេ គេនឹងបោះត្រាទីបន្ទាល់របស់គេដោយព្រះលោហិតរបស់ទ្រង់ ។

សាតាំងសប្បាយចិត្តណាស់ដោយសាសន៍យូដាចូលទៅក្នុងអន្ទាក់របស់វា ។ វានៅតែបន្តប្រើប្រាស់ទំរង់ដ៏ឥតប្រយោជន៏របស់វា យញ្ញបូជា និងបញ្ញត្តិរបស់វា ។ នៅពេលដែលព្រះយេស៊ូវព្យួរនៅលើឈើឆ្កាងហើយទ្រង់បានស្រែកថា ការស្រេចហើយ វាំងននក្នុងព្រះវិហាររហែកជាពីរ ពីលើចុះក្រោមបញ្ជាក់ថា ព្រះអម្ចាស់នឹងមិនជួបជាមួយនឹងសង្ឃនៅក្នុងព្រះវិហារដើម្បីទទួលយញ្ញបូជានិងបញ្ញត្តិរបស់គេទៀតទេនិងបង្ហាញផងដែរថាជញ្ជាំងខ័ណ្ឌចែករវាងពួកយូដានិងសាសន៏ដទៃបានរលាយហើយ ។ ព្រះយេស៊ូវបានប្រគល់អង្គទ្រង់ផ្ទាល់ជាដង្វាយយញ្ញបូជាលោះបាបសំរាប់សាសន៏ទាំងពីរនេះ ហើយប្រសិនបើមនុស្សបានសង្គ្រោះទាំងអស់ ទាំងពីរសាសន៏ត្រូវតែជឿព្រះយេស៊ូវ ជាយញ្ញបូជាលោះបាប និងជាព្រះអង្គសង្គ្រោះនៃលោកីយ៏ ។

នៅពេលដែលព្រះយេស៊ូវទ្រង់ជាប់នៅលើឈើឆ្កាង ទាហានបានយកលំពែងមកចាក់ចំហៀងទ្រង់ ហើយមានឈាមនិងទឹកហូរចេញមកតាមរន្ធផ្សេងៗពីគ្នា មួយជាឈាមនិងមួយទៀតជាទឹក ។ ឈាមសំរាប់លាងសំអាតអំពើបាបរបស់អ្នកដែលជឿលើព្រះនាមរបស់ទ្រង់ ។ ទឹកតំណាងអោយទឹករស់ដែលបានចេញពីព្រះយេស៊ូវប្រទានជីវិតដល់អ្នកជឿទាំងឡាយ ។

សូមអានម៉ាថាយ ២៧:៥១ យ៉ូហាន ១៩:៣៤ កិច្ចការ ជំពូកទី២៤ និង២៦ ។

ជំពូកទី១៧

## ការក្បត់ជំនឿដ៏ធំ

ខ្ញុំត្រូវបានគេនាំ ទៅឯពេលដែលអ្នកថ្វាយបង្គំរូបព្រះ បានបៀតបៀន និងសម្លាប់ដល់អ្នកគ្រីស្ទាន យ៉ាងឃោរឃៅ។ ឈាមបានហូរក្លាយជាត្លុក អភិជន អ្នកចេះដឹង និងមនុស្សសាមញ្ញធម្មតា ត្រូវបានគេសម្លាប់ ដោយគ្មានត្រាប្រណី។ គ្រួសារអ្នកមាន ត្រូវបានគេរឹបអូសយកទ្រព្យសម្បត្តិអស់ដោយសារមិនព្រមទទួលសាសនារបស់គេ។ ទោះបីជាគ្រីស្ទានទាំងនោះ បានទទួលការបៀតបៀនយ៉ាងណាក៏ដោយ ក៏គេមិនព្រមអោយជំហររបស់គេចុះទាបនោះឡើយ គេបានរក្សាសាសនារបស់គេអោយបរិសុទ្ធ ខ្ញុំបានឃើញថា សាតាំងបានរីករាយជាខ្លាំងចំពោះការរងទុក្ខវេទនានៃរាស្ត្ររបស់ព្រះ។ ប៉ុន្តែព្រះបានទទួលយកទុក្ករបុគ្គលដ៏ស្មោះត្រង់ និងគ្រីស្ទានដែលរងទុក្ខដោយសារទ្រង់។ រាល់ការឈឺចាប់ដែលគេបានរងទ្រាំ បានបង្កើនរង្វាន់របស់គេនៅស្ថានសួគ៌។ ប៉ុន្តែទោះបីជាសាតាំងរីករាយដោយពួកបរិសុទ្ធបានរងទុក្ខក៏ដោយ ក៏វានៅតែមិនស្កប់ចិត្តដែរ។ វាបានចង់គ្រប់គ្រងទាំងគំនិត ទាំងរាងកាយរបស់គេ។ សាតាំងចង់ដឹកនាំគេអោយធ្វើផ្ទុយពីព្រះហឫទ័យរបស់ព្រះនោះ គេនឹងបាត់បង់កម្លាំងចិត្តការអត់ធ្មត់ និងភាពរឹងមាំរបស់គេ។ ការឈឺចាប់ដែលគ្រីស្ទានបានរងទ្រាំបានទាញគេអោយកាន់តែជិតព្រះអម្ចាស់និងធ្វើអោយគេកាន់តែស្រឡាញ់គ្នានិងកោតខ្លាចដល់ទ្រង់ច្រើនជាងអ្នកដែលប្រឆាំងនឹងគេ។ ទោះបីជាពួកគេបានសម្លាប់រាប់ពាន់នាក់ក៏ដោយ ក៏ពួកគេបានកើតឡើងកាន់តែច្រើនឡើងដូចផ្សិត។ សាតាំងបានឃើញថាវាបានបាត់បង់គោលបំណងរបស់វាហើយ ហើយទោះបីជាការបៀតបៀន មានការរងទុក្ខនិងស្លាប់ក៏ដោយ ក៏ពួកគេនៅតែមានជំនឿលើព្រះគ្រីស្ទជារាស្ត្រនៃនគររបស់ទ្រង់ដដែល ហើយ



សាតាំងវាបានរៀបចំផែនការកាន់តែខ្លាំងឡើងដើម្បីប្រឆាំងនឹងការគ្រប់គ្រងរបស់ព្រះនិងកំចាត់ពួកជំនុំ។ វាបានដឹកនាំពួកមិនជឿដែលថ្វាយបង្គំរូបព្រះអោយកាន់យកជំ-នឿរបស់គ្រីស្ទានមួយផ្នែក។ ពួកគេបានប្រកាសថា គេជឿការជាប់ឆ្កាងនិងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទដោយមិនបានកែប្រែចិត្តឡើយ ហើយតម្រូវអោយចូលរួបរួមជាមួយនឹងពួកអ្នក ដែលដើរតាមព្រះយេស៊ូវ។ ឱ នេះជាគ្រោះថ្នាក់ដ៏គួរឱ្យភ័យខ្លាចរបស់ពួកជំនុំ! វាគឺជាពេលនៃការទង្គិះចិត្តខាងផ្លូវគំនិត។ អ្នកខ្លះបានគិតថា ប្រសិនបើគេបន្ទាបមករួបរួមជាមួយអ្នកថ្វាយបង្គំរូបព្រះ ដែលទទួលជំនឿរបស់គ្រីស្ទានមួយចំណែកវាជាមធ្យោបាយមួយនៃការកែប្រែចិត្តរបស់គេ។ សាតាំងបានស្វះស្វែងធ្វើឱ្យខូចគោលលទ្ធិនៃព្រះគម្ពីរ។ ទីបំផុត ខ្ញុំបានឃើញខ្នាតគំរូ (ស្តង់ដា) បានធ្លាក់ចុះ ហើយពួកមិនជឿបានរួបរួមជាមួយនឹងគ្រីស្ទាន។ គេធ្លាប់ថ្វាយបង្គំរូបព្រះ ហើយទោះបីជាគេអះអាងថា គេជាគ្រីស្ទានក៏ដោយ គេបាននាំមកជាមួយគេនូវការថ្វាយបង្គំរូបព្រះរបស់គេ។ គេគ្រាន់តែផ្លាស់ប្តូរនូវគោលបំណងនៃការថ្វាយបង្គំរបស់គេទៅជាថ្វាយបង្គំរូបអ្នកបរិសុទ្ធវិញប៉ុណ្ណោះ ហើយរហូតដល់ជារូបរបស់ព្រះគ្រីស្ទនិងរូបនាងម៉ារីជាមាតាព្រះ-យេស៊ូវទៀតផង។ គ្រីស្ទានក៏បានរួបរួមជាមួយពួកគេបន្តិចម្តងៗ ហើយសាសនារបស់គ្រីស្ទានក៏ត្រូវបានគេកែប្រែ ហើយពួកជំនុំក៏បានបាត់បង់ភាពបរិសុទ្ធ និងអំណាចរបស់ខ្លួន។ គ្រីស្ទានមិនយល់ព្រមរួបរួមជាមួយពួកគេទេ ហើយនៅតែថែរក្សាភាពបរិសុទ្ធរបស់ខ្លួននិងថ្វាយបង្គំព្រះអម្ចាស់តែមួយអង្គគត់។ ពួកគេមិនបានក្រាបថ្វាយបង្គំរូបណាដូចជាអ្វីនៅស្ថានសួគ៌ខាងលើ ឬនៅផែនដីខាងក្រោមឡើយ។

សាតាំងបានរីករាយនឹងការធ្លាក់ចុះរបស់មនុស្សជាច្រើន ហើយបន្ទាប់មកវាបានបំផុសពួកជំនុំដែលធ្លាក់ចុះឱ្យបង្ខំអ្នក ដែលរក្សាភាពបរិសុទ្ធនៃសាសនារបស់ខ្លួនឱ្យទទួលយកពិធីផ្សេងៗរបស់គេ និងថ្វាយបង្គំរូបសំណាកឬក៏សម្លាប់ពួកគេបង់។ ភ្លើងនៃ

ការបៀតបៀនត្រូវបានគេបង្កាត់ឡើងម្តងទៀតប្រឆាំងនឹងពួកជំនុំពិតរបស់ព្រះយេស៊ូ-គ្រីស្ទ ហើយមនុស្សរាប់លាននាក់ ត្រូវបានគេសម្លាប់ដោយគ្មានមេត្តា។

គេបានបង្ហាញនៅពីមុខខ្ញុំ នៅក្នុងរបៀបដូចខាងក្រោមនេះៈ ពួកមិនជឿដែលថ្វាយបង្គំព្រះមួយក្រុមធំបានកាន់បដាខ្មៅធំ មួយដែលមានរូបព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយ។ ក្រុមនោះហាក់ដូចជាពុះពោរដោយកំហឹង។ បន្ទាប់មកគេបានបង្ហាញខ្ញុំនូវក្រុមមួយទៀត ដែលមានកាន់បដាបរិសុទ្ធមួយដែលមានសរសេរថា បរិសុទ្ធនិងបរិសុទ្ធដល់ព្រះអម្ចាស់។ ទឹកមុខរបស់គេបង្ហាញភាពមាំមួននិងភាពនៃការអត់ទ្រាំនៃស្ថានសួគ៌។ ខ្ញុំបានឃើញពួកមិនជឿដែលថ្វាយបង្គំរូបព្រះ បានទៅរកគេ ហើយមានការសម្លាប់យ៉ាងធំ។ ពួកគ្រីស្ទានបានថយចេញឆ្ងាយពីពួកគេ ហើយពួកគ្រីស្ទានក៏នៅតែរួបរួមគ្នាយ៉ាងជិតស្និទ្ធនិងកាន់បដាកាន់តែណែន។ នៅពេលមានមនុស្សបានដួលជាច្រើន អ្នកផ្សេងទៀតបានប្រមូលផ្តុំគ្នានៅជុំវិញបដា ជំនួសពួកគេឡើងវិញ។

ខ្ញុំបានឃើញក្រុមអ្នកថ្វាយបង្គំរូបព្រះបានពិភាក្សាគ្នា។ គេមិនអាចធ្វើអោយគ្រីស្ទានធ្វើតាមគេឡើយ ហើយគេក៏បានព្រមព្រៀងគ្នាលើផែនការថ្មីមួយទៀត។ ខ្ញុំបានឃើញគេទម្លាក់បដាចុះ ហើយបានចូលទៅឯក្រុមគ្រីស្ទានដ៏រឹងមាំនោះ និងបានធ្វើសេចក្តីស្នើមួយចំនួនដល់ពួកគេ។ ដំបូងឡើយសេចក្តីស្នើរបស់ពួកគេត្រូវបានបដិសេធ។ បន្ទាប់មក ខ្ញុំបានឃើញក្រុមគ្រីស្ទានបានពិភាក្សាគ្នា។ អ្នកខ្លះនិយាយថា គេគួរតែទម្លាក់បដាចុះ ហើយទទួលសំណើរទាំងនោះ ដើម្បីសង្គ្រោះជីវិតគេ រួចដល់ចុងបំផុតគេនឹងប្រមូលកម្លាំងគេឡើងវិញ ដើម្បីលើកបដានៅចំពោះអ្នកមិនជឿ ដែលថ្វាយបង្គំរូបព្រះ។ ប៉ុន្តែ ខ្លះមិនយល់ព្រមនឹងផែនការនេះឡើយ ហើយសុខចិត្តស្លាប់នៅតែកាន់បដាយ៉ាងមាំដដែលជាជាងទម្លាក់វាចុះ។ ពេលនោះ ខ្ញុំបានឃើញមនុស្សជាច្រើននៃក្រុមគ្រីស្ទាននោះបានទម្លាក់បដាចុះ ហើយរួបរួមជាមួយអ្នកមិនជឿដែលថ្វាយបង្គំរូបព្រះនៅពេល



ដែលក្រុមគ្រីស្ទានដាច់ខាតបានចាប់បដា ហើយលើកអោយខ្ពស់ឡើងវិញ។ ខ្ញុំបានឃើញមនុស្សបានចាកចេញពីក្រុមអ្នកកាន់បដាបរិសុទ្ធម្នាក់ម្តងៗជាបន្តបន្ទាប់ ហើយទៅចូលរួមជាមួយនឹងក្រុមថ្វាយបង្គំរូបព្រះ ហើយគេបានរួបរួមជាមួយគ្នានៅក្រោមបដាខ្មៅដើម្បីបៀតបៀនដល់អ្នកដែលកាន់បដា ហើយមានមនុស្សជាច្រើនត្រូវបានគេសម្លាប់ ប៉ុន្តែបដាត្រូវបានគេលើកឡើងយ៉ាងខ្ពស់ ហើយមនុស្សម្នាក់ៗត្រូវបានលើកឡើងយ៉ាងមានរបៀបរៀបរយនៅជុំវិញបដានោះ។

ពួកយូដាដែលដំបូងឡើយខឹងនឹងពួកអ្នកមិនជឿប្រឆាំងនឹងព្រះយេស៊ូវ មិនអាចគេចផុតឡើយ។ នៅក្នុងបន្ទប់កាត់ក្តី ពួកយូដាដែលមានកំហឹងនេះចូលបានស្រែកឡើងនៅពេលដែលលោកពីឡាត់កំពុងស្ទាក់ស្ទើរក្នុងការកាត់ទោសដល់ព្រះយេស៊ូវនោះថា ចូរអោយឈាមវាធ្លាក់មកលើយើងនិងកូនចៅរបស់យើងចុះ។ ពូជរបស់សាសន៍យូដាបានទទួលបណ្តាសាដ៏អាក្រក់នេះនៅលើក្បាលរបស់គេ។ ពួកមិនជឿនិងពួកដែលអះអាងថាគ្រីស្ទាននោះ គឺជាសត្រូវរបស់គេដូចគ្នា។ អ្នកដែលបានអះអាងថាជាគ្រីស្ទានដោយពួកយូដាបានឆ្កាងព្រះគ្រីស្ទបានគិតថា គេទទួលរងទុក្ខកាន់តែខ្លាំង គេកាន់តែធ្វើអោយព្រះសព្វព្រះហឫទ័យខ្លាំងឡើង ហើយពួកយូដាដែលមិនជឿជាច្រើនត្រូវបានគេសម្លាប់នៅពេលពួកយូដាដទៃទៀតត្រូវបានគេនាំពីកន្លែងមួយទៅកន្លែងមួយ ហើយត្រូវបានគេធ្វើទារុណកម្មគ្រប់បែបយ៉ាងដោយសារឥទ្ធិពលនៃឈើឆ្កាងរបស់ព្រះគ្រីស្ទ។

ព្រះលោហិតរបស់ព្រះគ្រីស្ទនិងឈាមរបស់ពួកសិស្សដែលគេបានសម្លាប់ នឹងធ្លាក់មកលើគេ ហើយគេនឹងទទួលការជំនុំជំរះយ៉ាងរន្ធត់។ បណ្តាសារបស់ព្រះបានធ្លាក់មកលើពួកគេ ហើយពួកគេបានប្រមាថដល់ពួកមិនជឿនិងពួកគ្រីស្ទាន។ ពួកគេបានត្រូវបណ្តេញចេញ បានដកមុខដំណែង និងបានត្រូវគេស្អប់ខ្ពើមនៅពេលដែលគំនិតរបស់កាអ៊ីននៅលើគេ។ ខ្ញុំបានឃើញថា ព្រះបានថែរក្សាប្រជាជននេះយ៉ាងមាំមួន ហើយបាន

បំបែកគេពាសពេញពិភពលោកដែលគេមើលឃើញថា ពួកគេបានទទួលបណ្តាសាពិសេសពីព្រះ។ ខ្ញុំបានឃើញថា ព្រះបានបំបែកសាសន៍យូដាជាសាសន៍មួយចេញ តែនៅតែមានពួកខ្លះអាចដកចិត្តគេចេញពីអារក្សដែរ។ អ្នកខ្លះនឹងឃើញថា បទទំនាយដែលទាក់ទងនឹងពួកគេបានសំរេចហើយ ហើយគេបានទទួលព្រះយេស៊ូវ ជាព្រះអង្គសង្គ្រោះនៃលោកីយ៍និងបានឃើញអំពើបាបយ៉ាងធំនៅក្នុងសាសន៍របស់គេដោយបានបដិសេធព្រះយេស៊ូវនិងបានឆ្កាងទ្រង់។ មានពួកយូដាជាច្រើនបានកែប្រែចិត្ត ប៉ុន្តែសាសន៍យូដាទាំងមូល គេបានបដិសេធព្រះជារៀងរហូត។

ជំពូកទី១៨

## អាថ៌កំបាំងនៃភាពទុច្ចរិត

សាតាំងធ្លាប់មានបំណងអូសទាញគំនិតរបស់មនុស្សអោយចេញពីព្រះយេស៊ូវមកឯមនុស្សវិញ ។និងបំផ្លាញការទទួលខុសត្រូវរបស់គេម្នាក់ៗ។ គោលបំណងរបស់សាតាំងបានបរាជ័យនៅពេលដែលវាល្បួងព្រះរាជបុត្រានៃព្រះ។ វាបានទទួលជោគជ័យល្អនៅពេលដែលវាមកឯមនុស្សដែលបានធ្លាក់ចុះ។ គោលលទ្ធិនៃគ្រីស្ទសាសនាត្រូវបានកែប្រែ។ ប៉ាបនិងពួកសង្ឃហ៊ានលើកដំកើងមុខដំណែងរបស់គេ និងបានបង្រៀនមនុស្សអោយមើលមកឯពួកគេ ដើម្បីការអត់អោនទោសអោយពួកគេ ជាជាងសំឡឹងទៅឯព្រះគ្រីស្ទដើម្បីអត់ទោសដល់ពួកគេ។ ព្រះគម្ពីរត្រូវបានទុកសំរាប់តែពួកគេដើម្បីលាក់សេចក្តីពិតដែលនឹងចោទប្រកាន់ដល់ពួកគេ។

មនុស្សត្រូវបានគេបោកបញ្ឆោតទាំងស្រុង។ ពួកគេត្រូវបានទទួលការបង្រៀនថា ប៉ាបនិងពួកសង្ឃ គឺជាតំណាងព្រះគ្រីស្ទដែលតាមពិត គេជាតំណាងរបស់ពួកសាតាំង



ទេ ហើយនៅពេលដែលមនុស្សក្រាបថ្វាយបង្គំគេនោះ គឺបានក្រាបថ្វាយបង្គំសាតាំងទេ។ មនុស្សបានទាមទាររកព្រះគម្ពីរ ប៉ុន្តែពួកសង្ឃបានពិចារណាថា បើគេអនុញ្ញាតអោយមនុស្សមានព្រះបន្ទូលរបស់ព្រះសំរាប់អានខ្លួនឯង នោះវាជាគ្រោះថ្នាក់ ហើយក្រែងមនុស្សត្រូវបានបំភ្លឺ ហើយអំពើបាបរបស់ពួកគេត្រូវបានបើកសំដែងឡើង។ គេបានបង្រៀនមនុស្សអោយសំឡឹងទៅឯអ្នកបោកបញ្ឆោតទាំងនោះ និងទទួលពាក្យគ្រប់ម៉ាត់ពីពួកគេថា ជាពាក្យដែលមកពីព្រះបន្ទូលរបស់ព្រះ។ ពួកគេបានដាក់អំណាចនោះលើគំនិតពួកគេ ដែលមានតែព្រះមួយអង្គគត់អាចធ្វើបាន ហើយប្រសិនបើអ្នកណាហ៊ានធ្វើតាមជំនឿរបស់ខ្លួន សម្អប់ដែលពួកយូដានិងសាតាំងបានអនុវត្តទៅលើព្រះយេស៊ូវនឹងត្រូវបានគេបង្កឡើងទាស់នឹងពួកគេដែរ ហើយអ្នកដែលនៅក្នុងអំណាចនេះ នឹងស្រេក ឃ្លានរបស់គេ។

គេបានស្អប់ព្រះគម្ពីរ និងខំប្រឹងប្រែងកំចាត់ចេញពីផែនដីនូវព្រះបន្ទូលដ៏ឧត្តមរបស់ព្រះ។ គេបានហាមប្រាមការអានព្រះគម្ពីរដោយធ្វើឱ្យឈឺចាប់ឬសម្លាប់ចោលប្រសិនបើអ្នកណាហ៊ានប្រឆាំងនឹងគេ ហើយគេបានដុតបំផ្លាញនូវច្បាប់ចម្លងព្រះគម្ពីរណាដែលគេបានរកឃើញ។ ប៉ុន្តែខ្ញុំបានឃើញថា ព្រះបានថែរក្សាព្រះបន្ទូលរបស់ទ្រង់យ៉ាងល្អ។ ទ្រង់បានការពារវាជាច្រើនដង ព្រះបន្ទូលរបស់ទ្រង់សល់យ៉ាងតិច ប៉ុន្តែព្រះអម្ចាស់មិនបណ្តោយអោយព្រះបន្ទូលរបស់ទ្រង់បាត់បង់ឡើយ។ នៅសម័យចុងក្រោយព្រះគម្ពីរនឹងត្រូវបានគេបង្កើតអោយមានយ៉ាងច្រើន ដែលគ្រប់គ្រួសារអាចទទួលបាន។ ខ្ញុំបានឃើញថា នៅពេលមានព្រះគម្ពីរតិច វាមានតម្លៃនិងការកំសាន្តចិត្តដល់សាវកព្រះយេស៊ូវដែលត្រូវគេបៀតបៀន។ គេបានអានដ៏ពិសិដ្ឋបំផុត ហើយអ្នកដែលមានឱកាសដ៏មានតម្លៃនេះ មានអារម្មណ៍ថា គេបានសំភាសន៍ជាមួយព្រះរាជបុត្រារបស់ទ្រង់ព្រះយេស៊ូវនិងជាមួយពួកសាវក។ ប៉ុន្តែ ឱកាសដ៏មានព្រះពរនេះ បានបណ្តាល

អោយពួកគេបាត់បង់ជីវិតអស់ជាច្រើន។ គេបានរកឃើញថា ពួកគេត្រូវបានគេទាញចេញពីការអានព្រះគម្ពីរដោយកាប់ចិញ្ច្រាំ ចងភ្ជាប់នឹងបង្គោលសរសរ ឬកាប់សម្លាប់ដោយអត់អាហារនៅក្នុងគុកក្រោមដី។

សាតាំងមិនអាចលាក់ផែនការនៃសេចក្ដីសង្គ្រោះឡើយ។ គេបានឆ្កាងព្រះ-យេស៊ូវ ហើយទ្រង់មានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី។ វាបានប្រាប់ទេវតារបស់វាថា វាអាចធ្វើអោយការសុគត និងការមានព្រះជន្មរស់ឡើងវិញ ឱ្យទៅជាសារប្រយោជន៏របស់វា។ វាចង់អោយអ្នកដែលមានជំនឿលើព្រះយេស៊ូវ ជឿថាច្បាប់ដែលទាក់ទងនឹងយញ្ញបូជា និងការថ្វាយដង្វាយរបស់ពួកយូដាបានចប់ ហើយនៅគ្រាការសុគតរបស់ព្រះគ្រីស្ទ ប្រសិនបើវាអាចជំរុញពួកគេបន្ថែមទៀតថា បញ្ញត្តិដប់ប្រការក៏បានស្លាប់ជាមួយព្រះគ្រីស្ទដែរ។

ខ្ញុំបានឃើញថា មនុស្សជាច្រើនបានទទួលយកការបោកបញ្ឆោតរបស់សាតាំងនេះដោយងាយ។ ស្ថានសួគ៌ទាំងមូលពោរពេញដោយការឈឺចិត្តនៅពេលដែលបានឃើញច្បាប់ដ៏បរិសុទ្ធត្រូវបានគេជាន់ឈ្លីនឹងជើង។ ព្រះយេស៊ូវនិងពពួកទេវតានៃស្ថាន-សួគ៌បានពេញព្រះទ័យនឹងធម្មជាតិនៃច្បាប់របស់ព្រះជាខ្លាំង លោកជ្រាបថាព្រះអង្គនឹងមិនប្តូរឬលុបបំបាត់ច្បាប់នោះឡើយ។ ល័ក្ខខ័ណ្ឌដ៏អស់សង្ឃឹមរបស់មនុស្សបានបណ្ដាលអោយមានការព្រួយបារម្ភយ៉ាងខ្លាំងបំផុតនៅស្ថានសួគ៌និងជំរុញអោយព្រះយេស៊ូវលះ-បង់ព្រះជន្មសំរាប់អ្នកដែលល្មើសនឹងច្បាប់ដ៏បរិសុទ្ធរបស់ព្រះ។ ប្រសិនបើច្បាប់របស់ទ្រង់គេអាចផ្លាស់ប្តូរបាន នោះមនុស្សនឹងអាចបានសង្គ្រោះដោយមិនចាំបាច់ព្រះយេ-ស៊ូវសុគតឡើយ។ ការសុគតរបស់ព្រះគ្រីស្ទមិនបានបំផ្លាញច្បាប់របស់ព្រះវរបិតាទ្រង់ឡើយ។ ប៉ុន្តែជាការលើកដំកើងច្បាប់នោះនិងជំរុញអោយអនុវត្តតាមគំនិតសំខាន់ៗទាំងអស់វិញ។ បើពួកជំនុំរក្សាភាពបរិសុទ្ធនិងរឹងមាំខ្ជាប់ខ្ជួន សាតាំងមិនអាចបញ្ឆោត



គេនិងនាំគេអោយជាន់ឈ្លីច្បាប់របស់ព្រះបានឡើយ។ នៅក្នុងផែនការដ៏ធំនេះ សាតាំងបានវាយប្រហារយ៉ាងចំទៅលើគ្រឹះនៃនគររបស់ព្រះនៅស្ថានសួគ៌និងនៅផែនដី។ ការប្រឆាំងរបស់វាបណ្ដាលអោយព្រះទម្លាក់វាមកពីស្ថានសួគ៌។ ដើម្បីសង្គ្រោះខ្លួនវាបន្ទាប់ពីវាបះបោរមក វាបានសុំអោយព្រះផ្លាស់ប្តូរច្បាប់របស់ទ្រង់ ប៉ុន្តែព្រះបានប្រាប់សាតាំងនៅចំពោះទេវតាទាំងអស់ថា បើវាអាចធ្វើអោយអ្នកណាម្នាក់បំពានច្បាប់របស់ព្រះ វាទុកចិត្តអ្នកនោះជាខ្លាំងព្រោះថាអ្នកណាដែលរំលោភច្បាប់របស់ព្រះ អ្នកនោះត្រូវតែស្លាប់ជាមិនខាន។

សាតាំងបានសំរេចចិត្តថានឹងធ្វើដំណើរបន្តទៅទៀត។ វាបានប្រាប់ទេវតារបស់វាថា មានមនុស្សខ្លះមានការច្រណែននឹងច្បាប់របស់ព្រះជាខ្លាំងដែលវាមិនអាចទាញចូលក្នុងអន្ទាក់របស់វាបានឡើយ ច្បាស់លាស់ណាស់ដែលមនុស្សជាច្រើននឹងជឿថាគេកំពុងជាប់ចំណងនៃបញ្ញត្តិដប់ប្រការ ហេតុដូច្នេះហើយ វាត្រូវតែស្វែងរកវិធីធ្វើអោយអាប់ឱនដល់បញ្ញត្តិទីបួនដែលនាំអោយឃើញព្រះដ៏មានព្រះជន្មរស់។ វាបាននាំដំណាងរបស់វាអោយផ្លាស់ប្តូរថ្ងៃបរិសុទ្ធ និងកែប្រែបញ្ញត្តិតែមួយគត់នាំអោយឃើញព្រះពិតនៃបញ្ញត្តិទាំងដប់ ជាសញ្ញានៃស្ថានសួគ៌និងផែនដី។ សាតាំងបានបង្ហាញដល់ពួកគេនូវការមានព្រះជន្មរស់ឡើងវិញដ៏មានព្រះចេស្ដារបស់ព្រះយេស៊ូវ ហើយបានប្រាប់គេថាទ្រង់បានមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីមួយនៃសប្ដាហ៍ វាបានផ្លាស់ប្តូរថ្ងៃបរិសុទ្ធពីថ្ងៃទីប្រាំពីរទៅថ្ងៃទីមួយនៃសប្ដាហ៍វិញ។ ធ្វើដូច្នេះសាតាំងបានប្រើការមានព្រះជន្មរស់ឡើងវិញដើម្បីបំរើគោលបំណងរបស់វា។ វានិងទេវតារបស់វាសប្បាយចិត្តជាខ្លាំងដោយការខុសឆ្គងដែលវាបានរៀបចំ ត្រូវបានអ្នកដែលអះអាងថា ជាមិត្តរបស់ព្រះគ្រីស្ទទទួលយកយ៉ាងស្រួល។ មួយក្រុមពិនិត្យឃើញការខុសឆ្គងនៃសាសនាមួយក្រុមទៀត ការខុសឆ្គងផ្សេងៗត្រូវបានគេទទួលនិងត្រូវបានគេការពារយ៉ាងប្រុងប្រយ័ត្ន។ ព្រះទ័យ

របស់ព្រះបានបង្ហាញនូវក្នុងព្រះបន្ទូលរបស់ទ្រង់យ៉ាងច្បាស់ ត្រូវបានគេគ្របបាំងដោយការខុសឆ្គង និងប្រពៃណីដែលត្រូវបានគេបង្រៀនថា ជាបញ្ញត្តិរបស់ព្រះ។ ប៉ុន្តែទោះបីជាការបោកបញ្ឆោតដ៏ក្លាហាននៃស្ថានសួគ៌ត្រូវទទួលការឈឺចាប់រហូតដល់គ្រាដែលព្រះយេស៊ូវបង្ហាញអង្គទ្រង់ជាលើកទីពីរក៏ដោយ ក៏ក្នុងពេលនៃការខុសឆ្គង និងបោកបញ្ឆោតទាំងនេះ ក៏ព្រះអម្ចាស់មិនបានចាកចេញដោយគ្មានទីបន្ទាល់ដែរ។ មានស្មរបន្ទាល់ដ៏ស្មោះត្រង់ ដែលរក្សាបញ្ញត្តិទាំងអស់ ក្នុងកំឡុងពេលខ្មៅងងឹត និងការបៀត-បៀនរបស់ពួកជំនុំឡើយ។

ខ្ញុំបានឃើញថា ទេវតាបានពេញដោយការភ្ញាក់ផ្អើលនៅពេលដែលលោកបានឃើញការរងទុក្ខនិងការសុគតរបស់ព្រះមហាក្សត្រនៃសិរីល្អ។ ប៉ុន្តែខ្ញុំបានឃើញថា គ្មានអ្វីអស្ចារ្យដល់ទេវតានៅស្ថានសួគ៌ឡើយ ដែលព្រះអម្ចាស់នៃជីវិតនៃសិរីល្អ ដែលបំពេញស្ថានសួគ៌ដោយអំណារ និងភាពរុងរឿង និងបំបាក់ច្រវាក់នៃសេចក្តីស្លាប់ និងក្រោកចេញពីផ្នូរជាអ្នកឈ្នះដ៏មានជោគជ័យនោះឡើយ។ ហើយប្រសិនបើព្រឹត្តិការណ៍ទាំងនេះនឹងត្រូវបានរំលឹកដោយថ្ងៃឈប់សំរាក វាគឺជាការជាប់ឆ្កាង ប៉ុន្តែខ្ញុំបានឃើញថាទោះបីជាព្រឹត្តការណ៍ទាំងនេះត្រូវបានរៀបចំឡើងអោយកែប្រែឬលុបចោលច្បាប់ព្រះក៏ដោយ ក៏ទ្រង់ប្រទានភស្តុតាងដ៏ខ្លាំងបំផុត មិនអាចរលុបរលាយឡើយ។

ព្រឹត្តិការណ៍ទាំងពីរនេះមានអនុស្សាវរីយ៍ដល់គេ។ ដោយចូលរួមក្នុងពិធីបុណ្យលៀងព្រះអម្ចាស់ បុណ្យកាច់នំប៉័ង និងទឹកទំពាំងបាយជូរ យើងបង្ហាញពីការសុគតរបស់ព្រះអម្ចាស់រហូតទ្រង់យាងមកវិញ។ ដោយរក្សាអនុស្សាវរីយ៍នេះ ទស្សនីយភាពនៃការរងទុក្ខ និងការសុគតរបស់ទ្រង់ នៅថ្មី១ជានិច្ចក្នុងគំនិតយើង។ ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទត្រូវបានរំឭកឡើងវិញដោយការកប់ជាមួយទ្រង់ដោយការជ្រមុជទឹក និងងើបឡើងវិញពីផ្នូរនៃទឹកដូចជាការមានព្រះជន្មរស់របស់ទ្រង់ ដើម្បីរស់



ឡើងវិញនៃជីវិតថ្មីស្រឡាងដែរ។

គេបានបង្ហាញខ្ញុំថាច្បាប់របស់ព្រះបិតថេរនៅអស់កល្ប ហើយមាននៅផែនដីថ្មីរហូតដល់បំផុតកល្ប។ នៅគ្រាបង្កបង្កើតលោកីយ៍ នៅពេលដែលគ្រឹះនៃផែនដីបានរៀបចំឡើង ព្រះរាជបុត្រានៃព្រះ បានទតដោយការកោតសរសើរទៅលើការងារបង្កបង្កើត ហើយទេវតានៅស្ថានសួគ៌ទាំងអស់ ស្រែកឡើងដោយអំណរ។ នៅពេលនោះ គ្រឹះនៃថ្ងៃបរិសុទ្ធក៏បានរៀបចំឡើងដែរ។ នៅគ្រាបញ្ចប់ថ្ងៃទីប្រាំមួយនៃថ្ងៃបង្កបង្កើត ព្រះបានឈប់សំរាកពីគ្រប់ការដែលទ្រង់បានធ្វើនៅថ្ងៃទីប្រាំពីរ។ ថ្ងៃបរិសុទ្ធត្រូវបានដាក់នៅសួនច្បារអេដែន មុនមនុស្សធ្លាក់ចុះ និងត្រូវបានគោរពដោយអ័ដាមនិងអេវ៉ា និងទេវតានៃស្ថានសួគ៌ទាំងអស់។ ព្រះអម្ចាស់បានសំរាកនៅថ្ងៃទីប្រាំពីរ ហើយបានប្រទានពរនិងសរសើរថ្ងៃនោះ ហើយខ្ញុំបានឃើញថា ថ្ងៃបរិសុទ្ធនឹងមិនត្រូវបានគេដកចេញឡើយ ប៉ុន្តែពួកបរិសុទ្ធដែលបានសង្គ្រោះនិងទេវតាទាំងអស់ នឹងគោរពថ្ងៃនោះដោយលើកដំកើងព្រះអាទិករដ៏ឧត្តមដរាបអស់កល្ប។

សូមអាន ដានីយ៉ែល ជំពូកទី ៧ ថែស្សាឡូនីចទី២ ជំពូកទី២។

ជំពូកទី១៩

## សេចក្តីស្លាប់មិនមែនជាជីវិតអស់កល្ប ក្នុងសេចក្តីវេទនាទេ

សាតាំងបានចាប់ផ្តើមការបោកបញ្ឆោតរបស់វានៅឯសួនច្បារអេដែន។ វាបាននិយាយទៅកាន់នាងអេវ៉ាថានាងនឹងមិនស្លាប់ជាពិតមែន។ នេះគឺជាមេរៀនទីមួយរបស់សាតាំងមកលើភាពមិនស្លាប់របស់មនុស្ស ហើយវាបានបន្តការបោកបញ្ឆោតនេះរហូតមកដល់សព្វថ្ងៃ និងបន្តរហូតដល់សម័យដែលកូនព្រះត្រូវបានបង្វែរទៅក្នុង

ទាសភាពដែរ។ គេបានចង្អុលបង្ហាញខ្ញុំនូវអ័ដាមនិងអេវ៉ានៅក្នុងសួនច្បារអេដែន។ គេបានចូលទៅជិតដើមឈើដែលព្រះបានហាមឃាត់ ហើយពេលនោះ មានដាវជាអណ្តាតភ្លើងបានដាក់នៅជុំវិញដើមជីវិត ហើយមានគេនាំគាត់ចេញពីសួនច្បារអេដែន ក្រែងគាត់បេះផ្លែនៃដើមជីវិត ហើយក្លាយជាអ្នកមានបាបមិនស្លាប់ជារៀងរហូត។ ដើមជីវិតគឺមិនត្រូវស្លាប់ឡើយ។ ខ្ញុំបានឮសំឡេងទេវតាមួយអង្គសួរថា តើអ្នកណាមួយនៃគ្រួសារអ័ដាមនឹងត្រូវដើរកាត់ដាវនៃអណ្តាតភ្លើងនោះទៅឯដើមជីវិត។ ខ្ញុំបានឮទេវតាមួយទៀតឆ្លើយថា គ្មានអ្នកណាម្នាក់ក្នុងគ្រួសារអ័ដាមបានឆ្លងកាត់ដាវនៃអណ្តាតភ្លើងនិងចូលរួមនឹងដើមនោះឡើយ ដ្បិតគ្មានអ្នកមានបាបដែលមិនស្លាប់ឡើយ។ ព្រលឹងដែលមានបាប វាត្រូវតែស្លាប់ ដោយការស្លាប់ដ៏អស់កល្ប ជាសេចក្តីស្លាប់ដែលឋិតនៅរៀងរហូតដែលគ្មានសេចក្តីសង្ឃឹមនៃការរស់ឡើងវិញឡើយ ហើយពេលនោះ សេចក្តីក្រោធរបស់ព្រះនឹងត្រូវបានស្រាកស្រាន្ត។

វាជាការអស្ចារ្យណាស់ដល់ខ្ញុំ ដែលសាតាំងមានជោគជ័យយ៉ាងល្អក្នុងការធ្វើអោយមនុស្សជឿថា ព្រះបន្ទូលរបស់ព្រះបានថែងថា មនុស្សដែលមានបាបត្រូវតែស្លាប់ប្រែទៅជាមនុស្សដែលមានបាបនឹងមិនស្លាប់ទេ ប៉ុន្តែរស់នៅរៀងរហូតក្នុងការវេទនានោះ។ ទេវតាបានមានបន្ទូលថា ជីវិតគឺជីវិត ទោះបីជាឈឺចាប់ឬសប្បាយក៏ដោយ។ ស្លាប់គឺគ្មានការឈឺចាប់ គ្មានអំណរ គ្មានសម្អប់។ សាតាំងបានប្រាប់ដល់ទេវតារបស់វាអោយខំប្រឹងប្រែងអោយខ្លាំងដើម្បីផ្សព្វផ្សាយការបោកបញ្ឆោតនិងភូតកុហក ដូចដែលវាបាននិយាយទៅកាន់អេវ៉ាដំបូងនៅក្នុងសួនច្បារអេដែនថានាងមិនស្លាប់ជាពិតមែន។ ហើយនៅពេលដែលមនុស្សចាញ់បោកការបញ្ឆោតនោះ ហើយជឿថាមនុស្សមិនស្លាប់ទេ សាតាំងបានដឹកនាំគេអោយជឿតទៅទៀតថា មនុស្សនឹងរស់នៅដោយវេទនាជារៀងរហូត។ ហើយផ្លូវត្រូវបានរៀបចំសំរាប់សាតាំងដើម្បីធ្វើការតាមរយៈតំណាងរបស់



វា ហើយបង្ហាញនៅចំពោះមនុស្សថា ព្រះជាអ្នកប្រើអំណាចផ្តាច់ការ គួរអោយសងសឹកថាអ្នកណាដែលមិនបានធ្វើអោយទ្រង់សព្វព្រះហឫទ័យ ទ្រង់នឹងទម្លាក់ទៅក្នុងនរក នឹងធ្វើអោយអ្នកទាំងនោះទទួលសេចក្តីក្រោធរបស់ទ្រង់រហូត ហើយថាគេនឹងទទួលរងការឈឺចាប់គ្មានទីបញ្ចប់នៅពេលដែលទ្រង់នឹងទតមើលមកលើពួកគេដោយពេញព្រះទ័យ នៅពេលដែលពួកគេឈឺចុកចាប់នៅក្នុងទុក្ខវេទនានិងភ្លើងដ៏អស់កល្ប។ សាតាំងបានដឹងថា ប្រសិនបើមនុស្សទទួលការខុសឆ្គងនេះ គេនឹងស្អប់ព្រះជាជាងស្រឡាញ់និងកោតសរសើរទ្រង់ ហើយមនុស្សជាច្រើននឹងត្រូវបានដឹកនាំអោយជឿថា ការភ័យខ្លាចព្រះបន្ទូលរបស់ព្រះនឹងមិនត្រឹមត្រូវឡើយ ព្រោះការទម្លាក់មនុស្សដែលទ្រង់បានបង្កើតទៅក្នុងការឈឺចាប់អស់កល្ប វាផ្ទុយនឹងលក្ខណៈនៃសេចក្តីប្រណីសន្តោស និងសេចក្តីស្រឡាញ់របស់ទ្រង់។ សាតាំងបានដឹកនាំគេទៅកាន់ចំណុចខ្លាំងក្លាមួយទៀត ឱ្យមើលមិនឃើញសេចក្តីយុត្តិធម៌របស់ព្រះទាំងស្រុង និងការបំភ័យក្នុងព្រះបន្ទូលរបស់ទ្រង់និងតំណាងអោយទ្រង់ជាសេចក្តីមេត្តាករុណា និងថា នឹងគ្មានអ្នកណាត្រូវវិនាសឡើយ តែទាំងពួកបរិសុទ្ធ និងអ្នកមានបាប នឹងត្រូវបានសង្គ្រោះនៅក្នុងនគររបស់វា។ ជាលទ្ធផលនៃការខុសឆ្គងដ៏មានប្រជាប្រិយនៃការមិនស្លាប់របស់ព្រលឹងមនុស្សនិងការរងទុក្ខវេទនាដ៏គ្មានទីបញ្ចប់នេះ សាតាំងមានប្រៀបមួយក៏រិតទៀត ហើយដឹកនាំគេអោយយល់ថាព្រះគម្ពីរគឺជាសៀវភៅដែលមិនមានការបណ្តាលចិត្តអោយសរសេរទេ។ គេគិតថាព្រះគម្ពីរបង្រៀនរឿងល្អជាច្រើន តែរឿងទាំងនោះមិនអាចទីពឹងនិងស្រឡាញ់បានទេ ព្រោះវាបានបង្រៀនថាវាប្រកាសពីគោលលទ្ធិនៃការរងទុក្ខវេទនារហូត។

សាតាំងយកប្រៀបមួយក៏រិតទៀត ហើយដឹកនាំគេបន្តទៅទៀតឱ្យបដិសេធការមានព្រះ។ គេមិនអាចឃើញមានព្រះនៅក្នុងលក្ខណៈព្រះនៃព្រះគម្ពីរឡើយ ប្រសិនបើទ្រង់នឹងធ្វើទារុណកម្មគ្រួសារ មនុស្សមួយចំនួនទៅក្នុងការធ្វើទារុណកម្មយ៉ាងវេទនា

ដ៏អស់កល្បនិងបដិសេធព្រះគម្ពីរនិងអ្នកនិពន្ធព្រះគម្ពីរនិងបដិសេធការស្លាប់ជាការដេកលក់។

បន្ទាប់មកសាតាំងដឹកនាំមនុស្សមួយស្រទាប់ទៀតដែលភ័យខ្លាចនិងកំសាកអោយប្រព្រឹត្តបាប ហើយបន្ទាប់ពីគេមានបាបវាបានបង្ហាញពួកគេថា ឈ្នួលនៃអំពើបាបគឺមិនស្លាប់ទេ ប៉ុន្តែគឺជាជីវិតអស់កល្បក្នុងទារុណកម្មយ៉ាងរន្ធត់ដែលត្រូវរងទ្រាំក្នុងពេលដែលគ្មានទីបញ្ចប់។ សាតាំងបង្កើនឱកាសរបស់វានិងបំផ្លើសនៅមុខគំនិតដ៏ទន់ខ្សោយរបស់គេអំពីការខុសឆ្គងនៃស្ថាននរកដែលគ្មានទីបញ្ចប់ ហើយគ្រប់គ្រងគំនិតពួកគេ ហើយគេក៏បាត់បង់ហេតុផលរបស់គេ។ ពេលនោះសាតាំងនិងទេវតារបស់វាសំដែងសេចក្តីរីករាយយ៉ាងក្រៃលែង ព្រមទាំងរួបរួមជាមួយនឹងមនុស្សដែលមិនជឿសាសនានិងអ្នកមិនជឿថា មានព្រះដែលជាអ្នកជំនុំជំរះនៃគ្រីស្ទសាសនា។ គេយល់ឃើញថាលទ្ធផលនៃការបោកបញ្ឆោតគំនិតដ៏មានប្រជាប្រិយរបស់សាតាំងគឺជាលទ្ធផលធម្មជាតិនៃការជឿលើព្រះគម្ពីរនិងអ្នកនិពន្ធព្រះគម្ពីរ។

ខ្ញុំបានឃើញថា ទេវតានៃស្ថានសួគ៌ត្រូវបានបំពេញដោយការឈឺចិត្ត ដោយព្រោះការងារដ៏អង់អាចរបស់សាតាំង។ ខ្ញុំបានសួរថា តើហេតុអ្វីបានជាសេចក្តីភ័ន្តភាំងទាំងនេះមានអនុភាពលើគំនិតមនុស្សនៅពេលដែលទេវតារបស់ព្រះមានអំណាចនិងថាតើការត្រាស់បង្គាប់អាចបំបែកអំណាចរបស់សត្រូវបានឬទេ? ហើយខ្ញុំបានឃើញថាព្រះបានជ្រាបថា សាតាំងនឹងខំប្រឹងប្រែងគ្រប់ល្បិចកលដើម្បីបំផ្លាញមនុស្ស ហេតុដូច្នេះហើយទ្រង់បានបណ្តាលឱ្យគេសរសេរព្រះបន្ទូលរបស់ទ្រង់និងបានធ្វើផែនការរបស់ទ្រង់ចំពោះមនុស្សយ៉ាងច្បាស់ដែលអ្នកទន់ខ្សោយបំផុតមិនខុសឆ្គងឡើយ។ ហើយបន្ទាប់ពីទ្រង់បានប្រទានព្រះបន្ទូលទ្រង់ដល់មនុស្សមក ទ្រង់បានថែរក្សាព្រះបន្ទូលនោះដោយប្រុងប្រយ័ត្នដើម្បីមិនអោយសាតាំងនិងទេវតារបស់វាតាមរយៈភ្នាក់ងារឬតំណាងរបស់



វាអាចបំផ្លាញបានឡើយ។ នៅពេលដែលសៀវភៅផ្សេងៗទៀតត្រូវបានគេបំផ្លាញ ព្រះគម្ពីរបរិសុទ្ធមិនពុករលួយឡើយ។ ហើយនៅជិតសម័យចុងក្រោយនៅពេលដែលការបំភាន់របស់សាតាំងបានកើនឡើង សៀវភៅនេះបានកើនឡើងយ៉ាងសំបូរសំរាប់អ្នកចង់បានទាំងឡាយ មានការបើកសំដែងនៃព្រះទ័យរបស់ព្រះចំពោះមនុស្ស ប្រសិនបើគេចង់ប្រដាប់កាយរបស់គេទប់ទល់នឹងការបោកបញ្ឆោត និងការកុហកដ៏អស្ចារ្យរបស់សាតាំង។

ខ្ញុំបានឃើញថា ព្រះបានថែរក្សាព្រះគម្ពីរជាពិសេសតែមនុស្សចេះដឹងបានផ្លាស់ប្តូរព្រះបន្ទូលព្រះ នៅពេលខ្លះគ្រាដែលព្រះគម្ពីរមានចំនួនតិចដោយគិតថា ធ្វើអោយវាកាន់តែច្បាស់លាស់ឡើងនៅពេលដែលព្រះបន្ទូលបានធ្វើអោយគេឆ្ងល់ថាតើមួយណាច្បាស់លាស់ ដើម្បីអោយគេរៀនតាមព្រះគម្ពីរ ឬគំនិតដែលគេបង្កើតតាមប្រពៃណីរបស់គេ។

ប៉ុន្តែខ្ញុំបានឃើញថា ព្រះបន្ទូលរបស់ព្រះទាំងមូលជាបណ្តាញយ៉ាងល្អឥតខ្ចោះដែលបទគម្ពីរមួយចំណែកពន្យល់ដល់ចំណែកមួយទៀត។ អ្នកស្វែងរកសេចក្តីពិតមិនចាំបាច់ខុសឡើយ ព្រោះព្រះបន្ទូលរបស់ព្រះមិនគ្រាន់តែច្បាស់ និងងាយស្រួលសំរាប់ប្រកាសផ្លូវទៅជីវិតទេ ប៉ុន្តែព្រះបានប្រទានព្រះវិញ្ញាណបរិសុទ្ធ ដើម្បីដឹកនាំអោយយល់ផ្លូវនៃជីវិតដែលបានបង្ហាញនៅក្នុងព្រះបន្ទូលរបស់ទ្រង់ទៀតផង។

ខ្ញុំបានឃើញសេចក្តីមេត្តាករុណា និងការអាណិតអាសូររបស់ព្រះក្នុងការប្រទានព្រះរាជបុត្រារបស់ទ្រង់ឱ្យមកសុគតសំរាប់មនុស្សមានទោស។ អ្នកដែលជ្រើសរើសមិនទទួលសេចក្តីសង្គ្រោះដែលត្រូវបានចេញថ្លៃលោះដោយស្រឡាញ់ ពួកគេត្រូវតែទទួលទណ្ឌកម្ម។ ជាមនុស្សដែលព្រះបានបង្កើត បានជ្រើសរើសបះបោរប្រឆាំងនឹងនគររបស់ទ្រង់។ ប៉ុន្តែខ្ញុំបានឃើញថា ព្រះមិនបានបិទទ្វារទុកពួកគេនៅក្នុងស្ថាននរកអោយ

ទទួលរងទុក្ខវេទនាគ្មានទីបញ្ចប់ឡើយ។ ទ្រង់មិនអាចយកវាទៅស្ថានសួគ៌ឡើយ ដ្បិតការនាំគេទៅជាមួយនឹងពួកបរិសុទ្ធនឹងធ្វើអោយពួកគេវេទនាយ៉ាងក្រៃលែង។ ព្រះនឹងមិនយកគេទៅស្ថានសួគ៌ឡើយ ឬក៏មិនទុកអោយគេរងទុក្ខរហូតនោះដែរ។ ទ្រង់នឹងបំផ្លាញគេជាពិតប្រាកដនឹងធ្វើអោយពួកគេដូចជាគំនិតដែលគេមិនធ្លាប់គិតរួចទើបសេចក្តីយុត្តិធម៌របស់ទ្រង់នឹងបានស្កប់ព្រះទ័យ។ ទ្រង់បានសូនមនុស្សពីធូលីដី ហើយអ្នកមិនបរិសុទ្ធនឹងមិនស្តាប់បង្គាប់ នឹងឆេះដោយភ្លើង ហើយក៏ក្លាយទៅជាធូលីដីវិញ។ ខ្ញុំបានឃើញថា សេចក្តីមេត្តាករុណា និងការអាណិតអាសូររបស់ព្រះក្នុងរឿងនេះនឹងដឹកនាំគេទាំងអស់គ្នាអោយសរសើរតំកើងទ្រង់និងស្រឡាញ់ទ្រង់ ហើយបន្ទាប់ពីមនុស្សអាក្រក់ត្រូវបានបំផ្លាញចេញពីផែនដីមក ទេវតានៃស្ថានសួគ៌ទាំងអស់នឹងមានបន្ទូលថាអាម៉ែន។

សាតាំងបានមើលដោយពេញចិត្តមកអ្នកដែលអះអាងនូវព្រះនាមរបស់ព្រះគ្រីស្ទ និងបានប្រកាន់ខ្ជាប់ខ្លួននូវការភ័ន្តច្រឡំដែលវាបានបង្កើតឡើង។ ការងាររបស់វាគឺបង្កើតការភ័ន្តច្រឡំថ្មីៗ។ អំណាចរបស់វាកើនឡើង ហើយវាបានបង្កើតកលល្បិចជាច្រើន។ វាបានដឹកនាំអ្នកតំណាងរបស់វា ប៉ាបនិងពួកសង្ឃអោយលើកដំកើងខ្លួនឯងនិងបំផុសបំផុលមនុស្សអោយបៀតបៀនដល់អ្នកដែលស្រឡាញ់ព្រះនិងមិនព្រមទទួលយកការភ័ន្តច្រឡំដែលវាបាននាំមកយ៉ាងជូរចត់។ សាតាំងបានធ្វើការតាមរយៈភ្នាក់ងាររបស់វាដើម្បីបំផ្លាញសិស្សដែលដាច់ខាតជាមួយព្រះយេស៊ូវ។ ឱ គេបានធ្វើអោយពួកជាទីស្រឡាញ់របស់ព្រះរងទុក្ខវេទនានិងឈឺចាប់ជាទីបំផុត។ ទេវតាបានកត់ត្រាការរងទុក្ខនោះយ៉ាងម៉ត់ចត់។ ប៉ុន្តែសាតាំនិងទេវតាអាក្រក់របស់វាបានសំដែងការរីករាយនិងប្រាប់ដល់ទេវតាដែលគ្រប់គ្រងអោយគំរាមដល់ពួកបរិសុទ្ធដែលរងទុក្ខលំបាក វានឹងសម្លាប់ពួកគេដើម្បីនឹងមិនអោយមានគ្រីស្ទានពិតប្រាកដនៅលើផែនដីនេះឡើយ។



ពេលនោះខ្ញុំបានឃើញថា ពួកជំនុំរបស់ព្រះបានបរិសុទ្ធ។ ពេលនោះនឹងគ្មានគ្រោះថ្នាក់ដោយមនុស្សអាក្រក់ដែលមានចិត្តពុករលួយចូលមកពួកជំនុំនៃព្រះឡើយ ដ្បិតគ្រីស្ទានពិតប្រាដកដែលហ៊ានប្រកាសជំនឿរបស់ខ្លួននៅក្នុងគ្រោះថ្នាក់នៃឈើឆ្កាង បង្គោលសរសរ និងទារុណកម្មផ្សេងៗទៀតជាច្រើន ដែលសាតាំងនិងទេវតាអាក្រក់របស់វាបានបង្កើតឡើង និងដាក់ទៅក្នុងគំនិតមនុស្ស។

សូមអាន លោកុប្បត្តិ ជំពូកទី៣ សាស្តា ៩:៥, ១២:៧ លូកា ២១: ៣៣ យ៉ូហាន ៣:១៦ ធីម៉ូថេទី២ ៣:១៦ វិវរណៈ ២០:១៤-១៥ ២១:១, ២២:១២-១៩។

ជំពូកទី២០

## ការកែនម្រង់

តែទោះបីជាមានការបៀតបៀននិងការសម្លាប់ដល់ពួកបរិសុទ្ធយ៉ាងណាក៏ដោយ ក៏ការធ្វើទីបន្ទាល់បានលើកឡើងនៅដៃគ្រប់ៗគ្នាដែរ។ ទេវតារបស់ព្រះបានធ្វើការប្តេជ្ញាចិត្តទៅនឹងសេចក្តីជំនឿរបស់ពួកគេ។ គេបានស្វែងរកនៅក្នុងទីងងឹតនិងបានជ្រើសរើសចេញពីភាពងងឹតនូវមនុស្សដែលមានចិត្តស្មោះត្រង់បំផុត ពួកគេត្រូវបានកប់នៅក្នុងការខុសឆ្គង ប៉ុន្តែព្រះបានជ្រើសរើសពួកគេដូចជាព្រះអង្គបានជ្រើសរើសប៉ុលជាប្រដាប់សំរាប់ប្រកាសពីសេចក្តីពិត និងលើកសំឡេងពួកគេឡើងប្រឆាំងនឹងអំពើបាបរបស់អ្នកជឿទ្រង់។ ទេវតារបស់ព្រះបានបណ្តាលចិត្តលោកម៉ាទីនលូទើ លោកមេឡា-តុននិងមនុស្សដទៃនៅកន្លែងផ្សេងៗទៀតអោយស្រេកឃ្លានទីបន្ទាល់រស់នៃព្រះបន្ទូលរបស់ព្រះ។ ពួកខ្មាំងសត្រូវបានមកដូចជាទឹកជំនន់ហើយស្តង់ដាតែងលើកឡើងទាស់នឹង

វា។ លោកលូទើរត្រូវបានជ្រើសរើសឡើងអោយពុះពារនិងក្រោកឈរប្រឆាំងនឹងពួកជំនុំដែលធ្លាក់ចុះនិងពង្រឹងដល់អ្នកស្មោះត្រង់មួយចំនួនតូចអោយស្មោះត្រង់ទៅនឹងជំនឿដ៏បរិសុទ្ធរបស់គេ។ គាត់ធ្លាប់ភ័យខ្លាចព្រះមិនសព្វព្រះហឫទ័យ។ គាត់បានខំប្រឹងប្រែងតាមរយៈការងារដើម្បីអោយព្រះសព្វព្រះហឫទ័យ ប៉ុន្តែព្រះមិនបានសព្វព្រះ-ហឫទ័យនឹងគាត់ឡើយរហូតទាល់តែមានពន្លឺមកពីស្ថានសួគ៌កំចាត់ភាពងងឹតនៅក្នុងគំនិតគាត់ហើយដឹកនាំគាត់កុំអោយទុកចិត្តលើការងារ ប៉ុន្តែលើគុណសម្បត្តិនៃលោហិតរបស់ព្រះគ្រីស្ទនិងអោយចូលមកឯព្រះផ្ទាល់វិញ មិនមែនតាមប៉ាប ឬតាមអ្នកលន់តួជំនួសឡើយ ប៉ុន្តែតាមរយៈព្រះយេស៊ូវតែមួយអង្គគត់វិញ។ អូ! នេះគឺជាចំណេះដឹងដ៏មានតម្លៃសំរាប់លូទើរ គាត់បានអោយតម្លៃដល់ដំណឹង និងពន្លឺដ៏មានតម្លៃនេះដែលបានរះឡើងក្នុងការយល់ដឹងដ៏ងងឹតរបស់គាត់ និងបានបណ្តេញចេញនូវជំនឿឆ្វេងរបស់គាត់ខ្ពស់ជាងសម្បត្តិដ៏មានតម្លៃបំផុត នៅលើលោកីយ៏នេះ។ ព្រះបន្ទូលរបស់ព្រះថ្មីឡើងៗ។ អ្វីៗទាំងអស់ត្រូវបានផ្លាស់ប្តូរ។ សៀវភៅដែលគាត់មិនចូលចិត្តគិតដល់ព្រោះមិនបានឃើញអ្វីល្អនៅក្នុងនោះ គឺជាជីវិតសំរាប់គាត់ វាជាអំណររបស់គាត់ជាអ្នកអោយយោ-បល់ដល់គាត់និងជាគ្រូដ៏មានពររបស់គាត់។ គ្មានអ្វីអាចអន្ទោងគាត់ចេញពីការសិក្សាព្រះគម្ពីរឡើយ។ គាត់បានភ័យខ្លាចសេចក្តីស្លាប់ ប៉ុន្តែនៅពេលដែលគាត់បានអានព្រះ-បន្ទូលព្រះ ការភ័យខ្លាចរបស់គាត់បានបាត់បង់ ហើយគាត់បានកោតសរសើរអត្តចរិតរបស់ព្រះនិងស្រឡាញ់ទ្រង់។ ការស្វែងរកព្រះបន្ទូលរបស់ព្រះដោយខ្លួនឯងគាត់បានទទួលនូវមរតកដ៏មានតម្លៃដែលមាននៅក្នុងព្រះគម្ពីរ ហើយគាត់បានស្វែងរកសំរាប់ពួកជំនុំ។ គេបានធ្វើអោយគាត់ស្អប់ខ្ពើមអំពើបាបរបស់អ្នកដែលបានទុកចិត្តនឹងសេចក្តី-សង្រ្គោះ គាត់បានឃើញមនុស្សជាច្រើននៅក្នុងភាពងងឹតដូចគ្នាដែលបានគ្របដណ្តប់គាត់។ គាត់បានស្វែងរកដោយអន្ទះសារនូវឱកាសចង្អុលប្រាប់គេនូវកូនចៀមនៃព្រះ



ដែលលោះបាបមនុស្សលោក។ គាត់បានលើកសំឡេងគាត់ឡើងប្រឆាំងនឹងការខុសឆ្គងរបស់ពួកជំនុំប៉ាប ហើយខំប្រឹងបំបាក់ច្រវាក់នៃភាពងងឹតដែលបានឃុំឃាំងមនុស្សរាប់ពាន់នាក់និងបណ្តាលអោយគេទុកចិត្តលើការងារដើម្បីបានសង្រ្គោះ។ គាត់ចង់ជួយបើកគំនិតរបស់គេនូវសេចក្តីពិតនៃព្រះគុណដ៏អស្ចារ្យរបស់ព្រះនិងភាពប្រសើរឧត្តមនៃសេចក្តីសង្រ្គោះដែលបានមកតាមរយៈព្រះយេស៊ូវគ្រីស្ទ។ គាត់បានលើកសំឡេងរបស់គាត់ឡើងដោយច្រណែននិងក្នុងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធស្រែកប្រឆាំងនឹងអំពើបាបដែលមានរបស់មេដឹកនាំនៃពួកជំនុំ ហើយនៅពេលដែលគាត់ជួបព្យុះនៃការប្រ-ឆាំងពីពួកសង្ឃសេចក្តីក្លាហានរបស់គាត់មិនបានបរាជ័យឡើយ ដ្បិតគាត់បានពឹងផ្អែកយ៉ាងមាំទៅលើព្រះពាហុរបស់ព្រះនិងទុកចិត្តយ៉ាងមាំទៅលើទ្រង់ដើម្បីជោគជ័យ។ ហើយនៅពេលដែលគាត់បានរុញសមរភូមិកាន់តែជិតឡើងៗ កំហឹងរបស់ពួកសង្ឃបានពុះកញ្ជ្រោលឡើងទាស់នឹងគាត់។ គេមិនចង់អោយអ្នកណាកែប្រែឡើយ។ គេនឹងចាកចេញដោយងាយស្រួលនិងដោយសេចក្តីសប្បាយយ៉ាងព្រៃផ្សៃក្នុងភាពងងឹត។ គេចង់អោយពួកជំនុំនៅក្នុងភាពងងឹត។

ខ្ញុំបានឃើញថា លូទើរ ស្តីបន្ទោសអំពើបាបនិងគាំទ្រសេចក្តីពិតដោយក្លៀវក្លាជឿស៊ប់ គ្មានខ្លាចនិងអង់អាចក្លាហាន។ គាត់មិនខ្វល់ខ្វាយអំពីមនុស្សអាក្រក់និងអារក្សឡើយ។ គាត់បានដឹងថាគាត់មានព្រះមួយអង្គនៅជាមួយគាត់ដែលមានអំណាចជាងពួកវានោះ។ លូទើរ មានភ្លើងនៃឧត្តមគតិ មានសេចក្តីក្លាហាន ភាពអង់អាចក្លៀវក្លាជាយូរមកហើយ ប៉ុន្តែព្រះបានលើកលោកម៉ាឡាន់តុន ដែលមានអត្តចរិតផ្ទុយពីលោកលូទើរបន្ថែមជាមួយលូទើរដើម្បីបន្តការងារកែទម្រង់។ ម៉ាឡាន់តុនជាមនុស្សមុខខ្វះខ្លាចប្រយ័ត្នប្រយែងនិងអត់ធ្មត់ខ្លាំង។ គាត់បានស្រឡាញ់ព្រះយ៉ាងខ្លាំង។ គាត់មានចំណេះ-ដឹងខាងបទគម្ពីរជ្រៅជ្រះ ហើយប្រាជ្ញា និងការវិនិច្ឆ័យរបស់គាត់ល្អប្រសើរ។ សេចក្តី-

ស្រឡាញ់ដល់បុព្វហេតុនៃព្រះរបស់គាត់ដូចជាលោកលូទើរដែរ។ ព្រះបានចងចិត្តទាំងពីរនេះជាប់គ្នា គេទាំងពីរនាក់ជាមិត្តភ័ក្តិដែលមិនអាចបំបែកបានឡើយ។ លូទើរជាជំនួយដ៏ធំដល់ម៉ាឡាន់តុននៅពេលគាត់មានគ្រោះថ្នាក់ដោយការភ័យខ្លាច និងយឺតយ៉ាវ ហើយម៉ាឡាន់តុនជាជំនួយដ៏ល្អដល់លូទើរ ក្នុងការទប់គាត់កុំអោយល្បឿនពេក។ ការប្រយ័ត្នប្រយែងរបស់ម៉ាឡាន់តុនតែងតែរួចផុតពីបញ្ហាដែលនឹងត្រូវធ្លាក់មក បុព្វហេតុនោះ ប្រសិនបើការងារនេះទុកអោយលូទើរតែម្នាក់ឯង ហើយការងារអាចនឹងបរាជ័យក្នុងការជំរុញទៅមុខ ប្រសិនបើទុកអោយម៉ាឡាន់តុនធ្វើតែម្នាក់ឯង។ គេបានបង្ហាញខ្ញុំអំពីព្រះតម្រិះរបស់ព្រះក្នុងការជ្រើសរើសមនុស្សទាំងពីរនាក់នេះដែលមានអត្តចរិកខុសគ្នា អោយធ្វើការងារកែទម្រង់។

ពេលនោះខ្ញុំត្រូវបានគេនាំមកឯពេលវេលានៃពួកសាវក ហើយបានឃើញព្រះជ្រើសរើស ដៃគូពេត្រុស ក្លៀវក្លានិងជឿស៊ប់ជាមួយនឹងយ៉ូហាន ជាមនុស្សស្លូតអត់ធ្មត់និងស្លូតបូត។ ជួនកាលពេត្រុសឆាប់ច្រឡោត។ ហើយសិស្សជាទីស្រឡាញ់ (យ៉ូហាន) បានពិនិត្យពេត្រុសនៅពេលដែលឧត្តមគតិនិងជំនឿស៊ប់របស់គាត់ នាំអោយគាត់ទៅលឿនពេក ប៉ុន្តែវាមិនបានកែប្រែគាត់ទេ តែបន្ទាប់ពីពេត្រុសបានបដិសេធព្រះអម្ចាស់ ហើយបានកែប្រែចិត្ត និងលន់តួមក គាត់គ្រាន់តែត្រូវការប្រយ័ត្នប្រយែងយ៉ាងស្លូតបូតពីយ៉ូហានដើម្បីពិនិត្យជំនឿនិងយតិភាពរបស់គាត់តែប៉ុណ្ណោះ។ បុព្វហេតុរបស់ព្រះ-គ្រីស្ទនឹងជួបប្រទះនូវការឈឺចាប់ ប្រសិនបើទុកអោយយ៉ូហានធ្វើតែម្នាក់ឯង។ គាត់ត្រូវការគំនិតរបស់ពេត្រុស។ ភាពអង់អាចក្លាហាន និងថាមពលរបស់គាត់តែងតែរំដោះគាត់អោយរួចពីការលំបាក ហើយធ្វើអោយខ្មាំងសត្រូវរបស់គាត់ស្ងប់ស្ងៀម។ យ៉ូហានបានឈ្នះ។ គាត់បាននាំមនុស្សជាច្រើនមកឯបុព្វហេតុរបស់ព្រះគ្រីស្ទដោយការអត់ធ្មត់ពីកំណើត និងជំនឿស៊ប់របស់គាត់។



ព្រះបានលើកមនុស្សឡើងអោយស្រែកប្រឆាំងនឹងអំពើបាបដែលមាននៅក្នុងពួកជំនុំប៉ាបនិងនាំឆ្ពោះទៅមុខនូវការកែទម្រង់។ សាតាំងបានស្វះស្វែងបំផ្លាញទីបន្ទាល់ដ៏រស់នេះ ប៉ុន្តែព្រះបានធ្វើរបងការពារគេ។ ដើម្បីសិរីល្អនៃព្រះនាមទ្រង់ ទ្រង់បានអនុញ្ញាតអោយអ្នកខ្លះបោះត្រាទីបន្ទាល់ ដែលគេបានធ្វើដោយព្រះលោហិតរបស់ទ្រង់ ប៉ុន្តែនៅមានមនុស្សដ៏មានអំណាចផ្សេងៗទៀត ដូចជា លូទើរនិងម៉ាឡាន់តុនដែលអាចសរសើរដំកើងព្រះបានយ៉ាងល្អបំផុតដោយការរស់នឹងស្រែកប្រឆាំងនឹងអំពើបាបរបស់ប៉ាបសង្ឃនិងស្តេចទាំងឡាយ។ ពួកគេញាប់ញ័រនៅចំពោះសំឡេងរបស់លូទើរ។ តាមរយៈមនុស្សដែលព្រះបានជ្រើសតាំងនេះ កាំរស្មីនៃពន្លឺបានកំចាត់កំចាយភាពងងឹត ហើយមានមនុស្សជាច្រើនបានទទួលនិងដើរក្នុងពន្លឺនេះដោយក្តីអំណរ។ ហើយនៅពេលដែលស្មរបន្ទាល់មួយត្រូវបានគេសម្លាប់ មានស្មរបន្ទាល់ពីរឬច្រើននាក់ទៀតបានក្រោកឡើងជំនួស។

ប៉ុន្តែសាតាំងមិនបានពេញចិត្តឡើយ។ វាមានអំណាចបានតែលើរាងកាយតែប៉ុណ្ណោះ។ វាមិនអាចធ្វើអោយអ្នកជឿទទួលសេចក្តីជំនឿនិងសេចក្តីសង្ឃឹមរបស់គេឡើយ។ ហើយសូម្បីតែនៅក្នុងសេចក្តីស្លាប់ក៏ដោយ គេឈានទៅមុខដោយសេចក្តី-សង្ឃឹមដ៏ត្រចះត្រចង់នៃការមិនស្លាប់នៅគ្រារស់ឡើងវិញនៃយុត្តិធម៌។ វាមានលើសពីកម្លាំងដែលត្រូវស្លាប់។ វាមិនហ៊ានដេកមួយស្របក់ឡើយ។ គេបានពាក់គ្រឿងសឹករបស់គ្រីស្ទាននៅជុំវិញរៀបចំប្រយុទ្ធមិនគ្រាន់តែជាមួយខ្មាំងខាងវិញ្ញាណប៉ុណ្ណោះទេ ប៉ុន្តែជាមួយសាតាំងនៅក្នុងរូបរាងជាមនុស្ស ដែលស្រែកជាបន្តថា បោះបង់ជំនឿរបស់អ្នកស្លាប់។ មានគ្រីស្ទានមួយចំនួនតូចឈររឹងមាំនៅខាងព្រះ និងមានតម្លៃនៅក្នុងព្រះ-នេត្រទ្រង់ជាងពាក់កណ្តាលពិភពលោក ដែលមានឈ្មោះព្រះគ្រីស្ទ តែជាមនុស្សកំសាកនៅក្នុងបុព្វហេតុរបស់ទ្រង់។ នៅពេលពួកជំនុំត្រូវគេបៀតបៀន ពួកគេរួបរួមគ្នា ហើយ

វិតតែស្រឡាញ់គ្នា។ ពួកគេមានជំហររឹងមាំក្នុងព្រះអម្ចាស់។ អ្នកមានបាបមិនបានអនុញ្ញាតអោយរួបរួមជាមួយឡើយ ទោះបីជាអ្នកបោកបញ្ឆោតគេ ឬអ្នកចាញ់បោកបញ្ឆោតគេក្តី។ មានតែអ្នកដែលមិនសុខចិត្តបោះបង់ព្រះគ្រីស្ទទេ ដែលជាសាវក។ គេសុខចិត្តនៅជាអ្នកក្រ ជាអ្នកបន្ទាបខ្លួន និងរស់នៅដូចជាព្រះគ្រីស្ទ។

សូមអានលូកា ២២:៦១-៦២ យ៉ូហាន១៨:១០ កិច្ចការ ជំពូក៣ និង៤ដើម្បីសិក្សាអោយបានជ្រៅ សូមអាន "ការកែទម្រង់" ក្នុងសព្វវចនាធិប្បាយ។

## ជំពូកទី២១

## **ការរួបរួមគ្នារបស់ពួកជំនុំនិងលោកីយ៍**

ពេលនោះសាតាំងបានពិភាក្សាជាមួយនឹងទេវតារបស់វា ហើយនៅទីនោះពួកវាបានពិចារណាអំពីអ្វីដែលវាបានទទួល។ ជាការពិតណាស់ដែលវាបានរក្សាមនុស្សកំសាកមួយចំនួនអោយភ័យខ្លាចសេចក្តីស្លាប់ និងមិនហ៊ានរក្សាសេចក្តីពិត ប៉ុន្តែមានមនុស្សជាច្រើនសូម្បីតែអ្នកកំសាកបំផុតក៏ទទួលសេចក្តីពិតដែរ ហើយសេចក្តីភ័យខ្លាចនិងភាពកំសាករបស់គេបានចេញពីគេភ្លាម ហើយនៅពេលដែលគេបានឃើញការស្លាប់របស់បងប្អូនគេ និងការអត់ធន់របស់ពួកគេ គេបានដឹងថាព្រះនិងទេវតារបស់ទ្រង់បានជួយគេឱ្យទ្រាំទ្ររងទុក្ខវេទនាបែបនេះ ហើយគេក៏បានលូតលាស់ឡើងនិងគ្មានភ័យខ្លាចឡើយ។ នៅពេលដែលពួកគេបានទទួលការបៀតបៀនដល់ជីវិតរបស់គេផ្ទាល់ គេបានរក្សាសេចក្តីជំនឿរបស់គេជាមួយនឹងអ្នកអត់ធន់ និងមានជំហររឹងមាំដែលរហូតបានធ្វើអោយឃាតកររបស់គេញ័ររន្ធត់។ សាតាំងនិងទេវតារបស់វាបានសំរេចចិត្តថា មានវិធីដ៏មានជោគជ័យជាច្រើនទៀត ដើម្បីបំផ្លាញព្រលឹងមនុស្សដែលកាន់តាមច្បាប់នៅគ្រា



បញ្ចប់។ វាបានឃើញថាទោះបីជាវាបានធ្វើអោយគ្រីស្ទានរងទុក្ខវេទនាក៏ដោយ ក៏ជំហរមាំមួន និងសេចក្តីសង្ឃឹមដ៏មានពន្លឺរបស់គេ ដែលធ្វើអោយគេមានអំណរបណ្តាលអោយអ្នកខ្សោយបំផុតកាន់តែរឹងមាំឡើង ហើយបង្គោលនៃអណ្តាតភ្លើងមិនអាចធ្វើអោយគេរួញរាឡើយ។ ពួកគេបានយកតម្រាប់តាមសេចក្តីក្លាហានរបស់ព្រះគ្រីស្ទនៅពេលដែលទ្រង់បានសំដែងនៅចំពោះមុខឃាតកររបស់ទ្រង់ ហើយមនុស្សជាច្រើនបានទទួលស្គាល់សេចក្តីពិតដោយបានឃើញការមិនផ្លាស់ប្តូររបស់ពួកគេ និងសិរីល្អរបស់ព្រះដែលសណ្ឋិតនៅលើគេ។ សាតាំងបានសំរេចចិត្តថា វាត្រូវតែមកក្នុងរូបរាងជាអ្នកស្លូតបូត។ វាបានធ្វើអោយខូចគោលលទ្ធិនៃព្រះគម្ពីរ ហើយប្រពៃណីដែលបានបង្ខូចមនុស្សរាប់លាននាក់បានចាក់ឫសយ៉ាងជ្រៅ។ វាបានពង្រឹងសម្អប់របស់វា ហើយបានសំរេចចិត្តថា មិនបង្ខំគោលបំណងរបស់វាដោយការបៀតបៀនដ៏ជូរចត់បែបនេះទេ ប៉ុន្តែបែរជាដឹកនាំពួកជំនុំអោយប្រឈមមុខប្រជែងវិញ មិនមែនខាងសេចក្តីជំនឿរវាងអ្នកជឿ និងអ្នកបរិសុទ្ធទេ ប៉ុន្តែខាងប្រពៃណីផ្សេងៗវិញ។ នៅពេលដែលវាបានដឹកនាំពួកជំនុំអោយទទួលការចូលចិត្ត និងកិត្តិយសរបស់លោកីយ៍នៅពីក្រោយខ្នងការបន្លំថា ជាផលប្រយោជន៍ដល់គេ ពួកជំនុំបានចាប់ផ្តើមបាត់បង់ការសព្វព្រះហឫទ័យពីព្រះពួកជំនុំក៏បានបាត់បង់អំណាចបន្តិចម្តងៗនៅពេលដែលខ្លួនបានទទួលយកដោយត្រង់ៗនូវសេចក្តីជំនឿដែលបិទបាំងសេចក្តីប៉ងប្រាថ្នា ការរីករាយ និងមិត្តភ័ក្តិជាមួយលោកីយ៍។

ពួកជំនុំមិនមែនជាមនុស្សចំឡែកពីក្រៅណាមកទេ គឺជាអ្នកដែលបង្កើតឡើងនៅពេលមានការបៀតបៀនប្រឆាំងនឹងខ្លួនឯង។ តើមាសអាចបាត់បង់ពន្លឺបានយ៉ាងណា? តើមាសសុទ្ធផ្លាស់ប្តូរយ៉ាងណា? ខ្ញុំបានឃើញថា ប្រសិនបើពួកជំនុំបានរក្សាអត្ត-ចរិតបរិសុទ្ធនិងប្លែកពីគេរបស់ខ្លួន អំណាចនៃព្រះវិញ្ញាណបរិសុទ្ធដែលបានមកសណ្ឋិតលើពួកសាវកនឹងនៅជាមួយនឹងគេ។ អ្នកឈឺនឹងត្រូវបានព្យាបាល អារក្សនឹងត្រូវបានស្តី

បន្ទោស និងបណ្តេញចេញ ហើយគេនឹងមានចេស្តាព្រមទាំងជាអ្នកមានជ័យជំនះលើខ្មាំងសត្រូវទៀតផង ។

ខ្ញុំបានឃើញថា មានមនុស្សមួយក្រុមធំ បានប្រកាសពីព្រះនាមរបស់ព្រះគ្រីស្ទ ប៉ុន្តែព្រះមិនទទួលស្គាល់គេថា ជារបស់ទ្រង់ឡើយ ។ ព្រះអង្គមិនបានសព្វព្រះហឫទ័យចំពោះគេឡើយ ។ សាតាំងហាក់ដូចជាបានប្រើប្រាស់លក្ខណៈសាសនា និងចង់អោយមនុស្សគិតថាគេគឺជាគ្រីស្ទាន ។ វាចង់អោយគេជឿយ៉ាងខ្លាំងទៅលើព្រះយេស៊ូវ លើការជាប់ឆ្កាង និងលើការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ។ សាតាំងខ្លួនឯងនិងទេវតារបស់វាក៏បានជឿលើការទាំងអស់នេះដែរ ហើយបានញាប់ញ័រវន្ទត់ ។ ប៉ុន្តែប្រសិនបើសេចក្តីជំនឿនេះមិនបានបង្កើតអោយទៅជាការងារល្អ និងដឹកនាំអ្នកដែលទទួលជំនឿឱ្យធ្វើតាមការលះបង់ផ្ទាល់ខ្លួនរបស់ព្រះគ្រីស្ទក៏ដោយ ក៏វាមិនខ្វល់ឡើយ ដ្បិតគេគ្រាន់តែប្រើប្រាស់ឈ្មោះគ្រីស្ទានតែប៉ុណ្ណោះ តែចិត្តរបស់គេនៅខាងលោកីយ៍នៅឡើយ ហើយវាអាចប្រើប្រាស់ពួកគេសំរាប់ការងាររបស់វាបានប្រសើរជាងអ្នកដែលគ្មានជំនឿសោះទៅទៀត ។ នៅពីក្រោមឈ្មោះរបស់គ្រីស្ទាន គេលាក់រូបរាងមិនល្អរបស់គេ ។ គេបានចែកចាយបន្តនូវធម្មជាតិ មិនចេះស្អប់ស្អល់របស់គេ និងតណ្ហាអាក្រក់មិនអាចបង្ក្រាបបានរបស់គេ ។ ការនេះបានផ្តល់ឱកាសអោយអ្នកមិនជឿបោះភាពមិនល្អរបស់គេ នៅក្នុងព្រះភ័ក្ត្ររបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីស្តីបន្ទោសទ្រង់ និងធ្វើអោយអ្នកដែលអះអាងថាបរិសុទ្ធ នឹងសាសនាមិនស្អាតស្អំត្រូវបាត់បង់កិត្តិស័ព្ទ ។

គ្រូគង្វាលអធិប្បាយយ៉ាងរលូនអំពីរឿងរ៉ាវដែលស្របទៅនឹងសាស្ត្រាចារ្យខាងលោកីយ៍ ។ នេះគឺដូចជាសាតាំងបានធ្វើដែរ ។ គេមិនហ៊ានអធិប្បាយអំពីព្រះយេស៊ូវនិងសេចក្តីពិតចំៗរបស់ព្រះគម្ពីរទេ ព្រោះបើគេធ្វើអ្នកគាំទ្រលោកីយ៍នឹងមិនស្តាប់គេឡើយ ។ ពួកគេជាច្រើនជាអ្នកមាន ហើយត្រូវតែរក្សាទុកក្នុងពួកជំនុំ ទោះបីជាគេមិន



សមនឹងនៅកន្លែងនោះជាងសាតាំងនិងទេវតារបស់វាទៅទៀតក៏ដោយ ។ សាសនារបស់ព្រះយេស៊ូវត្រូវបានគេធ្វើអោយមានប្រជាប្រិយ៍និងកោតសរសើរនៅភ្នែករបស់លោក-យ៍ ។ គេបានប្រាប់ដល់មនុស្សថា អ្នកដែលកាន់សាសនានឹងត្រូវបានលោកីយ៍កោតសរ-សើរកាន់តែខ្លាំង ។ ការបង្រៀនដ៏ទូលំទូលាយបែបនេះខុសពីការបង្រៀនរបស់ព្រះ-គ្រីស្ទ ។ គោលលទ្ធិរបស់ទ្រង់និងលោកីយ៍មិនមានសេចក្តីសុខសាន្តឡើយ ។ អ្នកដែលដើរតាមទ្រង់ត្រូវតែបោះបង់ចោលលោកីយ៍ ។ ការងារដ៏រលូនទាំងនេះ មានប្រភពមកពីសាតាំងនិងទេវតារបស់វា ។ វាបានរៀបចំផែនការ ហើយអ្នកកាន់សាសនាតែឈ្មោះបានអនុវត្ត ។ អ្នកមានពុតនិងអ្នកមានបាបរួបរួមជាមួយពួកជំនុំ ។ រឿងកុហកដែលធ្វើអោយគេសប្បាយត្រូវបានគេបង្រៀន ហើយត្រូវបានគេទទួលយ៉ាងងាយ ។ ប៉ុន្តែប្រសិនបើសេចក្តីពិតត្រូវបានគេផ្សព្វផ្សាយក្នុងភាពបរិសុទ្ធរបស់វា វានឹងបិទមិនអោយអ្នកមានពុតនិងអ្នកមានបាបចូលឡើយ ។ ប៉ុន្តែគ្មានអ្វីខុសគ្នារវាងអ្នកដែលអះអាងថា ជាអ្នកជឿព្រះគ្រីស្ទនិងលោកីយ៍ឡើយ ។ ខ្ញុំបានឃើញថា ប្រសិនបើគម្របនៃការខុសឆ្គងត្រូវបានគេបកចេញពីសមាជិកនៃពួកជំនុំ វានឹងបង្ហាញនូវភាពទុច្ចរិតភាពអប្រិយ៍និងការពុករលួយដែលកូនព្រះដ៏គ្មានការទុកចិត្តលើខ្លួនឯងបំផុត នឹងមិនមានការស្ទាក់ស្ទើរនឹងហៅឈ្មោះថា ជាកូនរបស់ឪពុកឡើយ គឺជាអារក្ស ព្រោះតែការងារដែលគេធ្វើនោះឯង ។ ព្រះយេស៊ូវនិងទេវតានៃស្ថានសួគ៌ បានទតដោយសេចក្តីខ្ញាល់ខ្ញែមរអើមទៅលើទស្ស-នីយភាពនោះ ហើយព្រះមានដំណឹងសំរាប់ពួកជំនុំដ៏ពិសិដ្ឋ និងដ៏សំខាន់ ។ ប្រសិនបើគេទទួលវា និងធ្វើការកែទម្រង់មួយយ៉ាងហ្មត់ចត់នៅក្នុងពួកជំនុំ ដែលទទួលទីបន្ទាល់ដ៏រស់ដែលនឹងកំចាត់ពួកកំពុត និងអ្នកមានបាបចេញនិងនាំពួកជំនុំមករកការសព្វព្រះហឫទ័យរបស់ព្រះវិញ ។

សូមអាន អេសាយ ៣០:៨-២១ យ៉ាកុប ២:១៩ វិវរណៈ ជំពូកទី៣ ។

ជំពូកទី២២

## វិលៀមមីលើរ

ខ្ញុំបានឃើញថា ព្រះយេស៊ូវបានចាត់ទេវតារបស់ទ្រង់អោយធ្វើការក្នុងចិត្តកសិករម្នាក់ដែលមិនបានជឿព្រះគម្ពីរ ហើយបានដឹកនាំអោយគាត់ស្វែងយល់អំពីបទទំនាយ។ ទេវតារបស់ព្រះបានជួបអ្នកដែលព្រះបានជ្រើសរើសនោះម្តងហើយម្តងទៀត និងបានដឹកនាំគំនិតរបស់គាត់ ព្រមទាំងបានបើកអោយគាត់យល់អំពីបទទំនាយដែលធ្លាប់តែងងឹតដល់រាស្ត្ររបស់ព្រះ។ ការចាប់ផ្តើមអំពីច្រវាក់នៃសេចក្តីពិតត្រូវបានប្រទានអោយគាត់ ហើយទេវតាបាននាំគាត់អោយស្វែងរកពីការតភ្ជាប់ពីមួយទៅមួយទៀតរហូតទាល់តែគាត់បានពិនិត្យមើលដោយអស្ចារ្យ និងកោតសរសើរដល់ព្រះបន្ទូលរបស់ព្រះ។ នៅទីនោះគាត់បានឃើញច្រវាក់នៃសេចក្តីពិតដ៏គ្រប់លក្ខណ៍។ ពាក្យពេចន៍ដែលគាត់ចាត់ទុកថា គ្មានអ្នកណាបណ្តាលអោយសរសេរ ឥឡូវនេះបានបើកនៅចំពោះការជាក់ស្តែងរបស់គាត់នូវសម្រស់និងសិរីល្អ។ គាត់បានឃើញថាបទគម្ពីរមួយផ្នែកពន្យល់ដល់មួយផ្នែកផ្សេងទៀត ហើយនៅពេលដែលបទគម្ពីរមួយផ្នែកបានបិទការយល់របស់គាត់ គាត់បានរកឃើញនៅក្នុងព្រះបន្ទូល មួយវគ្គទៀតបានពន្យល់គាត់អំពីផ្នែកនោះ។ គាត់គោរពព្រះបន្ទូលដ៏ពិសិដ្ឋដោយអំណរ និងដោយការគោរពនិងស្ងើចសរសើរដ៏ជ្រាលជ្រៅបំផុត។

នៅពេលដែលគាត់បានតាមដានបទទំនាយគាត់បានឃើញថា អ្នកដែលរស់នៅលើផែនដីនេះកំពុងរស់នៅជិតចុងបញ្ចប់នៃប្រវត្តិសាស្ត្ររបស់លោកិយ៍ហើយ ហើយពួកគេមិនបានដឹងពីការនោះឡើយ។ គាត់បានមើលទៅឯការពុករលួយរបស់ពួកជំនុំហើយបានឃើញថា សេចក្តីស្រឡាញ់របស់គេត្រូវបានយកចេញពីព្រះយេស៊ូវហើយ



ហើយបានប្រគល់ទៅអោយលោកិយ៍ និងថាគេកំពុងស្វែងរកកិត្តិយសនៃលោកិយ៍ ជាជាងកិត្តិយសដែលមកពីខាងលើត្រេកអរនឹងការមានបាបនៃលោកិយ៍ ជាជាងប្រមូលទ្រព្យសម្បត្តិទុកនៅឯនគរស្ថានសួគ៌។ គាត់អាចឃើញភាពកំពុត ភាពងងឹតនិងសេចក្តីស្លាប់គ្រប់ទីកន្លែង។ វិញ្ញាណរបស់គាត់បានពុះកញ្ជ្រោលឡើង។ ព្រះបានត្រាស់ហៅគាត់អោយចាកចេញពីចំការដូចជាទ្រង់បានហៅអេលីសេអោយចាកចេញពីគោនិងស្រែដែលគាត់កំពុងភ្ជួរឱ្យទៅតាមអេលីយ៉ាដូច្នេះដែរ។ ជាមួយនឹងការញ័ររន្ធត់ វិលៀមមីលើរបានចាប់ផ្តើមបើកអាថិកំបាំងនៃនគររបស់ព្រះបង្ហាញមនុស្សម្នា។ គាត់បានទទួលកម្លាំងពីគ្រប់ការខំប្រឹងប្រែងទាំងឡាយ។ គាត់បាននាំមនុស្សរហូតទៅដល់បទទំនាយនៃព្រឹត្តិការណ៍នៃការយាងមកវិញរបស់ព្រះយេស៊ូវគ្រីស្ទ។ ដូចជាលោកយ៉ូហានបាទីស្ទបាននាំដំណឹងនៃព្រឹត្តិការណ៍លើកទីមួយរបស់ព្រះយេស៊ូវ និងរៀបចំផ្លូវថ្វាយទ្រង់យាងមកដែរ។ លោកវិលៀមមីលើរនិងអ្នកដែលរួបរួមជាមួយគាត់បានប្រកាសអំពីព្រឹត្តិការណ៍ទីពីររបស់ព្រះរាជបុត្រានៃព្រះ។

គេបាននាំខ្ញុំត្រឡប់ទៅឯសម័យនៃពួកសាវកហើយបានបង្ហាញសាវកយ៉ូហានជាទីស្រឡាញ់ដែលព្រះមានការងារពិសេសឱ្យគាត់បំពេញ។ សាតាំងបានប្តេជ្ញាបំផ្លាញកិច្ចការនោះ ហើយបានដឹកនាំអ្នកបំរើរបស់វាអោយសម្លាប់យ៉ូហាន។ ប៉ុន្តែព្រះបានចាត់ទេវតារបស់ទ្រង់ទៅការពារគាត់យ៉ាងអស្ចារ្យ។ អ្នកដែលបានឃើញអំណាចដ៏ខ្លាំងរបស់ព្រះដែលបានសំដែងក្នុងការរំដោះលោកយ៉ូហាន មានការភ្ញាក់ផ្អើល ហើយមានមនុស្សជាច្រើនបានជឿថា ព្រះបានគង់នៅជាមួយគាត់និងថាទីបន្ទាល់ដែលគាត់បាននាំមកទាក់ទងនឹងព្រះយេស៊ូវគឺត្រឹមត្រូវ។ អ្នកដែលស្វែងរកបំផ្លាញគាត់ភ័យខ្លាចមិនហ៊ានប៉ុនប៉ងសម្លាប់គាត់ម្តងទៀតឡើយ ហើយព្រះបានអនុញ្ញាតឱ្យគាត់រងទុក្ខ ព្រោះព្រះយេស៊ូវ។ គាត់ត្រូវបានខ្មាំងសត្រូវចោទប្រកាន់ខុសរឿងពិត និងមិនយូរប៉ុន្មាន ត្រូវបាន

បំបរបង់ទៅកាន់កោះមួយយ៉ាងឯកោ នៅទីនោះ ព្រះបានចាត់ទេវតារបស់ទ្រង់ទៅបង្ហាញដល់គាត់អំពីរឿងរ៉ាវ ដែលនឹងកើតឡើងដល់ផែនដីនេះ និងសណ្ឋាននៃពួកជំនុំព្រមទាំងតួនាទីដែលពួកជំនុំនឹងគ្រប់គ្រង ប្រសិនបើគេធ្វើអោយព្រះសព្វព្រះហឫទ័យនឹងជ័យជំនះចុងក្រោយ ។ ទេវតានៃស្ថានសួគ៌ បានចុះមកឯលោកយ៉ូហានដោយចេស្តា ។ ព្រះភ័ក្ត្ររបស់លោកចាំងដោយពន្លឺសិរីល្អនៃស្ថានសួគ៌ ។ លោកបានបង្ហាញដល់លោកយ៉ូហាននូវទស្សនីយភាពដ៏គួរអោយចាប់អារម្មណ៍យ៉ាងជ្រាលជ្រៅ និងរំភើបទាក់ទងនឹងពួកជំនុំរបស់ព្រះ និងបាននាំមកនៅចំពោះមុខគាត់នូវជម្លោះដ៏មានគ្រោះថ្នាក់ដែលពួកគេត្រូវរងទ្រាំ ។ លោកយ៉ូហានបានឃើញគេឆ្លងកាត់ការកាត់ទោសដោយភ្លើងធ្វើឱ្យស្លេកស្លាំង និងត្រូវគេកាត់ទោស ហើយទីបំផុត ក្លាយជាអ្នកឈ្នះដ៏មានជោគជ័យបានសង្គ្រោះក្នុងនគររបស់ព្រះដោយមានសិរីល្អ ។ ព្រះភ័ក្ត្ររបស់ទេវតាបានឡើងភ្លឺចាំងដោយអំណរ និងមានសិរីរុងរឿងអស្ចារ្យបំផុត នៅពេលដែលលោកបានបង្ហាញដល់លោកយ៉ូហានអំពីជោគជ័យចុងក្រោយនៃពួកជំនុំរបស់ព្រះ ។ លោកយ៉ូហានត្រូវបានធ្វើអោយអណ្តែតអណ្តូងនៅពេលដែលគាត់បានឃើញការរំដោះចុងក្រោយរបស់ពួកជំនុំ និងនៅពេលដែលគាត់ត្រូវបានទេវតានាំចេញទៅជាមួយនឹងសិរីល្អនៃទស្សនីយភាព ជាមួយនឹងការគោរព និងកោតសរសើរយ៉ាងជ្រាលជ្រៅ គាត់បានក្រាបចុះថ្វាយបង្គំទៀបជើងរបស់ទេវតា ។ ទេវតាក៏បានលើកគាត់ឡើង ហើយបន្ទោសគាត់ដោយថ្នមៗថា កុំអោយធ្វើដូច្នេះឡើយ ដ្បិតខ្ញុំជាបាវបំរើជាមួយនឹងអ្នក ហើយនឹងបងប្អូនអ្នកដែលមានសេចក្តីបន្ទាល់ពីព្រះយេស៊ូវដែរ ចូរថ្វាយបង្គំដល់ព្រះវិញ ដ្បិតការធ្វើបន្ទាល់ពីព្រះ-យេស៊ូវ នោះហើយជាវិញ្ញាណនៃសេចក្តីទំនាយ ។ ពេលនោះទេវតាបានបង្ហាញដល់លោកយ៉ូហាននូវទីក្រុងនៃស្ថានសួគ៌ ជាមួយនឹងភាពរុងរឿង និងសិរីល្អចាំងចែងរបស់នគរនោះ ។ លោកយ៉ូហានត្រូវបានធ្វើអោយអណ្តែតអណ្តូង និងរំភើបយ៉ាងខ្លាំងដោយ



សិរីល្អនៃទីក្រុងនោះ ។ គាត់មិនបាននឹកចាំពីការបន្ទោសរបស់ទេវតាពីមុន ក៏ក្រាបថ្វាយបង្គំនៅទៀបព្រះបាទទេវតាម្តងទៀត ដែលបានបន្ទោសដល់គាត់ ដែលមានបន្ទូលទៅគាត់ដោយថ្នមៗថា កុំអោយធ្វើដូច្នេះឡើយ ខ្ញុំក៏ជាបាវបំរើជាមួយនឹងអ្នកដែរ ហើយជាមួយនឹងពួកហោរា ជាបងប្អូនអ្នក និងពួកអ្នកដែលកាន់តាមព្រះបន្ទូលក្នុងគម្ពីរនេះផង ចូរថ្វាយបង្គំដល់ព្រះវិញចុះ ។

គ្រូអធិប្បាយនិងមនុស្សទាំងឡាយបានមើលគម្ពីរវិវរណៈថាជាគម្ពីរដែលមានអាថ៌កំបាំងនិងមានសារសំខាន់តិចជាងផ្នែកផ្សេងៗទៀតនៃបទគម្ពីរ ។ ប៉ុន្តែខ្ញុំបានឃើញថា សៀវភៅនេះ គឺពិតជាការបើកសំដែងដែលព្រះបានប្រទានសំរាប់ជាផលប្រយោជន៍ដ៏ពិសេសរបស់អ្នកដែលរស់នៅនាសម័យចុងក្រោយដើម្បីដឹកនាំពួកគេក្នុងការធ្វើអោយគេដឹងជាប្រាកដអំពីតួនាទីនិងការងារដ៏ពិតរបស់គេ ។ ព្រះបាននាំគំនិតរបស់លោកវីល្លៀមមីលើរទៅក្នុងបទទំនាយ និងប្រទានពន្លឺដ៏ឧត្តមដល់គាត់លើសៀវភៅវិវរណៈ ។

ប្រសិនបើគេបានយល់អំពីការបើកសំដែងរបស់ដានីយ៉ែល មនុស្សអាចយល់ពីការជាក់ស្តែងរបស់យ៉ូហានបានកាន់តែច្បាស់ ។ ប៉ុន្តែនៅពេលដ៏ត្រឹមត្រូវ ព្រះបានបណ្តាលចិត្តអ្នកបំរើរើសតាំងរបស់ទ្រង់ដែលយល់ច្បាស់និងនៅក្នុងអំណាចនៃព្រះវិញ្ញា-ណបរិសុទ្ធអោយបើកបទទំនាយ និងបានបង្ហាញពីភាពស្របគ្នារវាងការជាក់ស្តែងរបស់ដានីយ៉ែល និងរបស់យ៉ូហាន និងផ្នែកផ្សេងៗទៀតនៃព្រះគម្ពីរ និងអោយដក់ជាប់នៅក្នុងចិត្តមនុស្សនូវព្រះបន្ទូលដ៏ពិសិដ្ឋ និងគួរអោយភ័យខ្លាចដើម្បីរៀបចំសំរាប់ការយាងមករបស់កូនមនុស្ស ។ ការជឿស៊ប់យ៉ាងជ្រៅ និងមុតមាំបានធ្លាក់មកលើគំនិតរបស់អ្នកដែលបានឮទ្រង់ ហើយគ្រូគង្វាលមនុស្សម្នា អ្នកមានបាប និងមនុស្សមិនជឿសាសនាបានងាកមករកព្រះអម្ចាស់សម្រាប់ស្វែងរកការរៀបចំមួយ ដើម្បីឈរនៅក្នុងការជំនុំជំរះ ។

ទេវតារបស់ព្រះបានអមដំណើរវីល្លៀមមីលើរ នៅក្នុងបេសកកម្មរបស់គាត់។ គាត់មានចិត្តមោះមុតនិងមិនរុញរាឡើយ។ គាត់បានប្រកាសដំណឹងដោយគ្មានភ័យខ្លាចទាំងប្តេជ្ញាចិត្តទៅនឹងសេចក្តីជំនឿរបស់គាត់។ លោកីយ៍កំពុងស្ថិតនៅក្នុងភាពកំណាចនិងអាក្រក់ ពួកជំនុំនៃលោកីយ៍ល្ងមហៅចូលទៅក្នុងសកម្មភាពនៃកម្លាំងរបស់ទ្រង់ ហើយដឹកនាំពួកគេទៅក្នុងការរងទ្រាំនៃសេចក្តីលំបាក ការខ្វះខាត និងទុក្ខវេទនាដោយស្ម័គ្រចិត្ត។ ទោះបីជាត្រូវប្រឆាំងដោយពួកគ្រីស្ទាននិងដោយលោកីយ៍ព្រមទាំងប៉ះទង្គិចដោយសាតាំងនិងទេវតារបស់វាក៏ដោយ គាត់មិនបញ្ឈប់ការប្រកាសដំណឹងល្អដ៏អស់-កល្បដល់ហ្វូងមនុស្សឡើយ។ នៅគ្រប់ទីកន្លែង គាត់បានធ្វើការអញ្ជើញដោយសំឡេងស្រែកថា ចូរកោតខ្លាចដល់ព្រះនិងថ្វាយសិរីល្អដល់ទ្រង់ចុះ ដ្បិតពេលជំនុំជំរះបានមកដល់ហើយ។

សូមអាន ពង្សាវតាក្សត្រទី១ ១៩:១៦-២១ ដានីយ៉ែល ជំពូក ៧-១២ វិវរណៈ ជំពូកទី១, ១៤:៧, ១៩:៨-១០, ២២:៦-១០។



ជំពូកទី២៣

## សាររបស់ទេវតាទីមួយ

ខ្ញុំបានឃើញថា ព្រះបាននៅក្នុងការប្រកាសនៃពេលវេលាក្នុងឆ្នាំ១៨៤៣។ វាគឺជាផែនការរបស់ទ្រង់ ដែលដាស់មនុស្សនិងនាំគេទៅកាន់ចំណុចសាកល្បងដែលគេត្រូវសំរេចចិត្ត។ មន្ត្រីសាសនាទាំងឡាយត្រូវបានវិនិច្ឆ័យនិងជឿលើភាពត្រឹមត្រូវនៃតួ-នាទីដែលកើតឡើងនៅក្នុងរយៈពេលនៃបទទំនាយ ហើយគេបានទុកចោលនូវអំនួតនិងប្រាក់ខែរបស់គេ និងធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ហើយប្រកាសដំណឹងនោះ។ ប៉ុន្តែនៅពេលដែលដំណឹងពីស្ថានសួគ៌ មិនអាចរកកន្លែងនៅក្នុងចិត្តនៃអ្នកបំរើរបស់ព្រះគ្រីស្ទដ៏តិចតួចបាន ការងារនេះត្រូវបានប្រគល់អោយអ្នកដែលមិនមែនជាអ្នកផ្សាយដំណឹងល្អច្រើននាក់។ អ្នកខ្លះបានចាកចេញពីស្រែចំការរបស់គេដើម្បីប្រកាសដំណឹងល្អ នៅពេលដែលអ្នកខ្លះទៀតត្រូវបានត្រាស់ហៅអោយចាញចេញពីហាងលក់ទំនិញនិងមុខជំនួញរបស់ខ្លួនចេញទៅបំពេញការងារដែលមិនសូវមានប្រជាប្រិយ គឺការប្រកាសសាររបស់ទេវតាទីមួយ។ គ្រូគង្វាលបានទុកគំនិតនិកាយនិងអារម្មណ៍របស់ខ្លួនចោលមួយឡែក ហើយរួបរួមក្នុងការប្រកាសអំពីការយាងមកវិញរបស់ព្រះយេស៊ូវ។ មនុស្សម្នាបានផ្លាស់ប្តូរទីកន្លែងគ្រប់ទិសទីដំណឹងនោះបានទៅដល់ពួកគេ។ អ្នកមានបាបបានកែប្រែចិត្ត ហើយបានអធិដ្ឋានសុំការអត់ឱនទោស ហើយអ្នកដែលរស់នៅបានកត់សំគាល់ដោយការមិនធ្វើការសងសឹកវិញដោយទង្គឹះចិត្ត។

មាតាបិតាយកចិត្តទុកដាក់ចំពោះកូនជាខ្លាំង។ អ្នកដែលបានទទួលដំណឹងនេះបានចែកចាយជាមួយនឹងមិត្តភ័ក្តិ និងបងប្អូននិងដោយព្រលឹងរបស់គេក្រាបចំពោះទម្ងន់នៃដំណឹងល្អ ប្រកាសប្រាប់និងទទូចអង្វរ ពួកគេរៀបចំខ្លួនសំរាប់ការយាងមករបស់កូនមនុស្ស។ ករណីទាំងនេះគឺជាការរឹងរូសបំផុតដែលទាមទាររកដោយការប្រមាណដែលផុសចេញពីក្នុងចិត្ត។ ការងារសំអាតព្រលឹងមនុស្សបែបនេះបានដឹកនាំសេចក្តីស្រឡាញ់អោយចេញពីរឿងរ៉ាវខាងលោកិយ៍ទៅឯការលះបង់ដែលមិនធ្លាប់មានពីមុនមក។ មនុស្សរាប់ពាន់នាក់បានជឿសេចក្តីពិត ដែលប្រកាសដោយលោកវីល្លៀមមីលើរ និងអ្នកបំរើរបស់ព្រះដែលបានលើកឡើងក្នុងវិញ្ញាណនិងអំណាចរបស់អេលីយ៉ាដើម្បីប្រកាសដំណឹងល្អ។ អ្នកដែលប្រកាសពីដំណឹងដ៏ឧត្តមនេះដូចជាលោកយ៉ូហាន ជាអ្នកនាំមុខរបស់ព្រះយេស៊ូវជាដើម បានបង្ខំអោយដាក់ពូថៅនៅឫសឈើនិងបានត្រាស់ហៅពីហ្វូងមនុស្សឱ្យបង្កើតផលផ្លែនៃការកែប្រែចិត្ត។ ទីបន្ទាល់របស់គេត្រូវបានគន់គូរអោយ

កើតឡើង និងមានប្រសិទ្ធិភាពយ៉ាងមានអំណាច ដល់ពួកជំនុំនិងបង្ហាញអំពីអត្តចរិតពិតប្រាកដរបស់ខ្លួន ។ ហើយនៅពេលដែលគេបានលើកឡើងនូវការព្រមានដ៏ឧត្តមអោយគេចេញពីការក្រោធដែលនឹងមកដល់មនុស្សជាច្រើនដែលបានរួបរួមជាមួយពួកជំនុំ បានទទួលដំណឹងនៃការព្យាបាល គេបានឃើញការប្រព្រឹត្តិខុសរបស់គេ ហើយបានបន្ទាបខ្លួនគេនៅចំពោះព្រះ ដោយទឹកភ្នែកដ៏ជូរចត់នៃការកែប្រែចិត្ត និងការឈឺចាប់ខាងព្រលឹងយ៉ាងជ្រាលជ្រៅ ។ ហើយនៅពេលដែលព្រះវិញ្ញាណបរិសុទ្ធបានសណ្ឋិតលើពួកគេ គេបានជួយប្រកាសនូវសំរែកថា ចូរកោតខ្លាចព្រះ និងថ្វាយសិរីល្អដល់ទ្រង់ចុះ ដ្បិតការជំនុំជំរះរបស់ទ្រង់បានមកដល់ហើយ ។

ការអធិប្បាយអំពីពេលវេលាច្បាស់លាស់ បានធ្វើឱ្យមានការប្រឆាំងយ៉ាងធំកើតឡើងពីគ្រប់ស្រទាប់ ពីគ្រូគង្វាលនៃអាសនាវហូតដល់មនុស្សល្វិតល្វង់បំផុតជាអ្នកមានបាបដែលខ្លាចស្ថានសួគ៌ ។ ឯត្រង់ថ្ងៃនិងពេលកំណត់នោះគ្មានអ្នកណាដឹងទេ ត្រូវបានឮតាំងពីអ្នកមានបាបដ៏កំពុត និងអ្នកចំអកមើលងាយដែលឥតកោតខ្លាច ។ ក៏មិនដែលត្រូវបានបង្រៀនឬកែតម្រូវលើការប្រើប្រាស់មានធ្វើនៅក្នុងខគម្ពីរដោយអ្នកដែលបានចង្អុលបង្ហាញឆ្នាំដែលគេបានជឿថា ពេលវេលានៃបទទំនាយនឹងបានបញ្ចប់និងដល់ពេលវេលាដែលបង្ហាញថា ព្រះគ្រីស្ទជិតមកដល់គឺដល់មាត់ទ្វារហើយ ។ អ្នកគង្វាលចៀមជាច្រើនដែលអះអាងថាគេស្រឡាញ់ព្រះយេស៊ូវ បាននិយាយថា គេគ្មានការប្រឆាំងនិងការអធិស្ឋានអំពីការយាងមកវិញរបស់ព្រះគ្រីស្ទឡើយ ប៉ុន្តែគេទាត់ចោលពេលវេលាច្បាស់លាស់ ។ ព្រះនេត្រដែលឃើញធ្លុះរបស់ព្រះយេស៊ូវបានស្គាល់ចិត្តរបស់គេ ។ គេមិនចូលចិត្តព្រះយេស៊ូវនៅជិតទេ គេបានដឹងថា ជីវិតមិនមែនគ្រីស្ទានរបស់គេ មិនអាចនៅបាននឹងការសាកល្បងបានទេ ព្រោះគេមិនបានដើរតាមផ្លូវនៃការបន្ទាបខ្លួនដែលព្រះបានរៀបចំអោយនោះឡើយ ។ អ្នកគង្វាលក្លែងក្លាយទាំងនេះបានឈរនៅ



តាមផ្លូវនៃការងាររបស់ព្រះ ។ ស្តេចនេះបាននិយាយក្នុងអំណាចនៃជំនឿរបស់វាទៅកាន់មនុស្សទាំងឡាយ ដាស់គេអោយក្រោកឡើង ហើយដូចជាឆ្មាំគុកដែលបានសួរថា តើខ្ញុំត្រូវធ្វើយ៉ាងណាដើម្បីអោយបានសង្គ្រោះ ។ ប៉ុន្តែអ្នកគង្វាលទាំងនេះបានឈរនៅចំពោះសេចក្តីពិត ហើយមនុស្សបានប្រកាសដោយរលូននូវរឿងរ៉ាវទាំងឡាយដែលនាំគេចេញពីសេចក្តីពិត ។ ពួកគេបានរួបរួមជាមួយសាតាំង និងទេវតារបស់វា ហើយស្រែកថាសេចក្តីសុខសាន្ត សេចក្តីសុខសាន្ត នៅពេលដែលគ្មានសេចក្តីសុខសាន្ត ។ ខ្ញុំបានឃើញថាទេវតានៃព្រះបានកត់សំគាល់ទាំងអស់ ហើយអាវផាយរបស់អ្នកគង្វាលដែលមិនលះ-បង់ ត្រូវបានគ្របដណ្តប់ដោយឈាមមនុស្ស អ្នកដែលចូលចិត្តការសប្បាយរបស់ខ្លួននឹងនៅឆ្ងាយពីព្រះ និងងើបចេញពីសេចក្តីវេទនាខាងលោកិយ៍មិនរួចឡើយ ។

គ្រូគង្វាលជាច្រើនមិនបានទទួលដំណឹងនេះឡើយ ហើយអ្នកដែលទទួលដំណឹងនេះ គេបានរារាំង ។ ឈាមរបស់មនុស្សធ្លាក់មកលើពួកគេ ។ គ្រូអធិប្បាយនិងមនុស្សបានរួបរួមគ្នាប្រឆាំងនឹងដំណឹងពីស្ថានសួគ៌នេះ ។ ពួកគេបានបៀតបៀនវិលៀម-មីលើរ និងអ្នកដែលបានរួបរួមជាមួយគាត់ធ្វើការងារនេះ ។ ពាក្យកុហកត្រូវបានគេផ្សព្វផ្សាយ ដើម្បីធ្វើអោយខូចប្រយោជន៍ដល់ឥទ្ធិពលរបស់គាត់ ហើយមានពេលជាច្រើនបន្ទាប់ពីបានប្រកាសយ៉ាងត្រង់ៗ នូវអ្វីដែលជាឱវាទរបស់ព្រះ ដោយអនុវត្តសេចក្តីពិតដ៏មុះមុត ទៅកាន់ចិត្តនៃអ្នកស្តាប់របស់គាត់ គេបានបង្កកំហឹងឡើងទាស់នឹងគាត់ ហើយនៅពេលដែលគាត់បានចាកចេញពីកន្លែងប្រជុំ មានមនុស្សខ្លះបាន ស្ទាក់ផ្លូវគាត់ដើម្បីសម្លាប់គាត់ ។ ប៉ុន្តែព្រះបានចាត់ទេវតារបស់ទ្រង់ អោយមកការពារអាយុជីវិតរបស់គាត់ អោយរួចពីពួកមនុស្សដែលមានកំហឹង ។ ការងាររបស់គាត់មិនទាន់ចប់ទេ ។

អ្នកជឿជាច្រើនបានទទួលដំណឹងនេះដោយរីករាយ ។ ពួកគេបានដឹងថាដំណឹងនេះមកពីព្រះ ហើយត្រូវបានគេចែកចាយចំពេលវេលា ។ ទេវតាបានទតមើលដោយការ

ចាប់អារម្មណ៍យ៉ាងជ្រាលជ្រៅនូវលទ្ធផលនៃដំណឹងពីស្ថានសួគ៌ និងនៅពេលដែលពួកជំនុំបានងាកចេញនិងបដិសេធដំណឹងនោះ។ លោកបានពិភាក្សាជាមួយព្រះយេស៊ូវយ៉ាងក្រៀមក្រំ។ ព្រះយេស៊ូវបានបែរព្រះភ័ក្ត្រចេញពីពួកជំនុំ ហើយបង្គាប់ទៅទេវតាអោយថែរក្សាអ្នកមានតម្លៃណាដែលបានបដិសេធនូវទីបន្ទាល់នោះ ដ្បិតពន្លឺមួយទៀតមិនបានចាំងទៅលើពួកគេនៅឡើយទេ។

ខ្ញុំបានឃើញថា ប្រសិនបើអ្នកដែលអះអាងថាជាគ្រីស្ទាន បានស្រឡាញ់ការលេចមកនៃព្រះអង្គសង្គ្រោះរបស់គេ ប្រសិនបើគេបានដាក់សេចក្តីស្រឡាញ់របស់គេទៅលើទ្រង់ ប្រសិនបើគេបានដឹងថាគ្មានអ្នកណាមួយនៅលើផែនដីនេះអាចប្រៀបផ្ទឹមជាមួយទ្រង់បានទេ គេនឹងមានអំណរដូចផ្លេកបន្ទោរនៅគ្រានៃការយាងមកយ៉ាងស្និទ្ធស្នាលលើកទីមួយទៅហើយ។ ប៉ុន្តែគេបានបង្ហាញការមិនពេញចិត្តទៅវិញ នៅពេលដែលគេឮអំពីការយាងមកនៃព្រះអម្ចាស់របស់គេ មានភស្តុតាងនៃការសំរេចចិត្តថា គេមិនបានស្រឡាញ់ទ្រង់ឡើយ។ សាតាំងនិងទេវតារបស់វាមានជ័យជំនះ ហើយគ្រវែងជ័យជំនះរបស់វាទៅលើព្រះភ័ក្ត្ររបស់ព្រះគ្រីស្ទនិងទេវតាបរិសុទ្ធរបស់ទ្រង់ថាអ្នកដែលជឿរបស់ទ្រង់មានសេចក្តីស្រឡាញ់ទៅលើព្រះយេស៊ូវតិចណាស់ ដែលទ្រង់មិនចាំបាច់ប្រាថ្នាយាងមកជាលើកទីពីរឡើយ។

ខ្ញុំបានឃើញរាស្ត្ររបស់ព្រះរីករាយក្នុងការត្រួតពិនិត្យសំឡឹងរកព្រះអម្ចាស់របស់គេ។ ហើយព្រះបានរៀបចំបញ្ជាក់ដល់ពួកគេ។ ព្រះហស្តរបស់ទ្រង់កាន់ការគន់គូរខុសនៃរយៈពេលនៃបទទំនាយ។ អ្នកដែលកំពុងរង់ចាំព្រះអម្ចាស់មិនបានដឹងពីរឿងនោះឡើយ ហើយអ្នករៀនច្រើនបំផុតដែលប្រឆាំងនឹងពេលវេលា ក៏មិនបានឃើញកំហុសនោះដែរ។ ព្រះបានរៀបចំថារាស្ត្ររបស់ទ្រង់ត្រូវជួបការខកចិត្ត។ ពេលវេលាបានកន្លងផុតទៅ ហើយអ្នកដែលបានសំឡឹងដោយការរំពឹងយ៉ាងអំណរនូវព្រះអង្គ



សង្គ្រោះរបស់គេ បានក្រៀមក្រំ និងធ្លាក់ទឹកចិត្តនៅពេលដែលអ្នកដែលគេមិនស្រឡាញ់ការលេចមករបស់ព្រះយេស៊ូវ ប៉ុន្តែទទួលដំណឹងនោះ ដោយភ័យខ្លាចបានអរសប្បាយដោយទ្រង់មិនបានយាងមកតាមពេលដែលគេបានរំពឹងទុក។ ជំនឿរបស់គេមិនបានប៉ះ-ពាល់ដល់ចិត្តរបស់គេ និងសំអាតជីវិតគេទេ។ ការកន្លងផុតទៅនៃពេលវេលា ត្រូវបានគេគិតគូរយ៉ាងត្រឹមត្រូវដើម្បីបង្ហាញពីចិត្តបែបនេះ។ ពួកគេជាមនុស្សដំបូងដែលបែរចេញ និងចំអកអោយអ្នកដែលក្រៀមក្រំ និងខកចិត្តដែលពិតជាស្រឡាញ់ការលេចមកនៃព្រះអង្គសង្គ្រោះរបស់គេ។ ខ្ញុំបានឃើញព្រះតម្រិះរបស់ព្រះក្នុងការបញ្ជាក់ដល់រាស្ត្ររបស់ទ្រង់ និងបានប្រទានដល់គេនូវការសាកល្បងរកអ្នកដែលនឹងគេច និងបែរក្រោយនៅក្នុងគ្រាលំបាក។

ព្រះយេស៊ូវនិងទេវតានៃស្ថានសួគ៌ទាំងអស់បានទតមើលដោយអាណិតអាសូរនិងស្រឡាញ់មកលើអ្នក ដែលទន្ទឹងរង់ចាំដោយក្តីរំពឹងដ៏ផ្អែមល្ហែម ចាំជួបអ្នកដែលគេស្រឡាញ់។ ទេវតាបានហោះសំកាំងនៅពីលើពួកគេ និងទ្រទ្រង់គេនៅក្នុងគ្រាលំបាករបស់គេ។ អ្នកដែលមិនរវីរវល់នឹងដំណឹងនៃស្ថានសួគ៌ ត្រូវបានទុកនៅក្នុងភាពងងឹត ហើយសេចក្តីក្រោធរបស់ព្រះបានពុះពោរឡើងទាស់នឹងពួកគេ ព្រោះគេមិនបានទទួលពន្លឺដែលទ្រង់បានប្រទានអោយគេពីស្ថានសួគ៌មក។ អ្នកស្មោះត្រង់ជាអ្នកខកចិត្តដែលមិនបានយល់អំពីថា តើហេតុអ្វីដែលព្រះមិនបានយាងមក មិនត្រូវបានទុកនៅក្នុងងងឹតឡើយ។ ព្រះបាននាំគេទៅរកព្រះគម្ពីរម្តងទៀតដើម្បីស្វែងរករយៈពេលនៃបទទំនាយ។ ព្រះហស្តរបស់ព្រះអម្ចាស់ត្រូវបានរំកិលចេញពីលេខនិងកំហុសបានពន្យល់។ គេបានឃើញថា រយៈពេលនៃបទទំនាយបានចប់នៅឆ្នាំ១៨៤៣ បង្ហាញថាវានឹងត្រូវបញ្ចប់នៅឆ្នាំ១៨៤៤។ ពន្លឺពីព្រះបន្ទូលនៃព្រះបានចាំងមកលើទីតាំងរបស់គេ ហើយគេបានរកឃើញពេលវេលានៃការបង្អែបង្អង់ ប្រសិនបើការបើកសំដែងបង្អែបង្អង់ ចូររង់ចាំចុះ

នៅក្នុងសេចក្ដីស្រឡាញ់ចំពោះការយាងមកវិញភ្លាមៗរបស់ព្រះយេស៊ូវ គេបានពិនិត្យមើលការពន្យាពេលនៃការបើកសំដែង ដែលត្រូវបានគេគន់គូរដើម្បីបញ្ជាក់ពីពេលដែលគេបានរង់ចាំ។ គេក៏មានចំណុចនៃពេលវេលាមួយទៀត។ ខ្ញុំនៅតែបានឃើញថា ពួកគេជាច្រើនមិនអាចងើបរួចពីការធ្លាក់ទឹកចិត្តដ៏ធ្ងន់នោះ ដើម្បីមានកម្រិតថាមពលដែលបានកត់សំគាល់អំពីសេចក្ដីជំនឿរបស់គេ នៅឆ្នាំ ១៨៤៣ នោះឡើយ។

សាតាំងនិងទេវតារបស់វា មានជ័យជំនះមកលើពួកគេ ហើយអស់អ្នកដែលមិនបានទទួលដំណឹងនោះ បានអបអរសាទរដោយខ្លួនឯងជាមួយនឹងការជំនុំជំរះដ៏មានជោគជ័យនិងប្រាជ្ញារបស់គេក្នុងការមិនទទួលគំនិតភ័ន្តភាំងដែលគេបានហៅ។ ពួកគេមិនបានដឹងថា គេកំពុងបដិសេធឱវាទរបស់ព្រះទាស់នឹងខ្លួនឯងទេ ហើយនិងមិនដឹងថាគេកំពុងតែធ្វើការរួបរួមជាមួយនឹងសាតាំងនិងទេវតារបស់វាដើម្បីធ្វើអោយរាស្ត្ររបស់ព្រះបានចាកចេញពីដំណឹងដែលចេញពីស្ថានសួគ៌នោះដែរ។

អ្នកដែលជឿទៅលើដំណឹងនេះ ត្រូវបានគេសង្កត់សង្កិននៅក្នុងពួកជំនុំ។ ការភ័យខ្លាចបានគ្របសង្កត់ពួកជំនុំមួយរយៈ ដូច្នេះគេមិនបានបញ្ចេញសកម្មភាពដូចជាការដែលគេបានគិតនៅក្នុងចិត្តឡើយ ប៉ុន្តែការកន្លងទៅនៃពេលវេលា បានបង្ហាញពីអារម្មណ៍នៃសេចក្ដីពិតរបស់គេ។ គេមានបំណងលាក់បាំងទីបន្ទាល់ដែលអ្នកជឿបានបញ្ចេញថារយៈពេលនៃបទទំនាយ បានពន្យារហូតដល់ឆ្នាំ១៨៤៤។ គេបានពន្យល់នូវកំហុសរបស់គេយ៉ាងច្បាស់លាស់ និងប្រាប់ហេតុផលថា តើហេតុអ្វីបានជាគេរំពឹងថាព្រះអម្ចាស់របស់គេនឹងយាងមក នៅឆ្នាំ១៨៤៤។ ពួកអ្នកប្រឆាំងមិនអាចបញ្ចេញការប្រកែកណាមួយទាស់នឹងហេតុផលដ៏មានអំណាចដែលគេបានផ្ដល់អោយនោះទេ។ កំហឹងរបស់ពួកជំនុំក៏បានបង្កឡើងទាស់នឹងពួកគេ។ គេបានប្ដេជ្ញាចិត្តថានឹងមិនស្ដាប់ភស្តុតាងណាមួយឡើយ និងត្រូវបិទទីបន្ទាល់នេះពីពួកជំនុំ ដើម្បីកុំអោយអ្នកដទៃទៀត



បានឮ។ អ្នកដែលមិនហ៊ានទទួលយកពីអ្នកដទៃនូវពន្លឺដែលព្រះបានប្រទានអោយគេត្រូវបានបណ្ដេញចេញពីពួកជំនុំ ប៉ុន្តែព្រះយេស៊ូវបានគង់នៅជាមួយពួកគេ ហើយគេរីករាយក្នុងពន្លឺនៃព្រះភ័ក្ត្ររបស់ទ្រង់។ ពួកគេបានរៀបរយខ្លួនទទួលសាររបស់ទេវតាទីពីរ។

សូមអាន ដានីយ៉ែល ៨:១៤ ហាបាគុក ២:១-៤ ម៉ាឡាគី ជំពូក ៣និង៤ ម៉ាថាយ ២៤:៣៦ វិវរណៈ ១៤:៦-៧។

## ជំពូកទី២៤
## សាររបស់ទេវតាទីពីរ

ពួកជំនុំមិនបានទទួលពន្លឺនៃសាររបស់ទេវតាទីមួយឡើយ ហើយនៅពេលដែលពួកគេបដិសេធពន្លឺមកពីស្ថានសួគ៌ គេបានធ្លាក់ពីសេចក្ដីស្រឡាញ់របស់ព្រះ។ គេបានទុកចិត្តលើកម្លាំងរបស់គេផ្ទាល់ ហើយបានដាក់ខ្លួនគេជាអ្នកប្រឆាំងនឹងសាររបស់ទេវតាទីមួយដែលគេមិនអាចឃើញពន្លឺនៃសាររបស់ទេវតាទីពីរឡើយ។ ប៉ុន្តែអ្នកជាទីស្រឡាញ់របស់ព្រះដែលត្រូវគេជិះជាន់ បានឆ្លើយទៅនឹងសារនេះថា បាប៊ីឡូនបានរលំហើយ ហើយបានចាកចេញពីពួកជំនុំដែលដួលរលំនោះទៅ។

នៅជិតចុងបញ្ចប់នៃសាររបស់ទេវតាទីពីរ ខ្ញុំបានឃើញពន្លឺដ៏ធំពីស្ថានសួគ៌ចាំងមកលើរាស្ត្ររបស់ព្រះ។ កាំរស្មីនៃពន្លឺនេះភ្លឺដូចព្រះអាទិត្យ។ ហើយខ្ញុំបានឮសំឡេង របស់ទេវតាស្រែកឡើងថា នុ៎ះន៏! កូនកំឡោះមកហើយ ចូរចេញទៅជួបលោកចុះ។

សម្រែកពាក់កណ្ដាលអាធ្រាត្រ ត្រូវបានផ្ដល់មក ដើម្បីផ្ដល់អំណាចដល់សារ

របស់ទេវតាទីពីរ ។ ព្រះបានចាត់ទេវតាពីស្ថានសួគ៌ ដើម្បីដាក់ពួកបរិសុទ្ធដែលបាត់បង់សេចក្តីក្លាហាន និងរៀបចំគេសំរាប់ការងារដ៏ធំនៅចំពោះមុខគេ ។ អ្នកដែលមានទេពកោសល្យខ្ពស់បំផុត មិនមែនជាអ្នកទីមួយដែលទទួលសារនេះទេ ។ ព្រះបានចាត់ទេវតាអោយទៅឯអ្នកបន្ទាបខ្លួន អ្នកដែលជឿស៊ប់ ហើយបង្ខំគេអោយស្រែកថា នុ៎ះន៏! កូនកំឡោះ ចូរចេញទៅទទួលលោកចុះ ។ អ្នកដែលបានឮ ក៏ទទួលសំរែកនេះ ហើយប្រញាប់ប្រញាប់ផ្សព្វផ្សាយសំរែកនេះនៅក្នុងអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ និងដាស់បងប្អូនដែលបាក់ទឹកចិត្តអោយក្រោកឡើង ។ សំរែកនេះ មិនបានឈរនៅលើប្រាជ្ញានិងការសិក្សារបស់មនុស្សទេ ប៉ុន្តែនៅលើអំណាចរបស់ព្រះ និងពួកបរិសុទ្ធដែលបានឮសំរែកនេះហើយ ក៏ទទួលយក ។ អ្នកដែលមានព្រលឹងវិញ្ញាណខ្ពស់បំផុតទទួលសារនេះមុនគេ ហើយអ្នកដែលធ្លាប់ត្រូវគេដឹកនាំក្នុងការងារនេះ គឺជាអ្នកទទួលក្រោយបង្អស់និងជួយអោយសំរែកថា នុ៎ះន៏! កូនកំឡោះបានមកដល់ហើយ ចូរចេញទៅទទួលលោកចុះ បានល្អប្រសើរហើយ ។

នៅគ្រប់ទីកន្លែងនៃផែនដី ព្រះបានប្រទានពន្លឺមកលើសាររបស់ទេវតាទីពីរ ហើយសំរែកនោះបានរលាយទៅក្នុងមនុស្សរាប់ពាន់នាក់ ។ វាបានធ្វើដំណើរពីទីក្រុងមួយទៅទីក្រុងមួយ ពីភូមិមួយទៅភូមិមួយ រហូតដល់អ្នករង់ចាំរបស់ព្រះបានក្រោកឡើងយ៉ាងពេញលេញ ។ មានមនុស្សជាច្រើនមិនបានអនុញ្ញាតអោយដំណឹងនេះចូលទៅក្នុងពួកជំនុំឡើយ ហើយមនុស្សមួយក្រុមធំដែលមានទីបន្ទាល់រស់នៅក្នុងចិត្តគេបានចាកចេញពីពួកជំនុំដែលធ្លាក់ចុះនោះ ។ ការងារដ៏មានព្រះចេស្តាត្រូវបានបញ្ចប់ដោយសំរែកនាពេលកណ្តាលអាធ្រាត្រ ។ ដំណឹងនេះត្រូវបានគេស្វែងរកអស់ពីចិត្ត ហើយបានដឹកនាំពួកអ្នកជឿអោយស្វែងរកបទពិសោធន៍ដ៏រស់នោះដោយខ្លួនឯង ។ គេបានដឹងថា គេមិនអាចរៀនពីគ្នាទៅវិញទៅមកបានឡើយ ។



ពួកបរិសុទ្ធបានរង់ចាំយ៉ាងអន្ទះសារនូវព្រះអម្ចាស់របស់គេ ទាំងតមអាហារ ចាំយាម និងអធិស្ឋានសឹងតែឥតឈប់ឈរ ។ ទោះបីជាអ្នកមានបាបខ្លះបានរង់ចាំនូវពេលវេលាខុសដោយទន្ទឹងក៏ដោយ នៅពេលដែលពិធីម៉ាស់ដ៏ធំហាក់ដូចជាត្រូវបានគេកកូរកកាយដំណឹងនេះឡើងវិញ និងបានបញ្ចេញអោយឃើញវិញ្ញាណរបស់សាតាំង ។ គេបានចំអក និងបញ្ឈឺ ហើយគេបានឮនៅគ្រប់ទីកន្លែងទាំងអស់ ឯត្រង់ថ្ងៃនិងពេលកំណត់នោះ គ្មានអ្នកណាដឹងទេ ។ ទេវតារបស់អារក្សបានសំដែងសេចក្តីអរសប្បាយនៅជុំវិញគេ ជំរុញគេ ធ្វើអោយចិត្តគេរឹង ហើយបដិសេធនូវរាល់កម្មរស្មីនៃពន្លឺមកពីស្ថានសួគ៌ដែលនឹងទម្លាក់គេទៅក្នុងអន្ទាក់ ។ មនុស្សជាច្រើនបានតាំងចិត្តរង់ចាំព្រះអម្ចាស់របស់គេដែលមិនមានទាំងចំណែកនិងវាសនានៅក្នុងរឿងនេះឡើយ សិរីល្អរបស់ព្រះដែលគេបានធ្វើទីបន្ទាល់ ការបន្ទាបខ្លួន និងការលះបង់យ៉ាងជ្រាលជ្រៅរបស់អ្នករង់ចាំ និងទម្ងន់ដ៏ធ្ងន់នៃភស្តុតាងដែលបណ្តាលអោយគេព្រមទទួលសេចក្តីពិត ។ ប៉ុន្តែគេមិនបានជឿឡើយ ។ គេមិនបានរៀបចំខ្លួនឡើយ ។ វិញ្ញាណនៃការអធិស្ឋានដ៏ស្មោះត្រង់និងមុះមុត និងគ្រប់ទិសទីដោយពួកបរិសុទ្ធ ។ ភាពមុះមុតដ៏បរិសុទ្ធបាននៅលើគេ ។ ទេវតាដែលមានការចាប់អារម្មណ៍ដ៏ជ្រាលជ្រៅ បានទតមើលលទ្ធផល និងបានលើកអ្នកដែលបានទទួលសារនៃស្ថានសួគ៌ និងបានទាញគេនាំចេញពីរឿងរ៉ាវនៃលោកិយ៏អោយទទួលជំនួយដ៏ធំធេងពីរន្ធទឹកនៃសេចក្តីសង្គ្រោះ ។ ពេលនោះរាស្ត្ររបស់ព្រះ ត្រូវបានព្រះទទួលជាមួយនឹងទ្រង់ ។ ព្រះយេស៊ូវបានទតមើលទៅពួកគេដោយរីករាយ ។ រូបរបស់ទ្រង់ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងពួកគេ ។ គេបានថ្វាយដង្វាយគ្រប់គ្រាន់ជាការឧទ្ទិស និងរំពឹងថាត្រូវបានផ្លាស់ប្តូរទៅជាមិនស្លាប់ ។ ប៉ុន្តែទ្រង់បានរៀបចំដើម្បីអោយត្រូវខកចិត្តយ៉ាងក្រៀមក្រំម្តងទៀត ។ ពេលវេលាដែលគេបានរង់ចាំភស្តុតាង ដែលគួរអោយរំពឹងបានកន្លងផុតទៅ ។ ពួកគេនៅតែនៅលើផែនដីដដែល ហើយផលនៃបណ្តាសាហាក់ដូច

ជាមិនបានឃើញផ្ទាល់ភ្នែកសោះ។ គេបានដាក់ទ្រព្យសម្បត្តិរបស់គេនៅឯស្ថានសួគ៌ ហើយក្នុងការរង់ចាំដ៏រំភើប យ៉ាងផ្អែមល្ហែម បានសាកល្បងការរំដោះ ដ៏មិនចេះស្លាប់ ប៉ុន្តែ សេចក្តីសង្ឃឹមរបស់គេ មិនត្រូវបានគេដឹងឡើយ។

ការភ័យខ្លាចដែលមានចំពោះមនុស្សជាច្រើនមិនបានរលាយបាត់ភ្លាមៗនោះទេ។ គេមិនអាចមានជ័យជំនះភ្លាមៗលើអ្នកដែលអស់សង្ឃឹមនោះឡើយ។ ប៉ុន្តែនៅពេលដែលគ្មានសេចក្តីក្រោធដាក់ស្តែងរបស់ព្រះបានធ្លាក់មកលើពួកគេ គេបានធូរស្បើយពីការភ័យខ្លាចដែលគេមាន ហើយបានចាប់ផ្តើមចំអកមើលងាយ និងបន្ទុះបង្អាប់។ រាស្ត្ររបស់ព្រះត្រូវបានទទួលការបញ្ជោក់ និងការសាកល្បងម្តងទៀត។ លោកិយ៍សើចចំអក និងស្តីបន្ទោសដល់ពួកគេ ហើយអ្នកដែលបានជឿដោយគ្មានការសង្ស័យថាព្រះយេស៊ូវនឹងយាងមក និងប្រោសអ្នកស្លាប់អោយរស់ឡើង និងផ្លាស់ប្តូរពួកបរិសុទ្ធដែលរស់នៅ ហើយយកនគរទ្រង់ និងឋិតនៅរៀងរហូតដូចជាសាវករបស់ព្រះ-គ្រីស្ទបានថែងថា គេបានយកព្រះអម្ចាស់ខ្ញុំទៅបាត់ ហើយខ្ញុំមិនដឹងជាគេទុកទ្រង់នៅឯណាទេ។

សូមអានម៉ាថាយ ២៤:៣៦, ២៥:៦ យ៉ូហាន ២០:១៣ វិវរណៈ ១៤:៨។

ជំពូកទី២៥

## ការពន្យល់ពីចលនាអាត់វេន

ខ្ញុំបានឃើញមនុស្សមួយចំនួនហាក់ដូចជាត្រូវបានគេចងភ្ជាប់គ្នាដោយខ្សែពួរ។ មនុស្សជាច្រើននៅក្នុងក្រុមទាំងនេះនៅក្នុងភាពងងឹតទាំងស្រុង។ ភ្នែករបស់គេត្រូវបាននាំតម្រង់ឆ្ពោះទៅខាងឯផែនដី ហើយហាក់ដូចជាគ្មានទំនាក់ទំនងរវាងគេនឹងព្រះយេ-



ស៊ូវទាល់តែសោះ។ ខ្ញុំបានឃើញមនុស្សម្នាក់ៗខ្ចាត់ខ្ចាយនៅក្នុងក្រុមទាំងនេះ ដែលទឹកមុខរបស់គេដូចជាពន្លឺ ហើយភ្នែករបស់គេងើយមើលឡើងទៅលើឆ្ពោះទៅស្ថានសួគ៌។ ឆាយាបថពីព្រះយេស៊ូវដូចជាកាំរស្មីនៃពន្លឺ នៅពេលដែលទេវតារបស់អារក្សព័ទ្ធជុំវិញអ្នកដែលនៅក្នុងភាពងងឹត។ ខ្ញុំបានឮសំឡេងទេវតាស្រែកឡើងថា ចូរកោតខ្លាចព្រះ ហើយថ្វាយសិរីល្អដល់ទ្រង់ចុះ ដ្បិតពេលជំនុំជំរះ របស់ទ្រង់បានមកដល់ហើយ។

ពន្លឺនៃសិរីល្អបានមកសណ្ឋិតនៅលើក្រុមមនុស្សទាំងនេះ ដើម្បីបំភ្លឺដល់អ្នកដែលនឹងទទួលវា។ អ្នកដែលនៅក្នុងភាពងងឹតខ្លះ បានទទួលពន្លឺនេះ និងមានអំណរនៅពេលដែលមនុស្សផ្សេងទៀតបដិសេធពន្លឺពីស្ថានសួគ៌ ហើយបាននិយាយថា វាគឺជាការបោកបញ្ឆោតដែលនាំអោយគេវង្វេង។ ពន្លឺនោះក៏រសាត់បាត់ចេញពីគេ ហើយទុកអោយពួកគេនៅក្នុងភាពងងឹត។ អ្នកដែលទទួលពន្លឺពីព្រះយេស៊ូវ អបអរសាទរដោយអំណរក្នុងកំណើននៃពន្លឺដ៏ភ្លឺដែលបានថែងចាំងលើពួកគេ។ មុខរបស់គេបានភ្លឺឡើង និងថែងចាំងដោយអំណរដ៏បរិសុទ្ធ នៅពេលដែលក្រសែភ្នែករបស់គេសំឡឹងទៅលើឆ្ពោះទៅឯព្រះយេស៊ូវដោយការចាប់អារម្មណ៍យ៉ាងខ្លាំងក្លា ហើយសំឡេងរបស់ពួកគេត្រូវបានគេឮឡើងជាមួយនឹងសំឡេងរបស់ទេវតាថា ចូរកោតខ្លាចព្រះ ហើយថ្វាយសិរីល្អដល់ទ្រង់ចុះ ដ្បិតថ្ងៃជំនុំជំរះរបស់ទ្រង់បានមកដល់ហើយ។ នៅពេលដែលគេបានលើកសម្រែកនេះឡើង ខ្ញុំបានឃើញអ្នកដែលនៅក្នុងទីងងឹត ចាក់ពួកគេដោយចំហៀងនិងស្មា។ ពេលនោះអ្នកដែលអបអរសាទរនឹងពន្លឺជាច្រើនបានផ្តាច់ចំណងដែលចងពួកគេ ហើយបានឈរបែកពីក្រុមទាំងនោះ។ ហើយនៅពេលដែលមនុស្សជាច្រើនកំពុងផ្តាច់ចំណងដែលចងគេនោះ មនុស្សដែលនៅក្នុងក្រុមផ្សេងៗទាំងនេះដែលពួកគេគោរព បានឆ្លងកាត់ក្រុមនោះជាមួយនឹងពាក្យពេចន៍ដែលធ្វើអោយរីករាយ និងខ្លះទៀតជាមួយនឹងបណ្តាសា និងកាយវិការគំរាមកំហែង ពាក់ខ្សែដែលផុយនោះនឹងបាននិយាយជាបន្ត-

បន្ទាប់ថា ព្រះអង្គគង់នៅជាមួយយើង។ យើងឈរនៅក្នុងពន្លឺ។ យើងមានសេចក្ដីពិត។ ខ្ញុំបានសួរថា តើមនុស្សទាំងនេះជានរណា? គេបានប្រាប់ខ្ញុំថា គេជាអ្នកដឹកនាំ និងជាគ្រូគង្វាលដែលបានបដិសេធពន្លឺដោយខ្លួនឯង ហើយនឹងមិនចង់អោយមនុស្សដទៃទទួលពន្លឺឡើយ។ ខ្ញុំបានឃើញអ្នកដែលអបអរជាមួយនឹងពន្លឺ កំពុងមើលទៅលើដោយចាប់អារម្មណ៏និងប៉ងប្រាថ្នាយ៉ាងក្លៀវក្លា ដោយរំពឹងថា ព្រះយេស៊ូវនឹងយាងមកយកពួកគេទៅឯទ្រង់។ រំពេចនោះពពកបានមកគ្របបាំងលើអ្នកដែលមានអំណរក្នុងពន្លឺ ហើយមើលមុខរបស់គេក្រៀមក្រំ។ ខ្ញុំបានសួរអំពីបុព្វហេតុនៃពពកនេះ។ គេបានបង្ហាញខ្ញុំថា ពពកនេះគឺជាការខកចិត្តរបស់គេ។ ពេលវេលាដែលគេបានរំពឹងពីព្រះអង្គសង្គ្រោះរបស់គេយាងមក បានកន្លងបាត់ទៅ ហើយព្រះយេស៊ូវមិនបានយាងមកទេ។ ការបាក់ទឹកចិត្តក៏បានកើតឡើងចំពោះពួកគេ ហើយមនុស្សដែលខ្ញុំបានឃើញពីមុនបានកត់សំគាល់ថាជាគ្រូគង្វាលនិងអ្នកដឹកនាំបានមានអំណរ។ អ្នកដែលបានបដិសេធពន្លឺ បានមានជ័យជំ-នះយ៉ាងធំ នៅពេលដែលសាតាំងនិងទេវតាអាក្រក់របស់វា ក៏បានអរសប្បាយនៅជុំវិញពួកគេដែរ។

ពេលនោះខ្ញុំបានឮសំឡេងទេវតាមួយទៀត ស្រែកឡើងថា ទីក្រុងបាប៊ីឡូនដ៏ជាធំបានរលំហើយ បានរលំហើយ។ ពន្លឺបានចាំងមកលើអ្នកដែលខកចិត្ត ហើយគេក៏បានចោលភ្នែករបស់គេទៅឯព្រះយេស៊ូវម្ដងទៀត ដោយសេចក្ដីប្រាថ្នានៃការលេចមករបស់ទ្រង់យ៉ាងក្លៀវក្លា។ ពេលនោះខ្ញុំបានឃើញទេវតាមួយចំនួនកំពុងសន្ទនាជាមួយនឹងទេវតាទីពីរ ដែលបានស្រែកថា ទីក្រុងបាប៊ីឡូនដ៏ជាធំ បានរលំហើយ បានរលំហើយ ហើយទេវតាទាំងនោះបានលើកសំឡេងលោកឡើងជាមួយនឹងទេវតាទីពីរដោយស្រែកថា មើលហ្ន៎! កូនកំឡោះបានមកដល់ហើយ ចូរចេញទៅទទួលលោកចុះ។ សំឡេងដូរ-តន្ត្រីនៃទេវតាទាំងនេះ ហាក់បីដូចជាឮកងរំពងគ្រប់ទិសទី។ ហើយពន្លឺដ៏មានសិរីល្អ



និងភ្លឺចាំងយ៉ាងក្រៃលែង បានចាំងជុំវិញអ្នកដែលអបអរសារទរនឹងពន្លឺដែលបានផ្ដល់អោយគេ។ មុខរបស់គេបានភ្លឺដោយសិរីល្អដ៏ប្រសើរ ហើយគេក៏បានរួបរួមជាមួយនឹងទេវតានៅក្នុងសម្រែក មើលហ្ន៎! កូនកំឡោះបានមកដល់ហើយ ហើយនៅពេលដែលពួកគេបានលើកសំឡេងស្រែកឡើងយ៉ាងស្រុះគ្នាក្នុងចំណោមក្រុមផ្សេងៗគ្នាទាំងនោះ អ្នកដែលបដិសេធពន្លឺបានរុញពួកគេ ហើយសំឡឹងមើលដោយខឹង ទាំងប្រមាថនិងចំអកមើលងាយដល់គេផង។ ប៉ុន្តែទេវតារបស់ព្រះ បានត្រដាងស្លាបរបស់លោកពីលើអ្នកដែលបៀតបៀនគេ នៅពេលដែលសាតាំង និងទេវតារបស់វាកំពុងប្រឹងប្រែងទម្លាក់ភាពងងឹត មកលើពួកគេ ដើម្បីដឹកនាំអោយគេបដិសេធពន្លឺពីស្ថានសួគ៌។

ពេលនោះ ខ្ញុំបានឮសំឡេងមួយទៀត ស្រែកឡើងទៅកាន់អ្នកដែលរុញនិងចំអកអោយគេនោះថា ចូរចេញពីពួកគេមក កុំអោយប៉ះពាល់អ្នកមិនស្អាតឡើយ។ គេក៏បានស្ដាប់តាមសំឡេងនោះ មនុស្សជាច្រើនបានផ្ដាច់ចំណង ដែលបានចងគេចេញ ហើយបានចាកចេញពីអ្នកដែលនៅក្នុងភាពងងឹត រួចចូលរួមជាមួយនឹងអ្នកដែលទើបនឹងផ្ដាច់ចំណងថ្មី ហើយគេក៏បានរួមសំឡេងជាមួយគ្នា។ ខ្ញុំបានឮសំឡេងអធិស្ឋានយ៉ាងស្មោះត្រង់ និងឈឺចាប់ពីមនុស្សមួយចំនួនតូចដែលសល់នៅក្នុងក្រុម ដែលនៅក្នុងភាពងងឹត។ គ្រូគង្វាល និងអ្នកដឹកនាំបានដើរជុំវិញក្រុមផ្សេងៗទាំងនេះ រឹតចំណងបន្ថែម ប៉ុន្តែ ខ្ញុំនៅតែឮសំឡេងអធិស្ឋានដ៏ស្មោះត្រង់ដដែល។ ពេលនោះខ្ញុំបានឃើញអ្នកដែលបានអធិស្ឋាន ហុចដៃរកជំនួយសំដៅទៅរកក្រុមមួយ ដែលរួបរួមគ្នាដែលមានសេរីភាពទាំងរីករាយជាមួយព្រះ។ ចម្លើយពីពួកគេនៅពេលដែលគេងើយមើលទៅស្ថានសួគ៌ដ៏ស្មោះស្ម័គ្រ និងចង្អុលទៅលើផងនោះគឺ ចូរចេញពីពួកគេមក កុំនៅជាមួយគេឡើយ។ ខ្ញុំបានឃើញថាម្នាក់ៗស្រវារកសេរីភាព ហើយទីបំផុត គេបានផ្ដាច់ចំណងដែលបានចងគេ។ គេបានតទល់ជាមួយនឹងកម្លាំងដែលបានរឹតចំណងគេអោយតឹងឡើង ហើយមិន

យកចិត្តទុកដាក់នឹងការអះអាងថា ព្រះគង់នៅជាមួយយើង យើងមានសេចក្តីពិតនៅជាមួយយើង។ មនុស្សម្នាក់ៗបានបន្តចាកចេញពីក្រុមទាំងឡាយ ដែលនៅក្នុងភាពងងឹត និងរួបរួមជាមួយនឹងក្រុមមួយដែលមានសេរីភាព ដែលលេចឡើងនៅវាលស្រឡះមួយពីលើផែនដី។ ខ្សែភ្នែករបស់គេសំឡឹងទៅលើ ហើយសិរីល្អរបស់ព្រះនៅពីលើពួកគេ ហើយគេបានស្រែកនូវសេចក្តីអធិស្ឋានរបស់ព្រះ។ គេបានរួបរួមគ្នា ហើយគេហាក់បីដូចជាត្រូវបានរុំដោយពន្លឺនៃស្ថានសួគ៌ នៅជុំវិញក្រុមមួយនេះ មានមនុស្សខ្លះបានមកក្រោមឥទ្ធិពលនៃពន្លឺ ប៉ុន្តែមិនបានរួបរួមពិតប្រាកដទៅក្នុងក្រុមនេះទេ។ អ្នកដែលអបអរសាទរនឹងពន្លឺដែលបានចាំងមកលើពួកគេ បានសំឡឹងមើលទៅលើដោយចាប់អារម្មណ៍យ៉ាងក្លៀវក្លា។ ព្រះយេស៊ូវបានទតមកលើពួកគេដោយការសព្វព្រះហឫទ័យដ៏ផ្អែមល្ហែម។ គេបានរំពឹងថាព្រះយេស៊ូវនឹងយាងមក។ គេចង់អោយព្រះអង្គលេចមក។ គេមិនបានចោលភ្នែកមើលការរារង់របស់ផែនដីឡើយ។ ខ្ញុំបានឃើញពពកមកនៅលើពួកអ្នករង់ចាំម្តងទៀត។ ខ្ញុំបានឃើញគេបែរភ្នែកដ៏ក្រៀមក្រំរបស់គេចុះក្រោម។ ខ្ញុំបានសួរអំពីបុព្វហេតុនៃការផ្លាស់ប្តូរនេះ។ ទេវតាដែលបានយាងតាមខ្ញុំ បានមានបន្ទូលថា គេបានខកចិត្តម្តងទៀតក្នុងការរង់ចាំរបស់គេ។ ព្រះយេស៊ូវមិនទាន់អាចយាងមកផែនដីទេ។ គេត្រូវតែរងទុក្ខព្រោះព្រះយេស៊ូវតទៅទៀត និងរងទ្រាំនូវការពិបាកយ៉ាងខ្លាំង។ ពួកគេត្រូវតែបោះបង់ចោលការខុសឆ្គង និងប្រពៃណីដែលគេទទួលពីមនុស្ស ហើយបែរទៅរកព្រះ និងព្រះបន្ទូលរបស់ទ្រង់ទាំងស្រុង។ ពួកគេត្រូវតែសំអាតធ្វើអោយសស្អុះដែលបានតស៊ូទ្រាំទ្រនឹងការលំបាកដ៏ជូរចត់នោះនឹងបានជ័យជំនះដ៏អស់កល្ប។

ព្រះយេស៊ូវមិនបានយាងមកកាន់ផែនដីនេះ ដើម្បីសំអាតទីបរិសុទ្ធតាមរយៈការសំអាតផែនដីដោយភ្លើង ដូចជាក្រុមដែលរង់ចាំដោយអំណរបានរំពឹងគិតនោះទេ។



ខ្ញុំបានឃើញថា ការគិតគូររយៈពេលនៃបទទំនាយបានត្រឹមត្រូវ។ ពេលវេលានៃបទទំនាយបានបិទ នៅឆ្នាំ១៨៤៤។ គេមានកំហុសដោយគេមិនយល់ថា តើទីបរិសុទ្ធ និងធម្មជាតិនៃការសំអាតទីបរិសុទ្ធគឺជាអ្វី។ ព្រះយេស៊ូវបានយាងចូលទៅក្នុងទីបរិសុទ្ធបំផុត ដើម្បីសំអាតទីបរិសុទ្ធនៅថ្ងៃចុងបំផុត។ ខ្ញុំបានមើលទៅក្រុមដែលរង់ចាំដោយខកចិត្តម្តងទៀត។ មើលទៅគេក្រៀមក្រំ។ គេបានពិនិត្យភស្តុតាងនៃសេចក្តីជំនឿរបស់គេដោយយកចិត្តទុកដាក់ ហើយតាមដានរហូតដល់ការគិតគូរអំពីរយៈពេលនៃបទទំនាយរបស់គេ តែមិនអាចឃើញមានកំហុសអ្វីសោះ។ ពេលវេលាបានសំរេចហើយ ហើយតើព្រះអង្គសង្គ្រោះនៅឯណា? គេបានបាត់បង់ទ្រង់។

ពេលនោះ គេបានបង្ហាញខ្ញុំអំពីការខកចិត្តរបស់ពួកសាវក នៅពេលដែលគេបានទៅឯផ្នូរ ហើយមិនឃើញព្រះសពព្រះយេស៊ូវ។ នាងម៉ារីបាននិយាយថាគេបានយកព្រះអម្ចាស់ចេញពីផ្នូរហើយ យើងខ្ញុំមិនដឹងថា គេយកទៅទុកឯណាទេ។ ទេវតាបានប្រាប់ដល់ពួកសាវកដែលកំពុងកើតទុក្ខថា ទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញហើយ មើលទ្រង់យាងទៅឯស្រុកកាលីឡេ មុនអ្នករាល់គ្នា។

ខ្ញុំបានឃើញថាព្រះយេស៊ូវបានទតមកលើអ្នកខកចិត្តដោយការអាណិតអាសូរយ៉ាងជ្រាលជ្រៅបំផុត ទ្រង់បានចាត់ទេវតាអោយទៅកែតម្រង់គំនិតរបស់គេថា គេនឹងអាចរកទ្រង់ឃើញ ហើយអោយទៅតាមទ្រង់នៅកន្លែងដែលទ្រង់បានយាងទៅ ដើម្បីអោយគេអាចយល់ថា ផែនដីនេះមិនមែនជាទីបរិសុទ្ធទេ ហើយថាទ្រង់ត្រូវតែយាងចូលទៅក្នុងទីបរិសុទ្ធបំផុតនៃរោងឧបោសថនៅស្ថានសួគ៌ ដើម្បីសំអាតទីបរិសុទ្ធនោះ ដើម្បីអោយធួននឹងបាបរបស់សាសន៍អ៊ីស្រាអែល និងដើម្បីទទួលនគររបស់ព្រះវរបិតាទ្រង់ រួចយាងត្រឡប់មកផែនដីវិញ ហើយយកពួកគេទៅនៅជាមួយនឹងទ្រង់ជារៀងរហូតតទៅ។

ការខកចិត្តរបស់ពួកសាវក បានបង្ហាញយ៉ាងត្រឹមត្រូវនូវការខកចិត្តរបស់ពួកអ្នកដែលរង់ចាំព្រះអម្ចាស់របស់គេ នៅឆ្នាំ១៨៤៤។ គេបាននាំខ្ញុំអោយត្រឡប់មកកាន់ពេលដែលព្រះយេស៊ូវយាងចូលទៅក្នុងទីក្រុងយេរូសាឡិមដោយជោគជ័យ។ ពួកសាវកដ៏រីករាយបានជឿថា ពេលនោះទ្រង់នឹងយកនគរ ហើយសោយរាជ្យជាស្តេចនៃលោកីយ៍។ គេបានដើរតាមស្តេចរបស់គេដោយក្តីសង្ឃឹម។ គេបានកាត់ធាងចាកនិងយកអាវរបស់គេក្រាលផ្លូវថ្វាយទ្រង់យាង ហើយខ្លះបានដើរពីមុខទ្រង់ ហើយខ្លះទៀតដើរតាមក្រោយ ស្រែកថា ហូសាណាដល់ព្រះវង្សហ្លួងដាវីឌ ព្រះអង្គដែលយាងមកដោយនូវព្រះនាមព្រះអម្ចាស់ ទ្រង់ប្រកបដោយព្រះពរ ហូសាណានៅស្ថានដ៏ខ្ពស់បំផុត ការរំភើបនេះបានរំខានដល់ពួកផារិស៊ី ហើយគេចង់អោយព្រះយេស៊ូវបន្ទោសដល់សាវករបស់ទ្រង់។ ប៉ុន្តែទ្រង់បានមានបន្ទូលទៅកាន់គេថា បើអ្នកទាំងនេះនៅស្ងៀម នោះថ្មនឹងស្រែកឡើងវិញ។ បទទំនាយនៃគម្ពីរសាការី ៩:៩ ត្រូវតែបានសំរេច ហើយខ្ញុំបានឃើញពួកសាវកបានផ្តន្ទាទោសដោយការខកចិត្តយ៉ាងជូរចត់។ ពីរបីថ្ងៃក្រោយមក គេបានដើរតាមព្រះយេស៊ូវទៅកាន់ភ្នំកាល់វ៉ារី ហើយបានឃើញគេបោះដែកគោលទ្រង់ជាប់នឹងឈើឆ្កាង។ គេបានឃើញការសុគតដ៏ឈឺចាប់របស់ទ្រង់ ហើយបានឃើញគេដាក់ទ្រង់ក្នុងផ្នូរ។ ចិត្តរបស់គេពោរពេញដោយទុក្ខព្រួយ។ ក្តីរំពឹងរបស់គេមិនបានសំរេចមួយចំរៀកតូចណាសោះឡើយ។ សេចក្តីសង្ឃឹមរបស់គេបានស្លាប់ជាមួយព្រះយេស៊ូវ។ ប៉ុន្តែនៅពេលដែលទ្រង់មានព្រះជន្មពីសុគតឡើងវិញ ហើយបានលេចមកឯពួកសាវកដ៏សោកសៅរបស់ទ្រង់ សេចក្តីសង្ឃឹមរបស់គេបានរស់ឡើងវិញ។ គេបានបាត់បង់ព្រះអង្គសង្គ្រោះរបស់គេ ប៉ុន្តែគេបានរកទ្រង់ឃើញវិញ។

ខ្ញុំបានឃើញថា ការខកចិត្តរបស់អ្នកដែលជឿលើការយាងមកវិញរបស់ ព្រះ-អម្ចាស់ នៅឆ្នាំ១៨៤៤ មិនស្មើនឹងការខកចិត្តរបស់ពួកសាវកឡើយ។ បទទំនាយត្រូវ



បានសំរេចក្នុងសាររបស់ទេវតាទីមួយ និងទេវតាទីពីរហើយ។ ទេវតាបានផ្តល់អោយចំពេលវេលា ហើយបានបំពេញការងារដែលព្រះបានរៀបចំអោយលោកធ្វើ។

សូមអានដានីយ៉ែល ៨:១៤ ម៉ាថាយ ២១:៤-១៦, ២៥:៦ ម៉ាកុស ១៦:៦-៧ វិវរណៈ ១០: ៨-១១, ១៤:៧-៨។

## ជំពូកទី២៦

## ការបកស្រាយមួយទៀត

ទេវតាបានបង្ហាញខ្ញុំ នូវការចាប់អារម្មណ៍នៃស្ថានសួគ៌ទាំងអស់ចំពោះការងារដែលបានធ្វើមកលើផែនដី។ ព្រះយេស៊ូវបានត្រាស់បង្គាប់ទេវតាដ៏ខ្លាំងពូកែ និងមានចេស្តាមួយអង្គ អោយចុះទៅប្រកាសប្រាប់ដល់មនុស្សនៅលើផែនដី អោយរៀបចំខ្លួនសំរាប់ការលេចមកជាលើកទីពីរ។ ខ្ញុំបានឃើញទេវតាដ៏មានចេស្តា ចាកចេញពីវត្តមានរបស់ព្រះយេស៊ូវនៅស្ថានសួគ៌។ ពន្លឺដ៏មានសិរីល្អនិងភ្លឺត្រចះត្រចង់បានធ្វើដំណើរមុនលោក។ ខ្ញុំត្រូវបានគេប្រាប់ថា បេសកកម្មរបស់ទេវតានោះ គឺទៅបំភ្លឺពិភពលោកដោយសិរីល្អរបស់លោកនិងប្រកាសប្រាប់ដល់មនុស្សអំពីការមកដល់នៃសេចក្តីក្រោធរបស់ព្រះ។ មនុស្សជាច្រើនបានទទួលពន្លឺ។ អ្នកខ្លះហាក់ដូចជាមាំមួនណាស់ នៅពេលដែលអ្នកខ្លះទៀត មានអំណរនិងអណ្តែតអណ្តូង។ ពន្លឺនោះបានចាំងទៅលើមនុស្សទាំងអស់ ប៉ុន្តែអ្នកខ្លះ គ្រាន់តែបានមកក្រោមឥទ្ធិពលនៃពន្លឺនោះតែប៉ុណ្ណោះ មិនបានទទួលវាដោយអស់ពីចិត្តឡើយ។ ប៉ុន្តែអ្នកបានទទួលពន្លឺនោះ បានបែរមុខរបស់គេទៅឯស្ថាន-សួគ៌ ហើយសរសើរតំកើងព្រះ។ មនុស្សជាច្រើនបានទទួលសេចក្តីក្រោធយ៉ាងធំ។ គ្រូគង្វាលនិងមនុស្សជាច្រើន បានរួបរួមជាមួយនឹងពួកអាក្រក់ ហើយប្រឆាំងនឹងពន្លឺ

ដែលចាំងដោយទេវតានោះយ៉ាងខ្លាំង។ ប៉ុន្តែអ្នកដែលបានទទួលពន្លឺនោះ បានទាញចេញពីលោកិយ៍ ហើយបានរួបរួមគ្នាយ៉ាងជិតស្និទ្ធ។ សាតាំងនិងទេវតារបស់វា បានធ្វើការយ៉ាងមមាញឹកក្នុងគំនិតមនុស្សទាំងឡាយ ដែលវាអាចធ្វើទៅបានអោយចេញពីពន្លឺនោះ។ ក្រុមដែលមិនទទួលពន្លឺនោះ ត្រូវបានទុកនៅក្នុងភាពងងឹត។ ខ្ញុំបានឃើញទេវតាបានពិនិត្យដោយការចាប់អារម្មណ៍យ៉ាងជ្រាលជ្រៅ លើអ្នកដែលមានជំនឿរបស់ព្រះដើម្បីកត់ត្រានូវអត្តចរិតដែលគេបានបង្កើតនៅពេល ដែលដំណឹងដែលមានប្រភពពីស្ថានសួគ៌ ត្រូវបានទេវតាបង្ហាញដល់គេ។ ហើយនៅពេលដែលមនុស្សជាច្រើនមានសេចក្តីស្រឡាញ់ដល់ព្រះយេស៊ូវបានបែរចេញពីដំណឹងនៃស្ថានសួគ៌ដោយប្រមាថមើលងាយ និងស្អប់ខ្ពើម នោះទេវតាដែលមានពន្លឺនៅនឹងព្រះហស្ត បានធ្វើបញ្ជីដ៏គួរអោយខ្មាស់។ ស្ថានសួគ៌ទាំងមូលបានពេញដោយការតូចចិត្ត ពីព្រោះព្រះយេស៊ូវត្រូវបានមើលងាយដោយអ្នកដែលអះអាងថា ជាសិស្សរបស់ទ្រង់។

ខ្ញុំបានឃើញអ្នកខកចិត្តដែលមានការស្មោះត្រង់។ គេមិនបានឃើញព្រះអម្ចាស់របស់គេនៅពេលដែលគេបានរំពឹងទុកនោះឡើយ។ វាគឺជាគោលបំណងរបស់ព្រះដែលលាក់ពីអនាគត និងនាំវាស្រ្តរបស់ទ្រង់ទៅកាន់ចំណុចនៃការសំរេចចិត្តមួយ។ ប្រសិនបើគ្មានចំណុចនៃពេលវេលានេះ មនុស្សនឹងមិនបំពេញការងារដែលព្រះបានរៀបចំនោះឡើយ។ សាតាំងបានដឹកនាំគំនិតមនុស្សច្រើនណាស់ទៅកាន់អនាគតយ៉ាងឆ្ងាយ។ រយៈពេលមួយដែលគេបានប្រកាសអំពីការលេចឡើងរបស់ព្រះគ្រីស្ទ ត្រូវតែចងគំនិតអោយស្វែងរកការរៀបចំយ៉ាងស្មោះត្រង់នៅពេលបច្ចុប្បន្ន។ នៅពេលដែលពេលវេលាបានកន្លងផុតទៅ អ្នកដែលមិនបានទទួលពន្លឺពីទេវតាសោះ បានរួបរួមជាមួយនឹងអ្នកដែលស្អប់ដំណឹងនៃស្ថានសួគ៌ ហើយគេបានទៅរកអ្នកខកចិត្តដោយមើលងាយ។ ខ្ញុំបានឃើញទេវតានៃស្ថានសួគ៌ពិភាក្សាជាមួយព្រះយេស៊ូវ។ លោកបានកត់សំ-



គាល់ស្ថានភាពរបស់ពួកសិស្សដែលជឿលើព្រះគ្រីស្ទ។ ការកន្លងផុតទៅនៃពេលវេលាដ៏ជាក់លាក់មួយ បានសាកល្បង និងពិសោធពួកគេ ហើយមានមនុស្សជាច្រើន ត្រូវបានថ្លឹងនៅជញ្ជីង ឃើញថាមានទម្ងន់មិនគ្រប់។ គេបានប្រកាសខ្លាំងៗថា គេជាគ្រីស្ទាន តែគេបរាជ័យក្នុងការធ្វើតាមព្រះគ្រីស្ទនៅគ្រប់ចំណុច។ សាតាំងបានសំដែងសេចក្តីរីករាយចំពោះអ្នកដែលជាសាវករបស់ព្រះគ្រីស្ទតែមាត់ក្រៅ។ វាមានពួកគេនៅក្នុងអន្ទាក់របស់វា។ វាបានដឹកនាំមនុស្សភាគច្រើនអោយចាកចេញពីផ្លូវត្រង់ ហើយវាចង់អោយមនុស្សឡើង ទៅកាន់ស្ថានសួគ៌តាមផ្លូវផ្សេងវិញ អ្នកស្អាតស្អំ និងអ្នកបរិសុទ្ធ លាយឡំជាមួយអ្នកមានបាបនៅទីក្រុងស៊ីយ៉ូន និងអ្នកកំពុតដែលស្រឡាញ់លោកិយ៍។ គេបានសំឡឹងមើលអ្នកដែលមានសេចក្តីស្រឡាញ់ពិត គឺព្រះយេស៊ូវ ប៉ុន្តែការពុករលួយរបស់វាបានបំផ្លាញភាពបរិសុទ្ធរបស់វា។

អ្នកដែលមានចិត្តពុះកញ្ជ្រោល ដោយការរង់ចាំក្នុងសេចក្តីប្រាថ្នា ដើម្បីជួបព្រះយេស៊ូវយ៉ាងខ្លាំងក្លាត្រូវពួកអ្នកដែលអះអាងថា បងប្អូនរបស់គេហាមឃាត់មិនអោយនិយាយពីការយាងមកឡើយ។ ទេវតាបានឃើញទិដ្ឋភាពទាំងអស់ ហើយបានអាណិតអាសូរដល់អ្នកសំណល់ដែលស្រឡាញ់ការលេចមកបស់ព្រះយេស៊ូវ។ ព្រះបានបង្គាប់ដល់ទេវតាដ៏មានចេស្តាមួយអង្គទៀត អោយចុះទៅផែនដី។ ព្រះយេស៊ូវបានដាក់សំណេរមួយទៅទេវតា ហើយនៅពេលដែលលោកយាងដល់ផែនដី លោកបានស្រែកថា បាប៊ីឡូនដ៏ជាធំ បានរលំហើយ បានរលំហើយ។ ពេលនោះ ខ្ញុំបានឃើញអ្នកខកចិត្តម្តងទៀត មានការរីករាយ ហើយងើបភ្នែកសំឡឹងមើលទៅស្ថានសួគ៌ដោយសេចក្តីជំនឿនិងក្តីសង្ឃឹមចំពោះការយាងមកនៃព្រះអម្ចាស់របស់គេ។ ប៉ុន្តែមានមនុស្សជាច្រើននៅក្នុងភាពវង្វេងដូចជាដេកលក់ដដែល តែខ្ញុំអាចឃើញស្នាមនៃសេចក្តីទុក្ខព្រួយយ៉ាងជ្រាលជ្រៅនៅនឹងមុខគេ។ អ្នកខកចិត្តបានឃើញពីក្នុងព្រះគម្ពីរថា គេនៅក្នុងពេលរារង់

និងថាពួកគេត្រូវតែរង់ចាំការសំរេចនៃការបើកសំដែងនេះដោយអត់ធ្មត់។ ភស្តុតាងដូចគ្នាដែលបានដឹកនាំគេអោយទន្ទឹងរង់ចាំព្រះអម្ចាស់របស់គេ នៅឆ្នាំ១៨៤៣ បានដឹកនាំគេអោយរំពឹងថា ទ្រង់នឹងយាងមកនៅឆ្នាំ១៨៤៤។ ខ្ញុំបានឃើញថាមនុស្សភាគច្រើនមិនបានមានថាមពលនោះ ដែលកត់សំគាល់សេចក្ដីជំនឿរបស់គេ នៅឆ្នាំ១៨៤៣ នោះទេ។ ការខកចិត្តរបស់គេបានធ្វើអោយសេចក្ដីជំនឿរបស់គេធ្លាក់ចុះ។ ប៉ុន្តែនៅពេលដែលអ្នកខកចិត្តបានរួបរួមគ្នាជាមួយនឹងសំរែករបស់ទេវតាទីពីរ ទេវតានៃស្ថានសួគ៌បានទតមើលដោយការចាប់អារម្មណ៍យ៉ាងខ្លាំង និងបានកត់សំគាល់ផលនៃដំណឹងនោះ លោកបានឃើញអ្នកដែលមានឈ្មោះនៃគ្រីស្ទាន បែរចេញដោយការស្អប់ខ្ពើម និងការប្រមាថដល់អ្នកដែលបានខកចិត្ត។ នៅពេលដែលពាក្យពេចន៍បានចេញពីបបូរមាត់របស់អ្នកចំអកឡកឡឺយថា អ្នកមិនទាន់ទៅទេ ឬទេវតាបានកត់ពាក្យនោះ។ ទេវតាបានមានបន្ទូលថា អ្នកបានប្រមាថព្រះហើយ។

ទេវតាបានចង្អុលបង្ហាញខ្ញុំត្រឡប់ទៅការបកស្រាយរបស់អេលីយ៉ា អាវរបស់គាត់បានធ្លាក់មកលើអេលីសេ នោះមានក្មេងប្រុសជំទង់ៗបានដើរតាមគាត់ដោយស្រែកចំអកថា អាទំពែកអើយ ចូរឡើងទៅចុះ អាទំពែកអើយ ចូរឡើងទៅចុះ គេបានចំអកអោយព្រះ ហើយបានបង្កាត់ភ្លើងទណ្ឌកម្មឡើង។ គេបានរៀនការនេះពីឪពុកម្ដាយគេមក។ ហើយអ្នកដែលបានមើលងាយនិងចំអកអោយគំនិតរបស់ពួកបរិសុទ្ធអំពីការឡើងទៅស្ថានសួគ៌នឹងបានជួបនូវការវេទនារបស់ព្រះ ហើយនឹងបានដឹងថា វាមិនមែនជារឿងតូចតាចដែលត្រូវលេងសើចជាមួយនឹងទ្រង់ឡើយ។

ព្រះយេស៊ូវបានត្រាស់បង្គាប់ដល់ទេវតាមួយអង្គទៀត អោយហោះយ៉ាងលឿនទៅកែតម្រូវ និងពង្រឹងសេចក្ដីជំនឿរបស់មនុស្សដែលបានធ្លាក់ចុះ និងរៀបចំពួកគេអោយយល់អំពីសាររបស់ទេវតាទីពីរ និងការសំរេចមួយដែលនឹងធ្វើឡើងនៅពេល



ឆាប់ៗនេះនៅស្ថានសួគ៌។ ខ្ញុំបានឃើញទេវតាទាំងនោះទទួលអំណាចនិងភ្លើងពីព្រះយេស៊ូវ ហើយហោះយ៉ាងលឿនទៅកាន់ផែនដី ដើម្បីបំពេញបេសកកម្មរបស់ខ្លួនជាជំនួយដល់ទេវតាទីពីរ នៅក្នុងការងាររបស់លោក។ ពន្លឺដ៏ធំបានចាំងមកលើរាស្ត្ររបស់ព្រះ នៅពេលដែលទេវតាបានស្រែកថា មើលហ្ន៎! កូនកំឡោះបានមកដល់ហើយ ចូរចេញទៅទទួលលោកចុះ។ នោះខ្ញុំបានឃើញអ្នកខកចិត្តក្រោកឡើង ហើយប្រកាសព្រមគ្នាជាមួយទេវតាទីពីរថា មើលហ្ន៎! កូនកំឡោះបានមកដល់ហើយ ចូរចេញទៅទទួលលោកចុះ។ ពន្លឺពីទេវតាកំចាត់ភាពងងឹតគ្រប់ទិសទី។ សាតាំងនិងទេវតារបស់វា បានស្វែងរកវិធីកំចាត់ពន្លឺនេះពីការរីករាលដាល និងពីការមានជោគជ័យនៃពន្លឺនោះ។ ពួកវាបានប្រជែងជាមួយទេវតារបស់ព្រះ ហើយជំរាបលោកថា ព្រះបានបោកបញ្ឆោតមនុស្ស និងថាលោកមិនអាចធ្វើអោយមនុស្សជឿថាព្រះយេស៊ូវនឹងយាងមកដោយសារពន្លឺ និងអំណាចរបស់លោកបានឡើយ។ ទេវតារបស់ព្រះបានបន្តការងាររបស់លោក ទោះបីជាសាតាំងខិតខំរាំងផ្លូវយ៉ាងខ្លាំង និងទាញគំនិតមនុស្សពីពន្លឺនោះក៏ដោយ។ អ្នកដែលបានទទួលពន្លឺនោះមើលទៅសប្បាយរីករាយជាខ្លាំង។ គេចោលភ្នែករបស់គេទៅស្ថានសួគ៌ ហើយរង់ចាំការយាងមករបស់ព្រះយេស៊ូវ។ ខ្លះមានកង្វល់ជាខ្លាំង គេយំនិងអធិស្ឋាន។ ភ្នែករបស់គេហាក់សំឡឹងមើលមកខ្លួនឯង គេមិនហ៊ានសំឡឹងមើលទៅលើឡើយ។

ពន្លឺដ៏ភ្លឺពីស្ថានសួគ៌បំបែកភាពងងឹតចេញពីពួកគេ ហើយភ្នែករបស់គេដែលបានដាក់ការអស់សង្ឃឹមមកលើពួកគេ បានបែរទៅលើនៅពេលដែលការដឹងគុណ និងអំណរដ៏បរិសុទ្ធបានសង្កត់មកលើអ្វីៗទាំងអស់។ ព្រះយេស៊ូវ និងពពួកទេវតានៃស្ថានសួគ៌ទាំងអស់បានទតមើលដោយក្ដីអំណរយ៉ាងខ្លាំង មកលើអ្នករង់ចាំដោយស្មោះត្រង់។ អ្នកដែលប្រឆាំងទៅនឹងពន្លឺនៃសាររបស់ទេវតាទីមួយ និងបាត់បង់នូវពន្លឺនៃទេវតាទីពីរ

និងមិនអាចបានទទួលផលប្រយោជន៍ពីអំណាច និងសិរីល្អដែលមានដំណឹងថា មើលហ្ន៎! កូនកំឡោះបានមកហើយ ចូរចេញទៅទទួលលោកចុះ នោះឡើយ។ ព្រះយេស៊ូវបានបែរចេញពីពួកគេដោយការចងចិញ្ចើម។ គេបានមើលងាយនិងបដិសេធទ្រង់។ អ្នកដែលបានទទួលដំណឹងនោះនឹងត្រូវបានរុំដោយពពកនៃសិរីល្អ។ គេបានរង់ចាំ ទាំងចាំយាម និងអធិស្ឋាន អោយដឹងពីព្រះហឫទ័យរបស់ព្រះ។ គេមិនហ៊ានធ្វើអោយទ្រង់អាក់អន់ព្រះទ័យឡើយ។ ខ្ញុំបានឃើញអារក្ស និងទេវតារបស់វាស្វះស្វែងបិទបាំងពន្លឺពីស្ថានសួគ៌នេះពីរាស្ត្ររបស់ព្រះ។ ប៉ុន្តែដរាបណាអ្នកដែលរង់ចាំបានអបអរសាទរនឹងពន្លឺនោះនឹងចោលភ្នែករបស់គេឡើងលើចេញពីផែនដីទៅឯព្រះយេស៊ូវ សាតាំងមិនអាចមានអំណាចនឹងដកហូតពន្លឺដ៏មានតម្លៃនោះចេញពីពួកគេបានទេ។ ដំណឹងដែលបានប្រទានមកពីស្ថានសួគ៌នេះ បានប្រយុទ្ធជាមួយសាតាំង និងទេវតារបស់វា និងអ្នកដែលគ្រាន់តែអះអាងថា ស្រឡាញ់ព្រះយេស៊ូវ ប៉ុន្តែគេបានស្អប់ការយាងមករបស់ទ្រង់ បានប្រមាថ និងមើលងាយអ្នកស្មោះត្រង់ដែលទុកចិត្តទ្រង់។ ប៉ុន្តែទេវតាបានកត់សំគាល់រាល់ការអាម៉ាស់ រៀងរាល់ការមើលងាយ រៀងរាល់ការរំលោភបំពាន ដែលគេបានទទួលពីបងប្អូនដែលគ្រាន់តែថាតែមាត់របស់គេប៉ុណ្ណោះ។ មនុស្សជាច្រើនបានបំពងសំឡេងរបស់គេស្រែកឡើងថា មើលហ្ន៎! កូនកំឡោះបានមកហើយ ហើយបានចាកចេញពីបងប្អូនរបស់គេ ដែលមិនបានស្រឡាញ់ការលេចមករបស់ព្រះយេស៊ូវ។ និងមិនអនុញ្ញាតអោយគេថ្លែងអំពីការយាងមកជាលើកទីពីររបស់ទ្រង់។ ខ្ញុំបានឃើញព្រះយេ-ស៊ូវ បានបែរព្រះភ័ក្រ្តចេញពីអ្នកដែលបដិសេធ និងស្អប់ការយាងមករបស់ទ្រង់ ហើយទ្រង់បានត្រាស់បង្គាប់ទេវតាអោយដឹកនាំរាស្ត្ររបស់ទ្រង់ចេញពីមនុស្សមិនស្អាតក្រែងពួកគេត្រូវបានបង្ខូច។ អ្នកដែលបានស្តាប់តាមដំណឹងនោះបានឈរយ៉ាងមានសេរីភាពនិងរួបរួមគ្នា។ ពន្លឺដ៏ល្អនិងបរិសុទ្ធបានចែងចាំងមកលើពួកគេ។ ពួកគេបានលះបង់



លោកិយ៍ចោល កាត់ផ្តាច់ទ្រព្យលោកិយ៍ចោល កាត់ផ្តាច់ទ្រព្យសម្បត្តិរបស់គេចេញពីលោកិយ៍ និងកំចាត់ការចាប់អារម្មណ៍នៃលោកីយ៍របស់គេចោល។ ពួកគេបានលះបង់ទ្រព្យសម្បត្តិរបស់គេចោល ហើយទេវតាបាននាំភ្នែកគេអោយសំឡឹងឆ្ពោះទៅស្ថានសួគ៌ដោយរំពឹងថា នឹងឃើញអ្នករំដោះជាទីស្រឡាញ់របស់គេ។ អំណរដ៏ពិសិដ្ឋនិងបរិសុទ្ធបានចាំងចែងមកលើទឹកមុខរបស់គេ និងបានប្រាប់ពីសេចក្តីសុខសាន្ត និងអំណរដែលគេបានសោយរាជ្យ។ ព្រះយេស៊ូវបានត្រាស់បង្គាប់អោយទេវតាទៅចំរើនកម្លាំងដល់គេដ្បិតពេលវេលានៃការពិបាករបស់គេនៅបន្តទៅទៀត។ ខ្ញុំបានឃើញថា អ្នកដែលរង់ចាំមិនទាន់បានអត់ធន់ដូចដែលគេត្រូវធ្វើនៅឡើយទេ។ គេមិនទាន់រួចពីការខុសឆ្គងទេ។ ហើយខ្ញុំបានឃើញថា សេចក្តីមេត្តាករុណា និងសេចក្តីល្អរបស់ព្រះក្នុងការបញ្ជូនការព្រមានដល់មនុស្សនៅផែនដី និងដំណឹងដដែលៗដើម្បីនាំពួកគេឡើងទៅកាន់ចំណុចនៃពេលវេលាមួយ ដើម្បីដឹកនាំគេអោយស្រាវជ្រាវយ៉ាងហ្មត់ចត់ដោយខ្លួនឯងថាពួកគេគួរតែដកខ្លួនចេញពីការខុសឆ្គងដែលត្រូវបានគេបន្តតាំងពីអ្នកមិនជឿ និងអ្នកប៉ាបនិយមមក។ តាមរយៈដំណឹងទាំងនេះ ព្រះបាននាំរាស្ត្ររបស់ទ្រង់ចេញដែលទ្រង់អាចធ្វើការសំរាប់ពួកគេក្នុងអំណាចដ៏ខ្លាំងក្លា និងដែលគេអាចរក្សាគ្រប់ទាំងបញ្ញត្តិរបស់ទ្រង់ទាំងអស់។

សូមអាន ពង្សាវតាក្សត្រទី២ ២:១១-២៥ ដានីយ៉ែល ៨:១៤
ហាបាគុក ២:១-៤ ម៉ាថាយ ២៥:៦ វិវរណៈ ១៤:៨, ១៨:១-៥។

## ជំពូកទី២៧

# **ទីបរិសុទ្ធ**

ពេលនោះ ខ្ញុំបានឃើញការខកចិត្តយ៉ាងធ្ងន់ធ្ងរនៃរាស្ត្ររបស់ព្រះ។ គេមិនបានឃើញព្រះយេស៊ូវនៅពេលដែលគេបានរំពឹងគិតឡើយ។ គេមិនដឹងថា តើហេតុអ្វីបានជាព្រះអង្គសង្គ្រោះរបស់គេមិនយាងមកដូច្នេះទេ។ គេមិនអាចឃើញភស្តុតាងអ្វីដែលបញ្ជាក់ថាពេលវេលានៃបទទំនាយមិនទាន់ចប់នោះទេ។ ទេវតាបានមានបន្ទូលថា តើព្រះបន្ទូលរបស់ព្រះបានបរាជ័យ ឬតើព្រះខកខានមិនបានបំពេញសេចក្តីសន្យារបស់ទ្រង់ឬ? ទេទ្រង់បានបំពេញគ្រប់ទាំងសេចក្តីសន្យារបស់ទ្រង់ទាំងអស់។ ព្រះយេស៊ូវត្រូវបានលើកឡើង ហើយបានបិទទ្វារនៃទីបរិសុទ្ធនៃរោងឧបោសថនៃស្ថានសួគ៌ ហើយបានបើកទ្វារទីបរិសុទ្ធបំផុត និងបានយាងចូលទៅក្នុងដើម្បីសំអាតទីបរិសុទ្ធ។ ទេវតាបានមានបន្ទូលថា អ្នកដែលរង់ចាំដោយអត់ធ្មត់នឹងបានយល់ពីអាថ៌កំបាំង។ មនុស្សបានគិតខុសប៉ុន្តែគ្មានការបរាជ័យនៅខាងចំណែករបស់ព្រះគ្រីស្ទឡើយ។ អ្វីទាំងអស់ដែលព្រះបានសន្យាបានសំរេចហើយ ប៉ុន្តែមនុស្សសំឡឹងមើលមកផែនដីដោយភ័ន្តច្រឡំដោយជឿថា ផែនដីនោះជាទីបរិសុទ្ធដែលត្រូវបោសសំអាតនៅចុងបំផុតនៃរយៈពេលនៃបទទំនាយទៅវិញ។ ការរំពឹងរបស់មនុស្សបានបរាជ័យ ប៉ុន្តែសេចក្តីសន្យារបស់ព្រះមិនខុសទាល់តែសោះ។ ព្រះយេស៊ូវបានចាត់ទេវតារបស់ទ្រង់អោយតម្រង់ផ្លូវអ្នកខកចិត្តដើម្បីដឹកនាំគំនិតរបស់គេទៅកាន់ទីបរិសុទ្ធបំផុត ដែលទ្រង់បានយាងចូល ដើម្បីសំអាតទីបរិសុទ្ធ និងលោះអោយធួននឹងបាបរបស់សាសន៍អ៊ីស្រាអែល។ ព្រះយេស៊ូវបានប្រាប់ដល់ទេវតាថា អ្នកទាំងឡាយដែលបានរកទ្រង់ឃើញនឹងយល់ពីការងារដែលទ្រង់នឹងធ្វើ។ ខ្ញុំបានឃើញថា នៅពេលដែលព្រះយេស៊ូវបានគង់នៅក្នុងទីបរិសុទ្ធបំផុត



ទ្រង់បានអភិសេកជាមួយទីក្រុងយេរូសាឡិមថ្មី ហើយបន្ទាប់ពីទ្រង់បានបំពេញការងាររបស់ទ្រង់នៅក្នុងទីបរិសុទ្ធបំផុត រួចមកទ្រង់នឹងយាងមកកាន់ផែនដីដោយអំណាចដ៏សប្បុរស និងយកអ្នកសុចរិតជាអ្នកដែលបានរង់ចាំការយាងមកវិញរបស់ទ្រង់ដោយអត់ធ្មត់ទៅឯទ្រង់។

បន្ទាប់មកទេវតាបានបង្ហាញខ្ញុំនូវអ្វីដែលបានកើតឡើងនៅស្ថានសួគ៌ នៅពេលដែលរយៈពេលនៃបទទំនាយបានបញ្ចប់ នៅឆ្នាំ១៨៤៤។ ខ្ញុំបានឃើញថានៅពេលដែលការងាររបស់ព្រះយេស៊ូវនៅទីបរិសុទ្ធបានចប់ហើយ ទ្រង់បានបិទទ្វារអាគារ នោះភាពងងឹតយ៉ាងធំ បានគ្របលើអ្នកដែលបានឮ និងបានបដិសេធដំណឹងនៃការយាងមកវិញរបស់ព្រះគ្រីស្ទ ហើយគេក៏មើលទ្រង់លែងឃើញ។ ពេលនោះព្រះយេស៊ូវបានតែងអង្គដោយព្រះពស្ត្រាដ៏មានតម្លៃ។ នៅជុំវិញផ្នែកខាងក្រោមនៃព្រះពស្ត្រទ្រង់ មានត្បូងនិងកន្ទឹម ទ្រង់បានទម្លាក់ពីស្មារបស់ទ្រង់នូវការងារដ៏មានតម្លៃ។ ហើយនៅពេលដែលព្រះអង្គធ្វើចលនា វាបានបញ្ចេញពន្លឺដូចពេជ្រ បង្ហាញអក្សរដូចជាបានសរសេរឈ្មោះ ឬឆ្លាក់នៅលើអាវកាក់មាស។ បន្ទាប់ពីទ្រង់បានតែងអង្គទ្រង់រួចស្រេចជាមួយនឹងរបស់ម្យ៉ាងនៅលើព្រះសិរទ្រង់មើលទៅដូចជាមកុដនោះមក ទេវតាបានព័ទ្ធជុំវិញទ្រង់ ហើយឆ្លងទៅក្នុងជាន់ទីពីរដោយរាជរថនៃអណ្តាតភ្លើង។ ពេលនោះ ខ្ញុំត្រូវបានគេបង្គាប់អោយកត់សំគាល់នូវអាគារទាំងពីរនៅទីបរិសុទ្ធនៃស្ថានសួគ៌។ វាំងននឬទ្វារបានបើក ហើយគេបានអនុញ្ញាតអោយខ្ញុំចូលទៅ។ នៅក្នុងអាគារទីមួយ ខ្ញុំបានឃើញជើងចង្កៀងដែលមានចង្កៀងប្រាំពីរ ដែលមើលទៅភ្លឺចាំង ព្រមទាំងតុដែលមាននំប៉ុងតាំងទុកនៅពីលើ និងអាសនាគ្រឿងក្រអូប និងកំញាណ។ គ្រឿងសង្ហារឹមទាំងអស់ នៅក្នុងអាគារនេះមើលទៅដូចជាមាសសុទ្ធ ហើយបានចាំងរូបអ្នកដែលចូលទៅកន្លែងនោះ។ វាំងននដែលបាំងខ័ណ្ឌចែក អាគារទាំងពីរនេះ មើលទៅភ្លឺ រុងរឿងណាស់។ វាធ្វើពីសំភារៈខុសៗគ្នា

ហើយមានពណ៌ផ្សេងៗគ្នាដែលមានរឹមយ៉ាងស្អាតដែលមានរូបចម្លាក់មាសជាតំណាងទេវតានៅពីលើបន្ទប់នោះត្រូវបានគេលើកឡើង ហើយខ្ញុំបានគន់មើលទៅក្នុងអាគារទីពីរ។ ទីនោះ ខ្ញុំបានឃើញហិបមួយដែលបានលេចឡើងជាមាសសុទ្ធ។ នៅជាយជុំវិញហិបខាងលើមានស្នាដៃដ៏អស្ចារ្យតំណាងអោយមកុដ។ វាធ្វើពីមាសសុទ្ធ។ នៅក្នុងហិបមានបន្ទះថ្មដែលមានសរសេរក្រិត្យវិន័យដប់ប្រការ។ នៅចុងទាំងសងខាងនៃហិប មានចេរូប៊ីនដ៏គួរអោយស្រឡាញ់ដែលមានស្លាបត្រដាងលើហិបនោះ។ ស្លាបរបស់លោកបានលើកឡើងយ៉ាងខ្ពស់ ហើយប៉ះគ្នានៅពីលើព្រះសិររបស់ព្រះយេស៊ូវនៅពេលដែលទ្រង់បានឈរនៅក្បែរហិប ព្រះភ័ក្ត្ររបស់លោកបែររកគ្នា ហើយលោកសំឡឹងមើលទៅហិបខាងក្រោម ទតមើលទៅបញ្ញត្តិរបស់ព្រះដោយយកព្រះទ័យទុកដាក់។ នៅចន្លោះចេរូប៊ីនទាំងពីរ មានកំញាណមាស។ ហើយនៅពេលដែលសេចក្តីអធិស្ឋានរបស់ពួកបរិសុទ្ធបានមកឯព្រះយេស៊ូវ ទ្រង់បានថ្វាយសេចក្តីអធិស្ឋានទាំងនោះទៅឯព្រះវរបិតាក្លិនក្រអូបឈ្ងុយឈ្ងប់បានចេញពីកំញាណនោះ។ មើលទៅវាដូចជាផ្សែងដែលមានពណ៌យ៉ាងស្អាត។ នៅពីលើកន្លែងដែលព្រះយេស៊ូវបានឈរពីមុខហិប ខ្ញុំបានឃើញសិរីល្អដ៏មានពន្លឺភ្លឺថ្លាដែលខ្ញុំមិនមើលចំឡើយ។ វាលេចឡើងដូចជាបល្ល័ង្កដែលព្រះបានគង់នៅ។ នៅពេលដែលកំញាណបានឡើងទៅឯព្រះវរបិតា សិរីល្អដ៏អស្ចារ្យបានចេញពីបល្ល័ង្ករបស់ព្រះវរបិតាទៅឯព្រះយេស៊ូវ ហើយចេញពីព្រះយេស៊ូវវាបានចាំងទៅលើអ្នកដែលសេចក្តីអធិស្ឋានរបស់គេ បានឡើងទៅដូចជាកំញាណដ៏ក្រអូបឈ្ងុយឈ្ងប់។ ពន្លឺនិងសិរីល្អបានចាក់ទៅលើព្រះយេស៊ូវយ៉ាងបរិបូរចោលស្រមោលទៅលើទីសន្តោសប្រោស ហើយខ្សែនៃសិរីល្អក៏បានបំពេញព្រះវិហារទាំងមូល។ ខ្ញុំមិនអាចមើលទៅសិរីល្អនោះបានទៀតឡើយ។គ្មានភាសាណាអាចពិពណ៌នាពីសិរីល្អនោះបានឡើយ។ ខ្ញុំមានការរំភើបយ៉ាងខ្លាំង ហើយបានបែរចេញពីទស្សនីយភាពដ៏មានចេស្តា និងសិរីរុងរឿង



នោះ។

ទេវតាបានបង្ហាញខ្ញុំនូវទីបរិសុទ្ធនៅផែនដីដែលមានអាគារពីរ។ វាដូចជាទីបរិសុទ្ធនៅស្ថានសួគ៌ដូច្នេះដែរ។ ទេវតាបានប្រាប់ខ្ញុំថា វាគឺជាទីបរិសុទ្ធនៅផែនដីជារូបរាងនៃទីបរិសុទ្ធនៃស្ថានសួគ៌។ គ្រឿងសង្ហារឹមនៅអាគារទីមួយនៃទីបរិសុទ្ធនៃផែនដីដូចជាអាគារទីមួយនៃទីបរិសុទ្ធនៃស្ថានសួគ៌ដែរ។ អាគារបានលើកឡើង ហើយខ្ញុំបានមើលទៅក្នុងទីបរិសុទ្ធនៃទីបរិសុទ្ធបំផុត ហើយបានឃើញថាគ្រឿងសង្ហារឹមក៏ដូចជាទីបរិសុទ្ធបំផុតនៅស្ថានសួគ៌ដែរ។ សង្ឃបានធ្វើការបូជានៅអាគារទាំងពីរនេះនៅផែនដី។ នៅក្នុងអាគារទីមួយ សង្ឃបានធ្វើការរាល់ថ្ងៃក្នុងមួយឆ្នាំ ហើយបានចូលទៅក្នុងទីបរិសុទ្ធបំផុតម្តងក្នុងមួយឆ្នាំ ដើម្បីសំអាតពីអំពើបាបដែលបាននាំមកដាក់នៅទីនោះ។ ខ្ញុំបានឃើញថា ព្រះយេស៊ូវបានធ្វើការនៅក្នុងអាគារទាំងពីរនោះនៅទីបរិសុទ្ធនៃស្ថានសួគ៌។ ទ្រង់បានចូលទៅក្នុងទីបរិសុទ្ធនៃស្ថានសួគ៌ដោយលះបង់ព្រះលោហិតរបស់ទ្រង់ផ្ទាល់។ សង្ឃនៅផែនដីត្រូវបានដកចេញដោយការសុគត ហេតុដូច្នេះហើយបានជាពួកលោកមិនអាចបន្តទៅទៀតបាន ប៉ុន្តែខ្ញុំបានឃើញថា ព្រះយេស៊ូវគឺជាសង្ឃដ៏អស់កល្ប។ តាមរយៈយញ្ញបូជានិងការលះបង់ បាននាំមកកាន់ទីបរិសុទ្ធនៅផែនដីកូនចៅអ៊ីស្រាអែលត្រូវតែចាប់យកសេចក្តីល្អរបស់ព្រះអង្គសង្គ្រោះដែលនឹងយាងមក។ ហើយនៅក្នុងព្រះតម្រិះរបស់ព្រះ ការងារដ៏ចាំបាច់នេះ ព្រះបានប្រទានដល់យើងដែលយើងត្រូវតែមើលត្រឡប់ក្រោយទៅឯការនោះ ហើយយល់ពីការងាររបស់ព្រះយេស៊ូវនៅក្នុងទីបរិសុទ្ធនៅស្ថានសួគ៌។

នៅគ្រាជាប់ឆ្កាងពេលដែលព្រះយេស៊ូវបានសុគតនៅកាល់វ៉ារី ទ្រង់បានស្រែកថា ការស្រេចហើយ ហើយវាំងននក្នុងព្រះវិហារបានរហែកជាពីរ ពីលើចុះក្រោម។ ការនេះបង្ហាញថា ការងារនៅទីបរិសុទ្ធនៃផែនដីបានចប់ជារៀងរហូតហើយ ហើយថា

ព្រះនឹងមិនជួបជាមួយពួកគេតទៅទៀតនៅក្នុងព្រះវិហារនៅផែនដីនេះ ដើម្បីទទួលយញ្ញបូជារបស់គេឡើយ។ ពេលនោះ ព្រះលោហិតរបស់ព្រះយេស៊ូវបានខ្ចាយ ហើយដែលទ្រង់ត្រូវធ្វើការដោយព្រះអង្គផ្ទាល់នៅក្នុងទីបរិសុទ្ធនៅស្ថានសួគ៌។ ដូចដែលសង្ឃបានចូលទៅក្នុងទីបរិសុទ្ធបំផុតនៅផែនដីមួយឆ្នាំម្តង ដើម្បីសំអាតទីបរិសុទ្ធ ព្រះយេស៊ូវបានយាងចូលទៅក្នុងទីបរិសុទ្ធបំផុតនៅស្ថានសួគ៌ នៅចុងបញ្ចប់នៃ២៣០០ថ្ងៃនៃគម្ពីរដានីយ៉ែល ជំពូក៨ នៅឆ្នាំ១៨៤៤ដើម្បីលោះអោយធួននឹងបាបសំរាប់អ្នកដែលអាចបានទទួលប្រយោជន៏ដោយការសំរុះសំរួល និងសំអាតទីបរិសុទ្ធរបស់ទ្រង់ទាំងអស់។

សូមអាន និក្ខមនំ ជំពូក ២៥-២៨ លេវីវិន័យ ជំពូក ១៦

ពង្សាវតាក្សត្រ ទី២ ២:១១ ដានីយ៉ែល ៨:១៤ ម៉ាថាយ ២៧:៥០-៥១

ហេព្រើរ ជំពូក ៩ វិវរណៈ ជំពូក២១។

## ជំពូកទី២៨

## **សាររបស់ទេវតាទីបី**

នៅពេលដែលការងាររបស់ព្រះយេស៊ូវបានចប់នៅទីបរិសុទ្ធ ហើយបានយាងចូលទៅក្នុងទីបរិសុទ្ធបំផុត ហើយបានឈរនៅមុខហិបដែលមានបញ្ញត្តិរបស់ព្រះ ទ្រង់បានចាត់ទេវតាដ៏មានចេស្តាមួយអង្គទៀតជាមួយនឹងព្រះរាជសារទីបី។ ទ្រង់បានដាក់ភ្លើងនៅក្នុងព្រះហស្តរបស់ទេវតា ហើយនៅពេលដែលលោកបានចុះទៅកាន់ផែនដីដោយចេស្តា និងអំណាច លោកបានប្រកាសការព្រមានដ៏គួរអោយភ័យខ្លាច ជាការគំរាមដ៏រន្ធត់ដែលមិនធ្លាប់កើតមានដល់មនុស្ស។ ដំណឹងត្រូវបានរៀបចំឡើងដើម្បីដាក់កូនចៅរបស់ព្រះអោយនៅក្នុងការថែរក្សារបស់ទ្រង់ និងបង្ហាញគេអំពីពេលវេលានៃ



សេចក្តីល្បួង និងការទង្គឹះចិត្តដែលនៅចំពោះពួកគេ។ ទេវតាបានមានបន្ទូលថា ពួកគេត្រូវបាននាំមកជិតការប្រយុទ្ធជាមួយសត្វនោះនិងរូបវាហើយ។ សេចក្តីសង្ឃឹមតែមួយគត់អំពីជីវិតអស់កល្បរបស់គេ គឺការប្រកាន់ជំហរខ្ជាប់ខ្ជួន។ ទោះបីជាជីវិតរបស់គេត្រូវប្រឈមទល់នឹងបង្គោលភ្នក់ភ្លើងក៏ដោយ ក៏គេត្រូវតែប្រកាន់ជំហរនៃសេចក្តីពិតខ្ជាប់-ខ្ជួនដែរ។ ទេវតាទីបីបិទសាររបស់លោកដោយព្រះបន្ទូលបែបយ៉ាងនេះ "នេះគឺជាការអត់ធ្មត់របស់ពួកបរិសុទ្ធ គឺជាអ្នកដែលកាន់គ្រប់ទាំងបញ្ញត្តិរបស់ព្រះ និងស្មោះត្រង់ជាមួយនឹងព្រះយេស៊ូវ"។ នៅពេលដែលលោកមានបន្ទូលពាក្យទាំងនេះម្តងទៀត លោកបានចង្អុលទៅកាន់ទីបរិសុទ្ធនៃស្ថានសួគ៌។

គំនិតរបស់អ្នកដែលទទួលដំណឹងនេះ ត្រូវបានទេវតាតម្រង់ទៅទីបរិសុទ្ធបំផុតដែលព្រះយេស៊ូវឈរនៅពីមុខហិបសញ្ញា ធ្វើការទូលអង្វរជាគ្រាចុងក្រោយបង្អស់ និងសំរាប់អ្នកដែលល្មើសនឹងបញ្ញត្តិរបស់ព្រះដោយធ្វើព្រងើយកន្តើយ។ ការលោះអោយធួននឹងបាបនេះ ត្រូវបានធ្វើឡើងសម្រាប់អ្នកសុចរិតដែលបានស្លាប់ព្រមទាំងអ្នកសុចរិតដែលនៅរស់ផងដែរ។ ព្រះយេស៊ូវបានលោះអោយធួននឹងបាបសំរាប់អ្នកបានស្លាប់ហើយ ហើយបានធ្វើបាបដោយមិនដឹងខ្លួនដោយមិនបានទទួលពន្លឺពីបញ្ញត្តិរបស់ព្រះ។

បន្ទាប់ពីព្រះយេស៊ូវបានបើកទ្វារទីបរិសុទ្ធបំផុត គេបានឃើញពន្លឺនៃថ្ងៃបរិសុទ្ធ ហើយរាស្ត្ររបស់ព្រះត្រូវបានព្រះសាកល្បង និងបានដកពិសោធដូចជាព្រះបានសាកល្បងសាសន៏អ៊ីស្រាអែលជំនាន់ដើមដើម្បីឱ្យឃើញថា តើពួកគេគោរពច្បាប់របស់ទ្រង់ឬទេនោះដែរ។ ខ្ញុំបានឃើញទេវតាទីបី បានចង្អុលឡើងលើបង្ហាញដល់ពួកអ្នកដែលខកចិត្តអំពីទីបរិសុទ្ធបំផុតនៅទីបរិសុទ្ធនៃស្ថានសួគ៌។ ពួកគេបានដើរតាមព្រះយេស៊ូវដោយសេចក្តីជំនឿ ចូលទៅក្នុងទីបរិសុទ្ធបំផុត។ គេបានឃើញព្រះយេស៊ូវម្តងទៀតហើយអំណរ និងសេចក្តីសង្ឃឹមបានពន្លកឡើងវិញ។ ខ្ញុំបានឃើញគេមើលទៅខាង

ក្រោយដើម្បីរំលឹកពីអតីតកាល តាំងពីការប្រកាសពីព្រឹត្តិការណ៍នៃការយាងមកលើកទីពីររបស់ព្រះយេស៊ូវ រហូតដល់ការធ្វើដំណើររបស់គេទៅកាន់ការឆ្លងពេលវេលានៅឆ្នាំ១៨៤៤។ គេឃើញការខកចិត្តរបស់គេបានពន្យល់ ហើយក្តីអំណរនិងការប្រាកដប្រជាធ្វើអោយគេមានសកម្មភាពឡើងវិញ។ ទេវតាទីបីបានបំភ្លឺពីអតីតកាលបច្ចុប្បន្នកាល និងអនាគតកាល ហើយគេបានដឹងថា ព្រះបានដឹកនាំគេដោយទិព្វញ្ញាណដ៏អាថិកំបាំងរបស់ទ្រង់យ៉ាងពិតប្រាកដ ។

ខ្ញុំត្រូវបានបង្ហាញថា រាស្ត្រសំណល់បានដើរតាមព្រះយេស៊ូវចូលទៅក្នុងទីបរិសុទ្ធបំផុត ហើយបានមើលហិបសញ្ញា និងទីសណ្តោសប្រោស ហើយមានការចាប់អារម្មណ៍នឹងសិរីល្អយ៉ាងខ្លាំង។ ព្រះយេស៊ូវបានបើកគំរបហិបសញ្ញា ហើយមើលហ្ន៎! បន្ទះថ្មដែលមានក្រិត្យវិន័យដប់ប្រការបានសរសេរនៅលើនោះ។ គេបានតាមដានទៅឯសង្ឃពីបុរាណ ប៉ុន្តែគេបានញ័ររន្ធត់ នៅពេលដែលគេឃើញក្រិត្យវិន័យទីបួនបាននៅក្នុងចំណោមបញ្ញត្តិទាំងដប់ នៅពេលដែលពន្លឺដ៏ត្រចះត្រចង់បានចាំងមកលើក្រិត្យវិន័យទីបួននោះខ្លាំងជាងក្រិត្យវិន័យប្រាំបួនដទៃទៀត និងរង្វង់នៃសិរីល្អព័ទ្ធជុំវិញក្រិត្យវិន័យទីបួននោះ។ គេរកមិនឃើញមានអ្វីដែលផ្តល់ពតិមានដល់គេថា ថ្ងៃបរិសុទ្ធត្រូវបានលុបចោល ឬផ្លាស់ប្តូរទៅថ្ងៃទីមួយនៃសប្តាហ៍វិញនោះឡើយ។ វាមានអក្សរដូចកាលដែលព្រះបានមានបន្ទូលដោយមោះមុត និងភាពរុងរឿងគួរអោយរន្ធត់នៅលើភ្នំនៅពេលដែលមានផ្លេកបន្ទោរ ផ្គរលាន់ និងរន្ទះដូចកាលដែលទ្រង់បានសរសេរនៅលើបន្ទះថ្មដោយអង្គុលីដ៏បរិសុទ្ធរបស់ទ្រង់ផ្ទាល់ដូច្នោះដែរ។ ក្នុងរវាងប្រាំមួយថ្ងៃ ឯងអាចធ្វើការរបស់ឯងបាន តែដល់ថ្ងៃទីប្រាំពីរ គឺជាថ្ងៃឈប់សំរាកថ្វាយព្រះយេហូវ៉ាជាព្រះនៃឯងវិញ។ គេបានភ្ញាក់ផ្អើលនៅពេលគេឃើញការថែរក្សាក្រិត្យវិន័យដប់ប្រការ។ គេឃើញថាបន្ទះថ្មក្រិត្យវិន័យបានដាក់នៅជិតព្រះយេហូវ៉ាគ្របបាំងនិងការពារដោយភាពបរិសុទ្ធ



របស់ទ្រង់។ គេឃើញថា គេបានជាន់ឈ្លីលើក្រិត្យវិន័យទីបួននៃបញ្ញត្តិដប់ប្រការ ហើយបានគោរពថ្ងៃមួយដែលអ្នកមិនជឿព្រះ និងប៉ាបបានផ្តល់អោយជំនួសថ្ងៃដែលព្រះយេហូវ៉ា បានញែកចេញនោះវិញ។ គេបានបន្ទាបខ្លួនគេនៅចំពោះព្រះ ហើយកាន់ទុក្ខ (យំសោក) ចំពោះការទទឹងច្បាប់កន្លងមករបស់គេ។

ខ្ញុំបានឃើញកំញាណ នៅក្នុងផ្សែងនៃអាសនាគ្រឿងក្រអូប នៅពេលដែលព្រះយេស៊ូវបានថ្វាយការលន់តួទោសរបស់ពួកគេទៅឯព្រះវរបិតាទ្រង់។ ហើយនៅពេលដែលវាបានឡើងទៅលើ ពន្លឺដ៏ភ្លឺបាននៅលើព្រះយេស៊ូវ ហើយគេបានដឹងខ្លួនគេអំពីការរំលងបញ្ញត្តិរបស់ព្រះ ហើយទឹកមុខរបស់គេបានបំភ្លឺដោយក្តីសង្ឃឹម និងក្តីអំណរ។ គេបានរួបរួមជាមួយនឹងការងាររបស់ទេវតាទីបី ហើយបានបន្លឺសំឡេងឡើង និងប្រកាសការព្រមានដ៏ធំ។ ប៉ុន្តែដំបូងឡើយ មានមនុស្សតិចតួចទេដែលទទួលដំណឹងនោះតែពួកគេនៅតែបន្តប្រកាសការព្រមាននោះ។ បន្ទាប់មកខ្ញុំបានឃើញមនុស្សជាច្រើនទទួលដំណឹងរបស់ទេវតាទីបី ហើយបានស្រែករួមគ្នាជាមួយនឹងអ្នកប្រកាសដំណឹងពីដំបូង ហើយគេបានលើកដំកើងព្រះ និងបង្ហាញទ្រង់ដោយគោរពថ្ងៃឈប់សំរាកដែលទ្រង់បានញែក។

អ្នកដែលបានទទួលដំណឹងទីបីជាច្រើន មិនបានដឹងពីដំណឹងទីមួយ និងទីពីរទេ។ សាតាំងបានយល់អំពីរឿងនេះ ហើយភ្នែកដ៏អាក្រក់របស់វា បានសំឡឹងមើលទៅលើពួកគេ ប៉ុន្តែទេវតាទីបី បានចង្អុលបង្ហាញគេពីទីបរិសុទ្ធបំផុត ហើយអ្នកដែលបានដឹងពីដំណឹងមុនៗបានចង្អុលបង្ហាញផ្លូវទៅកាន់ទីបរិសុទ្ធនៅស្ថានសួគ៌។ មនុស្សជាច្រើនបានឃើញច្រវាក់នៃសេចក្តីដ៏គ្រប់ល័ក្ខណ៍នៅក្នុងសាររបស់ទេវតាទាំងបី ហើយបានទទួលដោយអំណរ។ គេបានជឿដំណឹងទាំងនោះតាមលំដាប់របស់វា ហើយបានដើរតាមព្រះយេស៊ូវដោយសេចក្តីជំនឿចូលទៅក្នុងទីបរិសុទ្ធនៅស្ថានសួគ៌។ ដំណឹងនេះត្រូវបាន

បង្ហាញដល់ខ្ញុំដូចជាយុទ្ធការសំរាប់ទប់រាងកាយ។ ហើយនៅពេលដែលមានមនុស្ស ទទួល និងយល់ពីដំណឹងនោះ ពួកគេបានទទួលការការពារប្រឆាំងនឹងកលល្បិចជាច្រើនរបស់សាតាំង។

បន្ទាប់ពីការខកចិត្តដ៏ធំ នៅឆ្នាំ១៨៤៤មក សាតាំងនិងទេវតារបស់វា ធ្វើការវាយអន្ទាក់ដើម្បីបំផ្លាញជំនឿរបស់ពួកជំនុំយ៉ាងមមាញឹក។ វាបានបំភ័ន្តគំនិតរបស់អ្នកដែលមានបទពិសោធន៍ផ្ទាល់ទាក់ទងនឹងរឿងនេះ។ វាបានលេចឡើងក្នុងរូបរាងនៃការបន្ទាបខ្លួន។ វាបានផ្លាស់ប្តូរដំណឹងទីមួយ និងទីពីរ និងទីបី និងបានបង្ហាញពីអនាគតសំរាប់ការសំរេចរបស់គេនៅពេលអ្នកដទៃបានចង្អុលត្រឡប់ក្រោយក្នុងអតីតកាលដែលអះអាងថា គេបានបំពេញរួចស្រេចហើយ។ មនុស្សទាំងនេះបានដកគំនិតមិនជឿចេញ និងលើកជំនឿរបស់គេឡើង។ ខ្លះបានស្រាវជ្រាវព្រះគម្ពីរដោយខ្លួនឯង ដើម្បីព្យាយាមស្ថាបនាជំនឿរបស់គេឡើងចេញពីពួកជំនុំ។ សាតាំងបានសំដែងសេចក្តីរីករាយជាខ្លាំងចំពោះរឿងនេះ ព្រោះវាបានដឹងថា អ្នកដែលរបូតពីយុទ្ធកា វាអាចបំភ័ន្តដោយការខុសឆ្គងជាច្រើននិងបោកបក់ដោយខ្យល់នៃគោលលទ្ធិ។ មនុស្សជាច្រើនដែលបានដឹកនាំក្នុងដំណឹងទីមួយ និងទីពីរ បានបដិសេធដំណឹងនោះ ហើយការបែកខ្ញែកខ្ចាត់ខ្ចាយ បានកើតឡើងពាសពេញពួកជំនុំ។ ពេលនោះ ខ្ញុំបានឃើញ វីល្លៀមមីលើរ។ មើលទៅគាត់អន្ទះ-សារ ហើយឱនចុះ ដោយសេចក្តីទុក្ខព្រួយ និងកង្វល់ ពីព្រោះតែរាស្ត្ររបស់គាត់។ គាត់បានឃើញក្រុមដែលបានរួបរួមគ្នា និងស្រឡាញ់គ្នា នៅឆ្នាំ១៨៤៤ បានបាត់បង់សេចក្តី-ស្រឡាញ់រវាងគ្នានិងគ្នា ហើយបានប្រឆាំងគ្នាទៅវិញទៅមក។ គាត់បានឃើញ គេបានត្រឡប់ទៅរកសណ្ឋាននៃការក្បត់ជំនឿវិញ។ ទុក្ខព្រួយយ៉ាងខ្លាំងបានបន្ថយកម្លាំងរបស់គាត់។ ខ្ញុំបានឃើញពួកអ្នកដឹកនាំបានឃ្លាំមើលលោក វីល្លៀមមីលើរ ខ្លាចក្រែងគាត់នឹងទទួលដំណឹងរបស់ទេវតាទីបី និងក្រិត្យវិន័យរបស់ព្រះ។ ហើយនៅពេលដែល



គាត់លំអៀងទៅរកពន្លឺពីស្ថានសួគ៌ ពួកមនុស្សទាំងនោះបានរៀបចំផែនការដើម្បីទាញគំនិតរបស់គាត់ចេញ។ ខ្ញុំបានឃើញឥទ្ធិពលរបស់មនុស្សបានខំប្រឹងរក្សាគំនិតរបស់គាត់នៅក្នុងភាពងងឹត និងទុកឥទ្ធិពលរបស់គាត់ក្នុងចំណោមពួកគេ នៅក្នុងរយៈពេលដែលវីល្លៀមមីលើរបានបំពងសំឡេងរបស់គាត់ទាស់នឹងពន្លឺស្ថានសួគ៌។ គាត់បានបរាជ័យក្នុងការមិនទទួលដំណឹងដែលនឹងបានពន្យល់យ៉ាងច្បាស់ពីការខកចិត្តរបស់គាត់ ហើយចោលពន្លឺនិងសិរីល្អពីអនាគតដែលនឹងបានរំឭកឡើងវិញនូវកម្លាំងដ៏ខ្សោះល្វើយរបស់គាត់ ធ្វើអោយសេចក្តីសង្ឃឹមរបស់គាត់បានភ្លឺឡើង និងបានដឹកនាំគាត់អោយសរសើរ-ដំកើងព្រះ។ ប៉ុន្តែគាត់បានលំអៀងទៅខាងប្រាជ្ញារបស់មនុស្សជាជាងព្រះវិញ និងបានបំបែកដោយការងារដ៏ពិបាកក្នុងបុព្វហេតុនៃចៅហ្វាយរបស់គាត់ ហើយដោយសារអាយុ គាត់មិនមានតម្លៃដូចជាអ្នកដែលបានរក្សាគាត់ពីសេចក្តីពិតឡើយ។ គេជាអ្នកទទួលខុសត្រូវ ហើយអំពើបាបក៏ធ្លាក់មកលើពួកគេ។ ប្រសិនបើ វីល្លៀមមីលើរបានទទួលសាររបស់ទេវតាទីបី រឿងរ៉ាវជាច្រើននៃការងងឹត និងការអាថ៌កំបាំងសំរាប់គាត់នឹងបានពន្យល់។ បងប្អូនរបស់គាត់បានប្រកាសសេចក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅ និងការចាប់អារម្មណ៍បែបនេះសំរាប់គាត់ គាត់បានគិតថាគាត់មិនបែកចេញពីពួកគេឡើយ។ ចិត្តរបស់គាត់បានទោរទៅរកសេចក្តីពិត ប៉ុន្តែពេលនោះគាត់បានសំឡឹងមើលទៅបងប្អូនគាត់។ គាត់បានប្រឆាំងនឹងសេចក្តីពិតនោះ។ តើគាត់អាចបែកចេញពីអ្នកដែលបានឈរទឹមស្មាជាមួយគាត់ក្នុងការប្រកាសអំពីការយាងមករបស់ព្រះយេស៊ូវឬទេ? គាត់បានគិតថា ពួកគេពិតជាមិនអាចនាំអោយគាត់វង្វេងឡើយ។

ព្រះបានបណ្តោយគាត់អោយនៅក្រោមអំណាចរបស់សាតាំង ហើយសេចក្តីស្លាប់មានអំណាចលើគាត់។ ទ្រង់បានលាក់គាត់ទុកក្នុងផ្នូរអោយឆ្ងាយពីអ្នកដែលទាញគាត់ចេញពីព្រះឥតឈប់ឈរ។ លោកម៉ូសេបានប្រព្រឹត្តខុសនៅពេលដែលគាត់ហៀប

នឹងបានចូលទៅក្នុងដែនដីដែលព្រះបានសន្យា។ ហើយខ្ញុំក៏បានឃើញថា វីល្បៀមមីលើរបានប្រព្រឹត្តខុសនៅពេលដែលគាត់ហៀបនឹងបានចូលទៅក្នុងទីកដីកាណាននៃស្ថានសួគ៌ដូចគ្នាដែរ ហើយដោយបណ្តោយឱ្យឥទ្ធិពលរបស់គាត់ប្រឆាំងនឹងសេចក្តីពិត។ មនុស្សដទៃទៀតបានដឹកនាំគាត់ទៅកាន់ចំណុចនេះ។ ខ្លះទៀតត្រូវតែទទួលខុសត្រូវចំពោះរឿងនេះ។ ប៉ុន្តែទេវតាបានរក្សាធូលីដីនៃរាស្ត្ររបស់ទ្រង់ ហើយគេនឹងក្រោកឡើងនៅពេលឮសំឡេងត្រែចុងក្រោយបង្អស់។

សូមអាន និក្ខមនំ ២០:១-១៧, ៣១:១៨ ថែស្សាឡូនីច ទី១ ៤:១៦ វិវរណៈ ១៤:៩-១២។

## ជំពូកទី២៩
## អាសនាដ៏រឹងមាំ

ខ្ញុំបានឃើញក្រុមមួយដែលបានឈរយាមយ៉ាងម៉ត់ចត់ និងមាំមួន ហើយដែលមិនមើលមុខអ្នកដែលរុះរើសេចក្តីជំនឿ ដែលបានស្ថាបនាឡើងរបស់ពួកជំនុំនោះផង។ ព្រះបានទតមកលើពួកគេ ដោយការកោតសរសើរ។ ទេវតាបានបង្ហាញជំហានបីដល់ខ្ញុំ មួយ ពីរ និងបី សាររបស់ទេវតាទីមួយ ទីពីរ និងទីបី។ ទេវតាបានមានបន្ទូលថា វេទនាមកដល់អ្នកដែលដកយកឬកកូរកកាយដំណឹងនេះ ការយល់សេចក្តីពិតនៃដំណឹងនេះមានសារសំខាន់ណាស់ វាសនារបស់មនុស្សពឹងផ្អែកលើអាកប្បកិរិយាដែលគេបានជឿ។ ទេវតាបាននាំខ្ញុំទៅកាន់ដំណឹងនេះម្តងទៀត ហើយបានបង្ហាញពីរបៀបដែលរាស្ត្រជាទីស្រឡាញ់របស់ព្រះបានទិញជំនឿរបស់គេ។ វាបានមកដោយការឈឺចាប់យ៉ាងខ្លាំង និងជម្លោះយ៉ាងតឹងតែង។ ព្រះបាននាំគេមួយជំហានម្តងៗ រហូតដល់ទ្រង់



បានដាក់គេនៅលើអាសនាដ៏រឹងមាំមិនរំកិលមួយ។ ពេលនោះ ខ្ញុំបានឃើញមនុស្សម្នាក់ៗនៅពេលដែលគេបានមកដល់អាសនាមួយនិងឡើងទៅលើ គេបានពិនិត្យមើលគ្រឹះរបស់វា។ អ្នកខ្លះបានឈានឡើងលើអាសនានោះដោយអំណរ។ ខ្លះទៀតបានចាប់ផ្តើមរកឃើញកំហុសក្នុងការចាក់គ្រឹះរបស់អាសនានោះ។ គេចង់ធ្វើការកែលំអអោយកាន់តែមាំឡើង នោះអាសនានឹងបានល្អត្រឹមត្រូវ ហើយមនុស្សម្នាក់ៗរឹតតែសប្បាយឡើង។ អ្នកខ្លះបានចុះពីអាសនានោះ ហើយបានពិនិត្យមើលវា ថែមទាំងបានរកឃើញបញ្ហាក៏ប្រកាសថា អាសនានេះបានធ្វើខុសហើយ។ ខ្ញុំបានឃើញថា មនុស្សស្ទើរតែទាំងអស់បានឈរយ៉ាងរឹងមាំនៅលើអាសនា និងបានជំរុញអោយអ្នកដែលបានចុះពីអាសនាឈប់ត្អូញត្អែរ ព្រោះព្រះគឺជាមេជាង ហើយគេកំពុងប្រយុទ្ធប្រឆាំងនឹងព្រះដែលបានដឹកនាំពួកគេទៅកាន់អាសនាដ៏មាំមួយនោះហើយ ហើយដោយការរួបរួមគ្នា ពួកគេស្ទើរតែទាំងអស់បានងើបភ្នែកគេឡើងទៅលើមេឃ ទាំងសរសើរដំកើងព្រះ ដោយសំឡេងខ្លាំងៗ។ ការនេះបានធ្វើអោយប៉ះពាល់ដល់អ្នកដែលបានត្អូញត្អែរ ហើយបានចុះចេញពីអាសនា ហើយគេក៏បានឈានឡើងទៅលើអាសនាវិញដោយបន្ទាបខ្លួន។

ទេវតាបានបង្ហាញខ្ញុំត្រឡប់ទៅការប្រកាស ពីការយាងមកលើកទី១របស់ព្រះគ្រីស្ទ។ លោកយ៉ូហានបានទទួលវិញ្ញាណ និងអំណាចរបស់លោកអេលីយ៉ា ដើម្បីរៀបចំផ្លូវថ្វាយព្រះយេស៊ូវយាងមក។ អ្នកដែលបដិសេធដំណឹងរបស់យ៉ូហាន នឹងមិនបានទទួលផលប្រយោជន៏ ពីការបង្រៀនរបស់ព្រះយេស៊ូវឡើយ។ ការប្រឆាំងរបស់គេទៅនឹងការប្រកាសពីការយាងមកលើកទី១របស់ទ្រង់ បានដាក់គេនៅត្រង់កន្លែង ដែលគេមិនអាចទទួល ដោយរៀបចំខ្លួននូវភស្តុតាងដ៏ធំបំផុតថា ទ្រង់ជាព្រះមែស៊ី។ សាតាំងបានដឹកនាំអ្នក ដែលបដិសេធដំណឹងរបស់លោកយ៉ូហាន អោយបន្តទៅមុខទៀត អោយបដិសេធព្រះយេស៊ូវ ហើយនិងឆ្កាងទ្រង់។ ដោយការធ្វើដូច្នេះ វាបានដាក់ពួកគេនៅ

កន្លែង ដែលគេមិនអាចទទួលព្រះពរនៅថ្ងៃទី៥០ ដែលបានបង្រៀនគេពីវិធីចូលទៅក្នុងទីបរិសុទ្ធនៃស្ថានសួគ៌។ ការរហែកនៃវាំងននក្នុងព្រះវិហារបង្ហាញថា យញ្ញបូជា និងបញ្ញត្តិរបស់ពួកយូដា ព្រះលែងទទួលតទៅទៀតហើយ។ ការថ្វាយដង្វាយដុតដ៏ធំត្រូវបានធ្វើហើយ និងត្រូវបានព្រះទទួលផង ហើយព្រះវិញ្ញាណបរិសុទ្ធ ដែលបានយាងមកនៅថ្ងៃបុណ្យទី៥០ បាននាំគំនិតរបស់ពួកសាវកពីទីបរិសុទ្ធនៅផែនដី ទៅទីបរិសុទ្ធនៃស្ថានសួគ៌ ដែលព្រះយេស៊ូវបានយាងចូល ដោយព្រះលោហិតរបស់ទ្រង់ និងខ្ចាយមកលើពួកសាវក នូវប្រយោជន៍នៃការលោះអោយធួននឹងបាបរបស់ទ្រង់។ ពួកយូដាត្រូវបានទុកនៅក្នុងការបោកបញ្ឆោត និងភាពងងឹតទាំងស្រុង។ គេបានបាត់បង់ពន្លឺទាំងអស់ ដែលគេមានលើគំរោងការនៃការសង្គ្រោះ ហើយនៅតែទុកចិត្ត លើយញ្ញបូជា និងដង្វាយរបស់គេតទៅទៀតដដែល។ គេមិនអាចទទួលបានការទូលអង្វររបស់ព្រះគ្រីស្ទជំនួសគេ នៅក្នុងទីបរិសុទ្ធឡើយ។ ទីបរិសុទ្ធនៅស្ថានសួគ៌ បានជំនួសទីបរិសុទ្ធនៅផែនដីហើយ តែគេមិនបានស្គាល់ផ្លូវទៅស្ថានសួគ៌ឡើយ។

មនុស្សជាច្រើនបានមើលដោយក្តីរន្ធត់ ទៅឯទិសដៅ ដែលពួកយូដាបានប្រព្រឹត្តិទៅលើព្រះយេស៊ូវ ក្នុងការបដិសេធន៍ និងការឆ្កាងទ្រង់។ ហើយនៅពេលដែលគេអានការប្រមាថ ដ៏គួរអោយអៀនខ្មាស់របស់ទ្រង់ គេគិតថា គេស្រឡាញ់ព្រះគ្រីស្ទ និងមិនបោះបង់ទ្រង់ ដូចពេត្រុស ឬក៏ឆ្កាងទ្រង់ ដូចពួកយូដាឡើយ។ ប៉ុន្តែព្រះដែលបានឃើញការអះអាង ពីការអាណិតអាសូររបស់គេ ចំពោះព្រះរាជបុត្រា ទ្រង់បានបង្ហាញដល់គេ និងបានធ្វើការសាកល្បង អំពីសេចក្តីស្រឡាញ់ចំពោះព្រះយេស៊ូវ ដែលគេបានអះអាង។

ទេវតាទាំងអស់បានទតមើល ដោយយកព្រះទ័យទុកដាក់ នូវការទទួលដំណឹងនេះ។ ប៉ុន្តែមនុស្សជាច្រើន ដែលបានអះអាងថា ស្រឡាញ់ព្រះយេស៊ូវ និងអ្នកដែលបាន



ហូរទឹកភ្នែក នៅពេលដែលគេបានអានរឿងរបស់ឈើឆ្កាង ជំនួសអោយការទទួលដំណឹងដ៏រីករាយ បានពុះពោរដោយកំហឹង ហើយបានមើលងាយដំណឹងល្អនៃការយាងមករបស់ព្រះយេស៊ូវ និងប្រកាសដំណឹងនោះថា ជាការបោកបញ្ឆោតវិញ។ គេមិនបានរួបរួមជាមួយនឹងអ្នក ដែលស្រឡាញ់ការលេចមករបស់ទ្រង់ឡើយ ប៉ុន្តែបានស្អប់ពួកគេវិញ ហើយបណ្តេញគេចេញពីពួកជំនុំ។ អ្នកដែលបដិសេធសារទីមួយ មិនអាចទទួលសារទីពីរឡើយ ហើយក៏មិនអាចទទួល សំរែកពាក់កណ្តាលអាធ្រាត្រ ដែលរៀបចំគេដើម្បីចូលទៅក្នុងទីបរិសុទ្ធបំផុត នៃទីបរិសុទ្ធស្ថានសួគ៌ជាមួយព្រះយេស៊ូវ ដោយជំនឿឡើយ។ ដោយការបដិសេធន៍ដំណឹងពីខាងដើម គេមិនអាចឃើញពន្លឺនៅក្នុងសាររបស់ទេវតាទីបី ដែលបង្ហាញគេពីផ្លូវចូលទៅក្នុងទីបរិសុទ្ធបំផុតឡើយ។ ខ្ញុំបានឃើញថា ពួកជំនុំតែឈ្មោះ បានឆ្កាងដំណឹងនោះ ដូចពួកយូដាបានឆ្កាងព្រះយេស៊ូវដែរ ដោយហេតុដូច្នេះហើយ បានជាគេមិនដឹងពីចលនានៅស្ថានសួគ៌ ឬពីផ្លូវចូលទៅក្នុងទីបរិសុទ្ធបំផុតឡើយ គេក៏មិនអាចទទួលការទូលអង្វររបស់ព្រះយេស៊ូវ ចំពោះព្រះវរបិតានៅទីនោះដែរ ដូចជាពួកយូដា ដែលបានថ្វាយយញ្ញបូជាដ៏ឥតប្រយោជន៍របស់ពួកគេដែរ។ គេបានថ្វាយសេចក្តីអធិស្ឋាន ដ៏ឥតប្រយោជន៍របស់គេ ទៅកាន់កន្លែងដែលព្រះយេស៊ូវបានចាកចេញទៅហើយ ហើយសាតាំងសប្បាយចិត្តណាស់ ចំពោះការភ័ន្តច្រឡំរបស់អ្នកដែលជឿព្រះយេស៊ូវតែមាត់ ហើយបានបោះគេចូលទៅក្នុងអន្ទាក់របស់វា និងប្រើប្រាស់លក្ខណៈសាសនា ព្រមទាំងដឹកនាំគំនិតរបស់គ្រីស្ទានតែសំបកក្រៅនេះទៅឯវា និងធ្វើការជាមួយនឹងអំណាចនៃសញ្ញា និងទីបន្ទាល់របស់វា។ វាប្រើវិធីមួយនេះ ដើម្បីបោកបញ្ឆោតអ្នកនេះ ហើយប្រើវិធីផ្សេងទៀត ដើម្បីបោកបញ្ឆោតមនុស្សដទៃផ្សេងទៀត។ វាមានកលល្បិចជាច្រើន ដែលវាបានរៀបចំសំរាប់បោកប្រាស់គំនិតខុសៗគ្នា។ អ្នកមើលទៅស្គាល់ការបោកបញ្ឆោតមួយ តែចាញ់កល ការបោកបញ្ឆោតមួយទៀត។

សាតាំងបោកបញ្ឆោតមនុស្សខ្លះ ដោយព្រលឹងវិញ្ញាណនិយម។ វាអាចមកជាទេវតានៃពន្លឺ ហើយផ្សព្វផ្សាយឥទ្ធិពលរបស់វាពាសពេញផែនដី។ ខ្ញុំបានឃើញការកែទម្រង់ខុសនៅគ្រប់ទីកន្លែង។ ពួកជំនុំបានរីករាយ និងគិតថា ព្រះកំពុងធ្វើការយ៉ាងអស្ចារ្យសំរាប់ពួកគេ នៅពេលដែលវិញ្ញាណផ្សេងបានធ្វើការសំរាប់ពួកគេនោះ។ គេនឹងស្លាប់ទៅ ហើយចាកចេញពីលោកីយ៍ និងពួកជំនុំ នៅក្នុងល័ក្ខខ័ណ្ឌដ៏អាក្រក់ជាងពីមុនទៅទៀត។

ខ្ញុំបានឃើញថា ព្រះមានកូនចៅដ៏ស្មោះត្រង់បំផុត នៅក្នុងចំណោមអ្នកដែលរង់ចាំតែមាត់ក្រៅ និងពួកជំនុំដែលធ្លាក់ចុះ ព្រមទាំងគ្រូគង្វាល និងមនុស្សម្នាដែលមិនទាន់បានហៅចេញពីពួកជំនុំទាំងនេះ។ មុននឹងការវេទនារបស់ព្រះបានចាត់មក ហើយគេនឹងទទួលសេចក្តីពិតដោយអំណរ។ សាតាំងដឹងរឿងនេះ ហើយមុនសំឡេងយ៉ាងខ្លាំងរបស់ទេវតាទីបី វាបានធ្វើអោយមានការរំជើបរំជួល នៅក្នុងអង្គការសាសនាទាំងនេះថា អ្នកដែលបដិសេធសេចក្តីពិតអាចគិតថា ព្រះគង់នៅជាមួយពួកគេ។ វាសង្ឃឹមថា នឹងបោកបញ្ឆោតអ្នកស្មោះត្រង់ និងដឹកនាំអោយគេគិតថា ព្រះនៅតែធ្វើការក្នុងពួកជំនុំ។ ប៉ុន្តែ ពន្លឺនឹងចាំងមក ហើយអ្នកដែលស្មោះត្រង់ នឹងចាកចេញពីពួកជំនុំ ដែលធ្លាក់ចុះ ហើយឈរជាមួយនឹងក្រុមសំណល់ (សំរាំង)វិញ។

សូមអានម៉ាថាយ ជំពូក៣, កិច្ចការជំពូក២, កូរិនថូសទី២ ១១: ១៤ ថែស្សាឡូនីចទី២ ២:៩-១២, វិវរណៈ ១៤:៦-១២។

ជំពូកទី៣០

## ព្រលឹងវិញ្ញាណនិយម

ខ្ញុំបានឃើញការបោកបញ្ឆោតរបស់ប៉ាប។ សាតាំងមានអំណាចនឹងនាំមកនូវ



ទ្រង់ទ្រាយមួយ ដែលគេបានការអះអាងថា ជាបងប្អូន ឬមិត្តភ័ក្តិរបស់យើង ដែលឥឡូវនេះ សំរាកនៅក្នុងព្រះយេស៊ូវ។ វានឹងធ្វើអោយលេចឡើងដូចរឿងមែនទែន ពាក្យដែលវាបន្លឺនៅទីនេះ ដូចជាពាក្យដែលយើងធ្លាប់ឮ និងត្រូវបានវានិយាយសំឡេងដែលធ្លាប់ចូលក្នុងត្រចៀកយើង នៅពេលដែលគេនៅរស់នៅដូច្នោះដែរ។ ទាំងអស់នេះគឺដើម្បីបោកបញ្ឆោតលោកីយ៍ និងដាក់អន្ទាក់ពួកគេ ឱ្យចូលទៅក្នុងការបោកបញ្ឆោតនេះ។

ខ្ញុំបានឃើញថា អ្នកបរិសុទ្ធត្រូវតែយល់អោយបានច្បាស់ នូវសេចក្តីពិតក្នុងពេលបច្ចុប្បន្ន ដែលមានការអះអាងពីបទព្រះគម្ពីរ។ គេត្រូវតែយល់អំពីសណ្ឋាននៃសេចក្តីស្លាប់ ដ្បិតវិញ្ញាណអារក្សនឹងលេចមកឯគេ អះអាងថា វាជាបងប្អូន ឬមិត្តភ័ក្តិជាទីស្រឡាញ់ ដែលនឹងថ្លែងទៅកាន់ពួកគេ នូវការបង្រៀនខុសពីបទព្រះគម្ពីរ។ វានឹងធ្វើទាំងអស់ក្នុងអំណាចរបស់វា ដើម្បីបង្កើតអោយមានការអាណិតអាសូរ និងធ្វើការអស្ចារ្យនៅចំពោះមុខគេ ដើម្បីបញ្ជាក់នូវអ្វីដែលគេបានអះអាង ដែលរាស្ត្ររបស់ព្រះត្រូវតែរៀបចំ ដើម្បីតស៊ូនឹងវិញ្ញាណទាំងនេះ ដោយសេចក្តីពិតនៃព្រះគម្ពីរ ថាមនុស្សស្លាប់មិនដឹងអ្វីទាំងអស់ និងថាអ្នកទាំងនោះ គឺជាវិញ្ញាណរបស់អារក្សទេ។

ខ្ញុំបានឃើញថា យើងត្រូវតែពិនិត្យឱ្យបានម៉ត់ចត់ នូវគ្រឹះនៃសេចក្តីសង្ឃឹមរបស់យើង ដ្បិតយើងនឹងត្រូវអោយហេតុផល សំរាប់សេចក្តីសង្ឃឹមនោះ ពីព្រះគម្ពីរ ដ្បិតយើងនឹងឃើញការបោកបញ្ឆោតនេះ រីករាលដាល ហើយយើងនឹងត្រូវតែប្រឈមដោះស្រាយមុខទល់នឹងមុខ។ ប្រសិនបើយើងមិនបានរៀបចំខ្លួនជាមុន សំរាប់ការបោកបញ្ឆោតនេះទេ យើងនឹងធ្លាក់ទៅក្នុងអន្ទាក់ ឬត្រូវបរាជ័យជាមិនខាន។ ប៉ុន្តែប្រសិនបើយើងធ្វើនូវផ្នែករបស់យើងណា ដែលយើងអាចធ្វើបាន ដើម្បីរៀបចំខ្លួនសំរាប់ជម្លោះដែលនៅបង្កើយចំពោះមុខយើងនោះ ព្រះនឹងធ្វើនូវចំណែករបស់ទ្រង់ ហើយព្រះពាហុ

(ដៃ) ដ៏មានអំណាចរបស់ទ្រង់ នឹងការពារយើង។ ទ្រង់នឹងបញ្ជូនទេវតាចេញពីសិរីល្អ ដើម្បីធ្វើជារបងការពារមនុស្សស្មោះត្រង់ រហ័សជាងពួកគេ ដែលត្រូវបានអារក្សបោកបញ្ឆោត និងបានដឹកនាំអោយទៅឆ្ងាយ ដោយការអស្ចារ្យដ៏កំភូតរបស់សាតាំង។

ខ្ញុំបានឃើញថា ការបោកបញ្ឆោតនេះ បានផ្សព្វផ្សាយយ៉ាងលឿន។ ទេវតាបានបង្ហាញខ្ញុំនូវរថយន្តមួយខ្សែ កំពុងបើកបរយ៉ាងលឿន ដូចផ្លេកបន្ទោរ ទេវតាបានបង្គាប់ខ្ញុំមើលយ៉ាងប្រុងប្រយ័ត្ន។ ខ្ញុំបានផ្តោតភ្នែករបស់ខ្ញុំសំឡឹងមើលទៅខ្សែរថយន្តនោះ។ វាហាក់ដូចជាលោកីយ៍ទាំងមូល នៅក្នុងរថយន្តនោះទាំងអស់។ បន្ទាប់មកទេវតាបានបង្ហាញខ្ញុំនូវអ្នកបើកបរ ដែលមើលទៅដូចជាមនុស្សត្រឹមត្រូវ ដែលអ្នកដំណើរទាំងអស់គោរពកោតខ្លាច។ ខ្ញុំមានការស្រឡាំងកាំង ហើយក៏បានសួរទៅទេវតាដែលនៅជាមួយខ្ញុំថា តើគាត់ជាអ្នកណា។ ទេវតាឆ្លើយថា ជាសាតាំង។ វាជាអ្នកបើកបរនៅក្នុងរូបរាងជាទេវតានៃពន្លឺ។ វាបានយកលោកីយ៍ទាំងមូល ធ្វើជាចំណាប់ខ្មាំងរបស់វា។ អារក្សបានអោយអំណាចទៅលើការបោកបញ្ឆោតយ៉ាងខ្លាំង អោយមនុស្សជឿដល់ការកុហកមួយថា ពួកវាខ្លាំងក្រៃលែង។ ភ្នាក់ងាររបស់វា អ្នកដែលមានលំដាប់បន្ទាប់ពីវា គឺជាវិស្វករ ហើយភ្នាក់ងារផ្សេងៗទៀតរបស់វា គឺជាអ្នកធ្វើការនៅក្នុងការិយាល័យផ្សេងៗ តាមដែលវាត្រូវការ ហើយពួកវាទាំងអស់គ្នាកំពុងធ្វើដំណើរដោយល្បឿនលឿន ដូចផ្លេកបន្ទោរ ឆ្ពោះទៅកាន់កន្លែងនៃសេចក្តីស្លាប់។ ខ្ញុំបានសួរទៅទេវតាថា តើមិនមានសល់មនុស្សទៀតទេឬអី។ ទេវតាបានបង្គាប់អោយខ្ញុំមើលទៅទិសម្ខាងទៀត ហើយខ្ញុំបានឃើញមនុស្សមួយក្រុមតូច កំពុងធ្វើដំណើរតាមផ្លូវដ៏ចង្អៀតមួយ។ ទាំងអស់គ្នាហាក់ដូចជាបានរួបរួមគ្នាយ៉ាងរឹងមាំ ហើយបានចងភ្ជាប់គ្នាដោយសេចក្តីពិត។

ក្រុមតូចនេះមើលទៅស្លេកស្លាំង នៅពេលដែលគេបានឆ្លងកាត់ការលំបាក និង



ទំនាស់យ៉ាងតឹងតែង។ ហើយហាក់ដូចជាព្រះអាទិត្យទើបតែចេញផុតពីពពក រួចចាំង-ចែងទៅលើមុខរបស់គេ ហើយធ្វើអោយគេមើលទៅមានជោគជ័យ នៅពេលដែលគេបានគិតថា ជោគជ័យរបស់គេមកដល់ហើយ។

ខ្ញុំបានឃើញថា ព្រះអម្ចាស់បានប្រទានឱកាសអោយលោកីយ៍ដោះអន្ទាក់។ រឿងមួយនេះ គឺជាភ័ស្តុតាងគ្រប់គ្រាន់សំរាប់គ្រីស្ទាន ប្រសិនបើគ្មានភ័ស្តុតាងណាផ្សេងទៀត មិនធ្វើឱ្យមានការខុសគ្នារវាងការល្អ និងការអាក្រក់ឡើយ។

លោកថូម៉ាសផែន ដែលរាងកាយរបស់គាត់បានក្លាយជាធូលីដី ហើយជាអ្នកដែលបានងើបឡើងនៅចុង១000ឆ្នាំ នៅគ្រារស់ឡើងវិញលើកទីពីរ ដើម្បីទទួលរង្វាន់របស់គាត់ និងទទួលការស្លាប់លើកទីពីរ បានទទួលការអះអាងពីសាតាំងថា បាននៅឯស្ថានសួគ៌ ហើយត្រូវបានលើកដំកើងយ៉ាងខ្ពស់នៅទីនោះ។ សាតាំងបានប្រើគាត់យ៉ាងច្រើននៅផែនដី ហើយឥឡូវនេះ វាបានបន្តការងារដូចគ្នានេះ តាមរយៈការធ្វើជាមានថូម៉ាសផែន ដែលត្រូវបានលើកដំកើង និងផ្តល់កិត្តិយសជាទីបំផុត ហើយដោយគាត់បានបង្រៀននៅផែនដី សាតាំងបានបង្ហាញថា គាត់បានបង្រៀននៅស្ថានសួគ៌ដែរ។ ហើយមនុស្សខ្លះនៅផែនដី ដែលបានមើលងាយក្តីវន្ទត់ទៅឯជីវិត និងការស្លាប់របស់គាត់ ហើយនិងការបង្រៀនមិនល្អរបស់គាត់ នៅពេលដែលគាត់រស់នៅ ឥឡូវនេះទទួលការបង្រៀនតាមគាត់ ដែលជាជនអប្រិយ និងពុករលួយម្នាក់ដែលមើលងាយព្រះ និងច្បាប់របស់ទ្រង់។

អានោះដែលជាឪពុកនៃការកុហក ចង និងបញ្ឆោតលោកីយ៍ ដោយការបញ្ជូនទេវតារបស់វា អោយទៅនិយាយជាមួយពួកសាវក ហើយធ្វើអោយវាកើតឡើងផ្ទុយពីអ្វីដែលគេបានសរសេរកាលពីគេនៅផែនដី ដែលបានបញ្ជាដោយខ្មោច។ ទេវតាកុហកទាំងនេះ ធ្វើអោយពួកសាវកបង្ខូចការបង្រៀនរបស់ខ្លួន និងប្រកាសថា គេជាអ្នក

កំផិត។ ដោយធ្វើដូច្នេះ វាអាចបោះអ្នកគ្រីស្ទានតែមាត់ ដែលមានឈ្មោះនៅរស់ តែបានស្លាប់វិញ និងលោកីយ៍ទាំងមូល ចូលទៅក្នុងការមិនច្បាស់លាស់ អំពីព្រះបន្ទូលរបស់ព្រះ ដ្បិតនោះ គឺជាផ្លូវកាត់ចេញពីដានយ៉ាងធំរបស់ព្រះ និងទំនងជាធ្វើអោយផែនការរបស់ទ្រង់មិនបានសំរេច។ ហេតុដូច្នេះហើយ បានជាវានាំគេអោយសង្ស័យលើប្រភពនៃព្រះគម្ពីររបស់ព្រះ រួចបង្កើតថូម៉ាស់ជែន ដែលមិនជឿសាសនាឡើង ដោយបានគិតថា គាត់ជាអ្នកនាំផ្លូវចូលទៅស្ថានសួគ៌ នៅពេលដែលគាត់បានស្លាប់ ហើយបានរួបរួមជាមួយនឹងពួកសាវក ដែលគាត់ស្អប់នៅផែនដី ហើយលេចឡើងដើម្បីបង្រៀនដល់លោកីយ៍។

សាតាំងបានចាត់ទេវតារបស់វានីមួយៗ តាមផ្នែករបស់វា។ វាបង្គាប់ទេវតារបស់វា អោយប៉ិនប្រសប់មានល្បិចកល និងវាងវៃ។ វាបង្គាប់ឱ្យទេវតាវាខ្លះ ធ្វើជាសាវក ហើយនិយាយជំនួសគេ នៅពេលដែលទេវតាខ្លះទៀត ធ្វើជាមនុស្សមិនជឿលើសាសនា និងកំណាច ដែលបានស្លាប់ដោយប្រមាថព្រះ ប៉ុន្តែ ឥឡូវនេះលេចឡើងជាអ្នកកាន់សាសនាមែនទែន។ គ្មានអ្វីខុសគ្នារវាងសាវកដ៏បរិសុទ្ធបំផុត និងអ្នកមិនជឿលើសាសនាដ៏អាក្រក់នោះទេ។ ទាំងពីរនេះ បានបង្កើតឡើងអោយបង្រៀនរឿងដូចគ្នា។ វាមិនសំខាន់លើអ្នកណា ដែលសាតាំងអោយនិយាយនោះទេ វាគឺជាកម្មបទតែមួយគត់ដែលត្រូវបំពេញ។ វាបានភ្ជាប់យ៉ាងស្និទ្ធស្នាល ជាមួយនឹងលោកជែនលើផែនដី ហើយបន្ថែមថា វាជាការងាយស្រួលសំរាប់គាត់ក្នុងការដឹង នូវពាក្យទាំងអស់ ដែលគាត់បានប្រើ និងសំណេរទាំងឡាយនៃកូនចៅដ៏មានភក្តីភាពរបស់គាត់ ដែលបានបំរើគាត់យ៉ាងស្មោះត្រង់ និងបានបំពេញគោលបំណងរបស់គាត់បានយ៉ាងល្អ។ សាតាំងបានអានការសរសេររបស់គាត់ជាច្រើន ហើយវាជាការងាយស្រួលសំរាប់វា ដើម្បីបញ្ជាអារម្មណ៍តាមរយៈទេវតារបស់វា ឥឡូវនេះ ហើយធ្វើអោយវាលេចឡើងថា វាមកពីថូម៉ាស់



ជែន ដែលជាអ្នកបំរើស្មោះត្រង់របស់វា កាលពីគាត់នៅរស់។ ប៉ុន្តែ នេះគឺជាស្នាដៃឯករបស់សាតាំង។ ការបង្រៀនទាំងអស់នេះ បានអះអាងថា មកពីពួកសាវក និងពួកអ្នកបរិសុទ្ធ និងមនុស្សអាក្រក់ ដែលបានស្លាប់ មកពីអំណាចសាតាំងយ៉ាងពេញទំហឹង។

ការនេះគ្រប់គ្រាន់ល្មមនឹងដកយកការអាក្រក់ ចេញពីគំនិតមនុស្សគ្រប់គ្នាទាំងអស់ និងដឹងពីការងារដ៏ងងឹត និងអាថ៌កំបាំងរបស់សាតាំង ដែលវាបានទទួលពីអ្នកដែលវាស្រឡាញ់ជាខ្លាំង និងអ្នកដែលស្អប់ព្រះយ៉ាងខ្លាំង ជាមួយនឹងពួកសាវកដ៏បរិសុទ្ធ និងពួកទេវតាក្នុងសិរីល្អ បាននិយាយដោយជាក់ស្តែងទៅកាន់លោកីយ៍ និងអ្នកមិនជឿថា ទោះបីជាអ្នកអាក្រក់យ៉ាងណាក៏ដោយ ទោះបីជាអ្នកជឿលើព្រះ ឬព្រះគម្ពីរ ឬមិនជឿក៏ដោយ ឬរស់នៅតាមការសប្បាយរបស់អ្នកក៏ដោយ ស្ថានសួគ៌គឺនៅតែជារបស់អ្នក ដ្បិតមនុស្សរាល់គ្នាដឹងថា ប្រសិនបើថូម៉ាស់ជែន នៅស្ថានសួគ៌នឹងរីករាយជាខ្លាំង គេពិតជានឹងទៅទីនោះដែរ។ ការនេះច្បាស់ណាស់ថា មនុស្សទាំងអស់នឹងឃើញ ប្រសិនបើគេនឹងទៅទីនោះ។ ឥឡូវនេះ សាតាំងកំពុងធ្វើនូវអ្វី ដែលវាបានព្យាយាមធ្វើតាំងពីវាធ្លាក់ចុះមក។ តាមរយៈមនុស្សម្នាក់ៗ ដូចជា លោកថូម៉ាស់ជែន ជាដើម។ តាមរយៈអំណាច និងការអស្ចារ្យកុហករបស់វា វាកំពុងដកយកចេញទាំងបង្ខំ នូវសេចក្តីសង្ឃឹមរបស់គ្រីស្ទាន និងដកយកព្រះអាទិត្យរបស់គេ ដែលបំភ្លឺពួកគេ នៅក្នុងផ្លូវតូចទៅកាន់ស្ថានសួគ៌ចេញ។ វាកំពុងធ្វើអោយលោកីយ៍ជឿថា ព្រះគម្ពីរគ្មានអ្វីល្អ ជាងសៀវភៅរឿងទេ គ្មានព្រះបណ្តាលអោយសរសេរនោះឡើយ នៅពេលដែលវាកាន់ហុចអ្វីមួយទៅជំនួសវិញ ដែលគ្រាន់តែជាការបញ្ចេញអោយឃើញវិញ្ញាណតែប៉ុណ្ណោះ។

នេះគឺជាប្រឡាយមួយស្មោះត្រង់ ដល់វាទាំងស្រុង ក្រោមការគ្រប់គ្រងរបស់វា ហើយវាអាចធ្វើអោយលោកីយ៍ជឿនូវអ្វីដែលវានឹងធ្វើ វាបានលាក់បាំងនូវសៀវភៅដែលនឹងជំនុំជំរះពួកវា និងអ្នកដើរតាមវា នៅកន្លែងដែលវាចង់ទុក។ ព្រះបានបង្កើត

ព្រះអង្គសង្គ្រោះ នៃលោកីយ៍នេះ មិនខុសពីមនុស្សសាមញ្ញឡើយ ហើយនៅពេលដែលទាហានរ៉ូម ដែលបានយាមផ្នូររបស់ព្រះយេស៊ូវ បានផ្សព្វផ្សាយរបាយការណ៍ខុស និងកុហក ដែលសម្តេចសង្ឃ និងពួកនាហ្មឺនបានដាក់ក្នុងមាត់គេ ដើម្បីអោយអ្នកក្រ ពួកសិស្ស ដែលចាញ់បញ្ឆោតនៃការបង្ហាញអោយឃើញវិញ្ញាណក្លែងក្លាយទាំងនេះ រំពូកអោយមានគំនិតថា ការប្រសូត ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវនោះ វាគ្មានអ្វីអស្ចារ្យឡើយ ហើយវាបានដាក់ព្រះយេស៊ូវ និងព្រះគម្ពីរទៅក្នុងស្រមោល នៅកន្លែងដែលវាចង់អោយទ្រង់គង់នៅ រួចនាំលោកីយ៍អោយមើលទៅវា និងការអស្ចារ្យ ហើយនិងឫទ្ធិបារមីដ៏កំភូតរបស់វា ដែលវាអះអាងយ៉ាងគគ្រឹកគគ្រេងថា ជាការងាររបស់ព្រះគ្រីស្ទ។ ធ្វើដូច្នេះ លោកីយ៍ក៏ធ្លាក់ចូលទៅក្នុងអន្ទាក់ ហើយបានល្បួងលោមអោយនៅស្ងៀម មិនអាចរកឃើញការបោកបញ្ឆោត យ៉ាងធំនោះឡើយ រហូតដល់ការវេទនារបស់ព្រះ ទាំងប្រាំពីរបានទម្លាក់មក។ សាតាំងបានសើច នៅពេលវាឃើញផែនការរបស់វា មានជោគជ័យយ៉ាងល្អ ហើយលោកីយ៍ទាំងមូលនៅក្នុងអន្ទាក់របស់វា។

សូមអាន សាស្តា ៩:៥, យ៉ូហាន ១១:១-៤៥, ថែស្សាឡូនីចទី២ ២:៩-១២, វិវរណៈ ១៣:៣-១៤។

## ជំពូកទី៣១

## ការលោភលន់

ខ្ញុំបានឃើញសាតាំង និងទេវតារបស់វាពិភាក្សាជាមួយគ្នា។ វាបានបង្គាប់អោយ ទេវតារបស់វាចេញទៅវាយអន្ទាក់របស់វា ជាពិសេសចំពោះអ្នក ដែលកំពុងរង់



ចាំការយាងមកជាលើកទីពីរ របស់ព្រះគ្រីស្ទ និងអ្នកដែលគោរពគ្រប់ទាំងបញ្ញត្តិទាំងអស់របស់ព្រះ។ សាតាំងបាន ប្រាប់ទេវតារបស់វាទាំងអស់ថា ពួកជំនុំកំពុងតែដេកលក់។ វានឹងបង្កើនអំណាច និងការអស្ចារ្យ កំភូតរបស់វា ហើយវាអាចគ្រប់គ្រងពួកគេ។ ប៉ុន្តែនិកាយដែលរក្សាថ្ងៃបរិសុទ្ធ គឺជានិកាយដែលវាស្អប់។ វាបានធ្វើការប្រឆាំងនឹងយើងជាបន្ត និងដកយកពីយើងនូវកម្មវត្ថុនៃការគោរពច្បាប់ ដែលគួរឱ្យស្អប់របស់ព្រះនោះ។

ចូរចេញទៅធ្វើអោយម្ចាស់ដី និងម្ចាស់លុយឈ្លក់នឹងការខ្វល់ខ្វាយ។ ប្រសិនបើអ្នក អាចធ្វើអោយគេដាក់សេចក្តីស្រឡាញ់របស់គេ ទៅលើការខ្វល់ខ្វាយទាំងនេះយើងនឹងបានពួកគេទៀតផង។ គេនឹងអះអាងនូវអ្វីដែលគេចូលចិត្ត ចូរធ្វើអោយពួកគេខ្វាយខ្វល់ តែទៅលើលុយកាក់ខ្លាំងជាងជោគជ័យនៃនគររបស់ព្រះគ្រីស្ទ ឬក៏ការផ្សព្វ-ផ្សាយសេចក្តីពិតដែលយើងស្អប់។ ចូរបង្ហាញដល់គេ នូវលោកីយ៍ក្នុងពន្លឺដ៏គួរអោយចាប់អារម្មណ៍បំផុត ដើម្បីឱ្យគេស្រឡាញ់ និងគោរពវា។ យើងត្រូវតែថែរក្សានូវគ្រប់មធ្យោបាយទាំងអស់ នៅក្នុងកណ្តាប់ដៃយើង។ គេមានមធ្យោបាយកាន់តែច្រើន គេនឹងធ្វើអោយអាប់ឱននគររបស់យើងកាន់តែខ្លាំង ដោយបានទទួលរាស្ត្ររបស់យើង។ ហើយបើគេចាត់តាំងការប្រជុំនៅកន្លែងផ្សេងៗជាច្រើន នោះយើងមានគ្រោះថ្នាក់ហើយ។ ពេលនោះចូរប្រុងប្រយ័ត្នអោយមែនទែន។ ចូរធ្វើអោយគេច្របូកច្របល់ ឱ្យអស់លទ្ធភាព។ ធ្វើអោយគេស្អប់គ្នាទៅវិញទៅមក។ បំបាក់ទឹកចិត្ត និងបាត់បង់សេចក្តីក្លាហានដល់គ្រូគង្វាលរបស់គេ ព្រោះយើងស្អប់ពួកគេ។ ចូរបញ្ឈប់នូវការដោះសារសមហេតុសមផលទាំងឡាយ ចំពោះអ្នកមានធនធាន ក្រែងគេចែកចាយវាបន្ត។ ចូរគ្រប់គ្រងរឿងលុយកាក់របស់គេ បើអាចធ្វើបាន ហើយត្រូវអូសទាញអ្នកបំរើការងាររបស់គេ ឱ្យប្រាថ្នាចង់បានប្រាក់។ ធ្វើដូច្នេះ នឹងធ្វើអោយគេបាត់បង់សេចក្តីក្លាហាន និង

ចិត្តអង់អាច។ ចូរប្រយុទ្ធនៅលើដីគ្រប់ចង្កាម។ ចូរធ្វើអោយគេមានលក្ខណៈជាអ្នកលោភលន់ និងស្រឡាញ់ទ្រព្យសម្បត្តិលោកីយ៍។ នៅពេលដែលលក្ខណៈនេះ គ្រប់គ្រងលើពួកគេ សេចក្ដីសង្គ្រោះ ហើយនិងព្រះគុណ នឹងដើរថយក្រោយ។ ចូរនាំគ្នាព័ទ្ធជុំវិញពួកគេឱ្យអស់លទ្ធភាព ហើយទាក់ទាញពួកគេ នោះគេពិតជានឹងក្លាយជារបស់យើង។ មិនមែនគ្រាន់តែអ្នកដែល យើងចូលចិត្តនឹងពួកគេនោះទេ ប៉ុន្តែ ឥទ្ធិពលនៃសំអប់របស់គេនឹងមិនទទួល ការដឹកនាំទៅស្ថានសួគ៌ពីអ្នកដទៃឡើយ។ ហើយអ្នកដែលប៉ុនប៉ងដាក់ការប្រឆាំង ដោយកំហឹងទៅលើគំនិតពួកគេ នោះវាអាចនឹងមិនមានប្រយោជន៍ឡើយ។

ខ្ញុំបានឃើញថា សាតាំងបានអនុវត្តផែនការរបស់វាបានយ៉ាងល្អ។ ហើយនៅពេលដែលអ្នកបំរើរបស់ព្រះចាត់តាំងអង្គប្រជុំ សាតាំង និងទេវតារបស់វាបានយល់អំពីការងាររបស់វា នៅលើផែនដី ដើម្បីបំផ្លាញការងាររបស់ព្រះ វាបានដាក់យោបល់របស់វាជានិច្ច ទៅក្នុងគំនិតនៃរាស្ត្ររបស់ព្រះ។ វាបានដឹកនាំអ្នកនេះទៅតាមផ្លូវនេះ ហើយដឹកនាំអ្នកខ្លះទៀតតាមផ្លូវនោះ ឆ្លៀតយកប្រយោជន៍ ពីលក្ខណៈអាក្រក់របស់បងប្អូនប្រុសស្រីទាំងឡាយ កកូរកកាយ និងធ្វើឱ្យរំជើបរំជួល នូវការរំខានពីធម្មជាតិរបស់គេឥតឈប់ឈរ។ ប្រសិនបើពួកគេត្រូវបានធ្វើឱ្យស្រឡាញ់ការកំណាញ់ និងការលោភលន់ សាតាំងរីករាយ នឹងឈរនៅខាងពួកគេណាស់ ហើយបន្ទាប់មក វាស្វះស្វែងនឹងនាំពួកគេដោយអំណាចគ្រប់បែបយ៉ាងរបស់វា អោយបង្ហាញនូវអំពើបាប ដែលជាការរំខានឥតឈប់ឈររបស់ពួកគេ។ ប្រសិនបើព្រះគុណរបស់ព្រះ និងពន្លឺនៃសេចក្ដីពិត បានរំលាយសេចក្ដីលោភ និងភាពអាត្មានិយមទាំងនេះតែបន្តិច នោះពួកគេមិនមានជ័យជំនះទាំងស្រុងលើការលោភលន់ និងការកំណាញ់នោះទេ នៅពេលនោះគេមិននៅក្រោមឥទ្ធិពលនៃសេចក្ដីសង្គ្រោះឡើយ។ សាតាំងបានចូលមក និងដកយកនូវគោលការណ៍ថ្លៃថ្នូរ និងសប្បុរសចេញ ហើយគេគិតថា គេបានធ្វើច្រើនពេកហើយ។ គេអស់កម្លាំងនឹងធ្វើល្អ



ហើយបានភ្លេចទាំងអស់ នូវការលះបង់ដ៏ធំ ដែលព្រះយេស៊ូវបានធ្វើសំរាប់ពួកគេ ដើម្បីលោះពួកគេ ពីអំណាចរបស់សាតាំង និងអាថិកំបាំងដ៏អស់សង្ឃឹម។

សាតាំងបានឆ្លៀតយកចំណេញ ពីការកំណាញ់ និងការលោភលន់របស់យូដាស ហើយបាននាំគាត់អោយរអ៊ូរទាំជាមួយនឹងទឹកអប់ ដែលនាងម៉ារីបានថ្វាយព្រះយេស៊ូវ។ យូដាសបានមើលទៅការនោះ ជាការខ្ជះខ្ជាយណាស់ គួរតែទុកប្រេងនោះ លក់យកលុយចែកអ្នកក្រីក្រវិញ។ គាត់មិនមែនខ្វាយខ្វល់ពីអ្នកក្រីក្រទេ តែគាត់បានពិចារណាអំពីដង្វាយសប្បុរសដ៏មានតម្លៃលើសលប់ ដែលបានថ្វាយទៅព្រះយេស៊ូវទៅវិញទេ។ យូដាសបានកាត់តម្លៃព្រះអម្ចាស់របស់គាត់យ៉ាងទាប ដោយលក់ទ្រង់យកប្រាក់បន្តិចបន្តួច តែពីរបីដុំប៉ុណ្ណោះ។ ហើយខ្ញុំបានឃើញថា មានមនុស្សដូចយូដាសខ្លះ នៅក្នុងចំណោមអ្នកដែលប្រកាសថា កំពុងរង់ចាំព្រះអម្ចាស់។ សាតាំងបានគ្រប់គ្រងលើពួកគេ តែគេមិនបានដឹងទេ។ គ្មានការលោភលន់ ឬការកំណាញ់ណាមួយ ដែលព្រះយល់ព្រមនោះទេ។ ទ្រង់ស្អប់វា ហើយទ្រង់ស្អប់សេចក្ដីអធិស្ឋាន និងពាក្យសំដីរបស់មនុស្ស ដែលមានការលោភលន់ និងកំណាញ់ផង។ ដោយសាតាំងបានឃើញពេលវេលារបស់វា នៅកាន់តែខ្លី វាដឹកនាំមនុស្សអោយកាន់តែកំណាញ់ឡើង កំណាញ់ឡើង លោភឡើង លោភឡើង ហើយវាក៏រីករាយ នៅពេលដែលវាឃើញពួកគេចងខ្លួនឯងជាប់ ដោយការលោភលន់ និងការកំណាញ់។ ប្រសិនបើភ្នែករបស់ពួកគេបានបើក គេនឹងឃើញសាតាំងក្នុងជ័យជំនះដ៏កំណាញ់ កំពុងរីករាយនៅជុំវិញពួកគេ និងកំពុងសើចចំពោះកំហុសរបស់អ្នក ដែលទទួលការឱ្យយោបល់របស់វា ហើយចូលក្នុងអន្ទាក់របស់វា។ រួចសាតាំង និងទេវតារបស់វា យកសកម្មភាពលោភលន់ និងការកំណាញ់របស់មនុស្សម្នាក់ៗទាំងនេះ ហើយបង្ហាញទៅឯព្រះយេស៊ូវ និងទេវតាបរិសុទ្ធរបស់ពួកគេ ដែលរៀបចំខ្លួននឹងទទួលការជំនុំជំរះ រួចសាតាំងកត់ត្រាអំពើអាក្រក់របស់គេ រួចមកប្រៀបធៀបទៅនឹងព្រះ

គម្ពីរ ដែលជាដំណឹងទាស់នឹងសេចក្ដីទាំងអស់នេះទាំងស្រុង ហើយក៏បង្ហាញទៅទេវតានៅស្ថានសួគ៌ធ្វើអោយមួរម៉ៅ ទាំងនិយាយដោយចោទប្រកាន់ថា នេះគឺជាអ្នកដែលដើរតាមព្រះគ្រីស្ទ និងព្រះបន្ទូលរបស់ទ្រង់ ទាំងអស់នេះគឺជាផលផ្លែនៃការជាប់ឆ្កាង និងការប្រោសលោះរបស់ព្រះគ្រីស្ទ ទេវតាបែរចេញពីទស្សនីយភាពនោះ ទាំងខ្ពើមរអើម។ ព្រះតម្រូវឱ្យរាស្ត្ររបស់ទ្រង់ធ្វើល្អជានិច្ច ហើយនៅពេលដែលគេមិនចង់ធ្វើល្អ និងការសប្បុរស ព្រះក៏ល្ងើយជាមួយនឹងគេដែរ។ ខ្ញុំបានឃើញថា ព្រះអង្គមិនសព្វព្រះទ័យជាមួយនឹងការបង្ហាញពីភាពកំណាញ់យ៉ាងតូចបំផុត នៃរាស្ត្ររបស់ទ្រង់ឡើយ ដ្បិតគឺពួកគេហើយ ដែលព្រះយេស៊ូវមិនសំចៃទុកព្រះជន្ម ដ៏មានតម្លៃរបស់ទ្រង់។ បុគ្គលដែលកំណាញ់ និងលោភលន់ នឹងធ្លាក់ចុះពីផ្លូវ។ ដូចជាយូដាស បានលក់ព្រះអម្ចាស់របស់គាត់ដែរ ពួកគេបានលក់គោលការល្អ និងសេចក្ដីសប្បុរស យករបស់បន្តិចនៃផែនដី។ អំពើទាំងអស់នេះនឹងត្រូវយកចេញពីរាស្ត្ររបស់ព្រះ។ អ្នកណាដែលចង់បានស្ថានសួគ៌ ត្រូវតែបានលើកទឹកចិត្ត ដោយគោលការនៃស្ថានសួគ៌ និងគ្រប់ថាមពល ដែលខ្លួនមានហើយជាជាងអោយព្រលឹងរបស់គេ ស្វះស្វែងរកសេចក្ដីកំណាញ់ គេគួរតែពង្រឹងចិត្តមេត្តាករុណា និងគួរបង្កើនការធ្វើល្អ ទៅរកគ្នាទៅវិញទៅមក និងបង្កើនអោយកាន់តែធំធាត់នូវគោលការរបស់ស្ថានសួគ៌ នៅគ្រប់កាលៈទេសៈ។ ទេវតាបាននាំព្រះយេស៊ូវមកឯខ្ញុំជាគំរូ ដ៏គ្រប់លក្ខណ៍។ ព្រះជន្មរបស់ទ្រង់គ្មានការចាប់អារម្មណ៍ លើភាពកំណាញ់ឡើយ ហើយត្រូវបានកត់សំគាល់ ដោយសេចក្ដីមេត្តាករុណា ដែលមិនគិតពីផលប្រយោជន៏ផ្ទាល់ព្រះអង្គឡើយ។

សូមអានម៉ាកុស ១៤:៣-១១, លូកា ១២:១៥-៤០,កូល៉ូស ៣: ៥-១៦, យ៉ូហានទី១ ២:១៥-១៧។



ជំពូកទី៣២

## ការវែងស្ទេ

ខ្ញុំបានឃើញមនុស្សខ្លះ ដែលមានសេចក្ដីជំនឿរឹងមាំ និងសំរែកយ៉ាងក្រៀមក្រំ កំពុងអង្វរករដល់ព្រះ។ ទឹកមុខរបស់គេស្លេកស្លាំង និងបង្ហាញពីការថប់បារម្ភ យ៉ាងជ្រាលជ្រៅ ដែលបានបញ្ជាក់ពីការពុះពារនៅក្នុងចិត្តពួកគេ។ ទឹកមុខរបស់ពួកគេបានបញ្ជាក់ពីភាពរឹងមាំ និងការស្មោះត្រង់យ៉ាងឧត្តម នៅពេលដែលតំណក់ញើសធំៗ ហូរធ្លាក់ពីថ្ងាសរបស់គេ។ យូរៗម្ដង មុខរបស់ពួកគេបានបំភ្លឺឡើង ដោយសញ្ញានៃការកោតសរសើររបស់ព្រះ ហើយការកោតសរសើរ ដោយស្មោះអស់ពីចិត្តយ៉ាងរឹងមាំ បានកើតឡើងលើពួកគេម្ដងទៀត។

ទេវតាអារក្សបានព័ទ្ធជុំវិញពួកគេ ជំរុញភាពងងឹតមកលើពួកគេ ដើម្បីលាក់បាំងព្រះយេស៊ូវពីពួកគេ ធ្វើអោយភ្នែករបស់គេបែរទៅរកភាពងងឹត ដែលនៅជុំវិញពួកគេ ហើយពួកគេក៏មិនស្មោះត្រង់ជាមួយព្រះ បន្ទាប់មក ពួកគេក៏រអ៊ូរទាំទាស់នឹងទ្រង់។ សុវត្ថិភាពតែមួយគត់របស់ពួកគេ គឺការចោលភ្នែករបស់គេសំឡឹងទៅលើ។ សាតាំងបានចោទប្រកាន់ទៅលើរាស្ត្ររបស់ព្រះ ហើយនាពេលដែលបរិយាកាសដ៏ពិសពុល ពីទេវតាអាក្រក់ទាំងនេះ បានគ្របសង្កត់ជុំវិញពួកអ្នក ដែលហត់ហេវទាំងនោះ ទេវតាដែលបានការពារពួកគេ បានបន្តត្រដាងស្លាបលើពួកគេ ដើម្បីកំចាត់ភាពងងឹតយ៉ាងក្រាស់ដែលនៅជុំវិញគេ។

ខ្ញុំបានឃើញមនុស្សខ្លះមិនបានចូលរួមក្នុងការឈឺចាប់ និងការអង្វរករទេ។ គេហាក់ដូចជាមិនខ្វាយខ្វល់ និងមិនរវីរវល់ពីអ្វីទាំងអស់។ គេមិនបានប្រឆាំងនឹងភាពងងឹតនៅជុំវិញខ្លួនគេឡើយ ហើយគេបានត្រូវខ្ទប់ដោយភាពងងឹត ដូចជាពពកយ៉ាងក្រាស់

វិញ។ ទេវតារបស់ព្រះបានចាកចេញពីគេ ហើយបានយាងទៅឯជំនួយរបស់អ្នកដែលស្មោះត្រង់ និងអ្នកអធិស្ឋាន។ ខ្ញុំបានឃើញទេវតារបស់ព្រះ ប្រញាប់ប្រញាល់ទៅឯជំនួយរបស់អ្នកដែលបានខំប្រឹងប្រែងអស់ពីកម្លាំង ដើម្បីទប់ទល់នឹងទេវតាអារក្ស និងខំប្រឹងប្រែងជួយខ្លួនឯង ដោយអំពាវនាវទៅព្រះ ដោយស្មារតីលះបង់។ ប៉ុន្តែទេវតាបានចាកចេញពីអ្នកដែលមិនខំប្រឹងប្រែងជួយខ្លួនឯង ហើយពួកគេក៏បាត់ពីភ្នែកខ្ញុំទៅ។

នៅពេលដែលអ្នកអធិស្ឋានទាំងនេះ បានបន្តសំរែកដ៏ស្មោះត្រង់របស់គេ ពេលនោះ កាំរស្មីនៃពន្លឺមកពីព្រះយេស៊ូវបានមកឯពួកគេ ហើយបានលើកទឹកចិត្តពួកគេ និងបានចែងចាំងទៅលើមុខរបស់គេ។

ខ្ញុំបានសួរពីអត្ថន័យនៃការរង្វៃ ដែលខ្ញុំបានឃើញទាំងនេះ។ ទេវតាបានបង្ហាញខ្ញុំថា បានកើតឡើងដោយទីបន្ទាល់យ៉ាងចំៗ ដែលចេញពីក្រុមប្រឹក្សានៃទីបន្ទាល់ពិតឡៅឌីសេ។ វានឹងមានឥទ្ធិពលរបស់វា លើចិត្តរបស់អ្នកទទួលទីបន្ទាល់ ហើយវានឹងដឹកនាំអោយលើកដំកើងភាពជាគំរូ និងបង្ហុរមកនូវសេចក្ដីពិតយ៉ាងចំៗ។ អ្នកខ្លះនឹងមិនទទួលទីបន្ទាល់ដ៏ពិតនោះទេ។ គេនឹងក្រោកឡើងប្រឆាំងនឹងទីបន្ទាល់នេះ ហើយនឹងបណ្ដាលអោយមានការសៅហ្មង ក្នុងចំណោមរាស្ត្ររបស់ព្រះ។

ខ្ញុំបានឃើញថា សាក្សីនៃទីបន្ទាល់ដ៏រស់មិនទាន់បានគេគោរពបានពាក់កណ្ដាលទេ។ ទីបន្ទាល់ដ៏រឹងមាំ ដែលជាវាសនារបស់ពួកជំនុំធ្លាក់ចុះ ត្រូវបានគេគោរពដោយពន្លឺប្រសិនបើគេមិនបដិសេធទាំងស្រុងទេ។ ទីបន្ទាល់នេះ ត្រូវតែធ្វើការសំរេចចិត្តយ៉ាងជ្រាលជ្រៅ ហើយអ្នកណាដែលទទួលវាពិតជាទទួលវាទាំងអស់ និងស្ដាប់បង្គាប់វា ហើយត្រូវបានសំអាតអោយបរិសុទ្ធ។

ទេវតាបានមានបន្ទូលថា ចូរកត់ត្រាចុះ រំពេចនោះខ្ញុំបានឮសំឡេងដូចជាឧបករណ៍តន្ត្រីជាច្រើន ទាំងឮជាបទយ៉ាងពិរោះរណ្ដំស្រុះគ្នាឥតទាស់។ វាពិរោះជាង



ភ្លេងទាំងឡាយ ដែលខ្ញុំធ្លាប់បានឮ។ វាហាក់ដូចជាពោរពេញដោយសេចក្ដីមេត្តាកុរណាការអាណិតអាសូរ និងក្ដីអំណរដ៏បរិសុទ្ធយ៉ាងខ្ពស់ត្រដែត។ វាធ្វើអោយរំភើបដល់រាងកាយខ្ញុំទាំងមូល។ ទេវតាបានមានបន្ទូលថា ចូរអ្នកមើល ពេលនោះការចាប់អារម្មណ៍របស់ខ្ញុំបានបែរទៅឯក្រុម ដែលខ្ញុំបានឃើញពីមុន ដែលត្រូវបានធ្វើអោយសៅហ្មងយ៉ាងដំណំ។ ទេវតាបានបង្ហាញខ្ញុំ នូវអ្នកដែលខ្ញុំបានឃើញពីមុន កំពុងយំសោក និងអធិស្ឋានដោយវិញ្ញាណនៃក្ដីទុក្ខសោក។ ខ្ញុំបានឃើញទេវតា ដែលថែរក្សាមួយក្រុមដែលជុំវិញពួកគេ បានបន្ថែមចំនួនមួយជាពីរ ហើយបានបំពាក់អាវុធអោយគេ តាំងពីក្បាលដល់ជើង។ ពួកគេបានធ្វើចលនាតាមរបៀបយ៉ាងត្រឹមត្រូវ និងហ្មឹងម៉ាត់ ដូចជាទាហានមួយក្រុមដូច្នេះដែរ។ ទឹកមុខរបស់គេបានបង្ហាញពីជម្លោះដ៏ធ្ងន់ធ្ងរ ដែលគេបានរងទ្រាំ គឺការពិបាកដ៏ឈឺចាប់យ៉ាងខ្លាំង ដែលបានកន្លងផុតទៅ។ តែលក្ខណៈពិសេសរបស់គេបានកត់ចំណាំ ដោយកំហឹងពីខាងក្នុងដ៏ខ្លាំងក្លារបស់គេ ដែលឥឡូវនេះចែងចាំងជាមួយនឹងពន្លឺ និងសិរីល្អនៃស្ថានសួគ៌។ គេបានជ័យជំនះ ហើយមានការដឹងគុណយ៉ាងជ្រាលជ្រៅ បានចេញពីពួកគេ ព្រមទាំងក្ដីអំណរដ៏ពិសិដ្ឋ និងបរិសុទ្ធ។

ចំនួននៃក្រុមនេះបានចុះថយ។ ខ្លះត្រូវបានគេធ្វើអោយសៅហ្មង ហើយបានចាកចេញទៅដោយខ្លួនឯង។ អ្នកដែលមិនយកចិត្តទុកដាក់ និងព្រងើយកន្តើយ ដែលមិនចូលរួមជាមួយអ្នក ដែលបានអោយតម្លៃទៅលើជ័យជំនះ និងសេចក្ដីសង្គ្រោះល្មមនឹងការឈឺចាប់ខ្លាំង ធ្ងន់ធ្ងរ និងអង្វរករសុំការរួបរួមមិនបានឡើយ ហើយពួកគេត្រូវបានទុកអោយនៅពីក្រោយភាពងងឹត ហើយចំនួនរបស់គេត្រូវបានបន្ថែម ដោយអ្នកដែលមានសេចក្ដីពិត ហើយបង្កើតជាក្រុមឡើង។ ទេវតាអារក្សនៅតែជុំវិញពួកគេ ប៉ុន្តែពួកវាមិនអាចមានអំណាចទៅលើគេឡើយ។

ខ្ញុំបានឮអ្នកដែលប្រដាប់កាយដោយអាវុធ បាននិយាយនូវសេចក្ដីពិត ដោយ

អំណាច។ វាបានជះឥទ្ធិពលជាខ្លាំង។ ខ្ញុំបានឃើញអ្នកដែលត្រូវបានគេចាប់ចងប្រពន្ធខ្លះដែលប្ដីបានចង កូនខ្លះដែលឪពុកម្ដាយបានចង។ អ្នកស្មោះត្រង់ដែលត្រូវបានរារាំងឬការពារពីការឮសេចក្ដីពិត ឥឡូវនេះបានចាប់យកសេចក្ដីពិត ដែលគេបាននិយាយដោយយកចិត្តទុកដាក់។ ការភិតភ័យដោយសារបងប្អូនគេទាំងឡាយបានបាត់បង់ទៅ។ សេចក្ដីពិតតែមួយគត់ បានលើកដំកើងពួកគេ។ វាគឺជាសេចក្ដីស្រឡាញ់ និងមានតម្លៃជាងជីវិតទៅទៀត។ គេបានស្រេកឃ្លានសេចក្ដីពិត។ ខ្ញុំបានសួរថា តើអ្វីទៅដែលធ្វើអោយមានការផ្លាស់ប្រែដូច្នេះ។ ទេវតាមួយអង្គបានឆ្លើយថា វាគឺជាភ្លៀងចុងរដូវការសំរាកពីព្រះវត្តមានរបស់ព្រះអម្ចាស់ សំរែកដ៏រំពងរបស់ទេវតាទីបី។ អំណាចដ៏ខ្លាំងពូកែបាននៅជាមួយនឹងអ្នក ដែលបានជ្រើសតាំងទាំងនេះ។ ទេវតាបានមានបន្ទូលថា ចូរមើលការចាប់អារម្មណ៏របស់ខ្ញុំ បានបំបែរទៅរកអ្នកអាក្រក់ និងអ្នកមិនជឿ។ ពួកគេទាំងអស់គ្នាជ្រួលជ្រើម។ កម្លាំងចិត្ត និងអំណាចនៃរាស្ត្ររបស់ព្រះ បានងើបឡើងហើយបានធ្វើអោយគេខឹងជាខ្លាំង។ ការច្របូកច្របល់មាននៅគ្រប់ជ្រុង។ ខ្ញុំបានឃើញគេបានចាត់វិធានការទាស់នឹងក្រុម ដែលមានអំណាច និងពន្លឺរបស់ព្រះនេះម្ដងទៀត។ ភាពងងឹតកាន់តែក្រាស់ឡើងនៅជុំវិញពួកគេ តែគេបានឈរមាំមួន ទុកចិត្តលើព្រះ និងស្រឡាញ់ទ្រង់ដដែល។ ខ្ញុំបានឃើញពួកគេបានអន្ទះសារ។ បន្ទាប់មកខ្ញុំបានឮពួកគេស្រែកទៅកាន់ព្រះដោយស្មោះស្ម័គ្រ។ គេស្រែកឥតឈប់ឈរ ទាំងថ្ងៃទាំងយប់។ ខ្ញុំបានឮសំឡេងនោះថា ឱព្រះអម្ចាស់អើយ សូមអោយព្រះហឫទ័យទ្រង់បានសំរេច ប្រសិនបើវាអាចជាការសរសើរតំកើងព្រះនាមទ្រង់ សូមរៀបចំផ្លូវដើម្បីរំដោះរាស្ត្រទ្រង់ សូមរំដោះយើងខ្ញុំពីអ្នកមិនជឿ ដែលនៅជុំវិញយើងខ្ញុំ គេប្រុងនឹងសម្លាប់យើងខ្ញុំហើយ ប៉ុន្តែព្រះពាហុទ្រង់អាចសង្គ្រោះបាន។ ទាំងអស់នេះគឺជាពាក្យ ដែលខ្ញុំចាំ។ គេហាក់បីដូចជាដឹងយ៉ាងច្បាស់នូវការមិនគួរគម្បីរបស់គេ គេបានបង្ហាញការចុះចូលទាំងស្រុង ទៅក្នុង



ព្រះហឫទ័យរបស់ព្រះ ហើយគ្រប់គ្នាបានអង្វរករយ៉ាងស្មោះអស់ពីចិត្ត ដោយគ្មានការរង់ចាំ និងកញ្ឆក់យកការរំដោះខ្លួនយ៉ាងរហ័សដូចយ៉ាកុប។

បន្ទាប់ពីការចាប់ផ្ដើមសំរែកដ៏ស្មោះត្រង់របស់គេបន្តិច ទេវតាបានទៅរំដោះគេដោយអាណិតអាសូរ។ ប៉ុន្តែទេវតាជាមេបញ្ជាការមួយខ្ពស់ មិនព្រមប្រគល់ពួកគេមកឡើយ។ ទេវតានោះបានមានបន្ទូលថា ព្រះហឫទ័យរបស់ព្រះមិនទាន់បានសំរេចទេ។ គេត្រូវតែផឹកពីពែងនេះ។ គេត្រូវតែមុជដោយការជ្រមុជទឹក។

រំពេចនោះខ្ញុំបានឮព្រះសូរសៀងរបស់ព្រះ ដែលបានអង្រួនផ្ទៃមេឃ និងផែនដី។ មានការរញ្ជួយផែនដីយ៉ាងខ្លាំង។ អាគារជាច្រើនបានរញ្ជួយ ហើយរលំដួលគ្រប់ទិសទី។ ពេលនោះខ្ញុំបានឮសូរសំរែកនៃជ័យជំនះដ៏កងរំពង ព្រមទាំងសំឡេងភ្លេងយ៉ាងឮនិងច្បាស់ៗ។ ខ្ញុំបានមើលទៅឯក្រុមមួយ ដែលមុននេះបន្តិច មានការទុក្ខព្រួយ និងជាប់ចំណង។ ការបង្ខាំងរបស់គេត្រូវបានគេបង្វែរ។ ពន្លឺដ៏ភ្លឺបានចែងចាំងទៅលើពួកគេ។ ពេលនោះមើលទៅគេល្អជាខ្លាំង។ ការខ្វល់ខ្វាយ និងសញ្ញានៃការទុក្ខព្រួយបានបាត់បង់ទៅ។ សុខភាពល្អ និងសម្រស់បានត្រូវគេមើលឃើញ នៅលើទឹកមុខរបស់គេគ្រប់គ្នា។ សត្រូវរបស់គេជាអ្នកមិនជឿ ដែលនៅជុំវិញគេ ដូចមនុស្សស្លាប់។ គេមិនអាចទ្រាំទ្រនឹងពន្លឺ ដែលចាំងទៅលើអ្នកដែលបានរំដោះចេញដ៏បរិសុទ្ធនោះឡើយ។ ពន្លឺ និងសិរីល្អនេះនៅពីលើពួកគេ រហូតដល់គេបានឃើញព្រះយេស៊ូវនៅក្នុងពពកលើមេឃ ហើយក្រុមអ្នករងទុក្ខបានផ្លាស់ប្រែមួយរំពេច ក្នុងមួយប៉ព្រិចភ្នែក ពីសិរីល្អមួយ ទៅសិរីល្អមួយ។ ហើយផ្នូរជាច្រើនបានរបើកឡើង រួចពួកបរិសុទ្ធបានក្រោកឡើង ប្រដាប់កាយដោយការមិនចេះស្លាប់ បញ្ចេញសំរែកជ័យឃោសលើសេចក្ដីស្លាប់ និងលើផ្នូរ ហើយរួបរួមជាមួយអ្នកបរិសុទ្ធដទៃទៀត ដែលត្រូវបានលើកឡើងទៅជួបព្រះអម្ចាស់របស់គេ នៅលើអាកាស នៅពេលដែលសំឡេងតន្ត្រីដ៏កងរំពង បន្លឺពីសិរីល្អ និងជោគជ័យ

បានចេញពីអណ្តាតរបស់អ្នកមិនស្លាប់គ្រប់គ្នា ហើយអណ្តែតចេញពីបបូរមាត់របស់អ្នកសុចរិត និងអ្នកបរិសុទ្ធគ្រប់ៗគ្នា។

សូមអានទំនុកដំកើង ជំពូក៨៦, ហូសេ ៦:៣, ហាកាយ ២:២១-២៣, ម៉ាថាយ ១០:៣៥-៣៩, ២០:២៣, អេភេសូរ ៦:១០-១៨, ថែស្សាឡូនីចទី១ ៤:១៤-១៨, វិវរណៈ ៣:១៤-២២។

ជំពូកទី៣៣

## អំពើបាបរបស់ទីក្រុងបាប៊ីឡូន

ខ្ញុំបានឃើញសភាពរបស់ពួកជំនុំ ផ្សេងៗគ្នាជាច្រើន តាំងពីទេវតាទីពីរបានប្រកាសពីការធ្លាក់ចុះរបស់គេមក។ ពួកគេបានធ្វើខុសកាន់តែខ្លាំងឡើងៗ តែគេនៅតែរក្សាឈ្មោះថា ជាសិស្សរបស់ព្រះគ្រីស្ទដដែល។ វាមិនអាចបែងចែកពួកគេចេញពីលោកីយ៍ឡើយ។ គ្រូគង្វាលរបស់គេបានយកអត្ថបទពីលោកីយ៍ ហើយអធិប្បាយពីរឿងដែលងាយស្រួល។ ចិត្តធម្មជាតិរបស់មនុស្ស គ្មានការប្រឆាំងនឹងរឿងនេះឡើយ។ មានតែអំណាច និងព្រលឹងនៃសេចក្តីពិត សេចក្តីសង្គ្រោះទេ ដែលចិត្តរបស់លោកីយ៍ស្អប់ខ្ពើម។ គ្មានអ្វីនៅក្នុងការងារដ៏មានប្រជាប្រិយ៍ ដែលបំផុសកំហឹងរបស់សាតាំង ដែលធ្វើអោយអ្នកមានបាបញ៉រ័រន្ធត់ ឬអនុវត្តទៅលើចិត្ត និងស្មារតីនៃសេក្តីពិតដ៏គួរអោយភ័យខ្លាចរបស់ការជំនុំជំរះ ដែលនឹងមកដល់នៅពេលឆាប់ៗនេះឡើយ។ ជាទូទៅមនុស្សតែងតែពេញចិត្តនឹងការល្អ ដែលគ្មានសេចក្តីពិត ហើយគេនឹងបន្ថែម និងគាំទ្រថា ជារឿងសាសនា។ ទេវតាបានមានបន្ទូលថា គ្មានអ្វីតូចជាងគ្រឿងសឹកនៃសេចក្តីសុចរិតទាំងមូល អាចមានជ័យជំនះ និងរក្សាជ័យជំនះលើភាពងងឹតឡើយ សាតាំង



បានយកតួនាទី ជាអង្គការរបស់ពួកជំនុំទាំងស្រុង។ ការនិយាយ និងទង្វើរបស់មនុស្សត្រូវបានគេយកមកដាក់ជំនួសអោយសេចក្តីពិត នៃព្រះបន្ទូលរបស់ព្រះ។ ទេវតាបានមានបន្ទូលថា មិត្តភ័ក្តិ និងវិញ្ញាណរបស់លោកីយ៍ គឺជាសត្រូវជាមួយនឹងព្រះ។ នៅពេលដែលសេចក្តីពិត ក្នុងភាពងាយស្រួល និងកម្លាំងរបស់វាមានហាក់ ដូចជាព្រះយេស៊ូវត្រូវបាននាំមកទាស់នឹងវិញ្ញាណរបស់លោកីយ៍ វាដាស់វិញ្ញាណនៃការបៀតបៀនភ្លាម។ មានមនុស្សជាច្រើន ច្រើនមែនទែនដែលអះអាងថា ជាគ្រីស្ទាន តែមិនស្គាល់ព្រះ។ លក្ខណៈនៃចិត្តពីធម្មជាតិរបស់គេមិនបានផ្លាស់ប្តូរឡើយ ហើយគំនិតលោកិយ៍នៅមានជាសត្រូវជាមួយនឹងព្រះដដែល។ ពួកគេគឺជាអ្នកបំរើដ៏ស្មោះត្រង់របស់សាតាំងផ្ទាល់ ថ្វីបើគេបានប្រើប្រាស់ឈ្មោះផ្សេងក៏ដោយ។

ខ្ញុំបានឃើញថា តាំងពីព្រះយេស៊ូវបានចាកចេញពីកន្លែងបរិសុទ្ធ នៃទីបរិសុទ្ធនៃស្ថានសួគ៌ ហើយបានយាងចូលទៅក្នុងវាំងននទីពីរ ពួកជំនុំត្រូវបានបោះបង់ចោលដូចជាសាសន៍យូដាដែរ ហើយគេបានបំពេញដោយបក្សីមិនស្អាត និងគួរអោយស្អប់ខ្ពើម។ ខ្ញុំបានឃើញភាពទុច្ចរិត និងអំពើហឹង្សាជាច្រើននៅក្នុងពួកជំនុំ តែគេនៅតែអះអាងថាគេជាគ្រីស្ទាន។ ការអះអាងរបស់គេ ការអធិស្ឋានរបស់គេ និងពាក្យសំដីរបស់គេ គឺជាការស្អប់ខ្ពើមនៅចំពោះ ព្រះភ័ក្ត្ររបស់ព្រះ។ ទេវតាបានមានបន្ទូលថា ព្រះនឹងមិនហិតក្លិនការប្រជុំរបស់គេឡើយ។ ភាពកំណាញ់ ការបំភ័ន្ត និងការឆបោកត្រូវបានពួកគេអនុវត្តដោយគ្មានការភ្ញាក់រឭក។ ហើយលើសពីនេះទៅទៀត លក្ខណៈអាក្រក់ទាំងអស់នេះ គេបានបំភ័ន្តរូបរាងខាងក្រៅនៃសាសនា។ ទេវតាបានបង្ហាញខ្ញុំ ពីអំនួតរបស់ពួកជំនុំតែខាងក្រៅ។ ព្រះមិនបានគង់នៅក្នុងគំនិតរបស់គេទេ ប៉ុន្តែគំនិតលោកីយ៍របស់គេបាននៅពីលើពួកគេ។ គេតុបតែងរូបកាយដែលត្រូវស្លាប់ ដ៏កំសត់របស់គេ ហើយសំឡឹងមើលខ្លួនឯងដោយការពេញចិត្ត និងអំណររីករាយ។ ព្រះយេស៊ូវ និងទេវតា

របស់ទ្រង់បានទតមើលទៅកាន់ពួកគេដោយកំហឹង។ ទេវតាបានមានបន្ទូលថា អំពើបាប និងអំនួតរបស់គេបានឮដល់ស្ថានសួគ៌ហើយ។ ចំណែករបស់គេត្រូវបានរៀបចំហើយ។ សេចក្តីយុត្តិធម៌ និងការជំនុំជំរះបានដេកលង់លក់យ៉ាងយូរ ប៉ុន្តែនឹងក្រោកឡើងនៅពេលឆាប់ៗ ព្រះអម្ចាស់បានមានបន្ទូលថា ការសងសឹកនោះស្រេចនឹងអញ អញនឹងសងដល់គេ។ គេបានដឹង ពីការគំរាមយ៉ាងគួរអោយភ័យខ្លាចរបស់ទេវតាទីបី ហើយគេនឹងផឹកពីសេចក្តីក្រោធរបស់ព្រះ។ ហើយពួកទេវតាអាក្រក់យ៉ាងច្រើនឥតគណនា បានពង្រាយពាសពេញផែនដីទាំងមូល។ ពួកជំនុំ និងអង្គការសាសនាទាំងឡាយត្រូវបានព័ទ្ធជុំវិញដោយពពួកទេវតាអាក្រក់។ ហើយវាសំឡឹងមើលទៅអង្គការសាស-នាទាំងនោះ ដោយភាពអំណរ ដ្បិតរូបរាងរបស់ សាសនា ត្រូវបានគ្របដណ្តប់ដោយភាពឧក្រិដ្ឋ និងទុច្ចរិតយ៉ាងក្រៃលែង។

ទេវតាទាំងអស់ ទតមើលដោយការតូចចិត្តមកលើមនុស្សជាតិ ដែលជាស្នាព្រះហស្តរបស់ព្រះ ដែលត្រូវបានបញ្ចុះដល់ភាពថោកទាបយ៉ាងជ្រៅបំផុត ហើយបានដាក់នូវកេរ្តិ៍តទាប ដូចសត្វតិរច្ឆានដោយមនុស្សដូចគ្នា។ តែគេបានអះអាងថា ជាអ្នកដើរតាមព្រះអង្គសង្គ្រោះ ជាទីស្រឡាញ់ ដែលសេចក្តីមេត្តាករុណារបស់ទ្រង់ មិនបានយកចេញឡើយ នៅពេលដែលទ្រង់បានទតឃើញ សេចក្តីទុក្ខសោករបស់មនុស្សទាក់ទងខាងផ្លូវចិត្ត នៅក្នុងអំពើបាបដ៏ធំសំបើម និងឈឺចាប់ ហើយទាក់ទងជាមួយនឹងទាសភាព និងព្រលឹងរបស់មនុស្ស។ ទេវតាបានកត់ត្រារឿងនេះទាំងអស់។ វាត្រូវបានទេវតាកត់ត្រានៅក្នុងសៀវភៅមួយ។ ទឹកភ្នែកនៃអ្នកមានជំនឿ និងស្រឡាញ់យ៉ាងស៊ប់ បុរសដែលជាប់ចំណង ស្ត្រីដែលជាប់ចំណង ឪពុកម្តាយ កូន បងប្អូនប្រុសបងប្អូនស្រីទាំងឡាយ ត្រូវបានទុកជាប់នៅស្ថានសួគ៌។ ការឈឺចាប់របស់មនុស្ស ត្រូវបានគេយកទៅពីកន្លែងមួយទៅកន្លែងមួយ ហើយត្រូវបានគេលក់ និងទិញថែមទៀត



ផង។ ព្រះនឹងទប់កំហឹងរបស់ទ្រង់តែបន្តិចទៀតទេ។ សេចក្តីក្រោធរបស់ទ្រង់បានឆេះទាស់នឹងសាសន៍នេះ ហើយជាពិសេសទាស់នឹងអង្គការសាសនា ដែលបានអោយសេចក្តីយល់ព្រម និងបានភ្ជាប់ខ្លួនគេដោយផ្ទាល់ ជាមួយនឹងទំនិញដ៏រន្ធត់នេះ។ ភាពអយុត្តិធម៌បែបនេះ ការប្រឆាំងបែបនេះ ការឈឺចាប់បែបនេះ អ្នកដែលអះអាងថា ជាអ្នកដើរតាមព្រះយេស៊ូវជាច្រើន អ្នកស្លូតបូត និងទន់ទាបជាច្រើន អាចមើលឃើញយ៉ាងពិបាក។ ហើយពួកគេជាច្រើនអាចទទួលយក ដោយការពេញចិត្ត ដ៏គួរអោយស្អប់ខ្ពើមមនុស្សជាច្រើនឥតគណនាទាំងនេះឈឺចាប់ខ្លួនឯង ហើយនៅតែហ៊ានថ្វាយបង្គំព្រះដដែល។ វាគឺជាការចំអកយ៉ាងខ្លាំង ហើយសាតាំងសប្បាយចំពោះរឿងនេះ និងបន្ទោសដល់ព្រះយេស៊ូវ និងទេវតារបស់ទ្រង់ដដែលៗ ដោយជោគជ័យនៃស្ថាននរក ដោយនិយាយថា សិស្សរបស់ព្រះគ្រីស្ទគឺជាមនុស្សដូច្នេះឯង?

អ្នកដែលអះអាងថា ជាគ្រីស្ទានទាំងនោះ បានឃើញការរងទុក្ខវេទនារបស់ទុក្ករបុគ្គល ហើយទឹកភ្នែកក៏ហូរកាត់ថ្ពាល់ទាំងគូរបស់គេ។ គេឆ្ងល់អំពីមនុស្សមានចិត្តរឹង ប្រព្រឹត្តអំពើឃោរឃៅដ៏អមនុស្សធម៌ ទៅរកមនុស្សជាតិដូចគ្នា ហើយនៅពេលជាមួយគ្នានោះ គេបានយកមនុស្សដូចគ្នាជាទាសករ។ ហើយមិនត្រឹមតែប៉ុណ្ណោះទេ គេកាត់ផ្តាច់ចំណងធម្មជាតិ ហើយគៀបសង្កត់ដល់មនុស្សដូចគ្នា ពីមួយថ្ងៃ ទៅមួយថ្ងៃយ៉ាងឃោរឃៅ។ ពួកគេអាចធ្វើទារុណកម្ម ជាច្រើនដោយអំពីឃោរឃៅ ឥតបង្អង់ដែដូចជាអំពើឃោរឃៅ ដែលពួកនិយមប៉ាប និងអ្នកមិនជឿបានអនុវត្តទៅលើអ្នកគ្រីស្ទានដែរ។ ទេវតាបានមានបន្ទូលថា នៅថ្ងៃជំនុំជំរះរបស់ព្រះ ពួកប៉ាបនិយម និងអ្នកមិនជឿនឹងទ្រាំបានជាងពួកមនុស្សទាំងនេះ។ សំរែក និងការឈឺចាប់របស់អ្នកដែលគេជិះជាន់បានឮដល់ស្ថានសួគ៌ ហើយទេវតាឈរដោយងឿងឆ្ងល់ នៅជិតអ្នកមានចិត្តរឹងរូស ដោយឈឺចាប់យ៉ាងខ្លាំង មនុស្សនៅក្នុងរូបភាពនៃអ្នក ដែលបានបង្កើតគេមក បាន

ធ្វើអាក្រក់ទៅលើមនុស្សដូចគ្នា។ ទេវតាបានមានបន្ទូលថា ឈ្មោះពួកទាំងនេះត្រូវបានសរសេរដោយឈាម បានខ្វែងដោយគំនូស ជោរជន់ដោយទឹកភ្នែក នៃអ្នកដែលមានការឈឺចាប់យ៉ាងខ្លាំង ដោយសារគេដុតទាំងរស់។ សេចក្តីក្រោធរបស់ព្រះ នឹងមិនឈប់ឡើយ ទាល់តែទ្រង់បានធ្វើអោយដីនៃពន្លឺបានផឹកកករ ពីពែងនៃសេចក្តីក្រោធរបស់ទ្រង់ និងទាល់តែទ្រង់បានប្រទាន រង្វាន់ដល់ទីក្រុងបាប៊ីឡូនមួយជាពីរ។ ចូរអោយរង្វាន់ដល់គេ ដូចដែលគេបានអោយដល់អ្នកទ្វេដងទៅគេតាមការងារ ដែលគេបានធ្វើមកលើអ្នក នៅក្នុងពែងដែលគេបានបំពេញ។ ចូរបំពេញអោយគេវិញមួយជាពីរ។

ខ្ញុំបានឃើញថា មេរបស់ទាសករនឹងត្រូវតែឆ្លើយទៅនឹងមនុស្សទាសកររបស់ខ្លួន ដែលខ្លួនបានគ្រប់គ្រងក្នុងស្តង់ដា និងអំពើបាបទាំងអស់របស់ទាសករ នឹងត្រូវធ្លាក់មកលើចៅហ្វាយនោះ។ ព្រះមិនអាចយកទៅស្ថានសួគិ នូវទាសករដែលគេបានរក្សាទុកក្នុងភាពល្ងង់ខ្លៅ និងភាពថោកទាបមិនដឹងពីព្រះសោះ មិនដឹងពីព្រះគម្ពីរសោះ មិនខ្លាចអ្វីក្រៅពីរំពាត់ខ្សែតីរបស់ចៅហ្វាយខ្លួន និងមិនលើកដំកើងតួនាទីណា ដូចជាចៅហ្វាយជាសត្វតិរច្ឆានរបស់ខ្លួននោះឡើយ។ ប៉ុន្តែទ្រង់យកអ្នកធ្វើការល្អបំផុត ដែលព្រះដ៏មានការអាណិតអាសូរវិញ។ វាធ្វើដូចជាមិនមែនជាវា នៅពេលដែលចៅហ្វាយនោះ ទទួលឈឺចាប់ដោយការវេទនាចុងក្រោយទាំងប្រាំពីរ ហើយរស់ឡើងវិញ ជាលើកទីពីរ និងទទួលការស្លាប់ដ៏គួរអោយខ្លាចជាលើកទីពីរ។ ពេលនោះសេចក្តីក្រោធរបស់ព្រះនឹងត្រូវបានស្ងប់។

សូមអាន អេម៉ូស ៥:២១, រ៉ូម ១២:១៩, វិវរណៈ ១៤: ៩-១០, ១៨:៦។



ជំពូកទី៣៤

## សម្រែកយ៉ាងខ្លាំង

ខ្ញុំបានឃើញទេវតាប្រញាប់ប្រញាល់ទៅមកនៅស្ថានសួគិ។ លោកបានចុះទៅកាន់ផែនដី ហើយបានឡើងទៅកាន់ស្ថានសួគ៌វិញ រៀបចំសំរាប់ការសំរេចព្រឹត្តិការណ៍សំខាន់អ្វីមួយ។ រួចខ្ញុំបានឃើញទេវតាដ៏មានបារមីមួយ អង្គទៀតត្រូវបានបង្គាប់អោយចុះទៅផែនដី ហើយរួមសំឡេងជាមួយទេវតាទីបី ដើម្បីផ្តល់កម្លាំង និងអំណាចទៅលើដំណឹងរបស់លោក។ អំណាចនិង សិរីល្អដ៏ខ្លាំងអស្ចារ្យត្រូវបានប្រទានដល់ទេវតានោះ ហើយនៅពេលដែលលោកបានចុះទៅផែនដី លោកបានបំភ្លឺដោយសិរីល្អរបស់លោក។ ពន្លឺបាននៅខាងមុខ និងតាមក្រោយទេវតានោះ ចាំងចូលទៅគ្រប់ទិសទី នៅពេលដែលលោកបានស្រែកដោយសំលេងខ្លាំងៗថា ទីក្រុងបាប៊ីឡូនដ៏ជាធំ បានរលំហើយ បានរលំហើយ។ ហើយបានក្លាយជាទីលំនៅរបស់អារក្ស និងជារន្ធរបស់វិញ្ញាណអាក្រក់ និងជាទ្រុងរបស់បក្សីមិនស្អាត និងគួរអោយស្អប់ខ្ពើមគ្រប់មុខ។ ដំណឹងនៃការដួលរលំរបស់ទីក្រុងបាប៊ីឡូន ដូចដែលទេវតាទីពីរបានប្រកាស ត្រូវបានប្រកាសម្តងទៀត ជាមួយនឹងការបន្ថែមនៃការពុករលួយ ដែលបានចូលទៅក្នុងពួកជំនុំតាំងពីឆ្នាំ១៨៤៤។ ការងាររបស់ទេវតានេះមកចំពេលហើយ រួមនៅក្នុងការងារដ៏ធំចុងក្រោយរបស់ទេវតាទីបី នៅពេលដំណឹងនោះកំពុងឮខ្លាំងឡើង នៅក្នុងសំរែកយ៉ាងខ្លាំងមួយ។ ហើយរាស្ត្ររបស់ព្រះត្រូវបានរៀបចំនៅគ្រប់ទិសទី អោយឈរនៅក្នុងពេលវេលានៃសេចក្តីល្បួង ដែលនឹងជួបនៅពេលឆាប់ៗនេះ។ ខ្ញុំបានឃើញពន្លឺយ៉ាងខ្លាំងនៅលើពួកគេ ហើយពួកគេបានរួបរួមជាមួយនឹងដំណឹងនោះ ព្រមទាំងប្រកាសដោយគ្មានការភ័យខ្លាច ដោយអំណាចយ៉ាងខ្លាំង នូវសាររបស់ទេវតាទីបី។

ព្រះបានបញ្ជូនទេវតាពីស្ថានសួគ៌ អោយមកបន្ថែមលើទេវតាដ៏មានចេស្តា ហើយខ្ញុំបានឮសំឡេង ដែលហាក់ដូចជាបានឮគ្រប់ទិសទី រាស្ត្ររបស់ខ្ញុំអើយ ចូរដកខ្លួនចេញពីវា ដ្បិតអំពើបាបរបស់វាបានទៅដល់ស្ថានសួគ៌ហើយ ហើយព្រះបាននឹកចាំពីការទុច្ចរិតរបស់វា។ ដំណឹងនេះហាក់ដូចជាការបន្ថែម ទៅលើដំណឹងរបស់ទេវតាទីបី ហើយបានរួមគ្នាដូចជាសម្រែកនាពេលកណ្តាលអាធ្រាត្រ បានរួបរួមគ្នាជាមួយនឹងដំណឹងរបស់ទេវតាទីពីរ នៅឆ្នាំ១៨៤៤ដែរ។ សិរីល្អរបស់ព្រះបានសណ្ឋិតលើពួកបរិសុទ្ធដ៏អត់ធ្មត់ដែលរង់ចាំ ហើយគេផ្តល់ការប្រមាណចុងក្រោយដ៏រឹងមាំ ដោយប្រកាសអំពីការធ្លាក់ចុះរបស់ទីក្រុងបាប៊ីឡូន ហើយហៅរាស្ត្ររបស់ព្រះអោយចេញពីទីក្រុងនោះ ដើម្បីអោយគេរួចពីវាសនាដ៏គួរអោយខ្លាចរបស់វា។

ពន្លឺដែលបានចាំងមកលើអ្នករង់ចាំ បានភ្លឺសព្វទិសទី និងអ្នកដែលមានពន្លឺ នៅក្នុងពួកជំនុំ ដែលមិនបានឮ និងមិនបានបដិសេធដំណឹងទីបី ហើយបានឆ្លើយតបនឹងការត្រាស់ហៅ និងបានចេញពីពួកជំនុំដែលដួលរលំ។ មនុស្សជាច្រើនមានការទទួលខុសត្រូវយ៉ាងយូរ តាំងពីដំណឹងនេះត្រូវបានផ្តល់អោយ និងពន្លឺបានចាំងលើពួកគេមក ហើយគេមានឱកាសនឹងជ្រើសរើសយកជីវិត ឬសេចក្តីស្លាប់។ អ្នកខ្លះបានជ្រើសរើសយកជីវិត ហើយបានឈរនៅជាមួយព្រះអម្ចាស់របស់គេ និងរក្សាគ្រប់ទាំងបញ្ញត្តិរបស់ទ្រង់។ ដំណឹងទីបីបានធ្វើការងាររបស់ខ្លួន មនុស្សទាំងអស់ត្រូវបានសាកល្បង ដោយដំណឹងនោះ ហើយអ្នកសុចរិតត្រូវបានហៅចេញពី អង្គការសាសនានោះ។ អំណាចដ៏ច្រើនលើសលុបបានធ្វើការនៅក្នុងអ្នកស្មោះត្រង់ នៅពេលដែលការបង្ហាញអំណាចរបស់ព្រះគ្រប់គ្រងដោយកោតខ្លាច ហើយទប់បងប្អូន និងមិត្តភ័ក្តិគេកុំឱ្យប្រើអំណាចរបស់គេ ដើម្បីរារាំងអ្នកដែលដឹង ពីការងាររបស់ព្រះវិញ្ញាណនៃព្រះមកលើពួកគេ។ ការត្រាស់ហៅចុងក្រោយ ត្រូវបានប្រកាសរហូតដល់ទាសករដ៏ក្រីក្រ និងអ្នកដែលមានជំនឿ ក្នុងចំណោម



ពួកគេ ដោយការបន្ទាបខ្លួន បញ្ចេញចម្រៀងនៃអំណរដ៏លើសលប់របស់គេ នៅគ្រាដែលមានឡើងវិញនូវសេចក្តីសប្បាយ និងការរំដោះរបស់ពួកគេ ហើយចៅហ្វាយរបស់គេមិនអាចត្រួតពិនិត្យលើគេ ដោយការភ័យខ្លាចទៀតទេ ហើយការរន្ធត់របស់គេត្រូវនៅស្ងៀម។ ការអស្ចារ្យដ៏ធំបានកើតឡើង អ្នកឈឺត្រូវបានព្យាបាល ហើយសញ្ញា និងការអស្ចារ្យបានដើរតាមពួកអ្នកជឿ។ ព្រះធ្វើការ ហើយពួកបរិសុទ្ធមិនខ្លាចលទ្ធផលអាក្រក់នោះឡើយ គេធ្វើតាមការកែប្រែនៃសម្បជញ្ញៈផ្ទាល់របស់គេ ហើយបានរួបរួមជាមួយនឹងអ្នក ដែលបានគោរពបញ្ញត្តិទាំងអស់របស់ព្រះ ហើយគេបានប្រកាសសាររបស់ទេវតាទីបី ដោយអំណាច។ ខ្ញុំបានឃើញថា សារទីបីបានបញ្ចប់ដោយអំណាច និងកម្លាំងខ្លាំងលើសលុបជាង សម្រែកនាពាក់កណ្តាលអាធ្រាត្រទៅទៀត។

អ្នកបំរើរបស់ព្រះមានពេញដោយអំណាចមកពីលើ ដែលមានមុខចាំងពន្លឺ និងការថែងចាំងនៃការលះបង់ដ៏បរិសុទ្ធ បានចេញទៅមុខបំពេញការងាររបស់ខ្លួន ហើយប្រកាសដំណឹងពីស្ថានសួគ៌។ ព្រលឹងដែលបានបែកខ្ញែកទៅក្នុងអង្គការសាសនាទាំង-ឡាយ បានឆ្លើយតបទៅនឹងការត្រាស់ហៅ ហើយអ្នកល្អបានប្រញាប់ប្រញាល់ ចេញពីទីក្រុងសុដុំម មុននឹងត្រូវបានទទួលការបំផ្លាញដូច្នោះដែរ។ រាស្ត្ររបស់ព្រះត្រូវបានរៀបចំ និងចំរើនកម្លាំង ដោយសិរីរុងរឿងដ៏ឧត្តម ដែលធ្លាក់មកលើគេជាច្រើនឥតគណនា ដើម្បីរៀបចំពួកគេអោយទប់ទល់នឹងការល្បួង។ ខ្ញុំបានឮសំឡេងជាច្រើនបានស្រែកឡើងនៅគ្រប់ទិសទី នេះគឺជាការអត់ធ្មត់របស់ពួកបរិសុទ្ធ នេះគឺជាពួកអ្នកដែលគោរពបញ្ញត្តិរបស់ព្រះ និងសេចក្តីជំនឿលើព្រះយេស៊ូវ។

សូមអានលោកុប្បត្តិ ជំពូក ១៩, វិវរណៈ ១៤:១២, ១៨:២-៥។

ជំពូកទី៣៥

## **សារទីបីបានបិទ**

ខ្ញុំត្រូវបានគេបង្ហាញអោយឃើញ នៅពេលដែលសារទីបីកំពុងបានបិទ។ អំណាចរបស់ព្រះជាម្ចាស់ បានប្រទានអោយរាស្ត្ររបស់ទ្រង់។ ពួកគេបានបំពេញកិច្ចការរបស់ពួកគេរួចជាស្រេច ហើយគេក៏ត្រូវបានរៀបចំសំរាប់វេលាសាកល្បង នៅមុខពួកគេដែរ។ ពួកគេបានទទួលភ្លៀងចុងក្រោយ ឬការធ្វើអោយស្រស់បំព្រង អំពីវត្តមានរបស់ព្រះជាម្ចាស់ ហើយទីបន្ទាល់ដ៏រស់ ក៏បានស្រស់ជាថ្មីឡើងដែរ។ ការព្រមានចុងក្រោយត្រូវបានបំភ្លឺឡើងនៅគ្រប់ទីកន្លែង ហើយវាបានធ្វើអោយអស់ទាំងជីវិត អ្នកដែលពុំព្រមទទួលសាររបស់ព្រះ បានកក្រើកឡើង។

ខ្ញុំបានឃើញពួកទេវតាធ្វើដំណើរទៅមក យ៉ាងរួសរាន់ទៅស្ថានសួគ៌ ហើយមានទេវតា មួយអង្គបានត្រឡប់មកពីផែនដី ដោយមានស្នាមទឹកខ្មៅរបស់អ្នកនិពន្ធជាប់នៅនឹងខ្លួន ហើយទេវតានោះបានទូលដល់ព្រះយេស៊ូវថា ភារកិច្ចរបស់លោកបានសំរេចហើយ គឺអស់អ្នកបរិសុទ្ធ ត្រូវបានរាប់រួចហើយ និងបានប្រថាប់ត្រារួចជាស្រេច។ នៅពេលនោះ ខ្ញុំបានឃើញព្រះយេស៊ូវ ដែលនៅចំពោះហឹបនៃបញ្ញត្តិទាំងដប់ប្រការបានទតមើលមកមនុស្សជាតិ រួចលើកព្រះហស្តរបស់ទ្រង់ ព្រមទាំងមានបន្ទូលជាខ្លាំងថា "ការស្រេចហើយ"។ ពួកទេវតានៅស្ថានសួគ៌ ក៏បានដោះមកុដរបស់លោកចេញ នៅពេលដែលព្រះយេស៊ូវមានបន្ទូលថា "អ្នកណាដែល មិនយុត្តិធមិ ចូរអោយអ្នកនោះ នៅតែអយុត្តិធមិចុះ អស់អ្នកណាដែលមិនស្អាតឱ្យនៅតែ មិនស្អាតចុះ អស់អ្នកណាដែលសុចរិត ឱ្យនៅតែសុចរិត ហើយអស់អ្នកដែលបរិសុទ្ធឱ្យនៅតែ បរិសុទ្ធចុះ"។

ខ្ញុំបានឃើញថា គ្រប់ទាំងករណីត្រូវបានគេធ្វើការសំរេចសេចក្តី ដើម្បីនឹង



ទទួលជីវិត ឬសេចក្តីស្លាប់។ ព្រះយេស៊ូវទ្រង់បានលុបចោល នូវអំពើបាបរបស់រាស្ត្រទ្រង់។ ទ្រង់បានទទួលនគររបស់ទ្រង់ ហើយការលោះឱ្យធួននឹងបាប ត្រូវបានធ្វើឡើងសំរាប់នគរនោះ។ នៅពេលដែលព្រះយេស៊ូវ កំពុងតែធ្វើការនៅទីបរិសុទ្ធនោះ ការជំនុំជំរះ បានកំពុងតែដំណើរការសំរាប់អ្នកសុចរិត ដែលបានស្លាប់រួចមក ក៏ធ្វើសំរាប់អ្នកសុចរិត ដែលមានជីវិតរស់នៅដែរ។ ប្រធានបទនៃនគរនេះ គឺត្រូវបានបង្កើតឡើង។ អាពាហ៍ពិពាហ៍របស់កូនចៀម ត្រូវបានចប់រួចរាល់ហើយ សិរីល្អរបស់នគរដែលនៅក្រោមស្ថានសួគ៌នោះ ត្រូវបានប្រទានដល់ព្រះយេស៊ូវ និងអស់អ្នកដែលជាទាសករនៃសេចក្តីសង្គ្រោះ។ ហើយព្រះយេស៊ូវនឹងគ្រងរាជ្យ ជាព្រះលើអស់ទាំងព្រះ។

នៅពេលដែលព្រះយេស៊ូវ យាងចេញពីទីបរិសុទ្ធបំផុតនោះ ខ្ញុំបានឮសំឡេងចង្រ្កង់ ដែលនៅជាប់នឹងស្បៃរបស់ទ្រង់ ហើយនៅខណៈដែលទ្រង់យាងចេញនោះ មានពពកខ្មៅងងឹត បានមកគ្របដណ្តប់អ្នក ដែលរស់នៅលើផែនដីទាំងមូល។ នៅពេលនោះគ្មានអ្នកណាមានទោសនឹងព្រះទៀតទេ។ នៅពេលដែលព្រះយេស៊ូវបានឈររវាង ព្រះជាម្ចាស់ និងអ្នកមានទោស ទ្រង់បានធ្វើការសំរបសំរួលអោយអ្នកមានទោស ប៉ុន្តែនៅពេលដែលព្រះយេស៊ូវ បានចាកចេញពីចន្លោះព្រះនឹងមនុស្ស នោះពុំមានការសំរបសំរួលនោះទៀតទេ ហើយនៅពេលនោះដែរ សាតាំងបានគ្រប់គ្រងអ្នកមានបាបវិញ។ នៅពេលដែលព្រះយេស៊ូវកំពុងធ្វើការនៅទីបរិសុទ្ធនោះ គ្រោះទុរ្ភិក្សមិនអាចធ្លាក់មកបានទេ ប៉ុន្តែក្រោយពីកិច្ចការរបស់ទ្រង់បានសំរេចនៅទីនោះ នោះគ្មានអ្វីអាចទប់ទល់មិនអោយសេចក្តីក្រោធរបស់ព្រះបានធ្លាក់មកឡើយ ហើយសេចក្តីក្រោធនោះ នឹងធ្លាក់មកលើអស់អ្នក ដែលពោរពេញទៅដោយអំពើបាប ដែលបានបដិសេធសេចក្តីសង្គ្រោះ និងដែលបានស្អប់សេចក្តីពិតជាក់ស្តែង។ ចំពោះអស់អ្នកបរិសុទ្ធដែលបានកោតខ្លាចដល់ព្រះ នៅពេលនោះបានរស់នៅ ពីមុខភាពបរិសុទ្ធរបស់ព្រះ ដោយគ្មានការរារាំងទៀត

ទេ។ ព្រះយេស៊ូវទ្រង់បានយាងទៅឯទីលានខាងក្រៅរបស់ទីបរិសុទ្ធ នៅស្ថានសួគ៌ ហើយទ្រង់បានយកអស់ទាំងអំពើបាប ដែលមនុស្សបានលន់តួ នៅពេលដែលទ្រង់គង់នៅឯទីបរិសុទ្ធបំផុតនោះ អោយទៅម្ចាស់ដើមកំណើតរបស់អំពើបាបវិញ គឺជាសាតាំង ហើយវាត្រូវតែទទួលរងទុក្ខ ចំពោះអំពើបាបទាំងនោះ។

នៅពេលនោះ ខ្ញុំបានឃើញព្រះយេស៊ូវ ទ្រង់បានដោះសំលៀកបំពាក់របស់សម្តេចសង្ឃចេញ ហើយទ្រង់បានបំពាក់អង្គទ្រង់ ដោយអាវផាយដ៏ល្អបំផុត ហើយនៅលើព្រះសិររបស់ទ្រង់ មានមកុដជាច្រើន ដែលព័ទ្ធជុំវិញដោយពពួកទេវតានៃស្ថានសួគ៌ ហើយទ្រង់ក៏បានយាងចេញពីស្ថានសួគ៌មក។ គ្រោះកាចនោះក៏បានធ្លាក់មកលើអ្នកដែលនៅឯផែនដី ហើយមានអ្នកខ្លះបានប្រកែកមិនទទួលស្គាល់ព្រះ ព្រមទាំងដាក់បណ្តាសាដល់ព្រះ ហើយមានអ្នកខ្លះទៀត បានរត់ទៅឯរាស្ត្ររបស់ព្រះ សូមអោយគេជួយ ដើម្បីអោយរួចពីការជំនុំជំរះរបស់ព្រះ។ ប៉ុន្តែអ្នកបរិសុទ្ធគ្មានអ្វីសំរាប់ពួកអ្នកទាំងនោះទេ ហើយនៅពេលនោះហើយ ដែលអ្នកមានបាប បានសំរក់ទឹកភ្នែកចុងក្រោយរបស់គេ គេបានអធិស្ឋានដោយការឈឺចាប់ ជាចុងក្រោយ ហើយបន្ទុកចុងក្រោយក៏បានប្រទានដល់ពួកគេដែរ។ នៅពេលដែលអ្នកបរិសុទ្ធបានមានចំណាប់ អារម្មណ៍អំពីសេចក្តីសង្គ្រោះរបស់ពួកគេនោះ ហើយនៅពេលនោះ សេចក្តីស្លាប់ និងជីវិតបានសំរេចរួចទៅហើយនៅចំពោះពួកគេ។ មានមនុស្សជាច្រើនដែលចង់បានជីវិត ប៉ុន្តែពួកគេមិនបានប្រឹងប្រែង ដើម្បីអោយបានជីវិតនោះទេ ពួកគេពុំបានជ្រើសរើសយកជីវិតទេ ហើយនៅពេលនេះ ក៏ពុំមានលោហិតលោះបាបរបស់ពួកគេទៀតដែរ ហើយក៏គ្មានព្រះអង្គសង្គ្រោះក្នុងការទូលអង្វរ ឬសោកសង្រេង សំរាប់អ្នកមានបាបទៀតនោះដែរ។ នៅនគរស្ថានសួគ៌ បាបរួបរួមជាមួយនឹងព្រះយេស៊ូវ នៅខណៈដែលពួកគេ បានឮពាក្យដ៏គួរឱ្យភយ័ខ្លាចថា "ការបានស្រេចហើយ"។ គំរោងការសំរាប់សេចក្តីសង្គ្រោះ បានចប់រួច-



រាល់ហើយ ប៉ុន្តែមានមនុស្សតិចណាស់ ដែលបានជ្រើសរើសយកគំរោងការនេះ ហើយនៅពេលដែលពាក្យ ដ៏ស្រទន់បានរលាយបាត់ទៅនោះ ការភ័យខ្លាច និងកិត្តិស័ព្ទបានមកជំនួសវិញ ហើយពួកគេបានឮសំឡេងមកថា "យឺតពេលហើយ! យឺតពេលហើយ!"

អស់អ្នកដែលពុំបានអោយតម្លៃ ទៅលើព្រះបន្ទូលរបស់ព្រះ បានរត់ទៅវិញទៅមក ពីសមុទ្រមួយទៅសមុទ្រមួយ ពីទិសខាងជើងទៅត្បូង ដើម្បីស្វែងរកព្រះបន្ទូលរបស់ព្រះ។ ប៉ុន្តែទេវតាបានមានបន្ទូលថា "ពួកគេនឹងរក មិនឃើញឡើយ"។ នឹងមានគ្រោះទុរ្ភិក្សនៅលើផែនដី តែវាមិនមែនជាទុរ្ភិក្ស ដោយគ្មានម្ហូបអាហារ ឬគ្មានទឹកនោះទេ តែវាគឺជាទុរ្ភិក្ស ដែលគ្មានព្រះបន្ទូលរបស់ព្រះវិញ។ ពួកគេនឹងព្រមលះបង់គ្រប់យ៉ាង ដែលគេនឹងមានការស្រេកឃ្លានជារៀងរហូត។ ពីមួយថ្ងៃទៅមួយថ្ងៃ ពួកគេបានរីករាយនឹងទ្រព្យរបស់លោកីយ៍ នឹងក្តីសប្បាយរបស់វា ហើយពួកគេបានបដិសេធព្រះយេស៊ូវ និងរាស្ត្ររបស់ទ្រង់ ដូច្នេះអ្នកដែលមិនស្អាត នឹងនៅតែមិនស្អាតរហូតទៅ។

អ្នកមានបាបជាច្រើនបានភ័យខ្លាចយ៉ាងខ្លាំង នៅពេលដែលពួកគេទទួលរងទុក្ខ ពីគ្រោះកាចទាំងនេះ។ ឪពុកម្តាយ និងមានការទាស់ទែងជាមួយកូន ហើយកូនជាមួយនឹងឪពុក ម្តាយ ហើយបងទាស់នឹងប្អូន។ នៅពេលនោះឯង សំឡេងទ្រហោយំនឹងឮរំពងគ្រប់ទិសទីថា "គឺឯងហើយ ដែលធ្វើអោយយើង មិនបានទទួលសេចក្តីពិត ដែលអោយយើងមិនបានសង្គ្រោះ នៅក្នុងពេលនេះ"។ ពួកគេបានបែរទៅឯគ្រូគង្វាលរបស់ពួកគេ ទាំងពោរពេញទៅដោយសេចក្តីស្អប់ខ្ពើម ព្រមទាំងស្តីបន្ទោសពួកគេថា "ពួកឯងមិនបានប្រាប់យើង និងមិនបានហាមយើងពីការនេះឡើយ ពួកឯងបានប្រាប់យើងថាពិភពលោកនេះ នឹងត្រូវកែប្រែជាថ្មី ដើម្បីអោយសេចក្តីភ័យខ្លាចបានស្ងប់ស្ងាត់ ប៉ុន្តែពួកឯងមិនបានប្រាប់យើងពីពេលវេទនានេះសោះ ផ្ទុយទៅវិញឯងបានប្រាប់យើងថាអ្នកដែលប្រាប់ និងហាមយើងពីការនោះគឺជាមនុស្សអាក្រក់ និងកំភូតទៅវិញ ហើយ

ថា ពួកគេនឹងបំផ្លាញយើង។ ប៉ុន្តែគ្រូគង្វាលយើង នៅពេលនេះ យើងបានឃើញហើយ ថា អ្នកឯងក៏មិនរួចពីទុក្ខវេទនានេះដែរ ហើយអ្នកឯងនឹងទទួលដប់ដង ច្រើនជាងពួក យើង។

សូមអាន អេសេគាល ៩:២-១១, ដានីយ៉ែល ៧:២៧, ហូសេ ៦:៣,
អេម៉ុស ៨:១១-១៣ និង វិវរណៈ ១៦,១៧:១៤។

## ជំពូកទី៣៦

## ពេលវេលានៃការរងទុក្ខរបស់យ៉ាកុប

ខ្ញុំបានមើលឃើញពួកបរិសុទ្ធ ចាកចេញពីទីក្រុង និងពីភូមិរបស់ពួកគេ ហើយ ពួកគេបានមករួមគ្នារស់នៅឯទីដាច់ស្រយាលពីគេ។ ទេវតាបានប្រទានម្ហូបអាហារ និងទឹកដល់ពួកគេ ប៉ុន្តែអ្នកមានបាបបានចងទុក្ខដោយការស្រេកឃ្លានវិញ ហើយ នៅពេលនោះ ខ្ញុំបានមើលឃើញអ្នកដឹកនាំរបស់ផែនដីនេះ បានប្រជុំគ្នា ហើយសាតាំង និងទេវតារបស់វាបានក្រវែលជុំវិញពួកគេទាំងនោះ។ ខ្ញុំក៏បានឃើញសេចក្តីប្រកាស នៅគ្រប់ទីកន្លែងថា "ប្រសិនបើពួកបរិសុទ្ធមិនព្រមលះបង់ចោលសេចក្តីជំនឿរបស់គេ ហើយបោះបង់ចោលនូវថ្ងៃបរិសុទ្ធ ទៅគោរពថ្ងៃទីមួយនៃសប្តាហ៍ទេនោះ ពួកគេនឹង ត្រូវស្លាប់"។ ប៉ុន្តែនៅពេលនេះអស់អ្នកបរិសុទ្ធ បាននាំគ្នានៅស្ងៀម ហើយទុកចិត្ត ទៅលើព្រះ និងបានពឹងផ្អែកទៅលើសេចក្តីសន្យារបស់ព្រះ ដែលថាទ្រង់នឹងនាំពួកគេ អោយរួចផុតពីការបៀតបៀនទាំងនេះ។ នៅកន្លែងខ្លះ មុនពេលកាត់ទោសប្រហារ-ជីវិត ពួកអ្នកមានបាបបានតាមរកអ្នកបរិសុទ្ធ ដើម្បីនឹងសម្លាប់គេ ប៉ុន្តែទេវតារបស់ព្រះ ដែលមានលក្ខណៈជាមនុស្ស បានការពារពួកបរិសុទ្ធ មិនអោយគេធ្វើបាបឡើយ។



សាតាំងប្រាថ្នានឹងបំផ្លាញរាស្ត្ររបស់ព្រះ ប៉ុន្តែព្រះយេស៊ូវបានអោយទេវតារបស់ទ្រង់ ថែរក្សាពួកគេ ពីព្រោះទ្រង់នឹងបានសរសើរដំកើង ដោយការតាំងសេចក្តីសញ្ញា ជាមួយ នឹងអស់អ្នកដែលរក្សាច្បាប់របស់ទ្រង់ នៅពេលដែលមានសេចក្តីទុក្ខនៅជុំវិញពួកគេ ហើយទ្រង់ក៏បានទទួលកិត្តិស័ព្ទ នៅពេលដែលរាស្ត្ររបស់ទ្រង់បានរង់ចាំទ្រង់ ដោយមិន គិតពីសេចក្តីស្លាប់នៅជុំវិញពួកគេ។

ក្រោយមក ខ្ញុំបានឃើញពួកបរិសុទ្ធបានទទួលរងទុក្ខខាងផ្លូវចិត្ត ពីព្រោះ ពួកគេរស់នៅដោយមានពួកអ្នកមានបាបព័ទ្ធជុំវិញទាំងអស់ ហើយពួកគេបានប្រឈម មុខនឹងការប្រឆាំងគ្រប់បែបយ៉ាង។ មានអ្នកខ្លះបានចាប់ផ្តើមភ័យខ្លាចថាព្រះបាន បោះបង់ពួកគេចោល ហើយបណ្តោយអោយពួកគេវិនាស ក្នុងកណ្តាប់ដៃរបស់អ្នក មានបាប ប៉ុន្តែប្រសិនបើគេបានបើកភ្នែករបស់គេនោះ ពួកគេនឹងឃើញថា ពួកគេមាន សុទ្ធតែទេវតានៅជុំវិញគេ ហើយបន្ទាប់ពីទេវតារបស់ព្រះគឺជាហ្វូងអ្នកមានបាប ហើយ ស្រទាប់ក្រោបង្អស់ គឺជាទេវតារបស់សាតាំង ពួកវាទាំងនោះចង់បៀតបៀនដល់ ពួកបរិសុទ្ធ ពួកគេត្រូវឆ្លងកាត់ទេវតារបស់ព្រះជាមុនសិន។ ទេវតារបស់ព្រះបាន ធ្វើអោយទេវតារបស់សាតាំងមានការពិបាក ហើយទីបំផុតពួកគេក៏ត្រូវដកថយទៅ វិញ។ វាគឺជាពេលនៃសេចក្តីរងទុក្ខវេទនា និងពោរពេញទៅដោយភាពភ័យខ្លាច សំរាប់រាស្ត្របរិសុទ្ធរបស់ព្រះ ពួកគេបានយំស្រែកពីមួយថ្ងៃទៅមួយថ្ងៃ ដល់ព្រះអោយ ជួយរំដោះពួកគេ។ បើមើលពីខាងក្រៅយើងឃើញថាពួកគេ គ្មានផ្លូវចេញមកបានទេ ពួកអ្នកមានបាបបានដាក់ទណ្ឌកម្មដល់ពួកគេ ហើយបានចំអកឡកឡើយថា "ហេតុអ្វី បានជាព្រះរបស់ឯងមិនជួយឯងទៅ? ហេតុអ្វីបានជាឯងមិនទៅខាងលើ ដើម្បីសង្គ្រោះ ជីវិតរបស់ឯងទៅ?" ប៉ុន្តែ ពួកបរិសុទ្ធពុំបានឆ្លើយតបទេ។ ពួកគេបានមានបញ្ហាជាមួយ ព្រះ ដូចជាលោកយ៉ាកុបដូច្នេះដែរ។ ទេវតាចង់រំដោះពួកគេអោយរួចដែរ ប៉ុន្តែពួកគេ

ត្រូវរង់ចាំបន្តិចទៀត ហើយពួកគេក៏ត្រូវតែផឹកពីពែងនោះ ព្រមទាំងទទួលបុណ្យជ្រមុជទឹកលាងបាបសិន។ ពួកទេវតាដែលមានជំនឿនឹងការទុកចិត្ត ទៅលើព្រះបានរង់ចាំពេលវេលា ហើយថែរក្សាពួកបរិសុទ្ធ។ ពេលវេលាដែលព្រះនឹងរំដោះពួកបរិសុទ្ធដោយអំណាចរបស់ទ្រង់ នោះបានជិតមកដល់ហើយ។ ព្រះជាម្ចាស់នឹងមិនរងទុក្ខក្នុងព្រះនាមរបស់ទ្រង់ ដើម្បីជួយរំដោះអស់អ្នកអាក្រក់នោះឡើយ។ អ្នកដែលបានរង់ចាំទ្រង់ដោយអត់ធ្មត់ និងមានឈ្មោះនៅក្នុងបញ្ជី។

ខ្ញុំត្រូវបានសំដែងអោយឃើញអំពីលោកណូអេ ដែលពេញទៅដោយសេចក្តី-ជំនឿ។ ភ្លៀងបានធ្លាក់មក ហើយទឹកក៏បានជន់ឡើង ហើយគ្រួសាររបស់ណូអេ ក៏បានចូលទៅ ក្នុងទូក ដោយព្រះជាអ្នកបិទទ្វារទូក។ ណូអេបានប្រកាសប្រាប់ មនុស្សម្នាទាំងឡាយដោយជំនឿ អំពីលោកីយ៍នេះ ប៉ុន្តែពួកគេបានប្រឆាំងនឹងណូអេទៅវិញ។នៅពេលដែលទឹកបានជន់ឡើង ទូទាំងពិភពលោក ហើយបន្ទាប់ ពីមនុស្សមួយចំនួនបានលង់ទឹកស្លាប់ នោះ ពួកគេបានមើលទៅឯទូក ដែលពួកគេមិនជឿ ដែលមានតែគ្រួសារណូអេនៅក្នុង នោះ។ ខ្ញុំបានឃើញថារាស្ត្ររបស់ព្រះ ដែលបានប្រកាសប្រាប់ពិភពលោកអំពីគ្រោះកាច ដែលកំពុងមកដល់ ត្រូវបានសង្គ្រោះ។ ពួកគេបានប្រាប់ដល់មនុស្សលើលោកនេះដោយសេចក្តីជំនឿ ហើយព្រះទ្រង់ក៏មិនព្រមរងទុក្ខជាមួយនឹងអ្នកមានបាបដែលធ្វើទុក្ខ បៀតបៀនដល់អ្នកដែលមិនព្រមគោរពសត្វនោះ ឬទទួលត្រារបស់វានោះដែរ។ ខ្ញុំបាន ឃើញថា ប្រសិនបើអ្នកមានបាប បានទទួលការអនុញ្ញាត ដើម្បីនឹងធ្វើបាបអ្នកបរិសុទ្ធ នោះសាតាំងនិងទេវតារបស់វាទាំងអស់ ដែលស្អប់ព្រះ នឹងមានសេចក្តីរីក-រាយយ៉ាងក្រៃលែង។ ប៉ុន្តែពួកសាតាំងគ្មានឱកាស នឹងបៀតបៀនរាស្ត្ររបស់ព្រះទៀតទេ នៅវេលាចុងក្រោយនេះ។ អស់អ្នកដែលប្រឆាំង នឹងព្រះរាជសារដែលថាពួកបរិសុទ្ធនឹងត្រូវបានទទួលយកទៅខាងស្ថានសួគ៌ និងធ្វើជាសាក្សីថា ព្រះបានការពាររាស្ត្ររបស់



ទ្រង់ និងបានរំដោះរាស្ត្ររបស់ទ្រង់។

នៅពេលដែលពួកបរិសុទ្ធបានចាកចេញពីទីក្រុង ហើយនិងភូមិរបស់គេ ពួកគេបានទទួលការបៀតបៀនពីសំណាក់អ្នកមានបាប។ ពួកអ្នកមានបាប បានលើកដាវសម្លាប់ពួកបរិសុទ្ធ ប៉ុន្តែដាវរបស់ពួកគេនឹងបាក់ជាកំណាត់ៗ ហាក់បីដូចជាចំបើង។ ទេវតារបស់ព្រះបានការពារពួកបរិសុទ្ធ នៅពេលដែលពួកគេបានយំសោក ទាំងថ្ងៃទាំងយប់ សុំអោយព្រះជួយរំដោះពួកគេ។

សូមអាន លោកុប្បត្តិ ជំពូក ៦ និង៧, ៣២:២៤-២៨,

ទំនុកដំកើង ៩១,ម៉ាថាយ ២០:២៣ និង វិវរណៈ ១៣:១១-១៧។

## ជំពូកទី៣៧

## **ការរំដោះពួកបរិសុទ្ធ**

វាគឺជាពេលពាក់កណ្តាលអាធ្រាត្រមួយ ដែលព្រះជ្រើសយកក្នុងការរំដោះរាស្ត្ររបស់ទ្រង់ ក្នុងខណៈដែលអ្នកមានបាបបានព័ទ្ធជុំវិញពួកបរិសុទ្ធ ស្រាប់តែព្រះអាទិត្យក៏បានលេចឡើង បញ្ចេញរស្មីយ៉ាងពេញទំហឹង ហើយព្រះច័ន្ទក៏នៅស្ងៀម។ ពួកអ្នកមានបាបក៏បានមើលទៅដោយមានការអស្ចារ្យ ហើយនៅពេលនោះគេនឹងបានឃើញសញ្ញា ហើយភាពអស្ចារ្យ តាមមកជាប់ៗគ្នា។ គ្រប់យ៉ាងមានលក្ខណៈខុសពីធម្មជាតិ ហើយពួកបរិសុទ្ធក៏បានសំឡឹងរង្វាន់របស់គេដោយសេចក្តីអំណរ។

ទឹកបានឈប់ហូរ ពពកដ៏ក្រាស់ហើយងងឹតបានលេចឡើង ហើយទង្គិចគ្នាប៉ុន្តែ មានប្រឡោះមួយយ៉ាងច្បាស់ដែលពោរពេញទៅដោយសិរីល្អ និងមានសំឡេងមួយបានចេញមកពីទីនោះ ដែលជាព្រះបន្ទូលរបស់ព្រះហាក់បីដូចជាទឹកដែលធ្វើអោយ

ស្ថានសួគ៌ និងផែនដីកក្រើកឡើង។ នឹងមានការរញ្ជួយផែនដីយ៉ាងខ្លាំង ផ្នូរខ្មោចទាំងឡាយបានកក្រើកឡើង ហើយអស់អ្នកណាដែលស្លាប់ ដោយសេចក្តីជំនឿលើសារទីបី ហើយដែលបានរក្សាថ្ងៃឈប់សំរាក នឹងងើបឡើងពីផ្នូររបស់គេ មកទទួលសេចក្តីសញ្ញា ដែលព្រះនឹងប្រទានអោយដល់ពួកគេ។

មេឃបានបើកឡើង ហើយបានបិទទៅវិញ ទាំងពោរពេញទៅដោយការភ័ន្តភាំង។ ភ្នំបានកក្រើកឡើង ហាក់បីដូចជាខ្យល់បក់ ហើយធ្វើអោយផ្ទាំងថ្មខ្ចាយទៅឆ្ងាយ។ ទឹកសមុទ្របានពុះកញ្ជ្រោលឡើង ហើយបានបំបែកផ្ទាំងសិលាធំៗនៅលើដី។ នៅពេលដែលព្រះបានមានបន្ទូលពីការយាងមករបស់ព្រះយេស៊ូវ ហើយនិងការតាំងសេចក្តីសញ្ញាដ៏អស់កល្ប ជាមួយនឹងរាស្ត្ររបស់ទ្រង់ ទ្រង់បានមានបន្ទូលមួយឃ្លាម្តងៗនៅពេលនោះឯងព្រះបន្ទូលរបស់ ទ្រង់បានឮខ្ទរនៅពាសពេញផែនដី។ សាសន៍អ៊ីស្រាអែលរបស់ទ្រង់បានឈរមើលទៅឯទ្រង់ ព្រមទាំងស្តាប់នូវព្រះបន្ទូលដែលចេញពីព្រះឱស្ឋរបស់ព្រះយេហូវ៉ា ដែលឮរំពងដូចជាផ្គរលាន់។ នៅចុងឃ្លានីមួយៗដែលព្រះបានមានបន្ទូល ពួកបរិសុទ្ធបានស្រែកឡើងថា "សិរីល្អ ហាលេលូយ៉ា" ហើយមុខរបស់គេបានភ្លឺឡើង ដោយសិរីរុងរឿងរបស់ព្រះ ហើយពួកគេក៏បានចែងចាំងរស្មីដូចជាម៉ូសេ នៅពេលដែលចុះពីភ្នំស៊ីណាយដែរ។ ពួកមានបាបមិនអាចសំឡឹងមើលមុខពួកបរិសុទ្ធបានទេ ដោយសារតែសិរីល្អទាំងនោះ ហើយនៅពេលដែលព្រះពរដ៏អស់កល្ប បានប្រទានអោយដល់ពួកបរិសុទ្ធ ដែលគោរពព្រះ ដោយការរក្សាថ្ងៃឈប់សំរាកនោះមានសំឡេងដ៏អស្ចារ្យ ស្រែកឡើងដោយជ័យជំនះ លើសត្វកំណាចនិងរូបរបស់វា។

នៅពេលនោះស្រាប់តែមានអំណរកើតមានឡើង ពេលដែលផែនដីគួរតែសំរាក។ ខ្ញុំបានឃើញអ្នករងទុក្ខដោយព្រោះសេចក្តីជំនឿ បានងើបឡើង ដោយជ័យ



ជំនះហើយបានបណ្តាច់ច្រវ៉ាក់ដែលចងពួកគេ។ នៅខណៈនោះ មេដឹកនាំអំពើបាបបានពោរពេញទៅដោយការភ័ន្តភាំង ហើយពុំដឹងថា នឹងធ្វើដូចម្តេចទេ ពីព្រោះអ្នកមានបាបពុំអាចយល់ព្រះបន្ទូលរបស់ព្រះបានទេ ហើយនៅខណៈនោះ ស្រាប់តែមានពពកលេចឡើងមក ហើយកូនមនុស្សក៏បានអង្គុយ នៅលើពពកនោះ។

ពពកនោះមើលទៅហាក់បីដូចជាតូចមែនទែន ហើយទេវតាក៏បានប្រាប់ថានេះគឺជា សញ្ញារបស់កូនមនុស្ស។ នៅពេលដែលដុំពពកនេះមកកាន់តែជិតឡើងៗនោះយើងអាចមើល ឃើញសិរីល្អនិងព្រះបារមីរបស់ព្រះយេស៊ូវដែលទ្រង់គង់លើពពកនោះ។ នៅជុំវិញទ្រង់ពោរពេញ ទៅដោយកងទេវតារួមទាំងមានពន្លឺចែងចាំងពីមកុដរបស់លោកដែលហែហមទ្រង់មក។ ខ្ញុំមិនអាចពិពណ៌នាពីភាពអស្ចារ្យនោះបានទេ នៅពេលដែលដុំពពកនោះបានរំកិលមកជិតឡើងៗ នោះយើងនឹងបានឃើញអង្គដែលពោរពេញទៅដោយសេចក្តីស្រឡាញ់ដែលជាព្រះយេស៊ូវ។ ទ្រង់មិនបានពាក់មកុដដែលធ្វើពីបន្លានោះទៀតទេ ប៉ុន្តែជាមកុដដែលពោរពេញទៅដោយសិរីរុងរឿង ហើយលើនោះមានពាក្យថា "ស្តេចលើអស់ទាំងស្តេច និងព្រះលើអស់ទាំងព្រះ" ព្រះនេត្ររបស់ទ្រង់ប្រៀបបានដូចជាអណ្តាតភ្លើង នៅក្រោមព្រះបាទទ្រង់មានលក្ខណៈដូចជាមាស ហើយព្រះសូរសៀងរបស់ទ្រង់ហាក់បីដូចជាការប្រគំតន្ត្រី។ ព្រះភ័ក្ត្ររបស់ទ្រង់ចែងចាំងដូចជាព្រះច័ន្ទ និងព្រះអាទិត្យ ហើយផែនដីនេះអោនលំទោននៅចំពោះទ្រង់ ហើយស្ថានសួគ៌ក៏បានលាតត្រដាងឡើង ភ្នំហើយនិងកោះក្នុងសមុទ្របានរើចេញពីទីរបស់វា។ អស់ទាំងស្តេចនៅលើផែនដី ពួកអ្នកមាន អ្នកធំ អ្នកមានសេរីភាពព្រមទាំងមនុស្សម្នាទាំងអស់របស់ផែនដីនេះ បានលាក់ខ្លួននៅក្នុងរូងភ្នំ ហើយនិងក្នុងក្រហែងថ្មភ្នំ។ ពួកគេបានសុំអោយភ្នំរលំសង្កត់ពួកគេ ដើម្បីអោយពួកគេរួចពីព្រះភ័ក្ត្ររបស់ព្រះ ហើយនិងរួចពីគ្រោះកាចដែលនឹងកំពុងមកដល់ ពីព្រោះពួកគេមិនអាច

ធន់ទ្រាំបាន។

អស់អ្នកដែលមានគំរោងការ នឹងសម្លាប់រាស្ត្ររបស់ព្រះនោះ នឹងត្រូវធ្វើជាសាក្សីនៃសិរីរុងរឿងរបស់ព្រះទៅលើពួកគេ ហើយនៅក្នុងបណ្តាការទាំងនោះ ពួកគេនឹងបានឮសំឡេងរបស់ពួកបរិសុទ្ធបន្លឺឡើង ដោយអំណរថា "មើលចុះ នេះហើយគឺជាព្រះរបស់យើង ពួកយើងបានរង់ចាំទ្រង់ ហើយទ្រង់នឹងជួយសង្គ្រោះពួកយើង"។ នៅពេលដែលកូនមនុស្សបានមានបន្ទូលទៅកាន់ពួកបរិសុទ្ធ ដែលបានស្លាប់ទៅនោះ ផែនដីក៏បានកក្រើកឡើងជាខ្លាំង។ ពួកអ្នកបរិសុទ្ធក៏បានងើបពីសេចក្តីស្លាប់ ព្រមទាំងបានបំពាក់នូវសំលៀកបំពាក់នៃសិរីល្អ ហើយបន្លឺសំឡេងថា "ជយោ ជយោ យើងមានជ័យជំនះលើសេចក្តីស្លាប់ ព្រមទាំងផ្នូរខ្មោចហើយ។ ឱសេចក្តីស្លាប់អើយ តើទ្រនិចរបស់ឯងនៅឯណាទៅ? ឱផ្នូរកប់ខ្មោចអើយ តើជ័យជំនះរបស់ឯងនៅឯណា? នៅពេលនោះពួកបរិសុទ្ធដែលមានជីវិតរស់នៅ និងពួកបរិសុទ្ធ ដែលទើបនឹងងើបពីស្លាប់ បានបន្លឺសំឡេងទាំងអស់ថា "ជយោ ជយោ"។ រាងកាយដែលបានពុករលួយនៅក្នុងផ្នូរ បានត្រឡប់មកជាមានជីវិតវិញ ហើយអស់អ្នកបរិសុទ្ធដែលនៅរស់បានផ្លាស់ប្រែមួយប៉ព្រិចភ្នែក ហើយពួកគេក៏បានទៅជួបព្រះជាម្ចាស់របស់គេនៅលើពពក។ តើវាជាការជួបជុំដ៏ល្អប្រសើរយ៉ាងណាទៅហ្ន៎? មិត្តភ័ក្តិដែលបានបែកពីគ្នាដោយសារតែសេចក្តី-ស្លាប់ និងមិនចាកចេញពីគ្នាទៀតឡើយ។

នៅសងខាងនៃរាជរថពពកនោះមានស្លាប ហើយនៅក្រោមនោះមានកង់-រទេះដ៏រស់។ រាជរថពពកនោះក៏បានធ្វើដំណើរឆ្ពោះទៅមុខជាដរាប ហើយកង់នោះបានបន្លឺសំឡេងថា "បរិសុទ្ធ "អស់ទាំងទេវតានៅជុំវិញនោះក៏ បានបន្លឺសំឡេងថា "បរិសុទ្ធ បរិសុទ្ធ បរិសុទ្ធ ព្រះជាម្ចាស់ទ្រង់អស្ចារ្យ"។ ពួកបរិសុទ្ធនៅលើពពកនោះក៏បានបន្លឺសំឡេងដែរថា "សិរីរុងរឿង ហាលេលូយ៉ា ព្រះជាម្ចាស់ទ្រង់ខ្ពស់បំផុត"។ រទេះនោះ



ក៏បានធ្វើដំណើរទៅកាន់ទីក្រុងបរិសុទ្ធ ប៉ុន្តែមុនពេលដែលគេចូលទៅក្នុងទីក្រុងនោះ ពួកបរិសុទ្ធ ត្រូវបានតំរៀបជួរបួនជ្រុងយ៉ាងត្រឹមត្រូវ ដោយមានព្រះយេស៊ូវនៅកណ្តាល។ ទ្រង់គឺជាស្នា ហើយក៏ជាព្រះសិរសា ខ្ពស់លើអស់ទាំងពួកបរិសុទ្ធ ហើយខ្ពស់លើសអស់ពួកទេវតា។ ទម្រង់នៃព្រះបាមីរបស់ទ្រង់ និងព្រះភ័ក្ត្រដែលពោរពេញទៅដោយសេចក្តីស្រឡាញ់របស់ទ្រង់ ត្រូវបានមើលឃើញពីគ្រប់ជ្រុង។

សូមអាន ពង្សាវតាក្សត្រទី២ ២:១១, អេសាយ ២៥:៩,
កូរិនថូសទី១ ១៥:៥១-៥៥, ថែស្សាឡូនីចទី១ ៤:១៣-១៧,
វិវរណៈ ១: ១៣- ១៦,៦:១៤-១៧, ១៩:១៦។

ជំពូកទី៣៨

## **ខ្វាន់របស់ពួកបរិសុទ្ធ**

នៅពេលនោះខ្ញុំបានឃើញទេវតាជាច្រើនបានយកមកុដជាច្រើន ចេញពីនគរដែលពោរពេញទៅដោយសិរីល្អមក។ មកុដមួយគឺសំរាប់រាស្ត្របរិសុទ្ធម្នាក់ ព្រមទាំងមានឈ្មោះរបស់គេ នៅលើមកុដផងដែរ។ នៅពេលដែលព្រះយេស៊ូវបានហៅឈ្មោះពួកគេអោយមកទទួល មកុដនោះទ្រង់បានបំពាក់មកុដដល់រាស្ត្ររបស់ទ្រង់ដោយព្រះហស្តស្តាំរបស់ទ្រង់ផ្ទាល់។ នៅក្នុងខណៈដែលទេវតាបានយកពិណមក ហើយព្រះយេស៊ូវក៏បានបង្ហាញពួកគេ ដល់ពួកបរិសុទ្ធផងដែរ។ មេទេវតាមួយអង្គបានចាប់ផ្តើមបទភ្លេង ហើយក្រោយមកក៏មានពោរពេញ ទៅដោយសំឡេងច្រៀងសរសើរដំកើង ដោយសេចក្តីរីករាយ។ ដៃដ៏ប៉ិនប្រសប់របស់ទេវតាគ្រប់អង្គបានវាសទៅលើខ្សែពិណដែលបញ្ចេញសំឡេងគ្រអួនពាសពេញស្ថានសួគ៌។ បន្ទាប់មក ខ្ញុំបានឃើញ

ព្រះយេស៊ូវបាននាំអស់អ្នកដែលបានលន់តួបាប ទៅឯទ្វាររបស់ទីក្រុង ទ្រង់ក៏បានបើកទ្វារនោះ ហើយគ្រប់ទាំងសាសន៍ដែលបានរក្សាសេចក្តីពិត ក៏បានចូលតាមទ្វារនោះ។ នៅពេលនោះភ្នែករបស់ពួកគេបានមើលឃើញសិរីល្អរបស់ព្រះ ឬរបស់ទីក្រុងនោះ។ ពួកគេបានមើលឃើញសិរីល្អនៅគ្រប់ទីកន្លែង ហើយព្រះយេស៊ូវក៏បានទតមើលមុខរាស្ត្ររបស់ទ្រង់ ហើយទ្រង់បានទតឃើញរស្មីចាំងចែងពីមុខរបស់ពួកគេ រួចទ្រង់ក៏បានមានបន្ទូលថា "អញបានមើលឃើញសេចក្តីរងទុក្ខវេទនារបស់ព្រលឹងឯង ហើយជាទីគាប់ចិត្តអញណាស់។ សិរីល្អនេះជារបស់ឯងរាល់គ្នាដ៏នៅអស់កល្ប ហើយទុក្ខវេទនារបស់ពួកឯងត្រូវបានបញ្ចប់ហើយ។ នឹងគ្មានសេចក្តីស្លាប់ទៀតទេ នឹងគ្មានការទួញសោកទៀតដែរ គ្មានការយំសោកទៀតទេ ហើយក៏គ្មានការឈឺចាប់ទៀតដែរ"។ ខ្ញុំបានមើលឃើញពួកបរិសុទ្ធបានក្រាបចុះដល់ព្រះបាទារបស់ព្រះយេស៊ូវ ហើយនៅពេលដែលព្រះហស្តស្តាំរបស់ទ្រង់បានអោយពួកគេក្រោកឡើង នោះពួកគេបានប្រគំតន្ត្រីដោយពិណមាសរបស់ពួកគេឮទ្រហឹងពេញទាំងនគរស្ថានសួគ៌ ហើយពួកគេក៏បានច្រៀងដល់កូនចៀមផងដែរ។

ហើយខ្ញុំក៏បានឃើញព្រះយេស៊ូវនាំរាស្ត្ររបស់ទ្រង់ទៅឯដើមនៃជីវិត ហើយពួកយើងក៏បានឮព្រះបន្ទូលដ៏ស្រទន់របស់ទ្រង់ទៀតថា "ស្លឹករបស់ដើមនេះ គឺសំរាប់ការផ្សះផ្សារជាតិសាសន៍នីមួយៗ។ ចូរទទួលទានចុះ" នៅលើដើមជីវិតនោះមានផ្លែដ៏ល្អជាច្រើន ដែលរាស្ត្របរិសុទ្ធអាចទទួលទានដោយឥតគិតថ្លៃ។ មានបល្ល័ង្កដែលពោរពេញទៅដោយសិរីល្អមួយនៅក្នុងទីក្រុងនោះ ដែលមានប្រភពទឹករស់ហូរនៅពីក្រោមដូចជាកញ្ចក់ដ៏ភ្លឺថ្លា។ នៅសងខាងទន្លេ នៃទឹកជីវិតនោះមានដើមជីវិត។ នៅតាមឆ្នេរមានដើមឈើជាច្រើន ដែលមានផ្លែផ្កាជាច្រើន។ គ្មានពាក្យណាមួយដែលអាចពិពណ៌នាអំពីស្ថានសួគ៌បានឡើយ នៅពេលដែលខ្ញុំបានឃើញនោះ ខ្ញុំស្ទើរតែបាត់បង់ស្មារតីដោយ



ភាពអស្ចារ្យរបស់ស្ថាននោះ ខ្ញុំបានដាក់ប៉ិចចុះ ហើយពោលថា "ឱសេចក្តីស្រឡាញ់របស់ព្រះល្អអីម្ល៉េះទេហ្ន៎ សេចក្តីស្រឡាញ់ដ៏អស្ចារ្យ ដែលគ្មានពាក្យណាមួយពណ៌នាពីស្ថានសួគ៌ និងសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះបានឡើយ"។

សូមអាន អេសាយ ៥៣:១១, វិវរណៈ ២១:៤, ២២:១-២។

## ជំពូកទី៣៩

## ផែនដីត្រូវបានគេបោះបង់ចោល

ខ្ញុំបានមើលទៅឯផែនដីនេះ ពួកអ្នកមានបាបបានស្លាប់អស់ហើយ សាកសពរបស់គេបានរាយលើផែនដីនេះ។ គ្រប់យ៉ាងដែលរស់នៅលើផែនដី បានទទួលការរងទុក្ខពីការក្រោធរបស់ព្រះ តាមរយៈគ្រោះកាចទាំង៧ ពួកគេបានខាំអណ្តាតរបស់គេដោយការឈឺចាប់ ព្រមទាំងបានដាក់បណ្តាសាដល់ព្រះផងដែរ។ អ្នកគង្វាលក្លែងក្លាយគឺជាសញ្ញាទាស់នឹងសេចក្តីក្រោធរបស់ព្រះយេហូវ៉ា ភ្នែករបស់គេបានបំផ្លាញនៅក្នុងរន្ធរបស់គេ ហើយអណ្តាតនៅក្នុងមាត់របស់គេ នៅពេលដែលគេកំពុងឈរមើល។ ក្រោយពីពួកបរិសុទ្ធត្រូវបានរំដោះដោយព្រះបន្ទូលរបស់ព្រះ នោះកំហឹងរបស់ពួកអ្នកមានបាបបានបែរដាក់គ្នា ហើយពិភពលោកនេះហាក់ដូចជាត្រូវបានបញ្ចប់ដោយការបង្ហូរឈាម ចំណែកសាកសពរបស់ពួកគេបានចោលពាសពេញពិភពលោកនេះ។

ពិភពលោកនោះស្ថិតនៅក្នុងសភាពដែលត្រូវបានគេបោះបង់ចោល ហើយទីក្រុង និងភូមិស្រុកនានាត្រូវបានរលំចុះដោយសារការរញ្ជួយផែនដី។ ភ្នំបានរើចេញពីកន្លែង ហើយបានបន្សល់ទុកនូវរូងភ្នំជាច្រើន ទឹកសមុទ្រក៏បានបង្កើតអោយមានផ្ទាំងថ្មនៅលើផែនដី ហើយផ្ទាំងថ្មទាំងនោះក៏ត្រូវបានកំទេច បំបែកនៅលើផែនដី ហើយក៏

បែកខ្ញែកនៅគ្រប់ទីកន្លែង។ ពិភពលោកនេះ មើលទៅហាក់បីដូចជាទីរហោស្ថានដែលគេ បោះបង់ចោល ដើមឈើត្រូវបានគេរំលំទាំងឫស ហើយបោះចោលពាសពេញផ្ទៃដី។ នេះហើយគឺជាទីលំនៅរបស់សាតាំង ព្រមជាមួយនឹងទេវតារបស់វា អស់រយៈពេល ១000ឆ្នាំ។ ពួកគេត្រូវបានជាប់ឃុំឃាំង នៅលើផ្ទៃដីដែលខ្ទេចខ្ទាំរបស់ផែនដីនេះ ហើយពួកគេក៏នឹងបានមើលឃើញនូវលទ្ធផលដែលគេបានប្រឆាំងនឹងច្បាប់របស់ព្រះ។ លទ្ធផលរបស់បណ្តាសាដែលពួកគេបានដាក់នោះ គឺពួកគេនឹងរងទុក្ខ អស់រយៈពេល ១000ឆ្នាំ។ ពួកគេបានត្រឹមតែរស់នៅលើផែនដីនេះទេ ហើយគ្មានឱកាសនឹងទៅរុកកួនភពឯទៀតបានឡើយ សាតាំងនឹងរងទុក្ខវេទនាជាទីបំផុត ក្នុងកំឡុងពេលនេះ។ ចាប់តាំងពីពេលដែលសាតាំងបានប្រព្រឹត្តបាបមក គេបានទទួលនូវអ្វីដែលគេមិនគួរទទួល ប៉ុន្តែនៅពេលនេះគេត្រូវបានកាត់ចេញពីអំណាចរបស់គេ ហើយសាតាំងត្រូវបានគេបោះបង់ចោល អោយគេនឹកឃើញនូវអំពើរបស់វា តាំងតែពីដើមមក។ ហើយវាក៏ត្រូវមើលទៅខាងមុខ ដោយសេចក្តីភ័យខ្លាច និងញាប់ញ័រ នៅពេលដែលគេនឹងរងទុក្ខវេទនា ដោយសារអំពើអាក្រក់ទាំងប៉ុន្មាន ដែលវាបានប្រព្រឹត្ត ហើយគេនឹងទទួលទណ្ឌកម្ម ចំពោះអំពើបាបទាំងនោះ។

ហើយខ្ញុំក៏បានឮសំឡេងស្រែកឡើង ដោយជ័យជំនះពីពួកទេវតា ព្រមទាំងពួកបរិសុទ្ធ ដែលមានសំឡេងដូចជាមានគ្រឿងតន្ត្រីរាប់ពាន់គ្រឿង មកប្រគំគ្នាពីព្រោះពួកគេបានត្រូវអាកំណាចល្បួង នឹងបៀតបៀនពីមុនមក។ ហើយគ្រប់ទាំងជីវិតរបស់ពិភពដទៃទៀត ក៏បានរំដោះចេញពីវត្តមាននៃសេចក្តីល្បួងដែរ។

នៅពេលនោះខ្ញុំក៏បានឃើញបល្ល័ង្កជាច្រើន ហើយព្រះយេស៊ូវនិងរាស្ត្ររបស់ទ្រង់បានអង្គុយលើបល្ល័ង្កទាំងនោះ។ ពួកបរិសុទ្ធបានក្លាយទៅជាស្តេច និងសង្ឃនៅចំពោះព្រះ ហើយពួកមានបាបដែលបានស្លាប់ត្រូវបានទទួលការជំនុំជំរះ តាមអ្វីដែល



ពួកគេបានប្រព្រឹត្ត។ ព្រះយេស៊ូវរួមជាមួយនឹងរាស្ត្ររបស់ទ្រង់ បានចាត់ចែងអោយមានការរងទុក្ខដល់អ្នកមានបាប ទៅតាមអំពើរបស់ពួកគេ ហើយវាក៏បានសរសេរទុកនៅក្នុងសៀវភៅនៃសេចក្តីស្លាប់ សំរាប់ឈ្មោះគេម្នាក់ៗ។ សាតាំងព្រមទាំងទេវតារបស់វាក៏ត្រូវបានជំនុំជំរះ ដោយព្រះយេស៊ូវ និងពួកបរិសុទ្ធដែរ ហើយទារុណកម្មរបស់គេនោះធ្ងន់ជាងអស់អ្នក ដែលគេបានបោកបញ្ឆោតទៅទៀត។ ក្រោយពេលអស់អ្នកដែលបានដើរតាមសាតាំងទទួលទោស ហើយវិនាសទៅនោះ សាតាំងត្រូវរងទុក្ខចុងក្រោយគេ ហើយយូរជាងគេ។

ក្រោយពេលដែលការជំនុំជំរះ ពួកមានបាបបានបញ្ចប់ទៅនោះ នៅចុងឆ្នាំទី១000នោះ ព្រះយេស៊ូវបានចាកចេញពីទីក្រុង ហើយពួកទេវតានៃស្ថានសួគ៌បានតាមទ្រង់ទៅ ព្រមទាំងពួកបរិសុទ្ធផងដែរ។ ព្រះយេស៊ូវបានយាងទៅឯលើភ្នំធំ ហើយក្រោយពេលដែលព្រះបាទរបស់ ទ្រង់ឈរនៅលើភ្នំនោះ ភ្នំនោះក៏បានក្លាយទៅជាទីវាលរាបដ៏ល្វឹងល្វើយ។ ហើយយើងបានមើលទៅឃើញទីក្រុងដ៏ស្អាតមួយ ដែលមានគ្រឹះ១២ មានទ្វារ១២ យើងបានស្រែកឡើងថា "ទីក្រុងដ៏អស្ចារ្យ បានមកពីព្រះនៃស្ថានសួគ៌ ហើយវាបានមកក្នុងសិរីល្អរបស់ព្រះ ហើយបានតាំងនៅលើទីរាបដ៏អស្ចារ្យដែលព្រះបានរៀបចំ"។

សូមអាន សាការី ១៤:៤-១២, វិវរណៈ ២០:២-៦, ២០:១២, ២១:១០-២៧។

ជំពូកទី៤០

## ការរស់ឡើងវិញជាលើកទីពីរ

នៅពេលនោះព្រះយេស៊ូវ និងទេវតាព្រមទាំងពួកបរិសុទ្ធបានចាកចេញពីទីក្រុង។ ពពួកទេវតាបានហែហមជុំវិញព្រះយេស៊ូវ ដែលមានពួក បរិសុទ្ធដ៏ច្រើនកុះករធ្វើដំណើរតាមផង។ បន្ទាប់មក ព្រះយេស៊ូវបានហៅពួកមានបាប ដែលបានស្លាប់ទៅទាំងភិតភ័យ ដោយព្រះបារមីរដ៏ពោរពេញរបស់ទ្រង់។ នៅពេលដែលពួកគេបានងើបមកទាំងមានភាពកំសោយ និងរូបកាយខ្ទេចខ្ទាំ ដូចនៅពេលដែលពួកគេបានចូលទៅក្នុងផ្នូរដែរ។ វាមានការខុសប្លែកគ្នាមែនទែន រវាងការរស់ឡើងវិញជាលើកទី១ និងរស់ឡើងវិញជាលើកទី២ ព្រោះថាកាលលើកទី១ នោះពួកបរិសុទ្ធបានងើបពីផ្នូរមកពោរពេញទៅដោយសិរីល្អរបស់ព្រះ តែលើកទី២នេះ មានការផ្ទុយគ្នាស្រះទៅវិញ។ ស្តេច អ្នកប្រាជ្ញ និងមនុស្សរបស់ផែនដីនេះ បានងើបចេញពីផ្នូរមក ហើយពួកគេក៏បានឃើញកូនមនុស្ស។ អស់អ្នកដែលបានបៀតបៀនដល់ព្រះយេស៊ូវបានមើលងាយទ្រង់ វាយធ្វើបាបទ្រង់ ហើយអស់អ្នកដែលបានបំពាក់មកុដបន្លាអោយទ្រង់នោះ នឹងសំឡឹងមើលទៅឯទ្រង់ ដែលគង់នៅក្នុងសិរីល្អរបស់ទ្រង់។ អស់អ្នកដែលបានស្តោះដាក់ទ្រង់ នៅពេលដែលទ្រង់បានត្រូវគេធ្វើទុក្ខនោះ បានបែរទៅឯទ្រង់ ហើយគេនឹងឃើញព្រះភ័ក្ត្ររបស់ទ្រង់ ដែលពោរពេញទៅដោយសិរីល្អ។ អស់អ្នកដែលបានទំលុះព្រះហស្ត និងព្រះបាទរបស់ទ្រង់ដោយដែកគោល ពេលនោះគេបានមើលទៅឯស្នាមរបួស របស់ទ្រង់ នៅលើឈើឆ្កាង។ អស់អ្នកដែលបានយកលំពែងទៅចាក់ទ្រង់ពីចំហៀង បានមើលទៅឯស្នាមរបួសនោះដែរ ហើយពួកគេទាំងនោះ នឹងបានដឹងជាក់ច្បាស់ថាម្នាក់នេះហើយដែលពួកគេបានឆ្កាងនៅលើឈើឆ្កាងនោះ។ នៅពេលនោះស្រាប់តែ



មានសំរែកនៃការឈឺចាប់ បានលេចមក នៅពេលដែលពួកគេបានរត់ទៅពួន ពីព្រះភ័ក្ត្ររបស់ស្តេចលើអស់ទាំងស្តេច ហើយព្រះលើអស់ទាំងព្រះ។

គ្រប់គ្នាបាននាំគ្នាពួននៅក្នុងផ្ទាំងថ្ម ដើម្បីបិទបាំងពួកគេពីសិរីល្អរបស់ទ្រង់ដែលពួកគេបានបៀតបៀន។ នៅពេលដែលគ្រប់គ្នាបានមានការស្អប់ស្អែង និងឈឺចាប់ដោយព្រោះតែសិរីល្អរបស់ទ្រង់នោះ ពួកគេក៏បានបន្លឺសំឡេងយ៉ាងព្រមគ្នាថា "មានពរហើយអស់អ្នកណាដែលបានមក ដោយនៅក្នុងព្រះនាមរបស់ព្រះ"។

នៅពេលនោះព្រះយេស៊ូវ ដែលអមដំណើរដោយទេវតាបរិសុទ្ធ និងពួកបរិសុទ្ធបានធ្វើដំណើរឆ្ពោះទៅឯទីក្រុងម្តងទៀត ហើយការយំសោក និងការឈឺចាប់របស់ពួកគេបានស្រែកឡើងរំពងអាកាស។ នៅពេលនោះខ្ញុំបានឃើញសាតាំងបានចាប់ផ្តើមធ្វើកិច្ចការរបស់វាសារជាថ្មី។ វាបានធ្វើអោយរូបកាយដ៏ខ្ទេចខ្ទាំ និងមានភាពកំសោយ បានរឹងមាំឡើងវិញ ហើយវាបានប្រាប់ថា វាហើយនិងទេវតារបស់វាមានអំណាចគ្រប់បែបយ៉ាង។ វាបានចង្អុលទៅអ្នកដែលទើបតែនឹងងើបពីស្លាប់ចំនួនរាប់លាននាក់ និងអ្នកចំបាំងជាច្រើនកុះករ ហើយនឹងស្តេចដែលមានការស្ទាត់ជំនាញក្នុងការធ្វើសឹក ព្រមទាំងបានទទួលជ័យជំនះ ក្នុងការច្បាំងកន្លងមកទៀតផង។ មានទាំងយក្សកំណាចជាច្រើន ហើយព្រមទាំងមនុស្សដែលមានភាពក្លាហាន ហើយដែលមិនដែលទទួលការបរាជ័យក្នុងការច្បាំងឡើយ។ មានទាំងណាប៉ូឡេអុងដែលពោរពេញទៅដោយក្តីអំនួត និងមហិច្ឆិតាលោភលន់ ដែលបានធ្វើអោយនគរមានភាពច្របូកច្របល់។ ពួកគេក៏បានឃើញរូបដ៏ខ្ពស់ ដែលមាននាមល្បីល្បាញ ដែលត្រូវបានគេរំលំចុះក្នុងចំបាំងដែរ។ ពួកនេះបានរលំចុះ ដោយសារតែការលោភលន់ក្នុងចំបាំងរបស់គេគេចង់បានអំណាច តែគេក៏បានស្លាប់ទៅ។ នៅខណៈពេលដែលពួកគេបានងើបពីផ្នូររបស់ពួកគេមក គេក៏នៅតែមានគំនិតដដែល។ សាតាំងបានពិភាក្សាជាមួយនឹងទេវតា

របស់វា ព្រមទាំងអ្នកចំបាំងដ៏ឆ្នើមរបស់គេថា "អ្នកដែលនៅក្នុងទីក្រុងនោះមានគ្នាតិចណាស់ ហើយពួកគេក៏មិនមានកម្លាំងដែរ ពួកយើងនឹងទៅឯទីនោះ ហើយដណ្តើមយកទីក្រុងនោះ ហើយយើងនឹងទំលាក់ពួកដែលរស់នៅទីនោះចេញ ហើយយើងនឹងបានគ្រងនូវមរតក ហើយនិងសិរីល្អរបស់ពួកគេ វិញ"។

សាតាំងក៏បានសំរេចក្នុងការបោកបញ្ឆោតពួកមនុស្ស ហើយវាក៏បានបញ្ជាអោយពួកគេរៀបចំដើម្បីនឹងធ្វើសឹកសង្គ្រាម។ ពួកគេបានផលិតអាវុធ សំរាប់ច្បាំង ដោយព្រោះគេមាន មនុស្សចំណានជាច្រើនក្នុងចំណោមពួកគេ ហើយគេក៏បានបន្តដំណើររបស់គេជាលំដាប់។ ស្តេចរបស់លោកីយ៍ ព្រមទាំងអ្នកចំបាំងបាននៅជាប់ជាមួយនឹងសាតាំង រួចបន្ទាប់មកគឺហ្វូងមនុស្ស។ ក្រុមរបស់គេនីមួយៗមានមេដឹកនាំម្នាក់ ហើយពួកគេក៏បានស្តាប់បញ្ជាក្នុងការធ្វើដំណើរនៅលើផែនដីដ៏ខ្ទេចខ្ទាំនោះ ទៅកាន់ទីក្រុងបរិសុទ្ធ។ ព្រះយេស៊ូវបានបិទទ្វារទីក្រុងនោះ ហើយទ័ពរបស់សាតាំងក៏បានព័ទ្ធជុំវិញទីក្រុង ទាំងច្បាំងផង។ ពួកគេបានត្រៀមរួចជាស្រេចនូវគ្រប់ទាំងអាវុធ ក្នុងការច្បាំងដ៏ធំនេះ ហើយពួកគេក៏បានរំពឹងទុកថា នឹងមានចំបាំងដ៏ធំនេះកើតឡើង។ ព្រះយេស៊ូវព្រមទាំងទេវតានិងពួកបរិសុទ្ធ បានធ្វើដំណើរទៅឯកំពូលកំផែងរបស់ទីក្រុង ហើយព្រះយេស៊ូវក៏បានមានបន្ទូលថា "មើលចុះពួកឯងជាអ្នកមានបាបអើយ នេះហើយគឺជារង្វាន់របស់ពួកបរិសុទ្ធ។ ពួកបរិសុទ្ធ ចូរមើលចុះ នេះហើយគឺជារង្វាន់របស់អ្នកមានបាប" ពួកទាហានរបស់សាតាំង ក៏បានឃើញរស្មីចែងចាំងចេញពីមកុដរបស់ពួកបរិសុទ្ធ ហើយបានមើលឃើញមុខរបស់ពួកគេ នោះពោរពេញទៅ ដោយសិរីល្អដែលសំដែងអោយឃើញព្រះយេស៊ូវ ហើយពួកគេក៏បានឃើញសិរី ល្អរបស់ស្តេចលើអស់ទាំងស្តេច និងព្រះលើអស់ទាំងព្រះផងដែរ នៅវេលានោះ សេចក្តីក្លាហានរបស់ពួកគេក៏បានរលាយបាត់ទៅ ហើយពួកគេក៏បានយល់ដឹងយ៉ាងច្បាស់ថា ឈ្នួលនៃអំពើ



បាបគឺសេចក្តីស្លាប់។ ពួកគេបានឃើញពួកបរិសុទ្ធដែលពួកគេធ្លាប់បានបៀតបៀនបំពាក់ទៅដោយសិរីល្អ និងកិត្តិនាម ហើយនិងទទួលបានជីវិតអស់កល្ប តែផ្ទុយទៅវិញពួកគេនៅខាងក្រៅទីក្រុង ដែលពោរពេញទៅដោយភាពសោកសង្រេង។

សូមអានម៉ាថាយ ២៣:២៩, វិវរណៈ ៦:១៥-១៦, ២០:៧-៩ ២២:១២-១៥។

ជំពូកទី៤១

## ការស្លាប់លើកទីពីរ

សាតាំងក៏បានរត់ទៅក្នុងកណ្តាលចំណោមហ្វូងមនុស្ស ដើម្បីធ្វើការបញ្ចុះ-បញ្ចូលសារជាថ្មី អោយពួកគេច្បាំង ប៉ុន្តែភ្លើងពីស្ថានសួគ៌បានធ្លាក់មកលើពួកគេ ហើយអស់ទាំងស្តេច អ្នកប្រាជ្ញ អ្នកមាន អ្នកក្រទាំងអស់ក៏បានឆេះក្នុងភ្លើងនោះ។ ខ្ញុំបានឃើញថាមានអ្នកខ្លះ បានឆេះខ្ទេចទៅនៅមួយរំពេច ហើយមានអ្នកខ្លះទៀតបានរងទុក្ខក្នុងភ្លើងជាច្រើនថ្ងៃ។ ពួកគេបានរងទុក្ខ ទៅតាមអំពើដែលរូបកាយគេបានធ្វើ។ ពួកទេវតាបាននិយាយថា "ដង្កូវនៃជីវិត នឹងមិនស្លាប់ទេ ហើយវានៅតែមានដង្ហើមដរាបណាវានៅមាន សូម្បីតែចំណែកតូចមួយ សំរាប់ស៊ី"។

ប៉ុន្តែទេវតារបស់សាតាំងបានរងទុក្ខជាយូរ ហើយសាតាំងមិនត្រឹមតែទទួលបន្ទុក និងទារុណកម្មនៃបាបរបស់វាប៉ុណ្ណោះទេ ប៉ុន្តែគ្រប់ទាំង អំពើបាបដែលពួកបរិសុទ្ធបានលន់តួ នឹងធ្លាក់មកលើវាដែរ ហើយវាក៏ត្រូវរង ទុក្ខចំពោះគ្រប់ទាំងវិញ្ញាណ ដែលវាបានធ្វើអោយបាត់បង់ទៅ ហើយភាពយុត្តិធម៌របស់ព្រះក៏ត្រូវបានទ្រង់សព្វព្រះទ័យដែរ នោះពួកទេវតានៃស្ថានសួគ៌ ព្រមទាំងពួកបរិសុទ្ធក៏បានបន្លឺសំឡេងថា "អាម៉ែន"។

ទេវតាក៏បានមានបន្ទូលថា "សាតាំងគឺជាឫស ហើយកូនរបស់វាគឺជាមែកធាង ហើយ នៅពេលនេះទាំងឫស ព្រមទាំងមែកធាងត្រូវបានឆេះអស់ទៅហើយ ពួកគេបានស្លាប់ជារៀងរហូត រួចពួកគេនឹងមិនរស់ឡើងវិញទៀតទេ ហើយព្រះជាម្ចាស់ទ្រង់នឹងធ្វើពិភពដ៏ស្អាតមួយ"។ ខ្ញុំក៏បានមើលទៅឃើញភ្លើង ដែលបានឆេះពួកអ្នកមានបាប បានបញ្ចេះសំអាតផែនដីដែរ ហើយគ្មានកាក សំណល់នៃបណ្តាសាទៀតទេ។ ផែនដីបានបែកខ្ទេចខ្ទាំ នៅពេលនេះបានក្លាយទៅជាដីរាប ហើយពិភពទាំងមូលរបស់ព្រះក៏បានស្អាត ហើយវិវាទដ៏ធំក៏បានបញ្ចប់ជារៀងរហូត។ គ្រប់យ៉ាងដែលយើងមើលឃើញ នោះសុទ្ធតែល្អ ហើយនិងបរិសុទ្ធទាំងអស់ ហើយពួកបរិសុទ្ធទាំងក្មេងទាំងចាស់ ទាំងតូចទាំងធំ ក៏បានថ្វាយបង្គំព្រះជាទីស្រឡាញ់ ហើយជាព្រះដ៏នៅអស់កល្បរៀងទៅ។ ផែនដីថ្មីនេះគឺជាកេរ្តិ៍មរតករបស់ពួកបរិសុទ្ធ ហើយគ្រប់ទាំងអស់នៃនគរ ព្រមទាំងភាពអស្ចារ្យដែលនៅក្រោមស្ថានសួគ៌ ត្រូវបានប្រគល់អោយពួកបរិសុទ្ធរបស់ព្រះដ៏ខ្ពស់ទាំងអស់ ហើយពួកគេនឹងគ្រងរាជ្យរៀងរហូតតទៅ ដរាបដល់អស់កល្ប។

សូមអាន អេសាយ ៦៦:២៤, ដានីយ៉ែល ៧:២៦-២៧,
វិវរណៈ ២០:៩-១៥, ២១:១, ២២:៣។

**ចប់ដោយបរិបូរ**